ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# សភា
# និង លទ្ធិប្រជាធិបតេយ្យ
# នៅសតវត្សទី ២១

ចងក្រងដោយ : ឯកឧត្តមបណ្ឌិត អ៊ុំ សារិទ្ធ
អគ្គលេខាធិការព្រឹទ្ធសភា

ខែឧសភា ឆ្នាំ២០១១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋាន

# សភា

# និង លទ្ធិប្រជាធិបតេយ្យ

# នៅសតវត្សទី ២១

ចងក្រងដោយ : ឯកឧត្តមបណ្ឌិត អ៊ុំ សារឹទ្ធ
អគ្គលេខាធិការព្រឹទ្ធសភា

ខែឧសភា ឆ្នាំ២០១១

# បញ្ជីមាតិកា

ទំព័រ


**I-សេចក្តីផ្តើម**........................................................................................ ១

- ទស្សនៈអំពីសភាប្រជាធិបតេយ្យ........................................................................ ១
- វិភាគទានរបស់សភាទៅលើលទ្ធិប្រជាធិបតេយ្យ...................................................... ៣
    + តើអ្វីទៅជាលទ្ធិប្រជាធិបតេយ្យ.......................................................... ៣
- អំពីសិទ្ធិរបស់ប្រជាពលរដ្ឋ............................................................................ ៣
- ស្ថាប័ននៃការគ្រប់គ្រងដោយភាពតំណាងដែលត្រូវរាយការណ៍........................................ ៤
- សង្គមស៊ីវិលដ៏សកម្ម.................................................................................... ៥
- គណបក្សនយោបាយ...................................................................................... ៥
- ប្រព័ន្ធឃោសនា........................................................................................... ៦
- សន្និដ្ឋានជំហានដំបូង.................................................................................... ៦
- លក្ខណៈវិនិច្ឆ័យរបស់សភាប្រជាធិបតេយ្យ.............................................................. ៧
- កំណត់សម្គាល់............................................................................................ ៨

**II-សភាដែលមានលក្ខណៈតំណាង**..................................................................... ៩

- បទបញ្ញា និងនីតិវិធីបោះឆ្នោតដើម្បីធានាថា សភាមួយដែលមានភាពតំណាងខាងនយោបាយ គ្រប់គ្រាន់ ........................................................................................................ ៩
- អំពីប្រព័ន្ធបោះឆ្នោត.................................................................................. ១០
- បទបញ្ញា និងនីតិវិធីបោះឆ្នោតដែលធានាឱ្យសភាឆ្លុះបញ្ចាំងបានដោយពិតប្រាកដនូវភាពចម្រុះ សង្គមរបស់ប្រជាជន.................................................................................... ១២
- អំពីតួនាទីរបស់នារីនៅក្នុងសភា...................................................................... ១២
- ភាពជាតំណាងឱ្យសហគមន៍ជនជាតិភាគតិច និងងាយរងគ្រោះ..................................... ១៤
- កំណត់សម្គាល់.......................................................................................... ១៥
- តួនាទីរបស់សភាទីពីរ ឬសភាជាន់ខ្ពស់................................................................ ១៦
- សិទ្ធិរបស់សមាជិកសភាទាំងអស់ត្រូវបានគោរព : សភាដែលបើកចំហចំពោះគ្រប់គណបក្ស............ ១៧

- សិទ្ធិដោយឡែករបស់គណបក្ស ឬក្រុមប្រឆាំង ឬភាគតិច........................................១៨
- សម្រាប់សមាជិកសភាធ្វើជាមូលដ្ឋាន........................................................................ ១៩
- សមភាពរវាងបុរស និងនារី.................................................................................... ១៩
- សមភាពរវាងសមាជិកសភាចេញមកពីសហគមន៍ជនជាតិភាគតិច និងងាយរងគ្រោះ.....................២០
- សម្រួលការងាររបស់សមាជិកសភាទាំងអស់ ........................................................២១
- ការពារនូវសិទ្ធិរបស់សមាជិកសភាក្នុងការបំពេញមុខងារ.................................................២២
- សិទ្ធិបុគ្គលរបស់សមាជិកសភា និងវិន័យរបស់គណបក្ស............................................. ២៣

**III-សភាដែលបើកចំហ និងមានតម្លាភាព.**........................................................... ២៥

- អនុញ្ញាតឱ្យអ្នកសារព័ត៌មាន និងប្រព័ន្ធឃោសនាផ្សព្វផ្សាយអំពីការងារសភានៅក្នុងល័ក្ខខ័ណ្ឌដ៏ល្អប្រសើរ........................................................................................................ ២៦
- ការចូលទៅជិតការងារសភា ..................................................................................២៧
- សេរីភាពខាងព័ត៌មាន ..........................................................................................២៨
- សិទ្ធិសម្ដែងមតិ ....................................................................................................៣០
- បទបញ្ញត្តិពាក់ព័ន្ធនឹងប្រព័ន្ធឃោសនា.......................................................................... ៣១
- តើសមាជិកសភាអាចជូនព័ត៌មានទៅសាធារណជនអំពីការងាររបស់ខ្លួនយ៉ាងដូចម្ដេច?..................៣៣
- គេហទំព័ររបស់សភា ...........................................................................................៣៥
- បង្កិតសភាឱ្យទៅក្បែរប្រជាជន.................................................................................៣៦
- ព័ត៌មាន និងការចូលរួមរបស់យុវវ័យ........................................................................ ៣៧
    + សកម្មភាពនៅក្នុងសាលារៀន ...................................................................... ៣៧
    + កម្មវិធីគាំទ្រដោយសភា .................................................................................៣៨

**IV-សភាដែលចូលជិតបាន**......................................................................................៣៩

- ការទាក់ទងផ្ទាល់រវាងប្រជាពលរដ្ឋ និងតំណាងរបស់ខ្លួន..................................................៣៩
- ទីស្នាក់ការប្រចាំនៅមូលដ្ឋាន...................................................................................... ៤១
- សមាជិកសភាចូលរួមដល់សេវាអភិវឌ្ឍន៍មូលដ្ឋាន...........................................................៤២
- សញ្ញាអាសន្នសម្រាប់អនាគត ការលើសបន្ទុកនៃសារអេឡិចត្រូនិច...........................................៤៣
- អនុញ្ញាតឱ្យប្រជាពលរដ្ឋដាក់បង្ហាញពាក្យបណ្ដឹង.............................................................. ៤៣

- គណៈកម្មការសភាខាងសិទ្ធិមនុស្ស........................................................................ ៤៧

- ការចូលរួមរបស់ប្រជាជនក្នុងដំណើរការធ្វើច្បាប់........................................................ ៤៨

- ការទាក់ទាញឱ្យគណៈកម្មការយកចិត្តទុកដាក់នឹងសវនាការសាធារណៈ........................... ៤៨

- បញ្ហាដទៃទៀតដែលគួរយកចិត្តទុកដាក់.................................................................. ៥០

- ជួយប្រជាពលរដ្ឋឱ្យគេទទួលស្តាប់.......................................................................... ៥១

- វេទិកា ឬការប្រជុំសាធារណៈ.................................................................................. ៥២

- អង្គធាតុដែលអនុគ្រោះឱ្យពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ.......................................៥២

- នារី និងការងារធ្វើច្បាប់ ឧទាហរណ៍មួយនៃកិច្ចសហប្រតិបត្តិការរវាងអង្គការ NGO និងសភា.....៥៣

- ឱកាសសម្រាប់សមភាពរវាងបុរស និងនារី.............................................................. ៥៤

- ការចូលរួមរបស់ប្រជាពលរដ្ឋតាមរយៈគណបក្សនយោបាយ........................................... ៥៥

- គំនិតផ្តួចផ្តើមរបស់ពលរដ្ឋ និងប្រជាមតិ................................................................. ៥៥

- ហេតុការណ៍ថ្មីៗនេះ.............................................................................................. ៥៦

- លទ្ធិប្រជាធិបតេយ្យដោយផ្ទាល់ និងលទ្ធិប្រជាធិបតេយ្យតំណាង................................. ៥៧

**V-សភាដែលចេះរាយការណ៍**.................................................................................. ៥៨

- ការទទួលខុសត្រូវបណ្តោយ និងទទឹង.....................................................................៥៩

- ការរាយការណ៍ ....................................................................................................៦០

- ការដកហូតអណត្តិសភា.........................................................................................៦១

- គោលការណ៍ និងក្រុមសីលធមិសភា....................................................................... ៦២

- ផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ឯកជន.................................................៦៤

- បញ្ជីទ្រព្យសម្បត្តិ និងហិរញ្ញវត្ថុ.............................................................................៦៦

- ភាពស្អិតស្អាញនៅក្នុងសម័យប្រជុំពេញអង្គរបស់សភា................................................ ៦៨

- ហិរញ្ញប្បទានរបស់គណបក្ស និងយុទ្ធនាការបោះឆ្នោត.................................................៦៩

១-ភាពពុំគ្រប់គ្រាន់នៃធនធាន..........................................................................៧០

២-វិសមភាពខាងធនធាន...................................................................................៧០

៣-ធនធានដែលអាចអនុគ្រោះ............................................................................ ៧០

- ឆ្លើយតបចំពោះការយកចិត្តទុកដាក់របស់អ្នកបោះឆ្នោត...............................................៧១

- យុទ្ធសាស្ត្រខាងច្បាប់ ( កំណត់បទបញ្ហា)....................................................................................៧១
- យុទ្ធសាស្ត្រឧបត្ថម្ភធន......................................................................................................................៧២
- យុទ្ធសាស្ត្រតម្លាភាព..........................................................................................................................៧២
- ស្ថាបជីពចររបស់សាធារណជន.........................................................................................................៧៤
- សភាអាចបង្កឥទ្ធិពលទៅលើសាធារណៈមតិ...................................................................................៧៤

**VI-សភាប្រកបដោយប្រសិទ្ធភាព**.........................................................................................................៧៥

(១) ក៏រិតជាតិ.....................................................................................................................................៧៥
- បរិក្ខា និងការចាត់តាំងរបស់សភា......................................................................................................៧៧
- ស្វយ័តភាពរបស់សភា........................................................................................................................៧៥
- ការត្រួតពិនិត្យថវិកា..........................................................................................................................៨០
- ភាពជាម្ចាស់នៃប្រក្រតីទិនការងាររបស់សភា.................................................................................... ៨០
- កែលំអដំណើរការធ្វើច្បាប់................................................................................................................ ៨០
- គុណភាពរបស់ច្បាប់...........................................................................................................................៨១
- មធ្យោបាយអេឡិចត្រូនិច.....................................................................................................................៨២
- តួនាទីរបស់សភាជាន់ខ្ពស់...................................................................................................................៨៣
- តាមដានស្ថានភាពដើរទៅមុខរបស់ច្បាប់.......................................................................................... ៨៣
- ការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពទៅលើសកម្មភាពរបស់អង្គប្រតិបត្តិ.............................................៨៤
- ការត្រួតពិនិត្យដោយប្រព័ន្ធគណៈកម្មការ.............................................................................................៨៦
- ការត្រួតពិនិត្យដោយ និងលើអង្គការសាធារណៈឯករាជ្យ.....................................................................៨៨
- ការត្រួតពិនិត្យដោយសំណួរ និងកោះហៅទៅកាន់សភា.......................................................................៨៩
- ការយល់ព្រមរបស់សភាទៅលើការតែងតាំងសម្រាប់មុខតំណែងទទួលខុសត្រូវរបស់អង្គប្រតិបត្តិ..... ៩១
- គណៈកម្មការត្រួតពិនិត្យពិសេស.......................................................................................................... ៩២
- ការសិក្សាអំពីករណីត្រួតពិនិត្យលើនយោបាយសន្តិសុខ............................................................................៩៣
- ច្បាប់ប្រឆាំងភេរវកម្ម........................................................................................................................ ៩៤
- ការត្រួតពិនិត្យថវិកា និងហិរញ្ញវត្ថុ.......................................................................................................៩៥
- ការត្រួតពិនិត្យថវិកា..........................................................................................................................៩៥

- ការត្រួតពិនិត្យចំណាយសាធារណៈ........................................................................ ៩៦
- ការលើកតម្កើងឯកភាពជាតិតាមមធ្យោបាយប្រជាធិបតេយ្យ........................................៩៨
- ការដោះស្រាយវិវាទ និងជម្លោះ........................................................................ ៩៩
**VII-សភាប្រកបដោយប្រសិទ្ធភាព**..............................................................១០០
(**២**) ការចូលរួមរបស់សភាក្នុងកិច្ចការអន្តរជាតិ..................................................១០០
- ការចូលរួមរបស់សមាជិកសភាក្នុងកិច្ចការពហុភាគី............................................. ១០២
- សិទ្ធិមនុស្ស............................................................................................១០៤
- សមភាពរវាងភេទ......................................................................................១០៥
- ការអភិវឌ្ឍ................................................................................................ ១០៧
- ពាណិជ្ជកម្ម.............................................................................................. ១០៩
- ការចូលរួមរបស់សភានៅក្នុងដំណើរការសមាហរណកម្មតំបន់.................................. ១១០
- សហប្រតិបត្តិការសភា..................................................................................១១២
- ការទូតសភា...............................................................................................១១២
- សហប្រតិបត្តិការអន្តរសភា............................................................................ ១១៣
- ការជួយខាងបច្ចេកទេស................................................................................ ១១៤
- សេចក្តីសន្និដ្ឋាន.......................................................................................... ១១៥
**VIII-ប្រឈមមុខនឹងអនាគតកាល**.........................................................................១១៦
- ដំណើរការកែទម្រង់ ប្រភពនៃការកែទម្រង់.......................................................... ១១៧
- ឋាមភាពនៃប្រជាធិបតេយ្យភាវូបនីយកម្ម ..........................................................១១៩
- លទ្ធិប្រជាធិបតេយ្យដែលបានចាក់ឫស..............................................................១១៩
- កត្តាជម្រុញការកែទម្រង់ និងឧបសគ្គដែលរារាំងដល់ការកែទម្រង់............................. ១២០
- គិតគូរពីអនាគត............................................................................................១២១

## I-សេចក្តីផ្តើម

- លទ្ធិប្រជាធិបតេយ្យ គឺជាតម្លៃសាកលមួយ ដែលពុំមែនជាអភ័យឯកសិទ្ធិ ឬកម្មសិទ្ធិផ្តាច់មុខរបស់ប្រទេសណាមួយ ឬតំបន់ណាមួយឡើយ ។

- ប្រជាជាតិទាំងអស់សុទ្ធតែឆ្លងកាត់នូវការបែកបាក់គ្នា និងសង្គ្រាមដើម្បីដណ្តើមអំណាចគ្នា ។ លទ្ធិប្រជាធិបតេយ្យត្រូវបានទទួលស្គាល់ថា ជាឧត្តមគតិខ្ពង់ខ្ពស់ និងជាឧបករណ៍ដ៏ថ្លៃថ្នូរនៃការបែងចែកអំណាចគ្នាតាមហិបឆ្នោត ដែលសភាដើរតួនាទីចម្បង ។

- សភា គឺជាស្ថាប័នជាសារវ័ន្ត ដែលឆន្ទៈរបស់ប្រជាជនត្រូវបានសម្តែង ច្បាប់ទាំងឡាយត្រូវបានអនុម័ត ហើយរដ្ឋាភិបាលត្រូវរាយការណ៍ជូនស្ថាប័ននេះ ។

- ទាំងប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យចាស់ និងប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យថ្មី សភានៃប្រទេសនីមួយៗកំពុងដំណើរការកែទម្រង់លើការដ្ឋានសំខាន់ៗដូចតទៅ

- ⊙ ទំនាក់ទំនងរវាងសភា និងប្រជាពលរដ្ឋ ព្រមទាំងម្ចាស់ឆ្នោត
- ⊙ ទំនាក់ទំនងរវាងសភា និងប្រព័ន្ធឃោសនា
- ⊙ ទំនាក់ទំនងរវាងសភា និងអង្គនីតិប្រតិបត្តិ
- ⊙ ទំនាក់ទំនងរវាងសភា និងសង្គមស៊ីវិល សមាគម អង្គការក្រៅរដ្ឋាភិបាល
- ⊙ ទំនាក់ទំនងរវាងសភា និងអង្គការអន្តរជាតិ
- ⊙ ប្រព័ន្ធការងារផ្ទៃក្នុង ( បទបញ្ជាផ្ទៃក្នុង នីតិវិធី សេវាបង្អែក បច្ចេកវិទ្យា ធនធានមនុស្ស ថវិកា និងមធ្យោបាយ) ដើម្បីបំពេញបាននូវមុខងារទាំងបី ( តំណាង ធ្វើច្បាប់ និងត្រួតពិនិត្យ) ។

### ទស្សនៈអំពីសភាប្រជាធិបតេយ្យ

១- សភា គឺជាគ្រឹះនៃលទ្ធិប្រជាធិបតេយ្យ ឆ្លុះបញ្ចាំងនូវឆន្ទៈរបស់ប្រជាជន តំណាងឱ្យក្តីសង្ឃឹមថា លទ្ធិប្រជាធិបតេយ្យ( ថ្នាក់ជាតិ/ក្រោមជាតិ) ឆ្លើយតបបានទៅនឹងសេចក្តីត្រូវការរបស់ប្រជាជន ហើយរួមវិភាគទានដោះស្រាយបាននូវបញ្ហាបន្ទាន់ៗ ដែលប្រជាជនជួបប្រទះនៅក្នុងជីវភាពប្រចាំថ្ងៃ ។

២- សភា គឺជាអង្គការតំណាងឱ្យសង្គមទាំងមូល (សង្គមចំរុះ) ត្រូវស្វែងរកឱ្យបាននូវការសម្រប សម្រួលរវាងផលប្រយោជន៍ផ្ទុយគ្នា ដោយធានាឱ្យបានការបង្រួបបង្រួមជាតិ ស្ថេរភាព និង ឯកភាពជាតិរបស់ប្រទេសជាតិ និងក្តីសង្ឃឹមប្លែកៗគ្នារបស់ក្រុម និងសមូហភាពទាំងឡាយ តាមរយៈមធ្យោបាយប្រជាធិបតេយ្យ ដែលឈរលើការសន្ទនាគ្នា និងការសម្រុះសម្រួលគ្នា ។

៣- សភា ក្នុងឋានៈជាអង្គនីតិបញ្ញត្តិ ត្រូវសម្របសម្រួលច្បាប់ទាំងឡាយឱ្យសមស្របទៅនឹងតម្រូវ ការ និងកាលៈទេសៈរបស់សង្គមដែលប្រែប្រួលឆាប់រហ័ស ។

៤- សភា ក្នុងឋានៈជាអ្នកត្រួតពិនិត្យរដ្ឋាភិបាលត្រូវធានាថា រដ្ឋាភិបាលបានរាយការណ៍ជូនប្រជា-ជន ។ ការគ្រប់គ្រងរដ្ឋ គ្រប់គ្រងសេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន ត្រូវធានាបាននូវតម្លាភាព គណនេយ្យភាពតាមគោលការណ៍នីតិរដ្ឋ ។ ការបែងចែកអំណាចរដ្ឋ និងសេវាសាធារណៈ ប្រព្រឹត្តទៅបានល្អប្រសើរ ។

៥- សភាត្រូវធានាថា ការការពារឯករាជ្យ អធិបតេយ្យភាព និងនយោបាយបរទេសរបស់រដ្ឋក្នុង ក្របខ័ណ្ឌតំបន់ និងអន្តរជាតិ ទាំងទ្វេភាគី និងពហុភាគី នាំមកនូវសុខសន្តិភាព និងការអភិវឌ្ឍ ដល់ប្រទេសជាតិ ។

ដើម្បីសម្រេចបេសកកម្ម៥ខាងលើនេះ សភាក៏ត្រូវសម្របសម្រួលខ្លួនទៅនឹងការប្រឈមក្នុងសតវត្ស ទី២១ នេះ

- សភាជាច្រើនខិតខំប្រឹងប្រែងត្រាប់ស្តាប់សម្លេងរបស់ប្រជាជន និងឆ្លើយតប ដើម្បីស្តារជំនឿទុកចិត្ត
- កែប្រែវិធីសាស្ត្រធ្វើការងាររបស់សភា ដើម្បី
    - ជាតំណាងដ៏ល្អរបស់ម្ចាស់ឆ្នោត/ប្រជាជន
    - កាន់តែជាប់កៀកកិតនឹងម្ចាស់ឆ្នោត/ប្រជាជន
    - កាន់តែបានរាយការណ៍ជូនម្ចាស់ឆ្នោត/ប្រជាជន
    - បើកចំហ និងមានតម្លាភាពនៅក្នុងនីតិវិធីរបស់សភា
    - ក្តាប់ជាប់កាន់តែបានល្អនូវភារកិច្ចសារវ័ន្តជាអ្នកធ្វើច្បាប់ និងជាអ្នកមានសិទ្ធិបើកភ្នែក មើលទៅលើអង្គនីតិប្រតិបត្តិ

## វិភាគទាននៃរបស់សភាទៅលើលទ្ធិប្រជាធិបតេយ្យ

### តើអ្វីទៅជាលទ្ធិប្រជាធិបតេយ្យ?

- លទ្ធិប្រជាធិបតេយ្យ គឺជាឧត្តមគតិផង និងជាសំណុំនៃស្ថាប័ន និងការអនុវត្តផង :

  ✻ ជាឧត្តមគតិដែលឆ្លុះបញ្ចាំងគោលការណ៍ ២ សាមញ្ញ គឺ

  ១- សមាជិករបស់ក្រុម ឬសមាគមទាំងមូលត្រូវតែអាចកំណត់ និងត្រួតពិនិត្យទៅលើបញ្ញត្តិ និងនយោបាយរបស់ក្រុម ឬសមាគមនោះ ដោយចូលរួមក្នុងការពិភាក្សាទៅលើផលប្រយោជន៍ជាសមូហភាព ។

  ២- ពួកគេត្រូវរាប់រកគ្នា និងត្រូវចាត់ទុកគ្នាជាអ្នកស្មើភាព ។

សម្រាប់រដ្ឋទំនើប គោលការណ៍នៃលទ្ធិប្រជាធិបតេយ្យនាំឱ្យមានសំណុំស្មុគស្មាញមួយនៃស្ថាប័នដែលបានបង្កើតឡើងតាមពេលវេលា និងស្ថិតស្ថេរនៅជាអចិន្ត្រៃយ៍

១- ក្របខ័ណ្ឌដែលធានាដល់សិទ្ធិរបស់ប្រជាពលរដ្ឋ

២- ស្ថាប័នដែលឆ្លុះបញ្ចាំងនូវការគ្រប់គ្រងមួយដោយភាពតំណាង និងដែលត្រូវរាយការណ៍

៣- សមូហភាពប្រជាពលរដ្ឋសកម្ម ឬសង្គមស៊ីវិល

៤- ស្ថាប័នសម្របសម្រួលកណ្តាលមួយចំនួននៅមានចន្លោះរវាងរដ្ឋាភិបាល និងប្រជាពលរដ្ឋ ដែលជាសំខាន់ មានគណបក្សនយោបាយ និងប្រព័ន្ធឃោសនា ។

សភាស្ថិតនៅក្នុងប្រភេទទី២ ដែលហៅថា ការគ្រប់គ្រង តែសភាមានតួនាទីសារវ័ន្តសម្រាប់សម្តែងជាមួយនឹងស្ថាប័នផ្សេងទៀត ។ ហេតុនេះ សភាស្ថិតនៅចំកណ្តាលបេះដូងនៃលទ្ធិប្រជាធិបតេយ្យ ។

### អំពីសិទ្ធិរបស់ប្រជាពលរដ្ឋ

ប្រជាពលរដ្ឋពុំអាចមានឥទ្ធិពលទៅលើច្បាប់ និងនយោបាយដែលពួកគេត្រូវគោរពតាមឡើយប្រសិនបើគ្មានការធានានូវសិទ្ធិជាគ្រឹះ

- សិទ្ធិដើម្បីមានសេរីភាពសម្តែងមតិ
- សិទ្ធិដើម្បីមានសេរីភាពបង្កើតសមាគម
- សិទ្ធិជ្រើសរើសតំណាងនៅក្នុងការបោះឆ្នោត

ក្របខ័ណ្ឌសិទ្ធិនេះ គឺជាការធានាសម្រាប់ម្នាក់ៗឱ្យទទួលបាននូវគោលការណ៍ប្រជាធិបតេយ្យ : ការរាប់រកគ្នាដោយស្មើភាព និងគ្មានការបែងចែក ។

ការគោរពនូវសិទ្ធិទាំងនេះ គឺជាការទទួលខុសត្រូវរបស់ប្រជាពលរដ្ឋទាំងអស់ តែមុនបង្អស់គឺសភាដែលកាន់អំណាចនីតិបញ្ញត្តិ ដើម្បីធានាថា ការរៀបចំ និងវិធីការពារនូវសិទ្ធិទាំងនេះ នៅក្នុងការជាក់ស្តែងសមស្របទៅនឹងបទដ្ឋានអន្តរជាតិខាងសិទ្ធិមនុស្ស ហើយពុំត្រូវបានប៉ះពាល់ដោយច្បាប់ផ្សេងទៀត ។

ក្រៅពីសិទ្ធិស៊ីវិល និងសិទ្ធិនយោបាយ នៅមានសិទ្ធិខាងសេដ្ឋកិច្ច និងសង្គម ក៏ជាផ្នែកមួយនៃសិទ្ធិជាមូលដ្ឋានគ្រឹះ ។ ការអនុវត្តនៅលើពិភពលោក មានការគិតគូរខុសគ្នារវាងប្រទេសធំ និងប្រទេសតូចអំពីបញ្ហាសិទ្ធិមនុស្សនេះ ។ ប្រទេសធំផ្តោតតែលើបញ្ហាសិទ្ធិស៊ីវិល និងសិទ្ធិនយោបាយជាសំខាន់ ។ ប្រទេសតូចផ្តោតអាទិភាពលើសិទ្ធិខាងសេដ្ឋកិច្ច និងសង្គម ។

## ស្ថាប័ននៃការគ្រប់គ្រងដោយភាពតំណាងដែលត្រូវរាយការណ៍

សរសរទី២នៃលទ្ធិប្រជាធិបតេយ្យ ស្ថិតនៅលើស្ថាប័នគ្រប់គ្រងដោយភាពតំណាងដែលត្រូវរាយការណ៍ជាក្រុមស្ថាប័នដែលរួមគ្នាកំណត់ច្បាប់ និងគោលនយោបាយរបស់សង្គម ហើយធានាដល់នីតិរដ្ឋ ។

នៅក្នុងក្របខ័ណ្ឌបុរាណនៃការបែងចែកអំណាច (នីតិប្រតិបត្តិ នីតិបញ្ញត្តិ និងតុលាការ) សភាក្នុងឋានៈជាអង្គការលេចចេញពីការបោះឆ្នោតដោយសេរីដើរតួនាទីសំខាន់ ។ គឺជាស្ថាប័នឆ្លុះបញ្ចាំងនូវឆន្ទៈរបស់ប្រជាជន ជាស្ថាប័នជាក់ស្តែងដែលដើរតួជាការគ្រប់គ្រងរបស់ប្រជាជន ដោយប្រជាជន ។ ដោយទទួលអាណត្តិពីប្រជាជន សភាជាតំណាងឱ្យប្រជាជនចំពោះមុខអំណាចផ្សេងទៀត និងចំពោះមុខអង្គការអន្តរជាតិ ឬក៏សភាក្រោមជាតិ ។

សភាដែលប្រជាធិបតេយ្យ លុះណាតែសភានោះអាចបំពេញដោយពិតប្រាកដនូវតួនាទីជាអ្នកសម្រុះសម្រួល (Médiateur) និងជាតំណាងឱ្យប្រជាជនចំរុះគ្នាទាំងមូល ។

មិនតែប៉ុណ្ណោះ សភានោះត្រូវបំពេញប្រកបដោយប្រសិទ្ធភាពនូវបេសកកម្ម និងមុខងាររបស់ខ្លួនដូចតទៅ

- ធ្វើច្បាប់
- អនុម័តចំណូល និងចំណាយនៅក្នុងក្របខ័ណ្ឌថវិកាជាតិ
- ត្រួតពិនិត្យសកម្មភាព គោលនយោបាយ និងភ្នាក់ងាររបស់អង្គនីតិប្រតិបត្តិ

- ផ្តល់សច្ចាប័នលើសន្ធិសញ្ញា ឬអនុញ្ញាតឱ្យមានការចុះសច្ចាប័ន និងត្រួតពិនិត្យទៅលើស្ថាប័នដែលបង្កើតដោយសន្ធិសញ្ញា
- ស្តាប់នូវបណ្តឹងតវ៉ា និងកែលំអការរំលោភបំពាន
- យល់ព្រមលើការកែប្រែរដ្ឋធម្មនុញ្ញ

ប្រសិទ្ធភាពកន្លែងនេះ ពុំត្រឹមតែលើវិធីសាស្ត្រនៃការធ្វើការងាររបស់សភាប៉ុណ្ណោះទេ តែថែមទាំងលើចម្លើយចំពោះសេចក្តីត្រូវការរបស់គ្រប់សមាសធាតុក្នុងសង្គមផងដែរ ។

## សង្គមស៊ីវិលដ៏សកម្ម

ពាក្យថាសង្គមស៊ីវិលមិនសំដៅតែអង្គការក្រៅរដ្ឋាភិបាល (NGO) ប៉ុណ្ណោះទេ តែថែមទាំងអង្គរបស់ប្រជាពលរដ្ឋសកម្មដែលខិតខំដើម្បីដោះស្រាយបញ្ហារួមរបស់ពួកគេ ដើម្បីជម្រុញ និងការពារផលប្រយោជន៍របស់ពួកគេ ។

សង្គមស៊ីវិលឯករាជ្យពីរដ្ឋាភិបាល តែពួកគេត្រូវតែទាក់ទងជាមួយរដ្ឋាភិបាលលើបញ្ហាទាំងអស់ ដែលពាក់ព័ន្ធដល់ពួកគេ និងលើផលប្រយោជន៍របស់អ្នកទាំងឡាយដែលពួកគេជាតំណាង ។

តួនាទីរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសប្រជាធិបតេយ្យមួយ ពុំត្រឹមតែបោះឆ្នោតជ្រើសការគ្រប់គ្រងប៉ុណ្ណោះទេ តែត្រូវថែរក្សាការប្រាស្រ័យទាក់ទងជាអចិន្ត្រៃយ៍ជាមួយអ្នកគ្រប់គ្រង ដើម្បីកុំឱ្យពួកគេផ្តាច់ខ្លួនពីប្រជាជន និងពីសេចក្តីត្រូវការរបស់ប្រជាជន ។

សភាប្រជាធិបតេយ្យខិតខំជម្រុញឱ្យមានសង្គមស៊ីវិលមួយខ្លាំងក្លា ហើយចាប់ដៃគូជាមួយសង្គមស៊ីវិល ដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហាទាំងឡាយរបស់ប្រទេស និងកែលំអគុណភាព និងភាពជាប់លាប់នៃច្បាប់ ។

## គណបក្សនយោបាយ

ក្នុងចំណោមស្ថាប័នសម្រុះសម្រួល (Mediation) រវាងរដ្ឋាភិបាល និងសង្គម គណបក្សនយោបាយមានសារសំខាន់ជាពិសេសសម្រាប់សភា ។

សភាពុំគ្រាន់តែជាតំណាងឱ្យប្រជាពលរដ្ឋជាបុគ្គលប៉ុណ្ណោះទេ ។

តាមរយៈគណបក្សនយោបាយ សភាក៏ជាតំណាងឱ្យប្រជាពលរដ្ឋផងដែរ នៅពេលប្រជាពលរដ្ឋទាំងនោះរួមបង្កើតជាក្រុម ដើម្បីជម្រុញនូវនិន្នាការនយោបាយទូទៅ ។

គណបក្សផ្តល់លទ្ធភាពឱ្យមានជម្រើសនៅក្នុងការបោះឆ្នោត ហើយធានាថាជម្រើសទាំងនោះត្រូវបានគិតគូរនៅក្នុងការងាររបស់សភា និងនៅក្នុងការពិភាក្សាជាសាធារណៈ ។

ជាការពិត គណបក្សនយោបាយតែងទទួលនូវការពុំអើពើចាប់អារម្មណ៍ពីសាធារណមតិផងដែរ ។ ប៉ុន្តែគណបក្សនយោបាយនៅតែចាំបាច់ដដែលសម្រាប់ដំណើរការដ៏ល្អរបស់សភាប្រជាធិបតេយ្យមួយ ។ គេអាចនិយាយថា ដោយមានជើងមួយឈរនៅក្នុងប្រព័ន្ធនៃការគ្រប់គ្រង ហើយជើងមួយទៀតនៅក្នុងសង្គមស៊ីវិលនោះ គណបក្សនយោបាយគឺជាបណ្តាញតភ្ជាប់រវាងប្រព័ន្ធគ្រប់គ្រង និងសង្គមស៊ីវិល ។

## ប្រព័ន្ធឃោសនា

ស្ថាប័នជាបណ្តាញតភ្ជាប់ទីពីរដែលមានសារសំខាន់បំផុតសម្រាប់សភា និងការងារសភានោះគឺ ប្រព័ន្ធឃោសនា ។

តាមរយៈប្រព័ន្ធឃោសនា ប្រជាពលរដ្ឋបានដឹងឮអំពីកិច្ចការសាធារណៈ ។ តាមរយៈការងារស៊ើបអង្កេត ប្រព័ន្ធឃោសនាដើរតួជាទម្ងន់ប្រឆាំងជានិច្ចមួយចំពោះការរំលោភបំពាន ។ របៀបដែលប្រព័ន្ធឃោសនាបំពេញមុខងារទាំងនេះ អាចជាភាគច្រើនកំណត់អំពីគុណភាពនៃជីវភាពប្រជាធិបតេយ្យ ។

មុខងាររបស់ប្រព័ន្ធឃោសនា កាន់តែត្រូវបានប៉ះពាល់ដោយការប្រកាន់បក្សពួករបស់អង្គនីតិប្រតិបត្តិនៅក្នុងការគ្រប់គ្រងដែលត្រួតត្រាដោយអង្គនីតិប្រតិបត្តិ ឬដោយផលប្រយោជន៍សេដ្ឋកិច្ចដ៏ខ្លាំងក្លាដទៃទៀត ។

ហេតុនេះ សភាត្រូវទទួលបន្ទុកគាំទ្រលទ្ធិប្រជាធិបតេយ្យ ដោយកំណត់នូវក្របខ័ណ្ឌច្បាប់សមស្របសម្រាប់ប្រព័ន្ធឃោសនា ដើម្បីធានាទាំងភាពឯករាជ្យរបស់ប្រព័ន្ធឃោសនា និងភាពចំរុះរបស់ពួកគេ ។

## សន្និដ្ឋានជំហានដំបូង

សភាផ្តល់វិភាគទានជាអាយុជីវិតដល់លទ្ធិប្រជាធិបតេយ្យព្រមពេលគ្នាលើគ្រប់កំរិត ។ ក្នុងចំណោមស្ថាប័នគ្រប់គ្រង សភាគឺជាស្ថាប័នតំណាងដែលសម្តែងនូវឆន្ទៈរបស់ប្រជាជន ក្នុងនោះមានភាពចំរុះ ហើយដែលបើកឱកាសឱ្យមានការពិភាក្សា និងការដោះស្រាយនូវភាពខុសគ្នា (ជម្លោះ-ទំនាស់) ។ សភាបង្ហាញនូវធម្មានុភាពប្រជាធិបតេយ្យ ដោយធានាឱ្យមានការពិភាក្សា និងការស្រុះស្រួលគ្នា (Compromis) ។

សភាក៏ជាមធ្យោបាយដើម្បីឆ្លុះបញ្ចាំងជាក់ស្តែងនូវផលប្រយោជន៍សមូហភាព ជាលទ្ធផលផលខ្ពង់ខ្ពស់ជាងការបូកបញ្ចូលគ្នានូវផលប្រយោជន៍របស់បុគ្គល ឬផ្នែក ។

គឺថាគ្មានជីវិតប្រជាធិបតេយ្យប្រកបដោយគុណភាពឡើយ ប្រសិនបើសភាពុំអាចបំពេញនូវបេសកកម្មជាសារវ័ន្តរបស់ខ្លួន ការងារធ្វើច្បាប់ ត្រួតពិនិត្យថវិកា និងត្រួតពិនិត្យលើអង្គនីតិប្រតិបត្តិ ។

ម្យ៉ាងទៀតដែលសំខាន់បំផុតគឺ សភាត្រូវគោរពដោយខ្លួនឯងនូវបទដ្ឋានប្រជាធិបតេយ្យ ដោយធានាថា បើកចំហ និងពឹងពាក់បាន រាយការណ៍ឱ្យម្ចាស់ឆ្នោតអំពីបែបបទនៃដំណើរការងាររបស់ខ្លួនឯងផ្ទាល់ ។

## លក្ខណៈវិនិច្ឆ័យរបស់សភាប្រជាធិបតេយ្យ

សភាមួយដែលចាត់ទុកថាប្រជាធិបតេយ្យ ត្រូវឈរលើលក្ខណៈវិនិច្ឆ័យដូចតទៅ

១- ***ជាតំណាង*** ខាងសង្គម និងនយោបាយរបស់ប្រជាជនចំរុះទាំងមូល ហើយធានាដល់តំណាង និងកិច្ចការពារស្មើភាពសម្រាប់សមាជិករបស់ខ្លួនទាំងអស់ ។

២- ***មានតម្លាភាព*** ដោយបើកចំហចំពោះប្រជាពលរដ្ឋទាំងអស់តាមរយៈប្រព័ន្ធឃោសនា និងមានតម្លាភាពនៅក្នុងការចាត់ចែងកិច្ចការ ។

៣- ***ចូលបិកបាន*** ដោយចលនាឱ្យប្រជាពលរដ្ឋ ជាពិសេស សមាគម និងចលនានៃសង្គមស៊ីវិលឱ្យចូលរួមក្នុងដំណើរការរបស់សភា ។

៤- ***មានរបាយការណ៍*** សមាជិកសភាត្រូវរាយការណ៍ឱ្យម្ចាស់ឆ្នោត អំពីរបៀបដែលខ្លួនបំពេញអណត្តិរបស់ខ្លួន និងអំពីភាពសុច្ចរិតរបស់ខ្លួន ។

៥- ***មានប្រសិទ្ធភាព*** មានការចាត់តាំងស្របតាមតម្លៃប្រជាធិបតេយ្យ ហើយការបំពេញនូវមុខងារនីតិកម្ម និងត្រួតពិនិត្យរបស់សភា ដើម្បីឆ្លើយតបទៅនឹងសេចក្ដីត្រូវការរបស់ប្រជាជនទាំងមូល ។

ពីប្រទេសមួយទៅប្រទេសមួយទៀត សភាតែងខុសគ្នា អាស្រ័យដោយប្រព័ន្ធនៃការគ្រប់គ្រង ឬបរិបទប្រវត្តិសាស្ត្រ នយោបាយ សេដ្ឋកិច្ច-សង្គម-វប្បធម៌/ប្រពៃណី ។

នៅលើពិភពលោកមានខ្លះជារដ្ឋសហព័ន្ធ ខ្លះជារដ្ឋឯកភាព ខ្លះប្រកាន់របបប្រធានាធិបតី ខ្លះប្រកាន់របបសភា ខ្លះមានសភាមួយថ្នាក់ ខ្លះទៀតមានសភាពីរថ្នាក់ ។

ពីប្រទេសមួយទៅប្រទេសមួយទៀត រឿងខុសគ្នាសំខាន់ត្រង់កំរិតនៃការអភិវឌ្ឍសេដ្ឋកិច្ច ។ ធនធានសម្រាប់សភានៃប្រទេសនីមួយៗមិនដូចគ្នាទេ ។ ដូច្នេះ គ្មានគំរូតែមួយគត់សម្រាប់លទ្ធិប្រជាធិបតេយ្យលើពិភពលោកនេះទេ ។

**<u>កំណត់សំគាល់</u>**

១- បទពិសោធន៍ល្អសម្រាប់សភាមួយវាជាបរិបទមួយ បទពិសោធន៍មួយពុំមានការធានាថា បទពិសោធន៍នេះអាចយកទៅអនុវត្តន៍បានល្អនៅក្នុងសភាមួយទៀតឡើយ ។

២- បទដ្ឋានប្រជាធិបតេយ្យ និងតម្លៃប្រជាធិបតេយ្យ តែងពុំមានអាទិភាព ឬតម្លៃដូចគ្នាក្នុងពេលតែមួយឡើយ ។ ជាឧទាហរណ៍ :

- សភាមួយសម្របសម្រួលកម្មវិធីធ្វើច្បាប់របស់រដ្ឋាភិបាល ដោយត្រួតពិនិត្យលើកម្មវិធីនេះផង និងកែសម្រួលផង
- អភ័យឯកសិទ្ធិសភា គឺសម្រាប់ការពារសមាជិកសភាអំពីការបំពានផ្តេសផ្តាសពីអង្គនីតិប្រតិបត្តិ តែអភ័យឯកសិទ្ធិនេះពុំអាចការពារខ្លួនឱ្យរួចផុតពីបទឧក្រិដ្ឋបានឡើយ
- សិទ្ធិផ្តួចផ្តើមធ្វើច្បាប់ផ្តល់ឱ្យសមាជិកសភាជាបុគ្គល អាចធ្វើឱ្យកម្មវិធីសភា និងការចាត់ចែងសកម្មភាពសភាត្រូវប៉ះពាល់
- ប្រព័ន្ធបោះឆ្នោតដែលឈរលើមណ្ឌលបោះឆ្នោត អាចបង្កិតតំណាងឱ្យទៅជិតអ្នកបោះឆ្នោត តែក៏អាចនាំឱ្យសភាជារូមខ្វះនូវភាពតំណាងជាច្រើនប្រការ

៣- សភាពេលខ្លះដើរតួនាទីសំខាន់ជាពិសេស ដើម្បីដោះស្រាយវិបត្តិក្នុងកាលៈទេសៈណាមួយរបស់ជាតិ ឬក៏សម្តែងនូវសកម្មភាពសំខាន់នៅក្នុងប្រវត្តិសាស្ត្រជាតិ ជាឧទាហរណ៍ :

- តួនាទីរបស់សភាអ៊ុយក្រែន នៅក្នុងការដោះស្រាយវិបត្តិជាតិបន្ទាប់ពីការបោះឆ្នោតប្រធានាធិបតី នាចុងឆ្នាំ ២០០៤
- តួនាទីរបស់សភាទួរគី មុនពេលសង្គ្រាមនៅអ៊ីរ៉ាក់ផ្ទុះឡើងនៅឆ្នាំ ២០០៣ ( ប្រឆាំងការឆ្លងកាត់របស់ទ័ពបរទេស និងការបញ្ជូនទ័ពទួរគីទៅក្រៅប្រទេស)

កាលៈទេសៈពិសេសបែបនេះ ពុំដែលបានគ្រោងទុកឡើយ ហើយពុំគិតថាត្រូវមានច្បាប់ឡើយ ។

ទោះជាមាននីតិវិធីប្រជាធិបតេយ្យបែបណាក្តី ប្រសិនបើសភាអាចបង្ហាញសមត្ថភាពខ្លួនខ្ពស់សមស្របទៅនឹងស្ថានការណ៍ ហើយចេញមុខ "និយាយដើម្បីប្រទេស" ក្នុងពេលវេលាដ៏ធ្ងន់ធ្ងរនោះ ប្រជាពលរដ្ឋពិតជាមានការវាយតម្លៃខ្ពស់ ។

## II-សភាដែលមានលក្ខណៈតំណាង

នេះជាលក្ខណៈវិនិច្ឆ័យទី១ : សភាត្រូវតែជាតំណាងឱ្យប្រជាជន ។ បានន័យថា សភាត្រូវសម្តែងនូវឆន្ទៈរបស់ប្រជាជន ដូចដែលប្រជាជនបានជ្រើសរើសនូវតំណាងរបស់ខ្លួន ព្រមទាំងគណបក្សនយោបាយដែលអ្នកជាប់ឆ្នោតទាំងនេះធ្វើសកម្មភាព ។

សភាអាចខ្វះនូវភាពតំណាងអាស្រ័យដោយកត្តា ២ គឺ

- ការខ្វះចន្លោះនៅក្នុងនីតិវិធីនៃការបោះឆ្នោត
- ការខ្វះចន្លោះនៅក្នុងប្រព័ន្ធបោះឆ្នោត

តាមរយៈនេះក្រុមសង្គមស៊ីវិល និងសហគមន៍ខ្លះមានអារម្មណ៍ថា ពួកគេគ្មានទទួលបានភាពអនុគ្រោះនៅក្នុងដំណើរការនយោបាយ ឬក៏ផាត់ចេញទាំងស្រុង ។ ប្រការនេះនាំឱ្យមានផលវិបាកប៉ះពាល់ដល់គុណភាពនិងជីវភាពសាធារណៈ ឬដល់ស្ថេរភាពនៃប្រព័ន្ធនយោបាយ និងឯកភាពសង្គម ។

សភាប្រជាធិបតេយ្យត្រូវឆ្លុះបញ្ចាំងនូវភាពចំរុះខាងសង្គមរបស់ប្រជាជនដូចជា ភេទ ភាសា សាសនា ក្រុមជាតិពន្ធ និងលក្ខណៈសម្បត្តិនយោបាយសំខាន់ៗផ្សេងទៀត ។

ដូច្នេះសភាដែលមានភាពតំណាងល្អ គឺជាសភាដែលមានគ្រប់សមាសភាពតំណាងឱ្យសង្គមទាំងមូល ។ ប្រការនេះពឹងផ្អែកលើដំណើរការបោះឆ្នោត ។ ចំណុចទី២ សភានោះត្រូវមាននីតិវិធីសភាប្រកបដោយសមធម៌ និងរួមសំបាច់គ្នា (គ្មានក្នុងគ្មានក្រៅ) ដោយផ្តល់ឱ្យសមាជិកទាំងអស់នូវលទ្ធភាព ដើម្បីសម្តែងនូវទស្សនៈ និងចូលរួមការងារសភាដោយស្មើភាពគ្នា និងដើម្បីកសាងនូវអាជីពសភា ។

ជាការពិត បញ្ហាសមាសភាពសភាគឺជារឿងកើតចេញពីដំណើរការមុនសភា តែសភាអាចមានឥទ្ធិពលដោយប្រយោលទៅលើសមាសភាពរបស់ខ្លួន អាស្រ័យដោយអំណាចធ្វើច្បាប់ដើម្បីកំណត់នូវបទបញ្ញាសំរាប់ការបោះឆ្នោត ។

លក្ខណៈវិនិច្ឆ័យសមធម៌ និងគ្មានក្នុងគ្មានក្រៅរបស់នីតិវិធី គឺជាការត្រួតត្រាផ្ទាល់របស់សភាខ្លួនឯង ។

### បទបញ្ញា និងនីតិវិធីបោះឆ្នោតដើម្បីធានាថា សភាមួយដែលមានភាពតំណាងខាងនយោបាយគ្រប់គ្រាន់

មានលក្ខណៈសម្បត្តិ ៣ យ៉ាង នៃដំណើរការបោះឆ្នោតដើម្បីសម្រេចគោលដៅនេះ

- ត្រូវមានការធានានូវនីតិវិធីបោះឆ្នោតប្រកបដោយសមធម៌ មានន័យត្រូវធានាថា គ្មានអ្នកបោះឆ្នោត ឬបេក្ខជន ឬគណបក្សណាមួយត្រូវខូចប្រយោជន៍ ឬរងគ្រោះដោយការរើសអើង ។
- បទដ្ឋានអំពីការបោះឆ្នោតដោយសេរី និងទៀងទាត់ត្រូវបានអនុម័តនៅគ្រប់កំរិត : ការចុះឈ្មោះអ្នកបោះឆ្នោត និងគណបក្សនយោបាយនៅគ្រប់ទិដ្ឋភាពនៃដំណើរការបោះឆ្នោត នីតិវិធីនៃការតវ៉ាប្រឆាំងលទ្ធផល ក្រោមការត្រួតពិនិត្យរបស់គណៈកម្មការបោះឆ្នោតឯករាជ្យ ។
- ត្រូវជៀសវាងការហាមឃាត់ រឹតត្បិត សំខាន់ដល់ជូរអ្នកបោះឆ្នោត ។ ជាឧទាហរណ៍ : ប្រទេសអូម៉ង់បានពង្រីកជូរអ្នកបោះឆ្នោតដល់អាយុ ២១ឆ្នាំ នៅឆ្នាំ ២០០៣ ។ ប្រទេសហ្វីលីពីនដែលមានអ្នកធ្វើការក្រៅប្រទេសច្រើន បានពង្រីកជូរអ្នកបោះឆ្នោតបន្ថែម ៧.៥ លាននាក់ នៅឆ្នាំ២០០៣ ។ ប្រទេសម៉ិចស៊ិកបង្កើន ១០លាននាក់បន្ថែមនៅឆ្នាំ២០០៥ ។

**អំពីប្រព័ន្ធបោះឆ្នោត**

លក្ខណៈវិនិច្ឆ័យទី២ អំពីភាពតំណាងខាងនយោបាយរបស់សភា គឺជាដំណើរការដ៏ល្អនៃប្រព័ន្ធបោះឆ្នោតនៅក្នុងបរិបទសេដ្ឋកិច្ច និងនយោបាយរបស់ប្រទេស សមធម៌ដែលគណបក្សនយោបាយផ្សេងៗត្រូវបានគិតគូរ និងរាប់រក ការគាំទ្រដែលគណបក្សនយោបាយបានទទួលពីអង្គបោះឆ្នោត គឺជាសន្ទស្សន៍វាស់វែងដ៏ល្អប្រសើរអំពីសាធារណៈមតិ ។

មានប្រព័ន្ធបោះឆ្នោត ៣ ដែលគេកំពុងប្រើប្រាស់ច្រើនបំផុត

- ការបោះឆ្នោតជាឯកត្តនាម ដែលក្នុងមណ្ឌលបោះឆ្នោតនីមួយៗ អ្នកបោះឆ្នោតជ្រើសរើសយកបេក្ខជនតែម្នាក់ ។ ប្រសិនបើការបោះឆ្នោតនោះមានតែមួយលើក បេក្ខជនដែលទទួលសន្លឹកឆ្នោតច្រើនជាងគេនឹងទទួលជ័យជំនះ ទោះបីគេពុំបានទទួលសម្លេងភាគច្រើនដាច់ខាតក៏ដោយ ។ ការបោះឆ្នោតឯកត្តនាម ២ លើក (ដោយការបំបាត់ចោលបេក្ខជនផ្សេងទៀតក្រៅពីបេក្ខជននាំមុខពីររូប) ជាការធានាថា បេក្ខជនជាប់ឆ្នោតទទួលបានសម្លេងភាគច្រើនពុំមែនដោយប្រៀបឡើយ តែដោយសម្លេងភាគច្រើនដាច់ខាត ។
- ការបោះឆ្នោតជាបញ្ជី ដោយការបែងចែកអាសនៈតាមសមាមាត្រ ។ ក្នុងករណីបែបនេះគណបក្សនយោបាយលើកបញ្ជីបេក្ខជន រៀបចំលំដាប់លេខរៀង ទៅតាមមណ្ឌលបោះ

ឆ្នោត ក្នុងក៏រិតតំបន់ និងក៏រិតជាតិ ។ ចំនួនបេក្ខជនជាប់ឆ្នោតតាមបញ្ជី គឺសមាមាត្រទៅនឹងចំនួនសន្លឹកឆ្នោតដែលបានបោះចំពោះគណបក្សនីមួយៗ នៅក្នុងមណ្ឌលបោះឆ្នោតនោះ ។

- ប្រព័ន្ធចំរុះ ។ ក្នុងករណីនេះ អ្នកបោះឆ្នោតម្នាក់មានពីរសម្លេង មួយសម្លេងសម្រាប់តំណាងនៅក្នុងមណ្ឌលបោះឆ្នោត តាមការបោះឆ្នោតឯកត្តនាម ។ មួយសម្លេងទៀតសម្រាប់បញ្ជី ឬគណបក្សដែលអនុញ្ញាតឱ្យមានការបែងចែកអាសនៈតាមសមាមាត្រ នៅក្នុងក៏រិតតំបន់ ឬក៏រិតជាតិ ។ ប្រព័ន្ធនេះមានឥទ្ធិពលដើម្បីធ្វើឱ្យមានតុល្យភាពរបស់គណបក្សនានានៅក្នុងសភា ដោយបញ្ចូលភាពសមាមាត្រខ្លាំង ឬខ្សោយទៅតាមចំនួនអ្នកតំណាងជាប់ឆ្នោត ស្របទៅតាមវិធីបោះឆ្នោតទាំងពីរនេះ ។

ការវិភាគទៅលើប្រព័ន្ធបោះឆ្នោតទាំង ៣ បង្ហាញថា

- ប្រព័ន្ធបោះឆ្នោតយកសម្លេងភាគច្រើនតែមួយលើក នាំឱ្យសភាមានលក្ខណៈតំណាងតិច បើគិតទៅតាមឆន្ទៈរបស់ប្រជាជន ។ សម្លេងឆ្នោតក្នុងក៏រិតជាតិបានបាត់បង់ជាច្រើន ។
- ការបោះឆ្នោតជាបញ្ជីនាំឱ្យសភាមានភាពតំណាងខ្ពស់របស់អ្នកបោះឆ្នោត ដែលបានជ្រើសរើសក្នុងចំណោមគណបក្សនយោបាយនានា ។ តែប្រព័ន្ធនេះមានផលវិបាកត្រង់ថាវាអាចផ្តាច់នូវទំនាក់ទំនងរវាងអ្នកបោះឆ្នោត និងអ្នកតំណាងមូលដ្ឋាន (ពុំដឹងជានរណាជាតំណាងខ្លួនពិតប្រាកដ) ភាពតំណាងឱ្យផលប្រយោជន៍មូលដ្ឋាន ។
- ប្រព័ន្ធចំរុះដែលបានអនុវត្តន៍នៅប្រទេសមួយចំនួន ដែលនេះជាការកែទម្រង់សាមញ្ញ នាំឱ្យសភាមានលក្ខណៈកាន់តែតំណាង និងរួមសំបាច់គ្នា ។ ជាឧទាហរណ៍ ករណីប្រទេសម៉ារ៉ុកឆ្នាំ២០០២ ។ ប្រទេសកូរ៉េឆ្នាំ ២០០៤ អនុវត្តន៍ប្រព័ន្ធ "មនុស្សម្នាក់សម្លេងពីរ" ដើម្បីជ្រើសរើសបេក្ខជនដែលខ្លួនស្រឡាញ់សម្រាប់មណ្ឌលខ្លួន និងដើម្បីជ្រើសរើសគណបក្សដែលខ្លួនស្រឡាញ់ ។ ឆ្នាំ១៩៩៩ ប្រព័ន្ធបោះឆ្នោតហ្វីលីពីនត្រូវបានចាប់ផ្តើមអនុវត្តន៍ប្រព័ន្ធចំរុះ ។
- ដោយពុំពាក់ព័ន្ធដល់ការបោះឆ្នោត និងប្រព័ន្ធបោះឆ្នោត ភាពជាតំណាងនយោបាយរបស់សភាក៏ត្រូវពឹងផ្អែកដល់អ្នកដែលបានប្រើសិទ្ធិបោះឆ្នោតរបស់ខ្លួនផង ។ អ្នកមួយចំនួនពុំបានទៅបោះឆ្នោត ព្រោះគេគិតថា អ្នកជាប់ឆ្នោតទោះជានរណាក៏ដោយពុំមែនជាតំណាង

ឱ្យផលប្រយោជន៍របស់អ្នកបោះឆ្នោតឡើយ ។ ប្រការនេះនាំឱ្យសមាសភាពរបស់សភាបន្ទាប់ពីការបោះឆ្នោតត្រូវប៉ះពាល់ ។ ជាឧទាហរណ៍ ចំណាយពេលនៃយុទ្ធនាការបោះឆ្នោត បណ្តាលឱ្យអ្នកជាប់ឆ្នោតកាន់តែក្លាយទៅជាតំណាងឱ្យក្រុមអ្នកឧបត្ថម្ភហិរញ្ញវត្ថុរបស់ខ្លួនជាជាងឱ្យអ្នកបោះឆ្នោត ។ សម្រាប់កិច្ចការនេះ ច្បាប់កាលណាដាក់កំណត់អំពីប្រភព និងបរិមាណនៃហិរញ្ញប្បទាន កំណត់អំពីអំណោយរបស់បុគ្គល និងហាមឃាត់អំណោយរបស់សហគ្រាស ឬសហជីព ព្រមទាំងវិធានការហិរញ្ញប្បទានសាធារណៈ ធានាដល់សមធម៌សម្រាប់គណបក្សនយោបាយទាំងអស់ ។

នៅកាលណាដាក់ដូចជានៅប្រទេសខាងលិច គេចាប់អារម្មណ៍អំពីការចូលរួមរបស់ប្រជាជនក្នុងកិច្ចការសាធារណៈ ជាពិសេស យុវវ័យ ដើម្បីឱ្យមានទំនុកចិត្តឡើងវិញលើប្រព័ន្ធបោះឆ្នោត ។

## **បទបញ្ញា និងនីតិវិធីបោះឆ្នោតដែលធានាឱ្យសភាឆ្លុះបញ្ចាំងបានដោយពិតប្រាកដនូវភាពចំរុះសង្គមរបស់ប្រជាជន**

អ្វីដែលគេយកចិត្តទុកដាក់ គឺភាពតំណាងរបស់នារី ភាពតំណាងរបស់សហគមន៍ជនជាតិភាគតិច ឬក៏សហគមន៍ងាយរងគ្រោះ ទាំងខាងភាសា សាសនា ជនជាតិ ជនជាតិដើម... ។ល ។ សភាប្រជាធិបតេយ្យតែងតែយកចិត្តទុកដាក់ដើម្បីបញ្ចូលទៅក្នុងសមាសភាពរបស់ខ្លួន ។

### **អំពីតួនាទីរបស់នារីនៅក្នុងសភា**

នៅគ្រប់សង្គមទាំងអស់ ការធ្វើនយោបាយតែងតែជាកិច្ចការរបស់បុរស ។

នៅក្នុងប្រទេសប្រជាធិបតេយ្យលោកខាងលិច សិទ្ធិបោះឆ្នោតក៏ទើបតែផ្តល់ឱ្យនារី ។ ទោះបីមានសមភាពជាមួយបុរសក្នុងការបោះឆ្នោត តែសមភាពនៃសំណាងជាប់ឆ្នោតនៅពុំទាន់សម្រេចបាននៅឡើយ ។ នៅក្នុងចំណោមសភាទាំងអស់លើពិភពលោក នារីជាសមាជិកសភាមានតែ ១៦,៤% ប៉ុណ្ណោះ ។ ក្នុងនោះមានសភា ១១ ដែលគ្មានសមាជិកជានារី ។ ក្នុងសភាមួយថ្នាក់ចំនួន ៦០ មានសមាជិកជានារីតិចជាង១០% ។

តាមការសង្កេតលើពិភពលោកបង្ហាញថា

១- បញ្ហាសមភាព និងយុត្តិធម៌ : គេយល់ថា លទ្ធិប្រជាធិបតេយ្យមួយដែលនារីពុំមានភាពតំណាងគ្រប់គ្រាន់នោះ ពុំមែនជាលទ្ធិប្រជាធិបតេយ្យពិតប្រាកដឡើយ ។ ការចូលរួមរបស់នារីក្នុងការ

រៀបចំគោលនយោបាយ គឺជាយុត្តិធម៌ និងសមភាព ។ ឱនភាពខាងសមភាពសម្រាប់នារី គឺជាឱនភាពនៃលទ្ធិប្រជាធិបតេយ្យ ។

២- វត្តមានរបស់នារីកែប្រែដំណើរការ និងវប្បធម៌នយោបាយ នារីពុំសូវមានអាកប្បកិរិយាបដិបក្ខ ហើយមានទំនោរទៅរកកុងសង់ស៊ីស : នារីមិនសូវយកឈ្នះចាញ់នៅក្នុងនយោបាយ ចង់ដោះស្រាយបញ្ហាច្រើនជាង ។ នារីធ្វើឱ្យពិភពនយោបាយមានមនុស្សធម៌ ។ វត្តមានរបស់នារីនាំឱ្យមានការផ្លាស់ប្តូរ ។ ដោយមានវត្តមានរបស់នារី នយោបាយចាប់ផ្តើមទទួលបាននូវទំនុកចិត្តឡើងវិញពីសាធារណៈមតិ ។

៣- នារីផ្លាស់ប្តូរអាទិភាពនយោបាយ ដែលពីមុនមកបុរសផ្តាច់មុខ។ នារីចាប់អារម្មណ៍ខ្ពស់អំពីបញ្ហាសង្គម ជាពិសេសភាពក្រីក្រ និងការអប់រំកុមារ ។ នារីគឺជាជនទី១ ដែលចាប់អារម្មណ៍អំពីបញ្ហាសេដ្ឋកិច្ច អប់រំ និងសុខាភិបាល ។ អាទិភាពរបស់នារីមានលក្ខណៈមនុស្សធម៌ជាង ទាំងសម្រាប់បុរស ទាំងសម្រាប់នារី ។ តាមការសង្កេតនេះគេយល់ថា ដើម្បីឱ្យនារីផលិតបាននូវលទ្ធផលជាក់ស្តែង លុះណាតែចំនួននារីមានគ្រប់គ្រាន់នៅក្នុងសភា ។ UNDP បានវាយតម្លៃថា ដើម្បីឱ្យនារីមានឥទ្ធិពលនៅក្នុងសភាបាន លុះណាតែនារីមានចំនួនយ៉ាងតិច ៣០%នៅក្នុងសភា ។

តើអ្វីជាឧបសគ្គធ្វើពុំឱ្យចំនួននារីកើននៅក្នុងសភានានាបាន?

- **ការស្ម័យដាក់ខ្លួននៅខាងក្រៅ** : នារីជាច្រើនញញើតនឹងចូលរួមក្នុងជីវភាពនយោបាយ អាស្រ័យដោយការប្រកួតប្រជែងនិងភាពសាហាវនៅក្នុងជីវភាពនោះ ព្រមទាំងពលិកម្មដែលត្រូវមានទៅលើជីវិតគ្រួសាររបស់ខ្លួន (ពេលវេលា ធនធាន ការយកចិត្តទុកដាក់)
- **ភាពបដិបក្ខរបស់បុរស** : ថ្នាក់ដឹកនាំគណបក្សនយោបាយសុទ្ធតែជាបុរសដែលអាចប្រឆាំងចំពោះនារី
- **ពេលវេលាប្រជុំ** : សភាមួយចំនួនប្រជុំភាគច្រើននៅពេលល្ងាច និងចុងសប្តាហ៍ ដែលពុំសមស្របទៅនឹងកាតព្វកិច្ចរបស់នារីដែលមានបន្ទុកក្នុងគ្រួសារ
- **ចំណាយនៃយុទ្ធនាការបោះឆ្នោត** : កាលណាចំណាយនោះជាបន្ទុកមួយផ្នែករបស់បេក្ខជន ពុំមែនជាចំណាយទាំងស្រុងរបស់គណបក្សនយោបាយ ។

**តើគេអាចកែប្រែបានដែរឬទេ ដើម្បីបង្កើនចំនួននារីនៅក្នុងសភា?**

បទពិសោធន៍នៃប្រទេសដែលមាននារីចូលរួមនៅក្នុងសភាបានច្រើនបង្ហាញថា គេអាចកែប្រែសភាពការណ៍បាន តែទាំងនោះពឹងផ្អែកលើវិធានការឆន្ទៈនិយម។ មាន ៨១ប្រទេសបានប្រើវិធានការនោះ អាស្រ័យដោយមានការជម្រុញពីចលនាលើកតម្កើងនារី ។ វិធានការខ្លះពឹងផ្អែកលើច្បាប់ វិធានការខ្លះទៀតពឹងផ្អែកលើគណបក្សនយោបាយ

- មានអសនៈរក្សាទុកសម្រាប់នារីនៅក្នុងសភា ក្នុងចំណោមអសនៈទាំងឡាយដែលគណបក្សនយោបាយដណ្តើមបាននៅក្នុងការបោះឆ្នោត ។
- ប្រភាគធានានៅលើបញ្ជីបេក្ខជនរបស់គណបក្សនយោបាយ ឬក៏កូតារក្សាទុកសម្រាប់នារី ក្នុងនោះលំដាប់លេខរៀងល្អសម្រាប់នារី ។
- បញ្ជីសម្រាប់ជ្រើសសម្រាំងបេក្ខជននៅក្នុងប្រព័ន្ធមណ្ឌលបោះឆ្នោត ឬក៏ការរួមបញ្ចូលគ្នានូវមណ្ឌលបោះឆ្នោត ដោយមានការតម្រូវឱ្យជ្រើសសម្រាំងយកបេក្ខជននៃភេទទីមួយៗ ។

នៅក្នុងប្រទេសកូរ៉េ គេបានកសាងច្បាប់មួយអំពីបញ្ហាខាងលើនេះ។ ច្បាប់បង្ខំឱ្យទុក ៥០%នៃអសនៈតាមសមាមាត្រឱ្យនារី ហើយត្រូវដាក់នារីម្នាក់ក្នុងចំណោមបេក្ខជនពីរនាក់ នៅលេខរៀងខាងលើគេ ។ ច្បាប់ស្តីពីហិរញ្ញប្បទាននយោបាយអនុញ្ញាតឱ្យមានថវិកាសាធារណៈបន្ថែម ឱ្យគណបក្សនយោបាយដែលបានដាក់នារីនៅក្នុងមណ្ឌលបោះឆ្នោតច្រើនជាង ៣០% មណ្ឌល ។

## ភាពជាតំណាងឱ្យសហគមន៍ជនជាតិភាគតិច និងងាយរងគ្រោះ

ប្រការពុំមានគណបក្សនយោបាយតំណាងឱ្យជនជាតិភាគតិចនៅក្នុងសភា ពុំមានន័យថា អត្តសញ្ញាណផ្ទាល់ និងផលប្រយោជន៍របស់ពួកគេពុំត្រូវបានទទួលស្គាល់ឡើយ ។

ជាការពិត ផលប្រយោជន៍ទាំងនេះតែងតែតំណាងដោយគណបក្សសំខាន់ៗ ។ ម្យ៉ាងទៀត គ្មានការហាមឃាត់មិនឱ្យគណបក្សចាត់តាំងអ្នកនាំពាក្យសម្រាប់ជនជាតិភាគតិច ឬក៏រៀបចំប្រព័ន្ធបោះឆ្នោត ដើម្បីឱ្យសមាជិកគណបក្សរបស់ខ្លួនឱ្យគាំទ្របន្ថែមដល់បេក្ខជនមកពីជនជាតិភាគតិចឡើយ ។ តែភាពតំណាងឱ្យជនជាតិភាគតិចនៅក្នុងក្របខ័ណ្ឌគណបក្សធំៗ នាំឱ្យមានលទ្ធផលល្អលុះណាតែភាគតិចនេះ គឺជាប្រភាគមួយដ៏ច្រើនក្នុងប្រជាជន ។

ដោយភ័យខ្លាចថា ជនជាតិភាគតិចពុំមានតំណាងដ៏ត្រឹមត្រូវនៅក្នុងសភា គេអាចរកដំណោះស្រាយទៅតាមប្រភេទនៃប្រព័ន្ធបោះឆ្នោត និងកំរិតនៃការប្រមូលផ្តុំភូមិសាស្ត្ររបស់ជនជាតិភាគតិចណាមួយ ឬជនជាតិភាគតិចជាច្រើនដែលពាក់ព័ន្ធ

- ការកាត់បន្ថយចំនួនផ្តើមនៃការចុះឈ្មោះ (Seuil d'enregistrement) ហិរញ្ញវត្ថុ ឬការចូលទៅកាន់សភា តាមវិធីនេះ គេកាត់បន្ថយចំនួនហត្ថលេខាចាំបាច់សម្រាប់ការចុះឈ្មោះរបស់គណបក្សនយោបាយណាមួយ ឬក៏ចំនួននៃអ្នកបោះឆ្នោតចាំបាច់ ដើម្បីបានទទួលនូវហិរញ្ញវត្ថុសាធារណៈ ។ ម្យ៉ាងទៀត គណបក្សដែលចុះឈ្មោះថាជារបស់ក្រុមជនជាតិភាគតិចជាតិ អាចត្រូវបានអនុញ្ញាតឱ្យចូលសភា ដោយចំនួនអ្នកបោះឆ្នោតតិចជាសម្លេងឆ្នោតរបស់ប្រជាជនទូទៅ ។
- កំណត់ការបែងចែកមណ្ឌលដែលអនុគ្រោះឱ្យក្រុមជនជាតិភាគតិចមានទស្សនៈវិស័យល្អ (ការរើសអើងវិជ្ជមាននៃការបោះឆ្នោត) ។ ក្នុងករណីមានក្រុមភាគតិចប្រមូលផ្តុំនៅក្នុងតំបន់ពិសេសមួយ គេអាចផ្តល់ចំនួនអសនៈអនុគ្រោះបំផុតចំពោះតំបន់នោះ ។
- កូតានៃបេក្ខជនរបស់គណបក្ស ដោយគណបក្សរៀបចំឱ្យមានភាគរយអប្បបរិមាសម្រាប់បេក្ខជនមកពីក្រុមជនជាតិភាគតិចនៅក្នុងបញ្ជីរបស់គណបក្ស ។ ជាឧទាហរណ៍ នៅសិង្ហបុរី ក្នុងចំណោមមណ្ឌល ១៤ លើ ២៣ មណ្ឌលបោះឆ្នោតទុកសម្រាប់ភាពតំណាងឱ្យក្រុមជនជាតិភាគតិច ហើយនៅក្នុងបញ្ជីរៀបចំដោយគណបក្សនីមួយៗ ជាកាតព្វកិច្ចត្រូវមានបេក្ខជនយ៉ាងតិចមួយរូបមកពីក្រុមជនជាតិភាគតិច ។
- អសនៈបម្រុងទុកសម្រាប់តំណាងឱ្យក្រុមជនជនភាគតិច វិធីនេះត្រូវបានអនុវត្តន៍យ៉ាងច្រើននៅលើពិភពលោក (២៥ប្រទេស) ។ ឥណ្ឌាបច្ចុប្បន្នរក្សាទុកអសនៈ ៧៩ ក្នុងចំណោម ៥៤៣ អសនៈរបស់សភាជាន់ទាប ឱ្យក្រុមវណ្ណៈ និងជនជាតិ ៤១ក្រុម ។ កោះម៉ូរីសរក្សាទុក ៨ អសនៈលើ ៧០អសនៈឱ្យអ្នកចាញ់តិចជាងគេ (Les Meilleurs perdants) ដែលតំណាងឱ្យសហគមន៍ជនជាតិទាំង៤ ដែលទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ ។ ប្រទេសស្លូវ៉ាគីរក្សាទុកមួយអសនៈឱ្យសហគមន៍ជាតិអ៊ីតាលី និងមួយអសនៈឱ្យសហគមន៍ជាតិហុងគ្រី ។

**<u>កំណត់សំគាល់</u>**

វិធីខាងលើនេះតែងនាំមកនូវផលវិបាកផ្សេងៗផងដែរ

- កូតាសម្រាប់ក្រុមជនជាតិភាគតិចនៅក្នុងបញ្ជីរបស់គណបក្សសំខាន់ៗ អាចរារាំងមិនឱ្យសហគមន៍សាមីរៀបចំតំណាងស្វយ័តរបស់ខ្លួន ដែលខ្លួនចង់បាននោះ ។

- វិធានការដែលចង់ឱ្យគាំទ្រដល់អង្គការស្វយ័ត អាចនាំឱ្យមានការបំបែកខ្លួននិយមខាងអត្តសញ្ញាណ រហូតប៉ះពាល់ដល់ឯកភាពជាតិ ។ ប្រទេសនូវែលហ្សេឡង់អនុញ្ញាតឱ្យក្រុមជនជាតិដើម Maoris នូវជម្រើសការចុះឈ្មោះលើបញ្ជីបោះឆ្នោតថ្នាក់ជាតិ ឬក៏លើបញ្ជីរបស់ Maoris ដោយឡែក ។
- ដូច្នេះត្រូវជ្រើសរើសដំណោះស្រាយតាមកាលៈទេសៈផ្ទាល់របស់ប្រទេសនីមួយៗ ។
- វាក៏អាចកើតករណីដែលសហគមន៍ងាយរងគ្រោះ ចំពោះភាពតំណាងនៅក្នុងសភា គឺជាភាគច្រើនរបស់ប្រជាជន ( ឧទាហរណ៍ : ករណីនារីកម្ពុជា) ។
- សម្រាប់ប្រទេសទើបចេញពីជម្លោះ ជួនកាលត្រូវរកដំណោះស្រាយពិសេសតាមការបោះឆ្នោត ក៏ដូចជាករណីប្រទេសដែលខិតខំរៀបចំតាមលទ្ធិប្រជាធិបតេយ្យ បន្ទាប់ពីមានអន្តរាគមន៍ពីកងទ័ពបណ្តាលមកពីការប៉ះទង្គិចរវាងសហគមន៍ ។ ដំណោះស្រាយនោះអាចជាដំណោះស្រាយបណ្តោះអាសន្ន ដែលទំនាស់ទៅនឹងនិយមន័យនៃលទ្ធិប្រជាធិបតេយ្យ ។ ឧទាហរណ៍ ករណីកោះ Fidji ដែលត្រូវអនុវត្តនូវភាពតំណាងរបស់ក្រុមជនជាតិភាគតិចធំៗ និងទុកឱ្យប្រជាពលរដ្ឋដែលចុះឈ្មោះនៅតាមមណ្ឌលណាមួយដើម្បីជ្រើសរើសសមាជិកសភាឱ្យបំពេញអសនៈដែលបើកចំហរ ។

## តួនាទីរបស់សភាទីពីរ ឬសភាជាន់ខ្ពស់

សភាជាន់ខ្ពស់អាចដើរតួនាទីគន្លឹះ ដោយតំណាងប្រជាជាតិទាំងមូលនៅក្នុងភាពចំរុះរបស់ខ្លួន ។

នៅក្នុងប្រព័ន្ធសហព័ន្ធ ភាពចំរុះនៃដែនដីរបស់ប្រទេសត្រូវបានឆ្លុះបញ្ចាំងនៅក្នុងភាពតំណាងរបស់រដ្ឋនានា ឬខេត្តនានា នៅក្នុងផលប្រយោជន៍ដែលឆ្លុះបញ្ចាំងឱ្យឃើញអំពីសារសំខាន់របស់សភាជាន់ខ្ពស់ ។ សភាជាន់ខ្ពស់អាចមានអណត្តិពិសេស ដើម្បីសិក្សាអំពីផលប៉ះពាល់របស់ច្បាប់នៅលើភូមិភាគ ឬមូលដ្ឋាននានា ។ មុខងារដែនដីនេះ ពុំមែនគ្រាន់តែជារឿងសំខាន់នៃប្រព័ន្ធសហព័ន្ធប៉ុណ្ណោះទេ ។ ដូចជាករណីប្រទេសបារាំងគេគ្រោងអំពីភាពតំណាងពិសេសសម្រាប់សភាជាន់ខ្ពស់ឱ្យប្រជាពលរដ្ឋដែលរស់នៅឯបរទេស ។ នៅក្នុងប្រទេសដែលប្រកាន់របបសភាពីរថ្នាក់ របៀបបោះឆ្នោតជ្រើសរើសសភាជាន់ខ្ពស់អាចប្រើប្រាស់ដើម្បីធានានូវភាពតំណាងរបស់ក្រុមសង្គម និងសហគមន៍ផ្សេងៗឱ្យបានល្អប្រសើរផងដែរ ចួនកាលតាមការអនុម័តយកនូវប្រព័ន្ធបោះឆ្នោតផ្សេងសម្រាប់សភាជាន់ខ្ពស់ ជួនកាលតាមរយៈនីតិវិធីនៃការតែងតាំង ( កាលណាគេគ្រោងទុកថា សមាជិកត្រូវបានតែងតាំង) ។ ដូច្នេះគេអាចកែលំអភាពតំណាងសង្គមរបស់សភា ជាឧទាហរណ៍ ដោយគ្រោងនូវភាពតំណាងឱ្យក្រុមពិសេសដូចជា ជនពិការ ក្រុមសង្គមដែលងាយរងគ្រោះ និងជនជាតិភាគតិចគ្រប់ប្រភេទ ។

## សិទ្ធិរបស់សមាជិកសភាទាំងអស់ត្រូវបានគោរព សភាដែលបើកចំហចំពោះគ្រប់គណបក្ស

ខ្លឹមសារជាសារវ័ន្តនៃការងារសភាប្រព្រឹត្តទៅនៅក្នុងគណៈកម្មការ មិនថាកិច្ចការនីតិកម្ម ឬត្រួតពិនិត្យ ឬកិច្ចការទាំងពីររួមគ្នាតែម្តង ។ នៅស្ទើរតែគ្រប់សភា សមាសភាពគណៈកម្មការទាំងនេះត្រូវបានកំណត់ជាមុនតាមអសនៈដែលគណបក្ស ឬក្រុមគណបក្សមានទាំងមូលនៅក្នុងសភា ។ នៅប្រទេស Serbie-Monténegro នៅក្នុងដំណើរការរៀបចំស្ថាប័នការងារក្នុងសភា គេគិតគូរដល់ភាពតំណាងតាមសមាមាត្ររបស់សមាជិកសភាតាមរដ្ឋនីមួយៗ និងតាមគណបក្សនីមួយៗ ។ សភាមួយចំនួនគេរក្សាទុកមុខងារប្រធានគណៈកម្មការពិសេសឱ្យសមាជិកម្នាក់របស់គណបក្សប្រឆាំង ឬគណបក្សភាគតិច ។ រដ្ឋសភាបារាំងផ្តល់ឱ្យគណបក្សប្រឆាំងឱ្យចាត់តាំងប្រធាន ឬអ្នករាយការណ៍សម្រាប់គណៈកម្មការស៊ើបអង្កេត ឬបេសកកម្មស្វែងរកព័ត៌មាន ។ នៅសភាលីទុយអានី តំណាងគណបក្សប្រឆាំងម្នាក់ត្រូវបោះឆ្នោតជ្រើសតាំងជាប្រធាន ឬជាអនុប្រធានគណៈកម្មការថវិកា និងហិរញ្ញវត្ថុ ។ ករណីដូចគ្នានេះ សម្រាប់សភាប្រទេស Westminster ដែលមានគណៈកម្មការគណនីសាធារណៈ ។

នៅក្នុងសភាជាច្រើន កង្វល់នៃការចូលរួមរបស់គ្រប់គណបក្ស ពុំគិតត្រឹមតែចំពោះគណៈកម្មការប៉ុណ្ណោះទេ គេគិតដល់ការប្រកាន់យកការសម្រេចជាអាទិភាព គឺកុងសង់ស៊ីស ។ គេអនុវត្តន៍គោលការណ៍នេះផងដែរនៅក្នុងគណៈកម្មការនីតិវិធី ដែលរៀបចំការងាររបស់សភា ។ ជាឧទាហរណ៍ នៅក្នុងប្រទេសហ្សីមបាវេ គណៈកម្មការពហុបក្សមួយរៀបចំការប្រជុំជារៀងរាល់សប្តាហ៍ជាមួយនឹងប្រធាន និងអនុប្រធានសភា ដើម្បីរៀបចំការងារសភាកុំឱ្យប្រកាន់គណបក្ស ។

នៅក្នុងកិច្ចការគណៈកម្មការនានា គេខិតខំរកឱ្យបានកុងសង់ស៊ីសផងដែរ ។ នៅក្នុងសភាប្រទេស Chypre ការពិភាក្សានៅក្នុងគណៈកម្មការ គឺឈរលើស្មារតីសម្រុះសម្រួល ហើយភាគច្រើននៃច្បាប់ត្រូវបានអនុម័តដោយឯកច្ឆ័ន្ទនៅក្នុងសម័យប្រជុំពេញអង្គ ។ នៅសភា Norvège គណៈកម្មការបើកទូលាយខាងកិច្ចការបរទេស អនុញ្ញាតឱ្យខាងរដ្ឋាភិបាលនូវលទ្ធភាពពិភាក្សាអំពីបញ្ហាសំខាន់បំផុតពាក់ព័ន្ធនឹងពាណិជ្ជកម្ម សន្តិសុខជាតិ និងគោលនយោបាយការបរទេសជាមួយគ្រប់គណបក្ស មុននឹងសម្រេចចុងក្រោយ ។ គណៈកម្មការនេះជម្រុញឱ្យមានកុងសង់ស៊ីសលើគោលនយោបាយការបរទេសរបស់ប្រទេស Norvège ចាប់តាំងពីសង្គ្រាមលោកលើកទី២ មក ។ សភាជាតិប្រទេសសេណេហ្គាល់ ប្រគល់ច្បាប់ដែលសំខាន់បំផុតឱ្យគណៈកម្មការចំពោះមុខ ដែលបង្កើតឡើងដោយប្រធានក្រុមនយោបាយទាំងអស់ ដើម្បីឱ្យបានទទួលនូវការ

ព្រមព្រៀងគ្នាទូលំទូលាយ ។ នៅប្រទេសអូស្ត្រាលី គេខិតខំរកកុងសង់ស៊ីសនៅក្នុងគណៈកម្មការ ដោយសមាជិកគណៈកម្មការជៀសវាងការប្រឈមមុខដាក់គ្នា និងខិតខំរកដំណោះស្រាយរួម ។ ប្រការនេះនាំឱ្យមានលទ្ធផលល្អ ហើយធ្វើឱ្យគោលនយោបាយរបស់រដ្ឋាភិបាលលើបញ្ហាសំខាន់ៗត្រូវបានថ្លឹងថ្លែងគ្រប់ជ្រុងជ្រោយ ។

ក្នុងករណីដែលកុងសង់ស៊ីសមិនអាចរកឃើញនៅក្នុងការងាររបស់គណៈកម្មការទេនោះ សភាជាច្រើនអនុញ្ញាតឱ្យមានការពិចារណាទៅលើរបាយការណ៍របស់ក្រុមភាគតិច ។

## សិទ្ធិដោយឡែកសម្រាប់គណបក្ស និងក្រុមប្រឆាំង ឬភាគតិច

គណបក្សប្រឆាំង ឬភាគតិចមានតួនាទីសំខាន់ដើម្បីសម្តែង ដោយតម្រូវឱ្យរដ្ឋាភិបាលធ្វើរបាយការណ៍ និងស្នើឡើងនូវជម្រើសនយោបាយជំនួសនៅក្នុងការពិភាក្សាសាធារណៈ ។

នៅក្នុងប្រព័ន្ធសភានិយម ដែលរដ្ឋាភិបាលមានគំនិតផ្តួចផ្តើមលើការពិភាក្សា និងសេចក្តីព្រាងច្បាប់ ដោយសារសម្លេងភាគច្រើនរបស់ខ្លួននោះ វាជាប្រការសំខាន់ដែលខាងគណបក្សប្រឆាំងមានសិទ្ធិធានាបញ្ចូលទៅក្នុងរបៀបវារៈរបស់សភានូវចំណុចពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់ និងការពិភាក្សា ព្រមទាំងការបែងចែកពេលវេលានិយាយ ។ ដូចគ្នានេះដែរ គណបក្សសម្លេងភាគតិចនៅក្នុងសភានៃប្រទេសប្រកាន់របបប្រធានាធិបតីនិយម ត្រូវតែមានសិទ្ធិដូចគ្នានេះដែរ ។ នៅប្រទេសប្រកាន់របបរាជានិយមដូចជា Arabie Seoudite ក្រុមដែលមានសមាជិក ១០ រូប របស់សភាមានសិទ្ធិដាក់សេចក្តីស្នើច្បាប់ ឬវិសោធនកម្មទៅលើច្បាប់ជាធរមាន ។ សិទ្ធិបែបនេះត្រូវបានទទួលស្គាល់ដោយសភាស្ទើរតែទាំងអស់លើពិភពលោក ។

សភាអ៊ីតាលីមានបទបញ្ជាផ្ទៃក្នុងដែលកំណត់ច្បាស់លាស់អំពីរយៈពេលនិយាយ ក្រុមប្រឆាំងអាចបញ្ចូលសំណួរជាអប្បបរិមានៅក្នុងរបៀបវារៈ ដោយមានការធានាពេលវេលាជាសមាមាត្រសម្រាប់និយាយក្នុងសំណួរនីមួយៗ ។ ក្នុងករណីសេចក្តីព្រាងច្បាប់ចេញមកពីខាងរដ្ឋាភិបាល រយៈពេលនិយាយសម្រាប់ក្រុមប្រឆាំងត្រូវច្រើនជាងខាងរដ្ឋាភិបាល ។

សភា Lituanie ផ្តល់ឱ្យក្រុមប្រឆាំងនូវរយៈពេលធានាសម្រាប់លើកសេចក្តីស្នើច្បាប់ និងរបៀបវារៈសភា ហើយផ្តល់អាទិភាពឱ្យប្រធានគណបក្សប្រឆាំងនៅពេលមានការប្រជុំសាកសួររដ្ឋមន្ត្រី ព្រមទាំងការពិភាក្សាទៅលើកម្មវិធីរបស់រដ្ឋាភិបាល និងរបាយការណ៍ប្រចាំឆ្នាំរបស់រដ្ឋាភិបាល ។

សភាអង់គ្លេសរក្សាទុក ២០ថ្ងៃ ក្នុងសម័យប្រជុំនីមួយៗសម្រាប់ការពិភាក្សាទៅលើសំណួរដែលលើកឡើងដោយគណបក្សប្រឆាំង ក្នុងនោះ ១០ថ្ងៃសម្រាប់ប្រធាននៃគណបក្សប្រឆាំងដែលសំខាន់ជាងគេ ។

## សម្រាប់សមាជិកសភាធ្វើជាមូលដ្ឋាន

ក្នុងកង្វល់អំពីភាពមានក្នុងមានក្រៅ គេត្រូវយកចិត្តទុកដាក់ដល់សមាជិកសភាដែលគ្មានការទទួលខុសត្រូវ ជាពិសេសនៅក្នុងក្រុមនយោបាយ នូវលទ្ធភាពប្រកបដោយការធានា ដើម្បីចូលរួមដល់គ្រប់សកម្មភាពរបស់សភា ។

សភាជាច្រើនរក្សាទុកឱ្យសមាជិកសភាទាំងនោះនូវរយៈពេលនិយាយ ដើម្បីបង្ហាញសេចក្តីស្នើច្បាប់ លើកសំណើដល់គណៈកម្មការ ឬដល់សភា អំពីគំនិតផ្តួចផ្តើមរបស់ខ្លួន ឬលើកយកមកពិភាក្សា ។

តែការធានាបែបនេះក៏អាចមានបញ្ហាផងដែរ ។ ឧទាហរណ៍នៅសភាអ៊ីស្រាអែល ការលើកសំណើច្បាប់មានច្រើនពេក ដែលធ្វើឱ្យស្ទុះគ្រស្ទាញដល់ការរៀបចំការងាររបស់សភាទៅវិញ ។ សភាស៊ុយអែតក៏សម្តែងនូវការលំបាកចំពោះគំនិតផ្តួចផ្តើមរបស់សមាជិកដែលពុំបានចុះឈ្មោះ ។

ក្នុងករណីបែបនេះ សភាអ៊ីតាលី និងសភាឥណ្ឌាមានដំណោះស្រាយដោយឡែករបស់ខ្លួន (ការចែកពេលឱ្យនៅក្នុងការសាកសួរសំណួរដល់រដ្ឋាភិបាល) ។

## សមភាពរវាងបុរស និងនារី

ដើម្បីឱ្យនារីមានសំណាងខ្ពស់ទទួលបាននូវអណត្តិសភា វាមិនគ្រប់គ្រាន់ទេ ត្រឹមតែឱ្យនារីបំពេញបាននូវតួនាទីរបស់ខ្លួននៅក្នុងសភា ។ សភាត្រូវខិតខំរៀបចំថែមទៀតដើម្បីសម្រួលឱ្យមានវិភាគទានរបស់នារីសម្រាប់គ្រប់សកម្មភាពដោយស្មើភាពជាមួយបុរស ។ ឧទាហរណ៍ នៅសភាអាហ្វ្រិកខាងត្បូង ទោះបីភាគរយនារីកើនឡើងក្តី នារីពេលខ្លះនៅតែលំបាកក្នុងការបំពេញតួនាទីនយោបាយ ។ សភាត្រូវខិតខំដើម្បីឱ្យរចនា-សម្ព័ន្ធ និងការចាត់តាំងរបស់ខ្លួនអនុគ្រោះឱ្យបំពេញបាននូវតម្រូវការជាក់ស្តែង និងជាយុទ្ធសាស្ត្ររបស់នារី ។ តាមការអង្កេតរបស់សហភាពអន្តរសភា កង្វល់ធំទី១របស់នារីនៅក្នុងនយោបាយ គឺសម្របសម្រួលជីវិតគ្រួសារទៅនឹងការងារ ។ ប្រទេសអឺរ៉ុបខាងជើងរៀបចំឱ្យមានការប្រជុំនៅពេលថ្ងៃ ជាការសម្រួលសម្រាប់សមាជិកាសភាជាមាតា ។ ការរៀបចំពេលម៉ោងប្រជុំពេញអង្គត្រូវគិតដល់សមាជិកាសភា ដើម្បីធ្វើយ៉ាងណាឱ្យកាតព្វកិច្ច នយោបាយ និងជីវភាពគ្រួសាររបស់គាត់ដើរទៅមុខទាំងអស់គ្នា ។

សភានៃប្រទេសអឺរ៉ុបច្រើនប្រជុំនាពេលថ្ងៃរសៀល ហើយច្រើនចប់នៅពេលយប់ ។ សភាអង់គ្លេសបានខិតខំកែប្រែម៉ោងប្រជុំថ្មី ដើម្បីជៀសវាងការប្រជុំពេលយប់ តែក៏មានការលំបាកយ៉ាងច្រើនប្រឈមនឹងការប្រែប្រួលនេះ ។ សភាអាហ្វ្រិកខាងត្បូងបានព្រមព្រៀងគ្នាមិនឱ្យមានការប្រជុំលើសពីម៉ោង១៨:00 ដើម្បីឱ្យសមាជិកសភា (បុរស/នារី) សម្របសម្រួលការទទួលខុសត្រូវវិជ្ជាជីវៈជាមួយនឹងគ្រួសារ ។

ដោយហេតុថា សារវ័ន្តនៃការងារសភាត្រូវប្រព្រឹត្តទៅនៅក្នុងគណៈកម្មការ សភាជាច្រើនខិតខំអនុគ្រោះឱ្យនារីបានចូលរួមការងារនៅក្នុងគណៈកម្មការ ហើយថែមទាំងបានមុខងារជាប្រធានដឹកនាំបន្ថែមទៀត ។ ធ្វើបែបនេះបាន លុះត្រាតែកែប្រែនីតិវិធី ។ បទបញ្ជាផ្ទៃក្នុងសភាប្រទេសកាម៉េរូនចែងថា សមាជិកសភាម្នាក់ត្រូវតែជាសមាជិកយ៉ាងហោចនៃគណៈកម្មការណាមួយ និងជាសមាជិកយ៉ាងច្រើនបំផុតនៅក្នុងគណៈកម្មការចំនួនពីរ ។ តាមរបៀបនេះ យ៉ាងហោចក៏មាននារីម្នាក់នៅក្នុងគណៈកម្មការនីមួយៗ ។ គណៈ-កម្មការពីរនៅក្នុងចំណោមគណៈកម្មការ៦ ត្រូវបានដឹកនាំដោយនារី ។

នៅក្នុងសភាខ្លះ គេផ្តួចផ្តើមឱ្យមានគណៈកម្មការសមភាពរវាងបុរស និងនារី ដើម្បីជម្រុញភាពត្រដិត្រសងខាងភេទនៅក្នុងសង្គមទាំងមូល ។ គណៈកម្មការនេះមានសមាសភាពស្មើគ្នា( បុរស/នារី) ដូចជាករណីសភាបារាំង ។

នៅក្នុងសភាជាច្រើន គេមានរៀបចំក្រុមសមាជិកាសភាអន្តរគណបក្ស ដើម្បីជម្រុញឱ្យមានការផ្លាស់ប្តូរ និងដើម្បីវាយតម្លៃលើកម្មវិធីការងាររបស់សភា សំដៅឱ្យមានសមភាពរវាងបុរស និងនារី ។

## សមភាពសម្រាប់សមាជិកសភាចេញមកពីសហគមន៍ជនជាតិភាគតិច និងងាយរងគ្រោះ

ក្របខ័ណ្ឌនីតិវិធីសម្រាប់គណបក្សប្រឆាំង និងភាគតិចត្រូវបានរាប់បញ្ចូលទាំងបញ្ហាតំណាងឱ្យជនជាតិភាគតិច និងងាយរងគ្រោះផងដែរ ។

តែក្នុងករណីដែលភាគតិចមានចំនួនតិចតួចបំផុតនោះ ពួកគេពុំអាចទទួលបាននូវសិទ្ធសភាខ្លះៗដូចជាតំណែងនៅក្នុងគណៈកម្មការនីតិកម្ម ឬគណៈកម្មការផ្សេងទៀតឡើយ ។ ក្នុងករណីបែបនេះមាននីតិវិធី ២ យ៉ាង

- ព្យួរការអនុវត្តនូវបទបញ្ញាដូចជា ចំនួនដំបូងអប្បបរិមានៃសមាជិកសភាជាប់ឆ្នោត (Seuil minimum) ។
- ផ្តល់សិទ្ធិពិសេសឱ្យភាគតិច : សិទ្ធិស្នើច្បាប់ ឬសិទ្ធិវេតូចំពោះសេចក្តីព្រាងច្បាប់ប្រភេទខ្លះ

ជាឧទាហរណ៍នៅប្រទេសបែលហ្ស៊ិក សភាចែកជាក្រុមបារាំង និងក្រុមហុល្លង់ពេលដែលត្រូវពិនិត្យបញ្ហាខ្លះៗ ។ គេតម្រូវឱ្យក្រុមនីមួយៗអនុម័តដោយសម្លេងភាគច្រើន ហើយវិធានការនីមួយៗត្រូវអនុម័តដោយសម្លេងភាគច្រើន ២ភាគ៣ នៃសម្លេងទាំងមូល ។

ជាធម្មតា ក្រុមជនជាតិភាគតិច និងក្រុមជនជាតិដើមតែងនិយាយភាសាខុសពីក្រុមភាគច្រើន ។ សភាជាច្រើនយកចិត្តទុកដាក់ដល់ភាសាការងារ ឱ្យមានការបកប្រែឯកសារ និងភាសានៃការពិភាក្សា។ សភាឥណ្ឌាអនុញ្ញាតឱ្យសមាជិកសភានិយាយបាននូវភាសាទាំងឡាយដែលរដ្ឋធម្មនុញ្ញទទួលស្គាល់។ សភាកាណាដាអនុញ្ញាតឱ្យប្រើបានទាំងភាសាបារាំង និងភាសាអង់គ្លេស ។

## សម្រួលការងាររបស់សមាជិកសភាទាំងអស់

ក្រៅពីរូបភាពនៃវិសមភាពខាងលើ សមាជិកសភាខ្លះត្រូវប៉ះពាល់ទាំងស្រុងដោយកត្តាពុំសូវមើលឃើញដូចជា ការខ្វះខាតធនធាន ឬសមត្ថភាព ។ សមាជិកសភាត្រូវធានាឱ្យបានទទួលនូវធនធានឱ្យស្មើភាពគ្នា ។ សេវាឯកសារ និងវិភាគរបស់សភាត្រូវបំរើដល់គ្រប់សមាជិកសភា ដោយមិនត្រូវប្រកាន់បក្សពួក ។

ជាឧទាហរណ៍ សភាខ្លះបានបំពាក់បច្ចេកវិទ្យាព័ត៌មាន ដើម្បីឱ្យសមាជិកអាចទទួលបានព័ត៌មានភ្លាមៗអំពីសេចក្តីព្រាងច្បាប់ និងសកម្មភាពសភាផ្សេងទៀត ។ វិសមភាពមិនស្ថិតនៅលើបញ្ហាសាមញ្ញនៃសម្ភារៈប៉ុណ្ណោះទេ តែនៅលើសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននោះឱ្យបានជាប្រយោជន៍ ។

សម្រាប់សមាជិកសភាទើបជាប់ឆ្នោតថ្មី នីតិវិធីសភាអាចជារឿងស្មុគ្រស្មាញ និងតឹងតែង រួមនឹងកម្មវិធីការងាររវល់ច្រើន ។ ជាធម្មតា សមាជិកសភាទើបជាប់ឆ្នោតត្រូវការពេលវេលាច្រើនមុននឹងចេះធ្វើការបាន ស្របទៅតាមការទទួលខុសត្រូវរបស់ខ្លួន ។ អាស្រ័យហេតុនេះបានជាសភាជាច្រើនរៀបចំកម្មវិធីផ្តល់ការណែនាំ និងផ្តល់យោបល់ដល់សមាជិកថ្មី។ កម្មវិធីសិក្សាខ្លះអាចរ៉ាប់រងដោយគណបក្សនយោបាយ ខ្លះទៀតដោយមន្ត្រីរដ្ឋបាលរបស់សភា ។

តាមការអង្កេតរបស់សហភាពអន្តរសភា កម្មវិធីបណ្តុះបណ្តាលសមាជិកថ្មី មានអង្គធាតុជាសារវ័ន្តដូចតទៅ

- សិទ្ធិ និងកាតព្វកិច្ចរបស់សមាជិកសភា
- នីតិវិធីសភា បទបញ្ជានៃការពិភាក្សានិងបោះឆ្នោតនៅក្នុងគណៈកម្មការ និងសម័យប្រជុំពេញអង្គ
- ការពិពណ៌នាអំពីសេវាសភាដែលផ្តល់ជូន និងរបៀបប្រើប្រាស់សេវាទាំងនោះ
- ការរៀបចំការងារសភា និងការប្រើប្រាស់សម្ភារៈអេឡិចត្រូនិច និងមធ្យោបាយផ្សេងទៀត
- ការផ្សព្វផ្សាយ និងទំនាក់ទំនងជាមួយប្រព័ន្ធឃោសនា
- ការរៀបចំកន្លែងធ្វើការ និងទំនាក់ទំនងជាមួយម្ចាស់ឆ្នោត

ជាឧទាហរណ៍ សភានូវែលហ្សេឡង់ផ្សព្វផ្សាយនូវមគ្គុទេសក៍ណែនាំការប្រើប្រាស់ដល់គ្រប់សមាជិកសភាតាម Website ដោយពន្យល់អំពីទិដ្ឋភាពការងាររបស់គណៈកម្មការ បទបញ្ជាអចិន្ត្រៃយ៍ នីតិវិធីតាមប្រភេទសកម្មភាព សេវារដ្ឋបាលដែលចាំបាច់ ដំបូន្មានដល់ប្រធានគណៈកម្មការ.... ។ល។

## ការពារនូវសិទ្ធិរបស់សមាជិកសភាក្នុងការបំពេញមុខងារ

ល័ក្ខខ័ណ្ឌមួយជាគ្រឹះដើម្បីឱ្យសមាជិកសភាមួយរូបក្លាយជាតំណាងបាន ហើយសមាជិកសភាទាំងឡាយបំរើបានប្រកបដោយប្រសិទ្ធភាពនូវអ្នកបោះឆ្នោតរបស់ខ្លួននោះ លុះណាតែអ្នកជាប់ឆ្នោតទាំងនោះអាចនិយាយដោយសេរី ដោយគ្មានការភ័យខ្លាច និងការគាំពារ (Sans crainte ni faveur) ។

មានឧទាហរណ៍ជាច្រើនដែលបង្ហាញថា សមាជិកសភាត្រូវដាក់ខ្លួនតាមឥទ្ធិពល និងការកៀបសង្កត់ពីសំណាក់អង្គនីតិប្រតិបត្តិ ជាពិសេសកាលណាសមាជិកសភាងើបឡើងប្រឆាំងនឹងការបំពានរបស់រដ្ឋាភិបាល ។ ពួកគេត្រូវរងឥទ្ធិពលពីកម្លាំងខ្លាំងៗរបស់សង្គម ។ អាស្រ័យហេតុនេះហើយបានជាសិទ្ធិរបស់សមាជិកសភាដើម្បីនិយាយដោយសេរីក្លាយជាកម្មវត្ថុនៃកិច្ចការពារពិសេសនៅក្នុងក្របខ័ណ្ឌ "អភ័យឯកសិទ្ធិ" ដែលការពារសមាជិកសភាប្រឆាំងនឹងការដាក់ទោសទណ្ឌទៅលើមតិដែលបានសម្តែងចេញ ឬការសម្រេចចិត្តបោះឆ្នោតនៅក្នុងការប្រតិបត្តិអណត្តិរបស់ខ្លួន និងនៅក្រោយពេលបញ្ចប់អណត្តិជាសមាជិកសភា (អភ័យឯកសិទ្ធិមួយជីវិត) ។

គោលបំណងនៃអភ័យឯកសិទ្ធិ ពុំត្រឹមតែការពារសមាជិកសភាប៉ុណ្ណោះទេ តែថែមទាំងអនុគ្រោះឱ្យពួកគេបំពេញមុខងារតំណាងអ្នកបោះឆ្នោតឱ្យបានល្អ និងការពារផលប្រយោជន៍របស់អ្នកបោះឆ្នោត ។ កិច្ចការពារសិទ្ធិរបស់សមាជិកសភា គឺជាល័ក្ខខ័ណ្ឌចាំបាច់ និងចម្បង ព្រោះបើគ្មានកិច្ចការពារនេះទេ សមាជិកសភាពុំអាចការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានរបស់ប្រទេសខ្លួនបានឡើយ ។ ភាពជាតំណាងរបស់សភាមួយពឹងផ្អែកយ៉ាងជិតស្និទ្ធទៅនឹងការគោរពសិទ្ធិមនុស្សរបស់សមាជិកសភានៃប្រទេសនោះ ។

ប្រទេសជាច្រើនបានអនុវត្តនីនូវអភ័យឯកសិទ្ធិពិសេស "ភាពពុំអាចបំពានបាន Inviolabilité" សម្រាប់រយៈពេលនៃអណត្តិសភាសម្រាប់បទល្មើសតូចតាច (Délits mineurs) ។ ក្នុងករណីធ្ងន់ធ្ងរ អភ័យឯកសិទ្ធិនេះអាចត្រូវលើក តែតាមការបោះឆ្នោតរបស់សភាខ្លួនឯង ។

ប្រទេសដែលអនុវត្តនីបទបញ្ញត្តិបែបនេះ សំដៅការពារសេរីភាពរបស់សមាជិកសភាប្រឆាំងនឹងការបំពានពីអង្គនីតិប្រតិបត្តិ តែក៏ត្រូវគិតគូរដល់អារម្មណ៍របស់សាធារណៈមតិដែលថា សមាជិកសភាគឺជាក្រុមជាន់

ខ្ពស់ពិសេស ដែលទទួលបានអភ័យឯកសិទ្ធិពុំសមស្របទៅនឹងច្បាប់ ។ តុល្យភាពចំពោះបញ្ហានេះកំពុងស្ថិតនៅក្នុងការគិតគូរថ្លឹងថ្លែងរបស់សភាជាច្រើន ដើម្បីកែប្រែនូវបទបញ្ញត្តិរបស់ខ្លួន ។

ក្នុងករណីយល់ថាមានការរំលោភទៅលើសិទ្ធិនេះ ដែលពុំអាចដោះស្រាយបានតាមនីតិវិធីជាធរមានរបស់ប្រទេស សមាជិកសភាអាចប្ដឹងទៅគណៈកម្មការសិទ្ធិមនុស្សសម្រាប់សមាជិកសភារបស់សហភាពអន្តរសភា ។ គណៈកម្មការនេះខិតខំដោះស្រាយករណីនេះ តាមរយៈការសម្រុះសម្រួលព្រមព្រៀងទៅវិញទៅមកជាសម្ងាត់ជាមួយនឹងរដ្ឋាភិបាល ឬភាគីពាក់ព័ន្ធ ។ លុះណាតែពុំអាចរកដំណោះស្រាយដោយស្រុះស្រួលគ្នាបានលើបញ្ហានេះ ទើបគណៈកម្មការផ្សព្វផ្សាយជាសាធារណៈ តាមរយៈក្រុមប្រឹក្សាភិបាលរបស់សហភាពអន្តរសភា ។

ក្រៅពីនោះ សមាជិកសភាដែលមានបញ្ហាអាចពឹងផ្អែកជាចំហចំពោះការគាំទ្រពីសហសេវិកនៅឯបរទេស ។ ជាឧទាហរណ៍ សភាអាល្លឺម៉ង់ Bundestag មានចេញយុទ្ធការ "សមាជិកសភាការពារសមាជិកសភា" ដើម្បីជាបណ្ដាញសម្រាប់គាំទ្រក្នុងកិរិតអន្តរជាតិ ។

## សិទ្ធិបុគ្គលរបស់សមាជិកសភា និងវិន័យរបស់គណបក្ស

បញ្ហាដែលលំបាកបំផុត និងចម្រូងចម្រាស់បំផុត គឺបញ្ហាតុល្យភាពរវាងភាពចាំបាច់នៃវិន័យរបស់គណបក្ស និងសិទ្ធិរបស់សមាជិកសភាម្នាក់ៗដើម្បីសម្ដែងមតិដោយសេរី ។

ជាធម្មតា គណបក្សនីមួយៗដែលមានកម្មវិធី និងការគាំទ្រ អនុគ្រោះឱ្យសមាជិកបានជាប់ឆ្នោតតែងរំពឹងទុកថា សមាជិកសភានឹងគាំទ្រត្រឡប់វិញនូវកម្មវិធីនយោបាយរបស់គណបក្សនៅក្នុងសភា ។

តែម្យ៉ាងទៀត នៅមានកាតព្វកិច្ចពុំត្រឹមតែចំពោះគណបក្សប៉ុណ្ណោះទេ នៅមានកាតព្វកិច្ចចំពោះអ្នកបោះឆ្នោត ព្រោះតែងមានទំនាក់ទំនងជាក់ស្ដែងរវាងការបោះឆ្នោត និងអំពើដែលនឹងត្រូវអនុវត្តនឹងដោយតំណាងជាប់ឆ្នោតរបស់ខ្លួននៅក្នុងសភា ។

សមាជិកសភាមានកាតព្វកិច្ចជាបុគ្គល ដើម្បីការពារផលប្រយោជន៍របស់អ្នកបោះឆ្នោតរបស់ខ្លួនប្រឆាំងនឹងគោលនយោបាយដែលខ្លួនយល់ថាមិនស្មោះត្រង់ ឬគ្រោះថ្នាក់ ទោះបីគោលនយោបាយនោះគាំទ្រដោយគណបក្សរបស់ខ្លួនក៏ដោយ ។

គណបក្សមានភារកិច្ចរៀបចំនីតិវិធីផ្ទៃក្នុងប្រជាធិបតេយ្យ ដែលអនុគ្រោះឱ្យមានការពិភាក្សាដោយសេរីទៅលើបញ្ហាចម្រូងចម្រាស់នានា ជាជាងការប្រើប្រាស់ការបង្គាប់បញ្ជាបង្ខំពីថ្នាក់ដឹកនាំគណបក្សនោះ ។

សម្រាប់សមាជិកសភា ការសម្របសម្រួលរវាងភាពស្មោះត្រង់ទៅនឹងគណបក្ស និងសម្បញ្ញជញ្ញៈផ្ទាល់ខ្លួនជាការពិបាកនឹងរកឃើញណាស់ ។

គណបក្សនៅក្នុងសភាមាននៅក្នុងដៃនូវទណ្ឌកម្មជាច្រើន ដើម្បីធ្វើឱ្យសមាជិកសភាខុសជួរវិលទៅរកវិន័យវិញ ។ ទោសធ្ងន់បំផុតគឺការបណ្តេញចេញពីគណបក្ស ដែលនាំឱ្យសមាជិកបាត់បង់នូវការគាំទ្រនៅពេលបោះឆ្នោតខាងមុខ ។ ប៉ុន្តែនៅមានចំណុចមួយ ដែលគណៈកម្មការសិទ្ធិមនុស្សរបស់សមាជិកសភានៃសហភាពអន្តរសភាតែងតែទាមទារ

- ការបណ្តេញចេញត្រូវសមស្របទៅតាមបទបញ្ជាផ្ទៃក្នុងរបស់គណបក្ស ដែលធានាឱ្យមានការប្រព្រឹត្តប្រកបដោយសមធម៌ ជាអាទិ៍ សិទ្ធិរបស់សមាជិកសភាដើម្បីការពារខ្លួន ។
- ការបណ្តេញចេញពុំត្រូវនាំឱ្យសមាជិកសភានោះបាត់បង់ជាស្វ័យប្រវត្តិនូវអសនៈរបស់ខ្លួននៅក្នុងសភា និងការបន្ថយអណត្តិរបស់សភាឡើយ ព្រោះប្រការនេះធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសម្រាប់សម្តែងមតិដោយសេរី ។
- ការបណ្តេញសមាជិកសភាពីសភា ចាំបាច់ត្រូវមានសេចក្តីសម្រេចរបស់សភាទាំងមូល ហើយអាចប្រកាសទៅបានតែបន្ទាប់ពីការផ្តន្ទាទោសពីបទឧក្រិដ្ឋ ហើយពុំមែនបណ្តាលមកពីការបណ្តេញចេញពីគណបក្សឡើយ ។

នៅមានបញ្ហាចម្រូងចម្រាស់ កាលណាសមាជិកសភាម្នាក់ចេញពីគណបក្សមួយដោយស្ម័គ្រចិត្ត ឬប្តូរគណបក្សនៅពាក់កណ្តាលអណត្តិ (ដែលគេហៅថា "ភាពអនាថាខាងនយោបាយ" Normadisme politique) ។ សេចក្តីសម្រេចបែបនេះមានផលជាផ្លែផ្កា ក្នុងន័យនិយាយពីអាជីព ជាឧទាហរណ៍ ដើម្បីបានទទួលមុខតំណែងជារដ្ឋមន្ត្រី តែវាបណ្តាលឱ្យសភាអស្ថេរភាព និងប្រឆាំងទៅនឹងឆន្ទៈរបស់អ្នកបោះឆ្នោត ។ ដូច្នេះហើយបានជាសភាជាច្រើនបានដាក់នូវបទបញ្ញត្តិប្រឆាំងការប្តូរគណបក្ស ដែលនាំដល់ការបាត់អសនៈនៅក្នុងសភា ។ ឧទាហរណ៍ រដ្ឋសភាឥណ្ឌាបានធ្វើវិសោធនកម្មនៅឆ្នាំ ១៩៩៥ នូវរដ្ឋធម្មនុញ្ញ ដើម្បីអនុញ្ញាតឱ្យបណ្តេញសមាជិកសភាពីគណបក្សនយោបាយ ពុំត្រឹមតែការចាកចេញពីគណបក្សប៉ុណ្ណោះទេ ថែមទាំងករណីបោះឆ្នោតផ្ទុយនឹងការណែនាំរបស់គណបក្ស ដោយគ្មានសេចក្តីអនុញ្ញាតជាមុនពីគណបក្ស ។ នាឆ្នាំ ២០០៣ គេបានបន្ថែមវិសោធនកម្មរដ្ឋធម្មនុញ្ញមួយទៀតដែលហាមឃាត់ការរំលាយបញ្ចូលគ្នាទាំងស្រុងរវាងគណបក្សនយោបាយផ្សេងៗ ។

រដ្ឋសភាស៊ុយអែតលើកអំពីបញ្ហាចាកចោលជួរ ដោយលើកហេតុផលថា ទោះបីសមាជិកសភាត្រូវបានជ្រើសរើសតាមបញ្ជីសមាជិកសភានៅតែត្រូវបានជ្រើសតាំងជាបុគ្គល ដូច្នេះត្រូវមានអណត្តិរបស់បុគ្គលផ្ទាល់ (Mandat Personel) ។ ដូច្នេះប្រសិនបើសមាជិកសភាណាម្នាក់ត្រូវបានបណ្តេញចេញពីគណបក្សរបស់ខ្លួន ឬក៏បានចាកចេញក្នុងកម្លុងពេលនៃយុទ្ធនាការបោះឆ្នោត ជននោះនៅតែជាសមាជិកសភាដដែល ។ ប៉ុន្តែសមាជិកសភាដែលបោះបង់ចោលនូវក្រុមនយោបាយរបស់ខ្លួននៅក្នុងអណត្តិ ពុំអាចបង្កើតក្រុមនយោបាយថ្មីដែលទទួលស្គាល់ដោយសភាបានឡើយ ។

អង្គការសភានៃប្រទេសជាសមាជិក Commonwealth បានអនុម័តនាឆ្នាំ ១៩៩៨ នូវគោលការណ៍ដូចតទៅ :

សន្តិសុខរបស់សមាជិកសភានៅក្នុងកម្លុងអណត្តិរបស់ខ្លួន មានសារសំខាន់បំផុតសម្រាប់ឯករាជ្យភាពរបស់សភា

**ក-** ការបណ្តេញសមាជិកសភាពីសភា ដូចជាទណ្ឌកម្មទៅលើការចាកចេញពីគណបក្សរបស់សមាជិកសភារូបនោះ ត្រូវចាត់ទុកធ្វើឱ្យប៉ះពាល់ទៅលើឯករាជ្យភាពរបស់សមាជិកសភាសាមី ។ ប៉ុន្តែវិធានការប្រឆាំងការចាកចោលជួរ អាចត្រូវមើលឃើញថាចាំបាច់នៅក្នុងប្រទេសខ្លះ ដើម្បីប្រឆាំងទៅនឹងអំពើពុករលួយ ។

**ខ-** ច្បាប់ទាំងឡាយដែលអនុញ្ញាតឱ្យដកសមាជិកសភានៅក្នុងពេលកំពុងបំពេញអណត្តិ ត្រូវប្រុងប្រយ័ត្ន ព្រោះច្បាប់ទាំងនោះអាចធ្វើឱ្យប៉ះពាល់ដល់ឯករាជ្យភាពរបស់សមាជិកសភា ។

**គ-** ពេលដែលសមាជិកណាម្នាក់ចេញពីគណបក្សរបស់ខ្លួនដោយស្ម័គ្រចិត្ត ប្រការនោះពុំបណ្តាលឱ្យសាមីជនបាត់បង់អសនៈរបស់ខ្លួនឡើយ ។

## III-<u>សភាដែលបើកចំហ និងមានតម្លាភាព</u>

សភាដែលបើកចំហ គឺជាសភាដែលការប្រជុំពិភាក្សាត្រូវបានបើកចំហឱ្យសាធារណជន ។ លើបញ្ហានេះ នាយុគសម័យបច្ចុប្បន្នវាមិនសាមញ្ញឡើយ ព្រោះសន្តិសុខរបស់ឥស្សរជនសាធារណៈ គឺជាការយកចិត្តទុកដាក់ជាអចិន្ត្រៃយ៍ ។ សភាជាច្រើនបានរកឃើញនូវផ្លូវកណ្តាលរវាងការបើកចំហ និងសន្តិសុខ ដោយធ្វើឱ្យស្ថាប័ននេះលេចឡើងជារបស់ប្រជាជនទាំងមូល និងជារបស់សមាជិកសភា។ នៅក្នុងរដ្ឋធម្មនុញ្ញនៃប្រទេសជាច្រើនដូចជាប្រទេសអាហ្វ្រិកខាងត្បូងចែងថា ប្រជាពលរដ្ឋត្រូវតែ (តាមដែលអាចធ្វើទៅបាន) អាចចូលទៅកាន់សភាដោយសេរី ។

ជាក់ស្តែង ប្រជាពលរដ្ឋភាគច្រើនពុំអាចតាមដានដោយផ្ទាល់នូវការងាររបស់សភាខ្លួនបានឡើយ ។ ដូច្នេះនៅការប្រជុំពិភាក្សា មានលទ្ធភាពដែលក្រុមអ្នកសារព័ត៌មានសរសេរ និងប្រព័ន្ធឃោសនាផ្សេងទៀតក្លាយជា "ភ្នែក" និង "ត្រចៀក" របស់ប្រជាពលរដ្ឋទាំងមូល ។

ត្រូវចាប់អារម្មណ៍ថា ការទទួលខុសត្រូវជំរាបឱ្យប្រជាជនបានយល់ជ្រួតជ្រាប ពុំមែនគ្រាន់តែជាភារកិច្ចរបស់ប្រព័ន្ធឃោសនាឯករាជ្យឡើយ ប៉ុន្តែជាភារកិច្ចដោយសភាខ្លួនឯងតែម្តង ។

អស់រយៈពេលជាច្រើនឆ្នាំមកហើយ ដែលសភាទាំងឡាយលើពិភពលោកខិតខំរាយការណ៍អំពីសកម្មភាពរបស់ខ្លួនតាមដែលអាចធ្វើទៅបាន និងទាក់ទាញនូវការយកចិត្តទុកដាក់ជាថ្មីរបស់ប្រជាពលរដ្ឋ ។ កិច្ចការនេះត្រូវសម្រួលមួយភាគធំអាស្រ័យដោយមធ្យោបាយឆ្លើយឆ្លងថ្មីដូចជា Internet ដែលជាឧបករណ៍សម្រួលដល់អន្តរកម្មរវាងតំណាង និងប្រជាពលរដ្ឋ ផ្ទុយពីមធ្យោបាយប្រាស្រ័យឆ្លើយឆ្លងឯកទិសផ្សេងទៀត ។

ប្រជាពលរដ្ឋពុំមានសង្ឃឹមនឹងប្រើឥទ្ធិពលរបស់ខ្លួនទៅលើសភាបានឡើយ ប្រសិនបើប្រជាពលរដ្ឋនោះពុំបានទទួលព័ត៌មានទាំស្រុងអំពីសកម្មភាពរបស់សភា ។ ក្រោមល័ក្ខខ័ណ្ឌនេះ ទើបប្រជាពលរដ្ឋអាចស្នើសុំឱ្យតំណាងរបស់ខ្លួនរាយការណ៍ឱ្យខ្លួន ។

## អនុញ្ញាតឱ្យអ្នកសារព័ត៌មាន និងប្រព័ន្ធឃោសនាផ្សព្វផ្សាយអំពីការងារសភា នៅក្នុងល័ក្ខខ័ណ្ឌដ៏ល្អប្រសើរ

សភាត្រូវការអ្នកសារព័ត៌មាន និងប្រព័ន្ធឃោសនា ដើម្បីជំរាបប្រជាពលរដ្ឋអំពីការងាររបស់ខ្លួន ។ ប៉ុន្តែមានការពុំទុកចិត្តគ្នាបំផុតរវាងស្ថាប័នទាំងពីរនេះ ។

អ្នកសារព័ត៌មានពុំឯកភាពជានិច្ចឡើយ ចំពោះការរឹតត្បិតមិនឱ្យមានការចូលស្តាប់នូវការពិភាក្សាខ្លះ ។ អ្នកសារព័ត៌មានកាន់តែពុំឯកភាពទៅនឹងច្បាប់ដែលដាក់ទោសទណ្ឌដល់ការប្រមាថ និងការបរិហារកេរ្តិ៍ (Outrage et Diffamation)ដែលកំណត់ពុំបានត្រឹមត្រូវ ចំពោះអ្វីដែលត្រូវឱ្យសាធារណជនបានយល់ដឹង ។

សមាជិកសភាវិញ តែងបន្ទោសទៅលើប្រព័ន្ធឃោសនាឱ្យទទួលខុសត្រូវ យ៉ាងហោចដោយភាគខ្លះចំពោះការធ្លាក់មុខមាត់ដែលសភាជាសមូហភាពបានទទួល ដោយវាយតម្លៃថា ការងាររបស់ពួកគេបានផ្សព្វផ្សាយដោយលំអៀង ។

ប្រព័ន្ធឃោសនាចាប់អារម្មណ៍ខ្ពស់តែលើការប្រជុំក្តួងក្តាំង លើបញ្ហាដូចជាចំណាយលើការធ្វើដំណើរ និងស្នាក់នៅ ដោយពុំជំនួសអ្វីដែលមានច្រើនទៀតនៅក្នុងបរិបទនៃសភាមួយដែលស្ថាបនា និងរឹងមាំឡើយ ។ (នេះជាកំណត់សម្គាល់របស់សភា Irlande) ។ រូបភាពជាប្រឡោះស្ថានឈើចំហ (Travée déserte)

ដែលនាំឱ្យមានអារម្មណ៍ថា សមាជិកសភាជាកូនសិស្សគេចខ្លួនមិនចូលសាលា (école buissonniere) ក្នុងពេលដែលសមាជិកសភាទទួលបន្ទុកភារកិច្ចសភាផ្សេងទៀតនៅក្នុងគណៈកម្មការ ឬនៅក្នុងមណ្ឌលរបស់ខ្លួន។

ការតន្ទៃកគ្គារវាងសមាជិកសភា និងប្រព័ន្ធឃោសនា គឺពុំអាចជៀសវាងបានឡើយដោយហេតុថា ជាមុខវិជ្ជាជីវៈពីរ វប្បធម៌ពីរ ការយកចិត្តទុកដាក់ពីរខុសគ្នា ។ ប៉ុន្តែម្ខាងត្រូវការម្ខាងទៀត ហើយទាំងសងខាងមានប្រយោជន៍ សហការគ្នាដើម្បីធ្វើឱ្យសភាមានរូបភាពល្អប្រសើរតាមដែលអាចធ្វើទៅបាន ។

ចំពោះប្រជាពលរដ្ឋ ត្រូវស្វែងរកនូវភាពបើកចំហ និងតម្លាភាពជាអតិបរិមា ដើម្បីបានយល់ដឹងអំពីសកម្មភាពនៃអ្នកតំណាងជាប់ឆ្នោតរបស់ខ្លួន ។

## ការចូលទៅជិតការងារសភា

ដោយការងារជាសារវ័ន្តរបស់សភាស្ថិតនៅក្នុងគណៈកម្មការនោះ សភាជាច្រើនកំពុងខិតខំបើកចំហគណៈកម្មការចំពោះសាធារណជន និងប្រព័ន្ធឃោសនា ។ តែចំពោះបញ្ហានេះ សមាជិកសភាខ្លះបារម្ភខ្លាចខាងក្រៅឃើញ :

- ការពិភាក្សារបៀបប្រកាន់តាមគណបក្ស
- ជនជាសាក្សីពុំហ៊ានលាតត្រដាងការពិត
- សមាជិកសភាខ្លះឆ្លៀតប្រើឱកាសនេះដើម្បីបង្កើនឥទ្ធិពលតាមរយៈវេទិកា
- ប្រព័ន្ធឃោសនាពុំស្រង់យកការពិតទាំងស្រុងនៃការងាររបស់សភា ដោយពេលខ្លះគណៈកម្មការពុំអាចប្រជុំចំហ
- ការកំរិតអាស្រ័យដោយបញ្ហាសន្តិសុខផ្ទាល់ខ្លួន ឬសន្តិសុខជាតិ

តម្លាភាពរបស់សភាកំពុងមានដំណើរការទៅមុខ ។ ជាឧទាហរណ៍ សភា Irlande បានបើកចំហការប្រជុំជានីតិវិធីខ្លះរបស់គណៈកម្មការមួយចំនួនឱ្យសាធារណជនចូល ដើម្បីឱ្យអ្នកសង្កេតការអាចយល់ដឹងអំពីការកំណត់របៀបវារៈប្រជុំ និងការធ្វើសវនាការជាសាធារណៈ (Audition publique)។

សភាតំណាងនៃសាធារណរដ្ឋ Chypre អនុញ្ញាតឱ្យប្រព័ន្ធឃោសនាចូលរួមស្តាប់ការប្រជុំរបស់គណៈកម្មការនានា ដោយមានករណីលើកលែងតិចបំផុត ។ រដ្ឋសភា Côde d'Ivoire ដែលពីមុនផ្សព្វផ្សាយតែរបាយការណ៍សង្ខេបនៃការប្រជុំរបស់គណៈកម្មការនោះ ចាប់ពីឆ្នាំ២០០១មក បានអនុញ្ញាតឱ្យអ្នកសារព័ត៌មានចូលរួមកិច្ចប្រជុំគណៈកម្មការនានា និងឱ្យផ្សព្វផ្សាយដល់សាធារណជន។ នៅប្រទេស Afrique de Sud

ប្រជាពលរដ្ឋ និងប្រព័ន្ធឃោសនាអាចចូលរួមសម័យប្រជុំរបស់គណៈកម្មការនានាបាន ។ កាប្រជុំជាសម្ងាត់អាចនឹងសម្រេចបានបន្ទាប់ពីការពិភាក្សា និងមានការយល់ព្រមពីប្រធានគណៈកម្មការ ។ សភាតំណាងអូស្ត្រាលីបានផ្ទេរទីប្រឹក្សាមួយរូបខាងប្រព័ន្ធឃោសនាទៅតាមគណៈកម្មការនានា ដើម្បីជួយគណៈកម្មការឱ្យកំណត់បាននូវយុទ្ធសាស្ត្រនៃការប្រាស្រ័យឆ្លើយឆ្លង និងប្រព័ន្ធឃោសនាពាក់ព័ន្ធនឹងការស៊ើបអង្កេតជាសា-ធារណៈ និងដើម្បីឱ្យសាធារណជនបានយល់ដឹងល្អជាងមុនអំពីសកម្មភាពរបស់គណៈកម្មការ ។

ក្នុងយុគសម័យបច្ចុប្បន្ន គេត្រូវការប្រព័ន្ធឃោសនាបំផុត ។

ការប្រកួតប្រជែងអំពីកម្មវត្ថុនៃព័ត៌មានប្រព្រឹត្តទៅយ៉ាងខ្លាំងក្លា ។ ដូច្នេះសមាជិកសភាពុំត្រឹមតែត្រូវបើកទ្វារស្ថាប័នប៉ុណ្ណោះទេ តែត្រូវឈានមុខថែមទៀត និងត្រូវបង្ហាញដល់អ្នកសារព័ត៌មានអំពីបញ្ហាទាំងឡាយដែលសក្តិសមនឹងការយកចិត្តទុកដាក់ ។

សភាជាច្រើនគ្មានសមត្ថភាពមាននូវអ្នកឯកទេសជាន់ខ្ពស់ខាងប្រព័ន្ធឃោសនាប្រភេទនេះឡើយ ។ វាចាំបាច់ត្រូវបណ្តុះបណ្តាលសមាជិកសភា ជាពិសេសប្រធានគណៈកម្មការនានា អំពីរបៀបទំនាក់ទំនងជាមួយប្រព័ន្ធឃោសនា ដើម្បីឱ្យពួកគាត់មានសមត្ថភាពផ្តួចផ្តើមគំនិតចាំបាច់នានា ។

ប្រព័ន្ធឃោសនាជាច្រើនជិតដាមដោយទស្សនៈថា អគារសភាជារបស់សមាជិកសភា ពុំមែនជាអគាររបស់ប្រជាជនឡើយ ។ តួយ៉ាងក្រុមទូរទស្សន៍ឯកជនពុំអាចចូលថតក្នុងសាលប្រជុំពេញអង្គបានឡើយ ព្រោះកិច្ចការថតនេះរ៉ាប់រងដោយសភានីមួយៗផ្ទាល់ ។ មូលហេតុសំខាន់មួយនៃការហាមមិនឱ្យចូលថតផ្ទាល់ ព្រោះពេលខ្លះមានសមាជិកសភាខ្លះមានឥរិយាបថមិនប្រក្រតី : ដេក ងោក ជជែកគ្នាជាមួយអ្នកអង្គុយជាប់ អានកាសែត.... ។ សភាប្រទេសខ្លះមានបទបញ្ជាសម្រាប់ថតដូចជា ឱ្យថត Zoomយកតែអ្នកនិយាយ មិនឱ្យថតទៅលើទិដ្ឋភាពរួមឡើយ ។

## សេរីភាពខាងព័ត៌មាន

ច្បាប់ស្តីពីការទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋទៅលើព័ត៌មានដែលគ្រប់គ្រងដោយស្ថាប័នសាធា-រណៈ គឺជាអង្គធាតុមួយដ៏សំខាន់នៃលទ្ធិប្រជាធិបតេយ្យ ដោយច្បាប់នេះសមស្របទៅនឹងសិទ្ធិស្វែងរកព័ត៌មានដែលមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិអំពីសិទ្ធិស៊ីវិល និងនយោបាយ ។ ប្រការនេះវាខុសគ្នាទៅនឹងកាតព្វកិច្ចរបស់ស្ថាប័នសាធារណៈ ដែលត្រូវផ្សព្វផ្សាយនូវរបាយការណ៍រៀងៗខ្លួន ។

ប្រទេសជាង ៥០ លើពិភពលោក មានច្បាប់ស្តីពីសេរីភាពខាងសារព័ត៌មាន ។ ប្រជាពលរដ្ឋ អង្គការ NGO និងប្រព័ន្ធឃោសនា អាចពឹងផ្អែកលើច្បាប់នេះ ដើម្បីបង្កើនតម្លាភាពរបស់ស្ថាប័នសាធារណៈ ។ សភានានាអាចយោងលើអត្ថបទច្បាប់នេះ ក៏អាចប្រើដើម្បីសភាខ្លួនឯងរាយការណ៍ផងដែរ ។

នៅក្នុងប្រទេសខ្លះ ព័ត៌មានអំពីសភាត្រូវគ្រប់គ្រងដោយច្បាប់ដោយឡែកសម្រាប់តែសភា ។ នៅប្រទេសខ្លះទៀត ច្បាប់ស្តីពីសេរីភាពខាងព័ត៌មានគ្របដណ្តប់ទៅលើគ្រប់ស្ថាប័នសាធារណៈ ។ ជាឧទាហរណ៍ ព្រឹទ្ធសភាប៉ូឡូញបានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន អំពីកាតព្វកិច្ចជំរាបដល់ប្រជាពលរដ្ឋអំពីកាលបរិច្ឆេទប្រជុំរបស់ព្រឹទ្ធសភា សិទ្ធិរបស់សាធារណជនដើម្បីចូលរួមសម័យប្រជុំរបស់ព្រឹទ្ធសភា និងគណៈកម្មការនានារបស់ព្រឹទ្ធសភា សិទ្ធិរបស់ម្នាក់ៗដើម្បីពិគ្រោះមើលទៅលើឯកសារកំណត់ហេតុ និងរបាយការណ៍សម័យប្រជុំពេញអង្គ ព្រមទាំងឯកសារ និងព័ត៌មានដទៃទៀតពាក់ព័ន្ធនឹងការងាររបស់ព្រឹទ្ធសភា និងយន្តការផ្សេងៗ ។

សភារ៉ូម៉ានីត្រូវគ្រប់គ្រងដោយច្បាប់ទូទៅ ស្តីពីសេរីភាពខាងព័ត៌មានជាប្រយោជន៍សាធារណៈ ។ ដូច្នេះសភារ៉ូម៉ានីបានផ្តល់ព័ត៌មានតាមប្រព័ន្ធពីរគឺ : ដោយសភាខ្លួនឯង និងតាមសំណើសុំរបស់សាធារណជន ។

សភាស្លូវ៉ាគី និងសភាអេក្វាឌ័រ គ្រប់គ្រងដោយច្បាប់នេះដូចគ្នា ។ តែថែមពីលើនេះ គេឈានដល់ការបង្កើតយន្តការឯករាជ្យដើម្បីទទួលពាក្យបណ្តឹង ក្នុងករណីដែលស្ថាប័នសាធារណៈ និងសភាខ្លួនឯងប្រកែកពុំផ្តល់ព័ត៌មានដល់សាធារណជន ។ សភា Jamaïque បានលើកឡើងអំពីគោលការណ៍៣ នៃច្បាប់ស្តីពីសេរីភាពខាងព័ត៌មាន

**ក**- លទ្ធភាពស្នើសុំឱ្យរដ្ឋាភិបាលរាយការណ៍

**ខ**- តម្លាភាព

**គ**- ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការសម្រេចបញ្ហាជាតិ ដោយអនុញ្ញាតឱ្យម្នាក់ៗមានសិទ្ធិទូទៅដើម្បីមើលទៅលើឯកសារផ្លូវការ ដែលគ្រប់គ្រងដោយអំណាចសាធារណៈ ។

អង្គការអន្តរជាតិបានផ្សព្វផ្សាយនូវប្រភេទគំរូនៃច្បាប់ស្តីពីសេរីភាពខាងព័ត៌មាន ដែលខ្លឹមសារទូទៅដូចខាងក្រោម

- គោលការណ៍នៃការផ្សព្វផ្សាយជាអតិបរិមា កាតព្វកិច្ចផ្សព្វផ្សាយ និងជម្រុញឱ្យមានការគ្រប់គ្រងដោយបើកចំហ ។
- ករណីលើកលែងត្រូវតែកំណត់ឱ្យច្បាស់ដូចជា ភាពរងគ្រោះ (Nocivité) និងផលប្រយោជន៍សាធារណៈ ។

- ការទទួលព័ត៌មានត្រូវតែបានសម្រួល ហើយការចំណាយ ឬរយៈពេលពុំត្រូវបានលើកជាមូលហេតុរារាំងឡើយ ។
- ការប្រកែកពុំផ្តល់ព័ត៌មានអាចត្រូវប្តឹងឧទ្ធរណ៍បានតាមរយៈអង្គការឯករាជ្យមួយ ដែលអាចចេញសេចក្តីសម្រេចបង្ខិតបង្ខំបាន ។

**សិទ្ធិសម្តែងមតិ**

បដិភាគនៃសិទ្ធិខាងព័ត៌មាន គឺសិទ្ធិប្រាស្រ័យឆ្លើយឆ្លង និងបោះពុម្ពផ្សាយដោយសេរី ។ សិទ្ធិនេះគឺជាសសរទ្រូងនៃដំណើរការប្រជាធិបតេយ្យ ព្រោះវាឈរលើមូលដ្ឋាននៃការសន្ទនា និងការបញ្ចុះបញ្ចូលគ្នារវាងប្រជាពលរដ្ឋដែលទទួលបានព័ត៌មាន ព្រមទាំងរវាងប្រជាពលរដ្ឋ និងតំណាងរបស់ខ្លួន ។ អំពីការងាររបស់ប្រព័ន្ធឃោសនានៅសភា វាជាការសំខាន់ដែលការរឹតត្បិតមានកំរិតតិចបំផុត ។

យោងទៅតាមអនុសញ្ញាពាក់ព័ន្ធនឹងសិទ្ធិមនុស្ស និងយុត្តិសាស្ត្រ (Jurisprudence) ការរឹតត្បិតដល់សេរីភាពនៃការសម្តែងមតិត្រូវគោរពដល់បទដ្ឋាន ៣ គឺ

ក- កំណត់ដោយច្បាប់

ខ- ចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ ឧទាហរណ៍ ដើម្បីការពារសន្តិសុខជាតិ ឬសិទ្ធិ និងកិត្តិនាម អ្នកដទៃ

គ- ជាភាគសមស្របទៅតាមគោលដៅចាំបាច់

ការរឹតត្បិតដែលញឹកញាប់បំផុត ដែលកំរិតនូវអ្វីៗដែលនិយាយ ឬសរសេរទៅលើសមាជិកសភា មានគោលបំណងការពារកិត្តិស័ព្ទ ឬជៀសវាងការបរិហារកេរ្តិ៍ ។

នៅក្នុងប្រទេសប្រជាធិបតេយ្យជាច្រើនគេវាយតម្លៃថាអ្នកធ្វើនយោបាយដោយដើរតួនាទីសាធារណៈរបស់ពួកគេ ត្រូវសម្របខ្លួនទៅនឹងសាធារណៈមតិ ត្រូវអនុគ្រោះថែមទៀតចំពោះអត្ថាធិប្បាយ ឬការទិទានច្រើនជាងបុគ្គលជាឯកជន ។ ទស្សនៈនេះត្រូវបានអនុម័តដោយយុត្តិសាស្ត្រអន្តរជាតិ ស្តីពីសេរីភាពនៃការសម្តែងមតិ ។

ប៉ុន្តែនៅប្រទេសខ្លះ ច្បាប់ស្តីពីបទបរិហារកេរ្តិ៍អាចនៅបន្តប្រើប្រាស់ ដើម្បីកំរិតដោយពុំត្រឹមត្រូវទៅលើសកម្មភាពរបស់ប្រព័ន្ធឃោសនាពាក់ព័ន្ធនឹងអ្នកធ្វើនយោបាយ ។ ច្បាប់ទាំងនេះកាន់តែរឹតត្បិត ប្រសិនបើវាជាផ្នែកមួយនៃក្រមព្រហ្មទណ្ឌ ដោយមានទោសទណ្ឌអាចជាប់ពន្ធនាគារសម្រាប់អ្នកសារព័ត៌មានដែលដើរហួសបន្ទាត់ ។

នៅក្នុងប្រទេសខ្លះ គឺកិរិតការខូចខាត និងផលប្រយោជន៍ដែលអាចទាមទារឱ្យសងនៅក្នុងកិច្ចការរដ្ឋប្បវេណី ដែលរារាំងដល់ការស៊ើបអង្កេត ឬការទិទានប្រថុយប្រថាន ។

ម្យ៉ាងទៀត សភាខ្លះមានបទបញ្ញត្តិពាក់ព័ន្ធនឹងការបំបាក់មុខមាត់ ដោយពង្រីកឱ្យទូលាយដើម្បីកិរិតដល់ការទិទាន ឬប្រើប្រាស់សម្រាប់រារាំងអ្នកសារព័ត៌មានដែលយកការខ្សែរខ្វាយព័ត៌មានទៅផ្សព្វផ្សាយ ។

មានមធ្យោបាយផ្សេងទៀតត្រូវបានគេប្រើប្រាស់ដើម្បីកាត់បន្ថយសកម្មភាព និងការទិទានស្របច្បាប់របស់អ្នកសារព័ត៌មានដូចជា ការដកហូតប័ណ្ណសម្រាប់ការចេញចូលមកយកព័ត៌មាននៅក្នុងសភា ។

សមាគមសភានៃប្រទេសCommenwealth បានកំណត់អំពីសភា និងប្រព័ន្ធឃោសនានាឆ្នាំ២០០៣ ដូចតទៅ

១- សភាត្រូវកែប្រែច្បាប់ បទបញ្ជាដែលសំដៅរារាំងដល់ប្រព័ន្ធឃោសនាពីបទប្រមាថមាក់ងាយដល់សភា ដោយគ្រាន់តែប្រព័ន្ធឃោសនានោះទិទានដល់ស្ថាប័ន ឬដល់សមាជិករបស់ខ្លួន ។

២- ព័ត៌មានមិនពិតប្រាកដ ពុំត្រូវចាត់ទុកជាការប្រមាថមើលងាយទៅលើសភាឡើយ ។ បទប្រមាថមើលងាយត្រូវកិរិតសម្រាប់តែករណីជ្រៀតជ្រែកធ្ងន់ធ្ងរដែលរារាំងដល់សភាពុំឱ្យបំពេញភារកិច្ចរបស់ខ្លួនបានប៉ុណ្ណោះ ។

៣- បញ្ហាចេញចូលសភាត្រូវតែដោះស្រាយដោយប្រព័ន្ធឃោសនាខ្លួនឯង ។ សភាត្រូវរក្សាសិទ្ធិហាមឃាត់ការចេញចូលរបស់អ្នកសារព័ត៌មានដែលពុំគោរពដល់បទបញ្ជាអចិន្ត្រៃយ៍ ឬការរំខានដល់សម័យប្រជុំពេញអង្គ ។

៤- ក្រមព្រហ្មទណ្ឌដែលកិរិតសេរីភាពខាងនិយាយស្តីត្រូវកែប្រែ ។

នៅមានគោលការណ៍មួយទៀតសម្រាប់អ្នកសារព័ត៌មាន ដែលមានសិទ្ធិលាក់ប្រភពព័ត៌មាន ដែលអាចអនុវត្តន៍បានទៅលើករណីបរិហារកេរ្តិ៍ផងដែរ ។

## <u>បទបញ្ញត្តិពាក់ព័ន្ធនឹងប្រព័ន្ធឃោសនា</u>

បញ្ហាចុងក្រោយអំពីទំនាក់ទំនងរវាងសភា និងប្រព័ន្ធឃោសនា គឺលទ្ធភាពសម្រាប់សភាដើម្បីកំណត់នូវក្របខ័ណ្ឌបទបញ្ជាមួយសម្រាប់សកម្មភាពរបស់ប្រព័ន្ធឃោសនា ។

ជាទូទៅ ក្របខ័ណ្ឌនេះកំណត់អំពីបញ្ហាកម្មសិទ្ធិ និងការត្រួតពិនិត្យ និងការគិតគូរអំពីខ្លឹមសារ ។

ទោះបីបញ្ហានេះស្មុគ្រស្មាញ ហើយបច្ចេកវិទ្យារបស់ប្រព័ន្ធឃោសនាវិវត្តលឿនក្តី តែអ្វីដែលសារធារណជនចង់បានពីប្រព័ន្ធឃោសនា នៅក្នុងសង្គមប្រជាធិបតេយ្យវាមានភាពសាមញ្ញ ព័ត៌មានពិតប្រាកដ, ពហុមតិនិងយោបល់, ការគោរពដល់កិត្តិយសរបស់ប្រជាពលរដ្ឋនៅក្នុងសមភាព ។

គោលការណ៍បែបនេះមានតម្លៃផងដែរសម្រាប់ព័ត៌មានដែលចេញមកពីសភាខ្លួនឯង ពីគណបក្សនយោបាយ ឬពីសមាជិកសភា ។

បញ្ហាអំពីកម្មសិទ្ធិ និងការត្រួតពិនិត្យមានសារសំខាន់សម្រាប់ភាពចម្រុះ និងពហុនិយមនៃទស្សនៈ ជាពិសេសសម្រាប់ទូរទស្សន៍ ។ នៅលើពិភពលោកនេះ ប្រព័ន្ធឃោសនាដែលប្រជាជនទទួលបានព័ត៌មាន និងពិភាក្សាអំពីកិច្ចការសាធារណៈគឺទូរទស្សន៍ លើកលែងតែទ្វីបអាហ្វ្រិកដែលវិទ្យុដើរតួនាទីសំខាន់ ។

ភាពពហុនិយមត្រូវបានគំរាមកំហែងទាំងពីរខាង

- សម្រាប់ប្រព័ន្ធឃោសនាដើរដោយដើមទុនសាធារណៈ ការគំរាមកំហែងធំចេញមកពីខាងរដ្ឋាភិបាល ឬការត្រួតពិនិត្យដោយគណបក្សធំដែលអាចរារាំងការទិទាន ឬកាត់បន្ថយទស្សនវិស័យប្រឆាំង ឬផ្តល់ជម្រើស ។
- សម្រាប់ប្រព័ន្ធឃោសនាឯកជន ការគំរាមកំហែងធំចេញមកពីពួកផ្តាច់មុខ ឬពួក Oligopoles ពហុនិយមត្រូវប្រឈមនឹងពួកប្រជានិយម(Populisme)ម្ខាង និងម្ខាងទៀតទៅនឹងឆន្ទៈការពារផលប្រយោជន៍របស់អ្នកមាន និងអ្នកមានបុព្វសិទ្ធិ ។

មធ្យោបាយប្រសើរបំផុតដើម្បីទប់ទល់ចំពោះការក្បៀបសង្កត់ទាំងនេះ គឺត្រូវបង្កើតអង្គការកំណត់បញ្ញត្តិឯករាជ្យដែលមានអំណាចរឹងមាំ ដែលអាចកំណត់អំពីការប្រមូលផ្តុំដើមទុនរួមជាមួយនឹងការចូលរួមបញ្ហាសគ្នានៃប្រព័ន្ធឃោសនាខុសៗគ្នា តែថែមទាំងបង្ការការជ្រៀតជ្រែករបស់រដ្ឋាភិបាលនៅក្នុងប្រព័ន្ធឃោសនាសាធារណៈ ។ សភាអាចចូលរួមវិភាគទានដ៏ធំធេងហួសពីការប្រកាន់តាមគណបក្ស ដើម្បីកំណត់ក្របខ័ណ្ឌអំពីអង្គការកំណត់បញ្ញត្តិបែបនេះ ដោយចាត់ទុកខ្លួនថាជាអ្នកធានាចំពោះឯករាជ្យភាពរបស់អង្គការនេះ ។ អ្នកឯកទេសជាច្រើនយល់ថា វាមានសារសំខាន់ណាស់ចំពោះនីតិវិធីនៃការតែងតាំងអង្គការបែបនេះ ។ សហគមន៍អឺរ៉ុប និងប្រទេសអាហ្វ្រិកខាងត្បូងបានធ្វើជំហរច្បាស់លាស់ចំពោះកិច្ចការនេះ ។

សម្រាប់បទបញ្ញត្តិអំពីខ្លឹមសារ មតិបានបែកខ្ញែកគ្នា ។

តើត្រូវប្រគល់ភារកិច្ចត្រួតពិនិត្យនេះទៅឱ្យអាជ្ញាធរឯករាជ្យ ឬទៅឱ្យអង្គការត្រួតពិនិត្យរបស់ប្រព័ន្ធឃោសនាខ្លួនឯងតែម្តង? អង្គការត្រួតពិនិត្យច្រើនកំណត់នូវបទដ្ឋានពាក់ព័ន្ធនឹងខ្លឹមសារនៅក្នុងការផ្តល់ការ

យល់ព្រមទៅលើអាជ្ញាប័ណ្ណជាអាទិ៍ កំណត់រយៈដំបូងអប្បបរិមាអំពីព័ត៌មាន និងការយកព័ត៌មានគ្របដណ្តប់ទៅលើកិច្ចការធម្មតា បទដ្ឋានអំពីការផ្សាយពាណិជ្ជកម្ម ឬពេលម៉ោងសម្រាប់កម្មវិធីហាមឃាត់ចំពោះអ្នកមានអាយុតិច ។ អ្នកឯកទេសយល់ថា វាជាកិច្ចការរបស់ប្រព័ន្ធឃោសនា ពុំមែនជារបស់សភាឡើយ ដើម្បីកំណត់ និងគោរពតាមបទដ្ឋានវិជ្ជាជីវៈ និងសីលធម៌ឱ្យបានកំរិតខ្ពស់បំផុត ។ ប៉ុន្តែអង្គការត្រួតពិនិត្យបែបនេះនៅតែខ្វះខាតដដែល អាស្រ័យដោយគ្មានទណ្ឌកម្មគ្រប់គ្រាន់ ឬគ្មានការចាត់ចែងប្រកបដោយប្រសិទ្ធភាព ក្នុងករណីនៃការបង្ហាញព័ត៌មានខុស ឬមួលបង្កាច់ ។

នៅប្រទេសប្រេស៊ីលពុំមានអាជ្ញាធរត្រួតពិនិត្យវិទ្យុ និងទូរទស្សន៍ឡើយ ហើយពុំមានក្រមវិជ្ជាជីវៈសម្រាប់ប្រព័ន្ធឃោសនាដែរ ។ គណៈកម្មការសិទ្ធិមនុស្សរបស់សភា ដោយសហការជាមួយសង្គមស៊ីវិលបានបង្កើតនូវប្រព័ន្ធតាមដានជាតិទៅលើកម្មវិធីទូរទស្សន៍ ។ ទូរទស្សនិកជនត្រូវបានលើកទឹកចិត្តឱ្យថ្កោលទោសទៅលើកម្មវិធីទាំងឡាយណាដែលពួកគេយល់ថា គួរឱ្យស្អប់ខ្ពើម ឬអាស្រូវ ហើយអ្នកផ្សព្វផ្សាយរឹងត្អឹងត្រូវបានកត់ឈ្មោះចូលក្នុង "បញ្ជីមួយនៃភាពអាម៉ាស់" ដែលក្លាយជាកម្មវត្ថុនៃការពិភាក្សាក្នុងកិច្ចប្រជុំប្រក្រតីជាមួយអ្នករៀបចំកម្មវិធីទូរទស្សន៍នានា ។ គោលការណ៍ជាមូលដ្ឋាននៃយុទ្ធនាការនេះគឺ កិត្តិយសស្មើគ្នាសម្រាប់អ្នកទាំងអស់គ្នា ។

ត្រូវបានចាត់ទុកប្រឆាំងនឹងគោលការណ៍នេះ ការបង្ហាញនូវភាពអន់ថយរបស់បុគ្គល ដោយមូលហេតុភេទ សម្បុរ ឬនិន្នាការភេទ ការមិនគោរពដល់ភាពចាត់ទុកថាគ្មានទោស ការថតរូបភាព ឬភាពយន្តនូវក្រុមឬបុគ្គលរងគ្រោះដោយគ្មានសេចក្តីអនុញ្ញាតពីពួកគេ ការសម្ភាសន៍មិនសមស្របជាមួយកុមារ ការបង្ហាញឆាកហឹង្សា ឬសិច នៅម៉ោងដែលមនុស្សមើលច្រើន..។ យុទ្ធនាការនេះបង្ហាញថា គណៈកម្មការសភាខាងសិទ្ធិមនុស្សអាចមានដែនសកម្មភាពធំធេង ហើយសភានីមួយៗអាចតំណាងឱ្យសាធារណៈមតិ ដើម្បីប្រឆាំងទៅនឹងផលប្រយោជន៍ពាណិជ្ជកម្មរបស់ក្រុមខ្លាំងខ្លះ ។

## តើសមាជិកសភាអាចជូនព័ត៌មានទៅសាធារណជនអំពីការងាររបស់ខ្លួនយ៉ាងដូចម្តេច?

សភាទាំងឡាយកំពុងខិតខំបើកចំហទៅកាន់ប្រជាជន លុបបំបាត់របាំងដែលរារាំងមិនឱ្យប្រព័ន្ធឃោសនាផ្សព្វផ្សាយព័ត៌មានដោយត្រឹមត្រូវ នៅក្នុងក្របខ័ណ្ឌបទបញ្ជាមួយដែលអនុគ្រោះឱ្យមានពហុនិយម និងមានខ្លឹមសារមិនរើសអើង ។

ប៉ុន្តែយុទ្ធសាស្ត្រដែលសភាទាំងឡាយដាក់អនុវត្តន៍ដោយខ្លួនឯង ដើម្បីជូនព័ត៌មានដល់ប្រជាពលរដ្ឋអំពីការងាររបស់ខ្លួន ធ្វើឱ្យប្រជាពលរដ្ឋចាប់អារម្មណ៍ និងជម្រុញឱ្យប្រជាពលរដ្ឋចូលរួម មានសារសំខាន់ផងដែរ ។

កិច្ចការនេះជាកិច្ចការពិបាក ដោយពុំគ្រាន់តែផ្តល់ព័ត៌មានប៉ុណ្ណោះទេ តែច្រើនជាងនេះធ្វើឱ្យប្រជា-ពលរដ្ឋភាគច្រើនបានយល់ដឹងអំពីដំណើរការ និងការងាររបស់សភា ។

សភាជាច្រើនទាំងចាស់ទាំងថ្មី មាននិន្នាការអនុម័តនូវយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយអំពីព័ត៌មាន និងការប្រាស្រ័យឆ្លើយឆ្លងដែលផ្តល់ទំនុកចិត្តឱ្យអ្នកទទួលខុសត្រូវមួយរូប ឬនាយកដ្ឋានតែមួយគត់ ។ យុទ្ធសាស្ត្រនេះគ្របដណ្តប់ទៅលើប្រព័ន្ធឃោសនាគ្រប់ប្រភេទ : វិទ្យុ ទូរទស្សន៍ Internet ការបោះពុម្ពផ្សាយ មជ្ឈមណ្ឌលព័ត៌មាន និងកម្មសិក្សាបណ្តុះបណ្តាលគ្រប់ប្រភេទ ។ ផលប្រយោជន៍នៃភាពចម្រុះបែបនេះគឺថា ប្រជាពលរដ្ឋអាចជ្រើសរើសប្រព័ន្ធឃោសនាណាមួយតាមការចូលចិត្តរបស់ខ្លួន ។

ឧទាហរណ៍ សភាហុងគ្រីប្រើប្រាស់វិទ្យុ ទូរទស្សន៍ សារព័ត៌មានជាមធ្យោបាយសំខាន់របស់ព័ត៌មាន ។ សម័យប្រជុំពេញអង្គសភាត្រូវបានផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ ព្រមទាំងតាម Internet ។ បណ្ណាល័យរបស់សភា និងនាយកដ្ឋាននានារបស់អគ្គលេខាធិការផ្តល់ព័ត៌មានបន្ថែម ។ ក្រៅពីនោះនៅមានទូរស័ព្ទពិសេស ឬសេវា E-mail សម្រាប់ប្រជាពលរដ្ឋប្រើប្រាស់ ដើម្បីសាកសួរសំណួរទៅលើការងារនីតិកម្មរបស់សភា ។ សមាគមផ្សេងៗអាចទទួលបានព័ត៌មានពីនាយកដ្ឋានកិច្ចការប្រជាពលរដ្ឋ (Office Civil) ។

តាមប្រពៃណី សភាតែងតែរក្សាកំណត់ហេតុនៃសម័យប្រជុំពេញអង្គ ។ សភាជាច្រើនមានស្ថានីយ៍ទូរទស្សន៍ផ្ទាល់ដើម្បីផ្សព្វផ្សាយការពិភាក្សា និងថតថែរក្សាទុក ។ ផលប្រយោជន៍ទី១ នៃប្រព័ន្ធបែបនេះ គឺដើម្បីសភាអាចត្រួតពិនិត្យទៅលើខ្លឹមសារផ្សព្វផ្សាយ និងបង្កើតបានជាវេទិកាទូលំទូលាយជាច្រើនសកម្ម-ភាព ។ ជាឧទាហរណ៍ សភាបារាំង-ម៉ិចស៊ិកមានស្ថានីយ៍ផ្ទាល់ ។

សាធារណរដ្ឋកូរ៉េបានប្រគល់ឱ្យស្ថានីយ៍សាធារណៈ KTV ដើម្បីផ្សព្វផ្សាយនូវសម័យប្រជុំពេញអង្គ ។ បញ្ហាសំខាន់ គឺធ្វើឱ្យស្ថានីយ៍ពិសេសបែបនេះផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យបានច្រើនបំផុត ។

នាពេលបច្ចុប្បន្ន សភាជាច្រើនពុំត្រឹមតែប្រើប្រាស់ទូរទស្សន៍ប៉ុណ្ណោះទេ តែឈានទៅប្រើប្រាស់ការផ្សព្វផ្សាយតាមគេហទំព័រនូវសម័យប្រជុំពេញអង្គថែមទៀត ។ ប្រការនេះនាំឱ្យប្រជាពលរដ្ឋនៅឯបរទេសអាចតាមដានការងារសភាបាន ។ ឧទាហរណ៍ សភាព័រទុយហ្គាល់ផ្សព្វផ្សាយតាមអាំងទែណែត ដែលអនុគ្រោះឱ្យប្រជាពលរដ្ឋអាចតាមដានសម័យប្រជុំពេញអង្គ ទោះបីពលរដ្ឋនោះនៅទីណាក៏ដោយ លើពិភពលោកនេះ ។

ការផ្សព្វផ្សាយតាមវិទ្យុក៏មានសារសំខាន់ សម្រាប់កន្លែងណាដែលការប្រើប្រាស់ទូរទស្សន៍នៅមានតិច ជាឧទាហរណ៍ នៅទ្វីបអាហ្វ្រិក ។ ជាឧទាហរណ៍ ទូរទស្សន៍ជាប្រភពព័ត៌មានសំខាន់សម្រាប់ ៩២% នៃប្រជាជនឥណ្ឌូនេស៊ី តែសម្រាប់តែ ២% នៃប្រជាជនអ៊ូហ្គង់ដាតែប៉ុណ្ណោះ ។

**គេហទំព័ររបស់សភា**

សភាជាច្រើនមានគេហទំព័ររបស់ខ្លួន ក្នុងនោះមានគេហទំព័រសាធារណៈដើម្បីជូនព័ត៌មានដល់ប្រជាពលរដ្ឋអំពីការពិភាក្សាក្នុងសភា និងកម្រងអត្ថបទច្បាប់សម្រាប់សាធារណជនប្រើប្រាស់ ហើយនឹងគេហទំព័រសម្រាប់ប្រជាពលរដ្ឋធ្វើអន្តរកម្មជាមួយសមាជិកសភា ។

ព្រឹទ្ធសភាឈីលី ចាត់ទុកបច្ចេកវិទ្យាព័ត៌មានថាបានផ្តល់ដង្ហើមប្រជាធិបតេយ្យអេឡិចត្រូនិច ដែលប្រជាពលរដ្ឋស្វះស្វែងរកបានព័ត៌មានអំពីច្បាប់ ពិនិត្យតាមដានជិតដល់ និងចូលរួម ព្រមទាំងអន្តរកម្ម ដែលធ្វើឱ្យកាន់តែមានតម្លាភាពដល់ដំណើរការកសាងច្បាប់ និងនីតិវិធីសភា ។ ប្រជាពលរដ្ឋអាចសាកសួរសំណួរតាមគេហទំព័រ ធ្វើអត្ថាធិប្បាយ ចូលរួមពិភាក្សា និងស្ទង់មតិ : មានព័ត៌មានគ្រប់គ្រាន់ចំពោះបញ្ហាដែលគេយកចិត្តទុកដាក់ ។ ប្រការនេះធ្វើឱ្យប្រជាពលរដ្ឋក្លាយជាតួសម្តែងនៅក្នុងដំណើរការប្រជាធិបតេយ្យ ។

នៅព្រឹទ្ធសភាអ៊ីតាលី តាមរយៈគេហទំព័រ អ្នកបោះឆ្នោតតែងផ្ញើ E-mail ទៅកាន់តំណាងរបស់ខ្លួនចង់ដឹងថា តើតំណាងរបស់ខ្លួនបោះឆ្នោតយ៉ាងដូចម្តេចទៅលើបញ្ហាណាមួយ ឬតំណាងរបស់គេមានយោបល់យ៉ាងណាចំពោះបញ្ហានោះ?

នៅ Lettonie តាមរយៈគេហទំព័ររបស់សភា ដែលមានចុះផ្សព្វផ្សាយនូវសេចក្តីព្រាងច្បាប់ទាំងស្រុង ក្លាយជាវេទិកាពិគ្រោះយោបល់ ព្រោះប្រជាពលរដ្ឋម្នាក់ៗអាចដឹងថា តើសេចក្តីព្រាងច្បាប់ដែលគេចាប់អារម្មណ៍បានដំណើរការទៅមុខយ៉ាងដូចម្តេច ។

ចំពោះបញ្ហា Website នេះគួរចាប់អារម្មណ៍ថា សម្រាប់គ្រប់ប្រទេសការប្រើប្រាស់នៅមានកំរិត ។ ការសម្តែងនូវលទ្ធិប្រជាធិបតេយ្យពិតប្រាកដ គឺទុកឱ្យប្រជាពលរដ្ឋជ្រើសរើសរូបភាពនៃការប្រាស្រ័យឆ្លើយឆ្លងដែលសមស្របសម្រាប់ពួកគេ និងដែលប្រើប្រាស់បាន ។ រវាងប្រទេសមាន និងប្រទេសក្រ ការប្រើប្រាស់កុំព្យូទ័រនៅខុសគ្នាខ្លាំងណាស់ រួមទាំងការប្រើប្រាស់ទូរស័ព្ទដៃផង ។ នៅឆ្នាំ ២០០៥ នៅលើពិភពលោក ការប្រើប្រាស់ទូរស័ព្ទដៃមាន ៥ដង ច្រើនជាង Internet ។ ការប្រើប្រាស់ Internet លើពិភពលោកមានត្រឹមតែ ១៥,៧% នៃប្រជាជនលើពិភពលោកតែប៉ុណ្ណោះ ។

ស្ថិតនៅចំពោះមុខការជាក់ស្តែងបែបនេះ ដំណោះស្រាយគឺត្រូវប្រើប្រាស់ប្រព័ន្ធទឹកល្បាក់ធ្លាក់ (Un systeme en cascade) ដោយបញ្ជូនព័ត៌មានតាមមធ្យោបាយអេឡិចត្រូនិចឱ្យដល់ទីស្នាក់ការរបស់សមាជិកសភា ទីស្នាក់ការរួមធំៗ ហើយពីទីនោះទុកឱ្យប្រជាជនប្រើប្រាស់នូវមធ្យោបាយសាមញ្ញ ដែលគេអាចជ្រើសរើសបាន ។

## បើកសភាឱ្យទៅកៀរប្រជាជន

សភាជាច្រើនមានរៀបចំជាមជ្ឈមណ្ឌលព័ត៌មាន និងអប់រំ ដែលបើកចំហរឱ្យមានដំណើរទស្សនកិច្ចជាសមូហភាព និងជាបុគ្គល ។

រដ្ឋសភាអ៊ីតាលីបានសម្ពោធនាឆ្នាំ ២០០៥ នូវមជ្ឈមណ្ឌលពហុមុខងារ និងពហុប្រព័ន្ធឃោសនា (Un centre multifunctions et multimédias) ដែលបើកជារៀងរាល់ថ្ងៃ អនុញ្ញាតឱ្យទស្សនិកជនតាមដានមើលការប្រជុំពេញអង្គតាមអេក្រង់ ពិគ្រោះព័ត៌មានអំពីសភាតាមរយៈប្រព័ន្ធឃោសនា ឬដើម្បីធ្វើការស្រាវជ្រាវជាប្រព័ន្ធ ។

សភាខ្លះទៀតរៀបចំផងដែរនូវទិវាបើកចំហរ (Journée de porte ouverte) តាមកាលបរិច្ឆេទប្រក្រតីប្រចាំឆ្នាំ ឬក្នុងឱកាសខួបអនុស្សាវរីយ៍ពិសេស ។

សភា Kiribati បើកទ្វារចំហរសម្រាប់សាធារណជនម្តងក្នុងមួយឆ្នាំ ដើម្បីអបអរទិវាបើកនីតិកាលរបស់សភា ។

សភា Estonie រៀបចំទិវាបើកចំហរនៅថ្ងៃទី ២៣ ខែមេសា ដើម្បីអបអរខួបអនុស្សាវរីយ៍នៃការបង្កើតសភា នាឆ្នាំ ១៩១៩ ។

ប្រជាពលរដ្ឋអាចស្គាល់ពីអគាររបស់សភាតាមរយៈដំណើរទស្សនកិច្ចដោយមានអ្នកជូន ។ ក្នុងសម័យប្រជុំពិសេស ភ្ញៀវអាចសាកសួរសំណួរដល់សមាជិករដ្ឋាភិបាលថែមទៀត ។ មិនតែប៉ុណ្ណោះ សភា Estonie រៀបចំទិវាព័ត៌មាននៅក្នុងភូមិភាគ និងតាមភូមិនៅជនបទ ដើម្បីឱ្យប្រជាពលរដ្ឋនៃភូមិភាគទាំងនេះសាកសួរសំណួរដល់សមាជិកសភា ។

សភាមួយចំនួនទៀតបានខិតខំនាំសភាទៅឱ្យប្រជាជន ។ ឧទាហរណ៍ ប្រទេស Botswana បានបើកយុទ្ធនាការ "សភាចល័ត" ដោយតំណាងរបស់ប្រធានសភា និងនាយកដ្ឋានព័ត៌មាន ដើម្បីពន្យល់អំពីតួនាទីរបស់អ្នកធ្វើច្បាប់នៅក្នុងសង្គម ។

ប្រទេសអាហ្វ្រិកខាងត្បូងរៀបចំដំណើរបេសកកម្មប្រជាធិបតេយ្យ ដើម្បីនាំសភាទៅក្បែរប្រជាជនដែលគ្មានព័ត៌មាន និងជំរាបជូនព័ត៌មានអំពីការងារនីតិកម្ម និងអំពីរបៀបដែលប្រជាជនអាចចូលរួមក្នុងដំណើរការនោះបាន ។ សភាជាន់ខ្ពស់អាហ្វ្រិកខាងត្បូង ជារៀងរាល់ឆ្នាំរៀបចំការប្រជុំមួយអាទិត្យនៅក្នុងខេត្តមួយ ដើម្បីបានជួបជាមួយគ្រប់មជ្ឈដ្ឋានទាំងអស់ ជាពិសេសតំណាងឱ្យជនបទ ។

សភាម៉ុងហ្គោលីបានបង្កើតមជ្ឈមណ្ឌលលើកតម្កើងសភាជាអចិន្ត្រៃយ៍នៅ ៥ មណ្ឌល ក្នុងរដ្ឋធានី និងប្រាំបួនកន្លែងនៅតាមខេត្ត ដោយមានទិសដៅដូចតទៅ

- ពង្រីកទំនាក់ទំនងជាប្រព័ន្ធរវាងសមាជិកសភា និងអ្នកបោះឆ្នោត រដ្ឋអំណាចមូលដ្ឋាន និងសង្គមស៊ីវិល ។
- រៀបចំកម្មសិក្សាបណ្តុះបណ្តាលមូលដ្ឋាន ការពិភាក្សា សវនាការសាធារណៈ និងសិក្ខាសាលា ។
- ជម្រុញប្រព័ន្ធឃោសនាមូលដ្ឋាន និងអ្នកជាប់ឆ្នោតឱ្យស្គាល់គ្នា និងលើកតម្កើងសកម្មភាពសភា ។

សភាស៊ុយអែតបានបើកនាឆ្នាំ ២០០៣ នូវសាខានៅទីក្រុងចំនួនបី ។ ដោយសហការជាមួយសាលាក្រុងទាំងបី សភាស៊ុយអែតបានបំពាក់អេក្រង់នៅសាលប្រជុំមួយសម្រាប់ជាការអប់រំ និងព័ត៌មាន ដែលមើលឃើញនូវគេហទំព័ររបស់សភាស៊ុយអែត ដើម្បីតាមដានមើលការងាររបស់សភា ។ សមាជិកសភាតាមភូមិភាគ អាចឆ្លៀតប្រើសាខាទាំងនេះដើម្បីជួបជាមួយអ្នកបោះឆ្នោត និងរៀបចំការពិភាក្សាផ្សេងៗ ។

## ព័ត៌មាន និងការចូលរួមរបស់យុវវ័យ

សភាជាច្រើនបានទទួលស្គាល់ថា មានការពិបាកនឹងធ្វើឱ្យយុវវ័យចាប់អារម្មណ៍ដល់ការងាររបស់សភា ។

នេះមិនមានន័យថា យុវវ័យមិនអើពើចំពោះនយោបាយឡើយ ព្រោះយុវវ័យជាច្រើនចូលរួមក្នុងចលនា សមូហភាព ឬយុទ្ធនាការផ្សេងៗ ។ ប៉ុន្តែប្រភេទយុវវ័យចូលរួមបោះឆ្នោតតិចជាងគេ ហើយមិនសូវចាប់អារម្មណ៍ដល់នយោបាយរបស់សភាឡើយ ។

អញ្ចឹងហើយបានជាសភាជាច្រើនបានខិតខំជាពិសេស ផ្សព្វផ្សាយតាមគ្រឹះស្ថានសិក្សាតាមរូបភាពផ្សេងៗដូចជា នៅក្នុងសាលារៀន នៅក្នុងសភាខ្លួនឯង ឬទាំងពីរតែម្តង ។

### + សកម្មភាពនៅក្នុងសាលារៀន

សកម្មភាពនេះចាប់ផ្តើមតាមរយៈការបង្រៀនអំពីសភានៅក្របខ័ណ្ឌនៃកម្មវិធីសិក្សា ។

សភាអាហ្វ្រិកខាងត្បូងកំពុងកំណត់នូវកម្មវិធីអប់រំប្រជាពលរដ្ឋ ដោយបង្ហាញដល់យុវវ័យអំពីដំណើរការរបស់សភា ការធ្វើច្បាប់ និងរបៀបដែលប្រជាពលរដ្ឋអាចចូលរួមដល់ដំណើរការកសាងច្បាប់ ។ កម្មវិធីនេះត្រូវបញ្ចូលក្នុងកម្មវិធីសិក្សា ។

សភា Islande បានបង្កើតគេហទំព័រសម្រាប់សិស្សអាយុពី ១៣ឆ្នាំ ទៅ១៥ឆ្នាំ តាមរយៈគំនូរជីវចរ ដើម្បីឱ្យសិស្សខិតខំឆ្លើយសំណួរទទួលបានពិន្ទុ ដែលជាប្រព័ន្ធគរុកោសល្យមួយដែលគេចូលចិត្តប្រើប្រាស់ ។

សភាហុំាងឡង់បានបង្កើតល្បែងអេឡិចត្រូនិចដែលគេហៅថា អ្នកធ្វើច្បាប់ ដើម្បីអនុញ្ញាតឱ្យក្រុមសិស្សរៀបចំច្បាប់អរូបី ដោយសម្តែងតួតាមរបៀបដូចសភា ។

ប្រទេសប្រជាធិបតេយ្យចាស់ៗវាយតម្លៃថា នៅក្នុងក្របខ័ណ្ឌនៃកម្មវិធីតាមសាលា សិស្សបង្កើតនូវសភាខ្លួនឯងផ្ទាល់ ជារូបរាងសភាជ្រើសតាំង ឬរូបភាពផ្សេងទៀត ហើយសិស្សទាំងនោះចូលរួមសម្រេចចិត្តលើបញ្ហាពាក់ព័ន្ធដល់បទបញ្ជា និងវិន័យនៃសាលារបស់ខ្លួន ។ គម្រោងបែបនេះមានសារសំខាន់ខ្ពស់នៅក្នុងប្រទេសដែលមានកង្វល់ លើកតម្កើងលទ្ធិប្រជាធិបតេយ្យ និងពង្រឹងវប្បធម៌សមស្របសម្រាប់ការគ្រប់គ្រង ។

រដ្ឋសភា Turquie បានសហការជាមួយក្រសួងអប់រំដើម្បីរៀបចំគម្រោងការ "សភារបស់សាលារៀន" នៅតាមសាលារៀនទូទាំងប្រទេស ដើម្បីឱ្យសិស្សទាំងបឋមសិក្សា និងមធ្យមសិក្សាបានយល់ដឹងពីវប្បធម៌នៃការបោះឆ្នោត ទោះបីគេជាអ្នកបោះឆ្នោត ឬជាបេក្ខជនក្តី ជួយពួកគេឱ្យចេះដោះស្រាយបញ្ហាតាមទស្សនវិស័យរបស់ពួកគេ យល់ពីដំណើរការប្រជាធិបតេយ្យ ជាពិសេសទស្សនៈអំពីការចូលរួមសាធារណៈ និងការអធ្យាស្រ័យគ្នា ចែករំលែកនូវវប្បធម៌ប្រជាធិបតេយ្យទៅគ្រប់សមាសធាតុនៃសង្គម ។

**+ កម្មវិធីគាំទ្រដោយសភា**

កម្មវិធីនេះមានជាច្រើនរូបភាព ។

សភាជាច្រើនរៀបចំកម្មវិធីទស្សនកិច្ចជាប្រក្រតីសម្រាប់សិស្សមកពីសាលារៀន ម្តងមួយអាទិត្យ ឬមួយខែ ដើម្បីឱ្យពួកក្មេងៗទូទាំងប្រទេសចូលរួមមើលសម័យប្រជុំពេញអង្គ និងកិច្ចប្រជុំគណៈកម្មការនានា លើកសំណួរដល់រដ្ឋមន្ត្រី និងជួបជាមួយសមាជិកសភារបស់ពួកគេ ។

សភាមួយចំនួនទៀតបានរៀបចំសម័យប្រជុំពេញអង្គសម្រាប់យុវវ័យ ដើម្បីសិស្សទាំងនោះរៀនអំពីនីតិវិធីសភា ដោយរៀបចំជាការពិភាក្សារបស់ពួកគេផ្ទាល់ និងកិច្ចប្រជុំលើកសំណួរ ។

សភា Norvège បានរៀបចំមណ្ឌលសម្តែង (Un centre de manifestation) មួយនាឆ្នាំ២០០៥ ដើម្បីឱ្យពួកសិស្សរៀនធ្វើតាមការងារសភា ។ ពួកគេធ្វើដូចជាសមាជិកសភានៅក្នុងសម័យប្រជុំពេញអង្គ

ឧប្បត្តិកឡើង ការប្រជុំគណៈកម្មការសភា និងក្រុមនយោបាយ ពួកគេតាក់តែងឯកសារចាំបាច់ និងប្រឈមមុខនឹងពួកអ្នកកាសែត ។

នៅក្នុងប្រព័ន្ធដែលចងភ្ជាប់សកម្មភាពរបស់សភាទៅនឹងកម្មវិធីរបស់សភា សិស្សជ្រើសតាំងតំណាងគ្រឹះស្ថានសិក្សា ដែលត្រូវចូលមកអង្គុយនៅក្នុងសភាជាតិមួយរបស់យុវវ័យ ។

ជាឧទាហរណ៍នៅប្រទេសប៉ូឡូញ គេរៀបចំជារៀងរាល់ឆ្នាំនូវកិច្ចប្រជុំប្រចាំឆ្នាំរបស់សមាជិកសភាជាយុវវ័យ ។ ដូចគ្នានេះដែរ នៅសភាដាណឺម៉ាក ។

នៅប្រទេសហុងគ្រី ជារៀងរាល់ឆ្នាំសមាជិកសភា និងតំណាងស្ថាប័នផ្សេងទៀត ជួបជាមួយពួកយុវវ័យ ដែលក្លាយជាមហោស្រពគន្ទ្រីសម្រាប់យុវវ័យនៅទ្វីបអឺរ៉ុប ។ នៅទីនោះ សិស្សចូលរួមក្នុងសន្និសីទនយោបាយ និងអាចពិភាក្សាបញ្ហារបស់ខ្លួនជាមួយសមាជិកសភាបាន ។

## IV-សភាដែលចូលដិតបាន

ជំពូកទី៣ និយាយអំពីមធ្យោបាយផ្សេងៗ ដែលអនុញ្ញាតឱ្យប្រជាពលរដ្ឋទទួលបានព័ត៌មានអំពីសភារបស់ខ្លួន ។ ដោយគ្មានព័ត៌មានច្បាស់លាស់ និងប្រចាំថ្ងៃស្ដីពីការងាររបស់សភានោះ គេពុំអាចមានឥទ្ធិពលអ្វីបន្តិចបន្តួចឡើយទៅលើស្ថាប័ននេះ មិនថាជាក៏រិតបុគ្គល ឬតាមរយៈអង្គការដែលមានរចនាសម្ព័ន្ធឈរលើមូលដ្ឋាននៃផលប្រយោជន៍រួម ។

ជំពូកទី៤ និយាយអំពីមធ្យោបាយផ្សេងៗ ដែលតាមរយៈនេះសភាបើកចំហឱ្យប្រជាពលរដ្ឋ និងអង្គការសង្គម ព្រមទាំងមធ្យោបាយផ្សេងៗ ដែលតាមរយៈនេះប្រជាពលរដ្ឋ និងអង្គការសង្គមសង្ឃឹមថា នឹងប្រើប្រាស់ដើម្បីបង្កឥទ្ធិពលទៅលើសភាវិញ ។

### ការទាក់ទងផ្ទាល់រវាងប្រជាពលរដ្ឋ និងតំណាងរបស់ខ្លួន

តាំងពីដើមរៀងមក ប្រជាពលរដ្ឋចូលទៅទាក់ទងជាមួយសភាតាមរយៈតំណាងជាប់ឆ្នោតរបស់ខ្លួន។ នៅក្នុងប្រទេសជាច្រើនដែលអ្នកបោះឆ្នោតត្រូវបែងចែកតាមមណ្ឌល ដោយមានមូលដ្ឋានភូមិសាស្ត្រ ហើយដែលសមាជិកសភាជាតំណាងឱ្យមូលដ្ឋានមួយច្បាស់លាស់ ។ ការទាក់ទងគ្នាប្រព្រឹត្តឡើងជាញឹកញាប់បំផុតនៅពេលដែលមានការជួបសន្ទនាគ្នានៅក្នុងភូមិភាគដែលអ្នកបោះឆ្នោតតាំងនៅ ។

អ្នកគាំទ្រប្រព័ន្ធនេះវាយតម្លៃថា គុណសម្បត្តិដ៏ធំគឺថា សមាជិកសភាបានទទួលព័ត៌មានពីអ្នកបោះឆ្នោតរបស់ខ្លួនអំពីបញ្ហា និងកង្វល់ផ្សេងៗ ហើយដោយពុំជឿតែលើរបាយការណ៍ ជាពិសេស កាលណាត្រូវវាយតម្លៃអំពីផលប៉ះពាល់របស់ច្បាប់ ។

ផ្ទុយទៅវិញ ការធ្វើរបៀបនេះនាំឱ្យសមាជិកសភាក្លាយទៅជាអ្នកជំនួយការខាងសង្គមកិច្ចប្រចាំគ្រប់ពេលវេលា ។

ឧទាហរណ៍នៅប្រទេសម៉ាលី អ្នកបោះឆ្នោតរង់ចាំថា កាលណាបោះឆ្នោតជ្រើសតាំងតំណាងរបស់ខ្លួនរួចហើយ តំណាងនោះត្រូវមកប្រចាំជាមួយគាត់គ្រប់ពេលវេលា ទាំងពិធីបុណ្យផ្សេងៗ បុណ្យសព ឬផ្តល់ជំនួយខាងសង្គមកិច្ច ។

សម្រាប់សមាជិកសភាម្នាក់ នោះគឺជាលំបាកតុល្យភាពមួយដ៏តានតឹង ព្រោះត្រូវឆ្លើយតបទៅនឹងការរំពឹងទុកដ៏ស្របច្បាប់របស់ម្ចាស់ឆ្នោត ដែលប៉ងប្រាថ្នាឱ្យតំណាងរបស់ខ្លួនយល់ និងការពារទស្សនៈ និងផលប្រយោជន៍របស់ខ្លួន ដោយខិតខំរៀបចំពេលវេលាកុំឱ្យជាន់នឹងមុខងារធ្វើច្បាប់ និងភារកិច្ចសភាដទៃទៀត ។

នាយុគសម័យបច្ចុប្បន្ន ការប្រើប្រាស់ E-mail បង្កើនល្បឿនយ៉ាងខ្លាំងដល់ការទាក់ទងរវាងអ្នកបោះឆ្នោត និងតំណាងរបស់ខ្លួន ។ តែប្រជាជនលើពិភពលោកតិចតួចប៉ុណ្ណោះដែលអាចប្រើប្រាស់ Internet បាន ។

អញ្ចឹងហើយបានជានៅប្រទេសជាច្រើន លទ្ធភាពដើម្បីជួបដោយផ្ទាល់ជាមួយសមាជិកសភា ជាកំរិតបុគ្គល ឬជាក្រុម ដោយជៀសវាងការចំណាយលើការធ្វើដំណើរ និងការបាត់បង់ពេលវេលា គឺជារឿងសំខាន់បំផុត ។ បញ្ហាចោទនោះគឺសមាជិកសភាត្រូវមានពេលវេលា ហើយមណ្ឌលរបស់គាត់ត្រូវមានមធ្យោបាយ ។

ចំពោះ**<u>បញ្ហាពេលវេលា</u>** សភាជាច្រើនអនុញ្ញាតឱ្យសមាជិកសភាមានពេលវេលាមួយថ្ងៃ ឬពីរថ្ងៃនៅដើម ឬចុងសប្តាហ៍នៃអាទិត្យនីមួយៗ ដើម្បីទៅកាន់មណ្ឌលរបស់ខ្លួន ។

ជាឧទាហរណ៍នៅប្រទេសស្រីលង្កា សភាប្រជុំនៅអាទិត្យទី១ និងអាទិត្យទី៣ជារៀងរាល់ខែ អាទិត្យទី២ និងអាទិត្យទី៤ ទុកសម្រាប់ការងារនៅក្នុងមណ្ឌលរបស់សមាជិកសភា ដើម្បីឱ្យអ្នកបោះឆ្នោតអាចជួបជាមួយសមាជិកសភារបស់ខ្លួន ។

នៅប្រទេសឈីលី សភាទាំងពីរប្រជុំ ៣អាទិត្យក្នុងមួយខែ ដើម្បីទុកអាទិត្យទី៤ សមាជិកសភាមានពេលវេលាគិតគូរអំពីកិច្ចការរបស់មណ្ឌលស្រុក ឬភូមិភាគ ហើយថែរក្សាការសន្ទនាជាអចិន្ត្រៃយ៍ជាមួយអ្នកបោះឆ្នោត ។

នៅក្នុងប្រទេសខ្លះ មុខងារជាសមាជិកសភាគឺជាសកម្មភាពពុំពេញពេលវេលា តំណាងប្រជាជនអាចថែរក្សានូវមុខវិជ្ជាជីវៈប្រក្រតី ។

នៅប្រទេស Malte សមាជិកសភាចុះទៅសាកសួរសុខទុក្ខអ្នកបោះឆ្នោតដល់ផ្ទះ មន្ទីរពេទ្យ និង កន្លែងធ្វើការ ដើម្បីទទួលបានព័ត៌មានឱ្យបានល្អប្រសើរអំពីសេចក្តីត្រូវការប្រចាំថ្ងៃ ហើយដំណើរបែបនេះមាន ជាញឹកញាប់ ។

ធ្វើរបៀបនេះ អនុញ្ញាតឱ្យសមាជិកសភាឱ្យយកចិត្តទុកដាក់ដោយផ្ទាល់ខ្លួនចំពោះប្រជាពលរដ្ឋ ហើយ បើចាំបាច់ ពន្យល់ប្រជាពលរដ្ឋអំពីវិធានការដែលបានសម្រេចនៅក្នុងក្របខ័ណ្ឌច្បាប់ ដែលអនុម័តដោយ រដ្ឋសភា ។

នៅសាធារណរដ្ឋប្រជាមានិតចិនដែលមណ្ឌលស្ថិតនៅឆ្ងាយៗ សភាប្រជុំពេញអង្គតែប៉ុន្មានថ្ងៃប៉ុណ្ណោះ ក្នុងមួយឆ្នាំ ដើម្បីឱ្យសមាជិកសភាមានលទ្ធភាពប្រកបមុខរបរផ្សេងទៀតពាក់កណ្តាលពេល ។ ដំណោះ-ស្រាយនេះនាំឱ្យសមាជិកសភាជួបដោយផ្ទាល់ជាមួយអ្នកបោះឆ្នោត យល់ដឹងអំពីការលំបាក និងបំណងប្រាថ្នា របស់ពួកគេ ។ សមាជិកសភាអាចរួមវិភាគទានផងដែរដល់ការអនុវត្តរដ្ឋធម្មនុញ្ញ និងច្បាប់តាមរយៈការងារ ដែលពួកគេធ្វើ ថែមទាំងតាមជីវភាពសង្គមរបស់ពួកគេ ។ ប្រព័ន្ធបែបនេះមានផលល្អមួយផ្នែក តែមួយផ្នែក ទៀត ធ្វើឱ្យសមាជិកសភាពុំបានទទួលការបណ្តុះបណ្តាលគ្រប់គ្រាន់សម្រាប់ការងារធ្វើច្បាប់ ។ គណៈកម្មា-ធិការអចិន្ត្រៃយ៍របស់រដ្ឋសភាចិនធ្វើការប្រជុំជាប់ នៅចន្លោះសម័យប្រជុំពេញអង្គរបស់សភា ។

**<u>ទីស្នាក់ការប្រចាំនៅមូលដ្ឋាន</u>**

ការិយាល័យមណ្ឌល ឬស្រុក គឺជាទីកន្លែងជួប (ពុំអាចជំនួសបាន) ដែលអនុញ្ញាតឱ្យអ្នកបោះឆ្នោត ទាក់ទងជាមួយតំណាងជាប់ឆ្នោតរបស់ខ្លួន ព្រមទាំងជាមួយបុគ្គលិកនៅមូលដ្ឋាន ។ ដោយយោងលើ សារសំខាន់នេះ សភានៃប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន បានចាប់ផ្តើមកម្មវិធីរៀបចំតាំងទីស្នាក់ការនៅតាម មណ្ឌលនីមួយៗ ដើម្បីឱ្យសមាជិកសភាអាចជួបជាមួយអ្នកបោះឆ្នោតរបស់ខ្លួន ។

នៅប្រទេស Zambie នេះគឺជាទិសដៅមួយដ៏សំខាន់នៃកម្មវិធីកែទម្រង់របស់សភាដែលប្រកបដោយ មហិច្ឆតា ។ នៅក្នុងដំណាក់កាលទី១ គំរូពាប្រភេទនៃទីស្នាក់ការគំរូត្រូវបានសាកល្បង ដើម្បីកំណត់ថាណា មួយដែលសមស្របបំផុតសម្រាប់កែលំអទំនាក់ទំនងរវាងសមាជិកសភា និងអ្នកបោះឆ្នោត :

- ទីស្នាក់ការនៅនឹងកន្លែង
- ទីស្នាក់ការដោយមានថវិកាចល័ត ដែលអនុញ្ញាតឱ្យសមាជិកសភាធ្វើដំណើរទៅគ្រប់កន្លែងក្នុង មណ្ឌលរបស់ខ្លួន

- ទីស្នាក់ការពនេចរ ដែលរួមមានរថយន្ត Land Rover មួយគ្រឿងប្រដាប់ដោយកុំព្យូទ័រមួយគ្រឿង និងទូរស័ព្ទដៃមួយគ្រឿង

បុគ្គលិករដ្ឋបាលត្រូវបានជ្រើសរើស និងបណ្តុះបណ្តាលសម្រាប់ប្រភេទទាំង ៣ នៃទីស្នាក់ការនេះ ។ តាមការសិក្សា គឺទីស្នាក់ការនៅនឹងកន្លែងដែលមានប្រសិទ្ធភាពជាងគេ ។ អ្នកបោះឆ្នោតចាត់ទុកទីស្នាក់ការដែលថវិកាចល័ត គឺមិនសូវសំខាន់ មិនទៀងទាត់ និងពិបាកទាក់ទង ។ ឯទីស្នាក់ការពនេចរ ជួបប្រទះបញ្ហាថែទាំខាងបច្ចេកទេស ។

នៅប្រទេសហ្សីមបាវេ ដំណើរការកែទម្រង់ដូចគ្នានេះ នាំឱ្យមានការបង្កើតមជ្ឈមណ្ឌលព័ត៌មានសភាប្រចាំនៅក្នុង ១២០មណ្ឌល ។ ដើម្បីឱ្យប្រជាពលរដ្ឋ និងអង្គការមូលដ្ឋានជួបជាមួយសមាជិកសភាអំពីបញ្ហា និងសេចក្តីត្រូវការរបស់ពួកគេ ។ មជ្ឈមណ្ឌលទាំងនេះផ្សព្វផ្សាយព័ត៌មានអំពីសភា និងផ្តល់ឱកាសឱ្យប្រជា-ពលរដ្ឋចូលរួមក្នុងដំណើរការធ្វើច្បាប់ផងដែរ ។ មជ្ឈមណ្ឌលនេះកសាងមូលដ្ឋានទិន្នន័យសេដ្ឋកិច្ច-សង្គមរបស់ភូមិភាគ ដែលធ្វើបច្ចុប្បន្នភាពជាប្រចាំ ដើម្បីកំណត់អំពីសេចក្តីត្រូវការជាបន្ទាន់បំផុតរបស់មណ្ឌល ។

ការសិក្សាអំពីការងាររបស់ទីស្នាក់ការនៅមូលដ្ឋាន បង្ហាញអំពីប្រសិទ្ធភាព ក្នុងឋានៈប្រព័ន្ធបង្វែរការប្រាស័យឆ្លើយឆ្លង និងការចូលរួមរបស់ប្រជាពលរដ្ឋ តែក៏ពឹងផ្អែកលើការចូលរួម និងការជម្រុញពីសមាជិកសភាផងដែរ ។ ទីស្នាក់ការទាំងនេះក៏អាចប្រើប្រាស់សម្រាប់ទទួលពាក្យបណ្តឹង និងកត់ត្រាបញ្ហាផ្ទាល់ខ្លួន ព្រមទាំងជូនព័ត៌មានអំពីសកម្មភាពធ្វើច្បាប់របស់សមាជិកសភាផងដែរ ។

## សមាជិកសភាចូលរួមដល់សេវាអភិវឌ្ឍន៍មូលដ្ឋាន

នៅក្នុងសង្គមកំពុងអភិវឌ្ឍន៍ គឺនៅក្នុងវិស័យដ៏សំខាន់បំផុតនៃជីវភាពប្រចាំថ្ងៃដែលប្រជាពលរដ្ឋចង់បានជំនួយអំពីតំណាងជាអ្នកជាប់ឆ្នោតរបស់ខ្លួន ទឹកសម្រាប់ប្រើប្រាស់ សេវាសុខាភិបាល និងអនាម័យសាធារណៈ ទីតាំងសមូហភាព រចនាសម្ព័ន្ធមូលដ្ឋាន.... ។ល។ ដូច្នេះសមាជិកសភាមានឱកាសធ្វើដោយផ្ទាល់ និងជួយផ្តើមគម្រោងអភិវឌ្ឍន៍នៅក្នុងមណ្ឌលរបស់ខ្លួន តាមរបៀបជាច្រើន :

- ដោយជួយអំណាចសាធារណៈឱ្យកំណត់អាទិភាពនៃការអភិវឌ្ឍ និងដាក់អាទិភាពនោះអនុវត្តន៍ ។
- ជួយដល់សមូហភាព និងក្រុមមូលដ្ឋានឱ្យរកបាននូវហិរញ្ញប្បទានចាំបាច់ ដើម្បីសម្រេចគម្រោងផែនការរបស់ខ្លួន ។
- ដោយសហការជាមួយអង្គការ NGo នៅក្នុងក្របខ័ណ្ឌកម្មវិធីមូលដ្ឋាន ។

- បើគ្មានលទ្ធភាពក្រៅពីនេះ លើកបញ្ហាទៅក្រសួងពាក់ព័ន្ធ ធ្វើអនុសាសន៍អំពីការផ្ទេរថវិកាទៅកាន់ស្រុករបស់ខ្លួន ។

នៅក្នុងប្រទេសអាហ្វ្រិកខ្លះ សមាជិកសភាទទួលក្នុងនាមជាគម្រោងការមូលដ្ឋាន នូវមូលនិធិដែលដកចេញពីថវិកាអភិវឌ្ឍន៍របស់រដ្ឋាភិបាលកណ្តាល ដែលសមាជិកសភាអាចប្រើប្រាស់បានតាមឆន្ទានុសិទ្ធិរបស់ខ្លួន ។

នៅប្រទេសឥណ្ឌា សមាជិកសភាអាចផ្តល់យោបល់ឱ្យគេចាប់ផ្តើមការងារអភិវឌ្ឍន៍នៅក្នុងមណ្ឌលរបស់ខ្លួន ក្នុងទឹកប្រាក់ ២០លានរូពីក្នុងមួយឆ្នាំ ។ គណៈកម្មការពិសេសរបស់សភាទាំងពីរធានានូវទំនាក់ទំនងជាមួយក្រសួងសាមី ដើម្បីជួយសមាជិកសភាឱ្យបើកការដ្ឋានកសាង ។

## សញ្ញាអាសន្នសម្រាប់អនាគត : ការលើសបន្ទុកនៃសារអេឡិចត្រូនិច

នៅចុងម្ខាងនៃការអភិវឌ្ឍ បញ្ហាមួយបានចាប់ផ្តើមមានភាពធ្ងន់ធ្ងរនៅក្នុងប្រទេសដែលមានការប្រើប្រាស់ Internet ខ្លាំងក្លា បញ្ហាកំណើនស្រួចស្រាល់នៃសារផ្ញើមកសមាជិកសភា និងសេវារបស់សភា ។ សភាអាមេរិកកំពុងជួបបញ្ហានេះ ដោយសាររាល់ពេលដែលសាធារណជនបានដឹងអំពីបញ្ហាអ្វីមួយដែលប្រុងចម្រូងចម្រាស់ មហាជនផ្ញើសារព្រមៗគ្នាមកកាន់តំណាងរបស់ខ្លួន ដែលគ្មានសមត្ថភាពនឹងឆ្លើយតបដោយចំនួនច្រើនពេក ។ ចំនួនសារដ៏ច្រើនសម្បើមដែលកើនឡើងមកពីក្រៅស្រុកជាមណ្ឌលរបស់ខ្លួន ព្រមទាំងនិន្នាការរបស់អង្គការខ្លះដែលប្រើសារដើម្បីឡបប៊ីពីចំងាយ ។ ដោយសារប្រព័ន្ធឆ្លើយឆ្លងនេះលឿនភ្លាមៗ អ្នកផ្ញើសារតែងរង់ចាំនូវចម្លើយភ្លាមៗ តែបញ្ហាថវិកាសម្រាប់ប្រើប្រាស់ពុំគ្រប់គ្រាន់ឡើយ ។ ដូច្នេះបច្ចេក-វិទ្យាគ្រាន់តែអាចកាត់បន្ថយក្រដាស តែពេលខ្លះពុំបានជម្រុញលទ្ធិប្រជាធិបតេយ្យឡើយ ។ សារអេឡិច-ត្រូនិចបែរជានាំមកនូវភាពតានតឹង និងការមិនសប្បាយចិត្តពីសាធារណជន ដែលមិនយល់ពីរបៀបធ្វើការរបស់សមាជិកសភា និងភាពរាំងស្ទះដែលសមាជិកសភាត្រូវជួបប្រទះឡើយ ។

ជាការពិត សារអេឡិចត្រូនិចនាំឱ្យចំណេញពេលវេលា និងប្រាក់កាស (សន្សំសំចៃក្រដាស និងតែមប្រៃសណីយ៍) ផ្តល់ឱកាសឱ្យបើកចំហទៅខាងក្រៅ និងភ្ជាប់ទំនាក់ទំនងជាមួយក្រុមផ្សេងៗនៃអ្នកបោះឆ្នោតដែលយកចិត្តទុកដាក់ចំពោះកម្មវត្ថុពិសេសណាមួយ ។

## អនុញ្ញាតឱ្យប្រជាពលរដ្ឋដាក់បង្ហាញពាក្យបណ្តឹង

មុខងារដ៏សំខាន់មួយរបស់សភា តម្រូវឱ្យរៀបចំនូវប្រព័ន្ធមួយ ដែលអនុញ្ញាតឱ្យប្រជាពលរដ្ឋដាក់បង្ហាញនូវពាក្យបណ្តឹង និងចាត់ចែងការស៊ើបអង្កេតទៅលើកម្មវត្ថុដែលប្រជាពលរដ្ឋបានលើកឡើង ។

ជាទូទៅ ប្រជាពលរដ្ឋមានបំណងដាក់ពាក្យបណ្តឹងប្រឆាំងនឹងអំណាចសាធារណៈ ឬក៏ពឹងពាក់តាមរយៈតំណាងជាប់ឆ្នោតរបស់ខ្លួន ។ អញ្ចឹងហើយបានជាមានសារសំខាន់ត្រូវមានទីស្នាក់ការ ។

ជាការពិត តំណាងជាប់ឆ្នោតមានទម្ងន់ច្រើនជាងប្រជាពលរដ្ឋធម្មតា នៅពេលដែលត្រូវប្តឹងប្រឆាំងនឹងអំណាចសាធារណៈ ។

សភានានាតែគ្រោងទុកផងដែរនូវផ្លូវដើរទូទៅ គឺផ្លូវនូវសិទ្ធិធ្វើញត្តិ (Droit de pétition) និងគណៈកម្មការដែលត្រូវពាក់ព័ន្ធ ។ សិទ្ធិធ្វើញត្តិនេះចាប់ប្រភពទន្ទឹមនឹងកំណើតរបស់សភានៅលើពិភពលោកយើងនេះ ។ ជាអាទិ៍ សភាអង់គ្លេសត្រូវបង្កើតឡើងនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សារបស់ព្រះមហាក្សត្រដែលប្រជុំអំពីបញ្ហាញត្តិ ។ នៅប្រទេសបារាំងសិទ្ធិដាក់ញត្តិមកសភា ដូចជាផ្លូវនៃការតវ៉ាបានកើតមានតាំងពីកំណើតសាធារណរដ្ឋបារាំង ។

ជាមួយនឹងឥទ្ធិពល និងសារសំខាន់កើនឡើងរបស់សភា វិធីនៃការធ្វើញត្តិ គឺជាមធ្យោបាយសំខាន់នៃការតវ៉ា រហូតដល់សភាត្រូវតែបង្កើតឡើងនូវគណៈកម្មការពិសេស ដើម្បីពិនិត្យទៅលើញត្តិដ៏ច្រើនដែលកាន់តែកើនឡើង ។ អង្គការទាំងនោះរាប់ទាំងគណៈកម្មការសិទ្ធិមនុស្សដែលមានគោលដៅចម្បងគឺ ជួសជុលអយុត្តិធម៌ ។

នាពេលសព្វថ្ងៃនេះ គណៈកម្មការទាំងនេះត្រូវបានទទួលបន្ទុកពិនិត្យទៅលើញត្តិ ដែលមានមូលហេតុពីបញ្ហាមានលក្ខណៈទូទៅ និងគាំទ្រដោយហត្ថលេខីជាច្រើន ។ ជាឧទាហរណ៍នៅប្រទេសព័រទុយហ្គាល់ ញត្តិមួយត្រូវបានយកមកពិចារណា លុះត្រាមានហត្ថលេខាជាង ២០.០០០នាក់ ។

នៅប្រទេសជាច្រើន ប្រព័ន្ធមួយផ្សេងទៀតត្រូវបានជ្រើសរើសឡើង ។ ពាក្យបណ្តឹងជាទូទៅត្រូវបានទទួលដោយអ្នកសម្របសម្រួលម្នាក់(Un médiateur) ឬព្រះរាជអាជ្ញាសាធារណៈ (Procureur public) ដែលអាចជាដំបូងទាក់ទងតាមរយៈសមាជិកសភាម្នាក់ ឬជាញឹកញាប់ដោយអ្នកតវ៉ាផ្ទាល់តែម្តង ។ ទោះបីជាមានករណីបែបនេះក្តី គឺសភាដែលមានភារៈរៀបចំ និងត្រួតពិនិត្យមើលទៅលើក្របខ័ណ្ឌដែលអនុញ្ញាតឱ្យការពារនូវសិទ្ធិរបស់សាធារណជន ។

មុខងារជាអ្នកសម្រុះសម្រួល ឬជាព្រះរាជអាជ្ញាសាធារណៈបង្កើតនៅក្រុមប្រទេស Scandinavie បានក្លាយជាផ្លូវដ៏សំខាន់សម្រាប់ប្រជាពលរដ្ឋជាបុគ្គលតវ៉ាប្រឆាំងនឹងអំណាចសាធារណៈ ។ ជាការពិតសមត្ថកិច្ចរបស់អ្នកសម្រុះសម្រួលខុសប្លែកគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត ប៉ុន្តែអ្នកសម្រុះសម្រួលនេះ ជា

ទូទៅត្រូវទទួលបន្ទុកស៊ើបអង្កេតទៅលើសកម្មភាពរបស់អំណាចសាធារណៈ កាលណាសកម្មភាពនោះនាំឱ្យមានការរំលោភទៅលើសិទ្ធិមនុស្ស ការរំលោភបំពាន ឬការខ្វះខាតផ្សេងទៀត ។

នៅពេលទទួលពាក្យបណ្តឹងណាមួយរបស់ពលរដ្ឋណាម្នាក់ អ្នកសម្រុះសម្រួលមានបុព្វសិទ្ធិស៊ើបអង្កេត ហើយក្នុងករណីមានការរំលោភបំពានមែននោះ អាចទាមទារឱ្យមានសំណងសម្រាប់អ្នកប្តឹងតវ៉ា ឬ/និងការកែប្រែនូវការអនុវត្តរបស់ស្ថាប័នដែលនាំឱ្យមានការតវ៉ា ។ នៅក្នុងប្រទេសជាច្រើន សេចក្តីសម្រេចរបស់អ្នកសម្រុះសម្រួលពុំមែនចាប់បង្ខំឡើយ តែជាសេចក្តីសម្រេចដែលតែងមានទម្ងន់ ។ គេបានវាយតម្លៃថា សេចក្តីសម្រេចមានផលប្រយោជន៍ ព្រោះជៀសវាងបាននូវការជំរះក្តី អាចស្នើឡើងនូវសំណងជាច្រើនរូបភាព និងផ្តល់យោបល់សម្រាប់ការកែប្រែដ៏មានប្រយោជន៍ចំពោះនីតិវិធីរដ្ឋបាល ។

ជាឧទាហរណ៍នៅប្រទេសអៀកឡង់ដ៏ រហូតដល់ឆ្នាំ ១៩៦០ ប្រជាពលរដ្ឋដែលមានបណ្តឹងតវ៉ាតែងដាក់មកសភា (ឬមកគណៈកម្មការខាងញត្តិ) ឬក៏ទៅតុលាការ ។ ភាពស្មុគ្រស្មាញរបស់រដ្ឋទំនើប ដោយហេតុថាសភាតែងគ្របពីលើដោយរដ្ឋាភិបាល រយៈពេល និងសោហ៊ុយដ៏ធំធេងនៃនីតិវិធីតុលាការ ហើយនឹងការពុំទុកចិត្តរបស់ប្រជាពលរដ្ឋទៅលើស្ថាប័នទាំងនេះ បាននាំនូវការបង្កើតមុខងារអ្នកសម្រុះសម្រួល ។ ប្រការនេះគឺធ្វើតាមប្រពៃណីដែលមានតាំងពីយូរយារនៅប្រទេសស៊ុយអែត និងប្រទេសហ្វាំងឡង់ដ៏ ។ ប្រទេសដាណឺម៉ាក គឺជាប្រទេសទី១ ដែលជ្រើសយកដំណោះស្រាយនេះ បន្តដោយប្រទេសនូវែលហ្សេឡង់ដ៏ ប្រទេសអង់គ្លេស និងប្រទេសអៀកឡង់ដ៏ខាងជើង ។ ជាការពិត ចំនួនពាក្យបណ្តឹងមានចំនួនតិចតួចបើប្រៀបធៀបទៅនឹងសេចក្តីសម្រេចរាប់លានក្នុងមួយឆ្នាំដែលមុខងារសាធារណៈបានសម្រេចយក តែសកម្មភាពរបស់អ្នកសម្រុះសម្រួលតែងមានផលកាត់បន្ថយទម្ងន់ទៅលើស្ថាប័នសាធារណៈ ហើយស្ថាប័នសាធារណៈតែងយកចិត្តទុកដាក់គិតគូរនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ។

ឧទាហរណ៍មួយទៀតនៅប្រទេសអាហ្សង់ទីន ដែលយកតាមប្រពៃណីដ៏ល្អរបស់ប្រទេសអឺរ៉ុបខាងជើង ។ ប្រទេសនេះបានបង្កើតមុខងារអ្នកសម្រុះសម្រួល (Ambudsman) ដែលទទួលខុសត្រូវចំពោះមុខសភាជាតិ ។ អ្នកសម្រុះសម្រួលត្រូវទទួលបន្ទុកការពារផលប្រយោជន៍របស់ប្រជាពលរដ្ឋ ក្រុមប្រជាពលរដ្ឋ និងសហគមន៍ ជាទូទៅប្រឆាំងទៅនឹងអំពើទាំងឡាយរបស់រដ្ឋាភិបាល ដែលរំលោភបំពានទៅលើសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ ។ លទ្ធផលទទួលបានគឺល្អប្រសើរ ។ អ្នកសម្រុះសម្រួលអនុញ្ញាតឱ្យប្រជាពលរដ្ឋចូលរួមថែមទៀតនៅក្នុងយន្តការត្រួតពិនិត្យ ។

នៅប្រទេសខ្លះ អ្នកសម្រុះសម្រួលត្រូវទទួលខុសត្រូវចំពោះមុខរដ្ឋាភិបាល ។ តែតាមបទពិសោធន៍របស់ប្រទេសអាហ្សង់ទីន ភាគច្រើននៃប្រជាពលរដ្ឋចង់ឱ្យស្ថាប័ននេះទទួលខុសត្រូវចំពោះអង្គនីតិបញ្ញត្តិ ។

នៅទ្វីបអាមេរិកឡាទីន ការរំលោភសិទ្ធិមនុស្សតែងកើតរាលដាលនៅក្រោមរបបយោធា ដែលការបង្កើតនូវមុខងារព្រះរាជអាជ្ញាសាធារណៈ (ឬនៅក្នុងប្រទេសខ្លះ នូវគណៈកម្មការជាតិខាងសិទ្ធិមនុស្សដែលមានសមត្ថកិច្ចដូចគ្នា) គឺជាអង្គធាតុជាគ្រឹះនៃលទ្ធិប្រជាធិបតេយ្យ ។

ឆ្លងតាមបទពិសោធន៍របស់ប្រទេសនានា ស្ថាប័នអ្នកសម្រុះសម្រួល ឬព្រះរាជអាជ្ញាសាធារណៈនឹងមានប្រសិទ្ធភាពលុះណាតែ

- ឯករាជ្យទាំងស្រុងពីរដ្ឋាភិបាល
- មានអំណាចស៊ើបអង្កេតទូលាយ
- មានធនធានគ្រប់គ្រាន់ និងនីតិវិធីប្តឹងដោយឥតយកថ្លៃ
- ការចូលទៅប្តឹងដោយងាយស្រួល គិតតាមភូមិសាស្ត្រ ដោយមានការិយាល័យមូលដ្ឋាន និងតាមមធ្យោបាយអេឡិចត្រូនិចផងដែរ
- ត្រូវទទួលខុសត្រូវចំពោះមុខសភា និងរាយការណ៍ឱ្យសភា

នៅប្រទេសខ្លះ គេអនុវត្តន៍ការទទួលខុសត្រូវទាំងស្រុងចំពោះមុខសភា ឬក៏ត្រូវរាយការណ៍ឱ្យគណៈកម្មការពិសេសណាមួយរបស់សភា ។

នៅប្រទេស Malte អ្នកសម្រុះសម្រួលគឺជាអ្នកទទួលខុសត្រូវម្នាក់របស់សភា ដែលត្រូវរាយការណ៍តាមរយៈប្រធានសភា ។

នៅប្រទេសអ៊ុយក្រែន ស្នងការសភា (អ្នកសម្រុះសម្រួល) សម្រាប់សិទ្ធិមនុស្សត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខសភា សម្រាប់សិទ្ធិមនុស្សនៅក្នុងប្រទេសទាំងមូល ។ ស្នងការនេះធ្វើការដោយសហការជាមួយគណៈកម្មការមួយចំនួនរបស់សភា យោងទៅតាមពាក្យបណ្តឹង ឬការតវ៉ា ។ ដែនសកម្មភាពរបស់ស្នងការគ្របដណ្តប់ទៅលើសិទ្ធិសេដ្ឋកិច្ច សង្គម និងសិទ្ធិស៊ីវិល ។

នៅប្រទេសណាមីប៊ី អ្នកសម្រុះសម្រួលត្រូវទទួលខុសត្រូវចំពោះគណៈកម្មការពិសេសរបស់សភាដោយមានភារកិច្ចដូចតទៅ

- ពិនិត្យលើរបាយការណ៍ប្រចាំឆ្នាំ ឬរបាយការណ៍ដទៃទៀតដែលដាក់មករដ្ឋសភា ស្របតាមច្បាប់ពាក់ព័ន្ធ និងមុខងារអ្នកសម្រុះសម្រួល ។

- ផ្ទៀងផ្ទាត់ថា សេវារបស់អ្នកសម្រុះសម្រួលត្រូវបានបំពេញដោយត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធភាពនូវមុខងាររបស់ខ្លួន និងផ្តល់អនុសាសន៍សម្រាប់គោលដៅនេះ ។
- គូសបញ្ជាក់ថា រដ្ឋការ ក្រសួង និងទីភ្នាក់ងារសាធារណៈផ្តល់ព័ត៌មានតាមសំណើ និងសហប្រតិបត្តិការជាមួយនឹងសេវារបស់អ្នកសម្រុះសម្រួល ។

**<u>គណៈកម្មការសភាខាងសិទ្ធិមនុស្ស</u>**

នៅប្រទេសខ្លះទៀត អ្នកសម្រុះសម្រួល ឬថ្នាក់ស្មើគ្នានេះត្រូវទទួលខុសត្រូវនៅចំពោះមុខគណៈកម្មការសភាទទួលបន្ទុកខាងសិទ្ធិមនុស្ស ដែលមានសមត្ថកិច្ចការពារ និងលើកគម្រោងសិទ្ធិជាគ្រឹះនៅក្នុងប្រទេសទាំងមូល ។

នៅប្រទេសហ្វីលីពីន គណៈកម្មការសិទ្ធិមនុស្សរបស់សភាតំណាង បានបង្កើតមជ្ឈមណ្ឌលឯកសារស្តីពីសិទ្ធិមនុស្សនៅក្នុងស្ថាប័នមូលដ្ឋានរបស់រដ្ឋ ដោយមានមូលហេតុបណ្តាលមកពីបរិបទដែលមានការតស៊ូប្រដាប់អាវុធ និងបាតុកម្មជាញឹកញាប់ប្រឆាំងទៅនឹងការរំលោភបំពានលើសិទ្ធិមនុស្ស។ មជ្ឈមណ្ឌលឯកសារគឺជាបណ្តាញសម្រាប់ថែរក្សាអភិបាលកិច្ចល្អលើបញ្ហាសិទ្ធិមនុស្ស ។ តាមរយៈសកម្មភាពអប់រំ បណ្តាញនេះធ្វើការជាមួយសាលារៀន និងសាកលវិទ្យាល័យ ព្រមទាំងសាលាយោធា និងនគរបាល ។

នៅប្រទេសប្រេស៊ីល គណៈកម្មការសភាខាងសិទ្ធិមនុស្ស ដែលខ្លួនឯងទទួលពាក្យបណ្តឹងក្នុងករណីមានការរំលោភបំពាន និងផ្តើមការស៊ើបអង្កេត គឺជាអង្គការដ៏សំខាន់មួយសម្រាប់ការត្រួតពិនិត្យទៅលើការគោរពសិទ្ធិមនុស្ស ។ ដោយហេតុថា ប្រទេសប្រេស៊ីលគឺជារដ្ឋសហព័ន្ធ រដ្ឋាភិបាលកណ្តាលមានអំណាចតិចតួចទៅលើរដ្ឋសហព័ន្ធ។ ដូច្នេះគណៈកម្មការសិទ្ធិមនុស្សដោយសហការជាមួយប្រព័ន្ធឃោសនានានា និងសង្គមស៊ីវិល ត្រូវជូនព័ត៌មានពីការរំលោភបំពានកើតមាននៅភូមិភាគផ្សេងៗ និងប្រើឥទ្ធិពលទៅលើរដ្ឋអំណាចពាក់ព័ន្ធឱ្យកែប្រែ ។ ជួនកាលក្នុងករណីខ្លះ សកម្មភាពរបស់គណៈកម្មការនេះជម្រុញឱ្យសភាសហព័ន្ធអនុម័តច្បាប់ដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្សឱ្យបានឆាប់ ។

តាមការសិក្សារបស់សហភាពអន្តរសភា ជាទូទៅ សភាមានការទទួលខុសត្រូវទៅលើបញ្ហាសិទ្ធិមនុស្ស ។ កិច្ចការពារសិទ្ធិជាគ្រឹះរបស់ប្រជាជន គឺជាអង្គការដ៏សំខាន់នៃសកម្មភាពរបស់សភា ហើយកិច្ចការពារគ្របដណ្តប់ទៅលើបុគ្គលទាំងអស់ដែលកំពុងរស់នៅក្នុងដែនដីរបស់ជាតិ ហើយពុំមែនតែជនទាំងឡាយដែលមានលក្ខន្តិកៈជាពលរដ្ឋឡើយ

១- សភាធ្វើច្បាប់ និងកំណត់ក្របខ័ណ្ឌគតិយុត្តិសម្រាប់សិទ្ធិមនុស្សនៅក្នុងក្របខ័ណ្ឌជាតិ ។ សភាអនុម័តសន្ធិសញ្ញាអន្តរជាតិ ហើយធានាថាបទបញ្ញត្តិដែលកំណត់ដោយសន្ធិសញ្ញា ត្រូវបានចែងនៅក្នុងច្បាប់ជាតិ និងត្រូវបានគោរព ។

២- សភាអនុម័តថវិកា និងកំណត់អាទិភាពជាតិ ដូច្នេះត្រូវធានាថា មានមូលនិធិគ្រប់គ្រាន់ត្រូវបានចំណាយទៅលើការគោរពសិទ្ធិមនុស្ស ហើយមូលនិធិទាំងនោះត្រូវបានប្រើប្រាស់ដោយសមស្រប ។

៣- សភាត្រួតពិនិត្យទៅលើសកម្មភាពរបស់រដ្ឋាភិបាល ហើយដូច្នេះត្រូវពិនិត្យមើលជាបន្តបន្ទាប់ទៅលើគោលនយោបាយ និងសេចក្ដីសម្រេចផ្សេងៗរបស់រដ្ឋាភិបាល ធានាថារដ្ឋាភិបាល រដ្ឋការ និងសេវាផ្សេងទៀតរបស់រដ្ឋគោរពតាមកាតព្វកិច្ចអំពីសិទ្ធិមនុស្ស ។

៤- សភារចនាមតិសាធារណៈ និងរួមវិភាគទានដើម្បីដាក់តាំងនូវវប្បធម៌គោរពសិទ្ធិមនុស្សនៅក្នុងប្រទេសរបស់ខ្លួន ។

## ការចូលរួមរបស់ប្រជាជនក្នុងដំណើរការធ្វើច្បាប់

ការចូលរួមដោយផ្ទាល់របស់ប្រជាជនក្នុងការងារធ្វើច្បាប់ មានរូបភាពជាច្រើន

- ជាញឹកញាប់ សមាជិកសភាអញ្ជើញប្រជាពលរដ្ឋឱ្យចូលរួមផ្ដល់យោបល់របស់ខ្លួន ឬផ្ដល់ភ័ស្ដុតាងចំពោះមុខគណៈកម្មការនីតិកម្ម ។
- ការរៀបចំនូវសវនាការសាធារណៈ ដើម្បីស្ទាបស្ទង់មតិរបស់ភាគីពាក់ព័ន្ធទៅលើច្បាប់ដែលកំពុងរៀបចំ គឺជាប្រពៃណីរបស់សភាតាំងពីបុរាណកាល ។ ការអនុវត្តបែបនេះក្លាយជាទូទៅ និងមានជាប្រព័ន្ធបំផុត ។

## ការទាក់ទាញឱ្យគណៈកម្មការយកចិត្តទុកដាក់នឹងសវនាការសាធារណៈ

ការចូលរួមរបស់ប្រជាពលរដ្ឋដោយផ្ទាល់ក្នុងការងារធ្វើច្បាប់ មានសារសំខាន់សម្រាប់លទ្ធិប្រជាធិបតេយ្យ ។

ជាឧទាហរណ៍នៅប្រទេសនូវែលហ្សេឡងដ៏ ដែលអនុញ្ញាតឱ្យប្រជាពលរដ្ឋចូលអន្តរាគមន៍នៅក្នុងការរៀបចំការធ្វើច្បាប់ ដែលកំណត់ជីវភាពរបស់ពួកគេ ។ ការចូលរួមនេះធ្វើឡើងតាមរយៈគណៈកម្មការនានារបស់សភាតំណាង ដែលទទួលនូវពាក្យបណ្ដឹង និងសំណើរបស់ប្រជាពលរដ្ឋ ។ ប្រព័ន្ធនៃការរួមវិភាគទានដល់សេចក្ដីព្រាងច្បាប់នេះ គឺជាអង្គធាតុមួយដ៏សំខាន់នៃដំណើរការរបស់សភា និងជីវភាពប្រជាធិបតេយ្យរបស់ប្រទេស ។ ប្រជាពលរដ្ឋត្រូវបានទទួលស្គាល់ចំពោះការស៊ើបអង្កេតរបស់សភា និងបញ្ហាដទៃទៀតដែលបាន

ដាក់មកគណៈកម្មការនានា ។ ប្រជាពលរដ្ឋមានលទ្ធភាពបញ្ចេញទស្សនៈលើគ្រប់បញ្ហា និងជាយថាហេតុជម្រុញឱ្យមានអត្ថបទច្បាប់ថ្មី ។

គេអាចរៀបចំដំណើរការចូលរួមរបស់ប្រជាពលរដ្ឋតាមរបៀបជាច្រើន ។ សភានូវែលហ្សេឡង់ដ៏អញ្ជើញជាបន្តបន្ទាប់នូវគ្រប់ភាគីពាក់ព័ន្ធជាបុគ្គល ឬជាសមូហភាព ឱ្យធ្វើសំណើនៅក្នុងសារព័ត៌មាន និងប្រព័ន្ធឃោសនាដទៃទៀត រួមទាំងក្នុងគេហទំព័ររបស់សភា ។

សភាដទៃទៀតចាត់ទុកសមាគមរបស់ប្រជាពលរដ្ឋ ឬអង្គការ NGo ដែលមានជំនាញនៅក្នុងបញ្ហា ឬវិស័យដោយឡែកជារចនាសម្ព័ន្ធដែលមានសមត្ថភាពបំផុត ឱ្យបញ្ជូននូវទស្សនៈរបស់សង្គមស៊ីវិល ។ ហេតុនេះហើយបានជាសភាអញ្ជើញជាពិសេសនូវគណៈកម្មការ ដែលទំនងថាពាក់ព័ន្ធនឹងអត្ថបទច្បាប់នោះ ឬតាមរយៈការស៊ើបអង្កេតកំពុងធ្វើឡើង ឱ្យធ្វើសំណើឡើង ។

នេះគឺជាវិធីដែលសភាទូរគីបានធ្វើកាលពីឆ្នាំ ២០០៤ ក្នុងពេលមានការពិគ្រោះយោបល់លើការកែប្រែក្រមព្រហ្មទណ្ឌ ។

រដ្ឋសភាសាធារណរដ្ឋឆេក រៀបចំសវនាការសាធារណៈរបស់តំណាងវិស័យវិជ្ជាជីវៈ និងរបស់ប្រជា-ពលរដ្ឋពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់ ។

សាធារណរដ្ឋ Macédoine មានការិយាល័យទំនាក់ទំនងសម្រាប់អង្គការ NGo នៅក្នុងសភា ដើម្បីជម្រុញការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងការងារនីតិកម្ម ។ ការិយាល័យនេះត្រួតពិនិត្យមើលផងដែរលើភាពតំណាង និងលក្ខន្តិកៈរបស់សមាគមរបស់ប្រជាពលរដ្ឋ ។

សភាដទៃទៀតចុះបញ្ជីផ្លូវការនូវអង្គការ NGo និងក្រុមដទៃទៀតដែលគួរចាប់អារម្មណ៍ នៅក្នុងគោលបំណងដូចគ្នានេះដែរ តែថែមទាំងធានាថា ក្រុមងាយរងគ្រោះត្រូវបានគិតគូរនៅក្នុងនីតិវិធីពិគ្រោះយោបល់ ។ ការរៀបចំទាំងនេះអាចមានទម្រង់ជាស្ថាប័ន ។

សភាបេឡារុស, ស្លូវានី និងទុយនីស៊ី បានបង្កើតក្រុមប្រឹក្សាពិគ្រោះយោបល់របស់តំណាងអង្គការ NGO និងអ្នកជំនាញឯកទេសដទៃទៀត ដែលប្រចាំនៅអមគណៈកម្មការជំនាញមួយចំនួន ។

ប្រទេស Lettonie និងMali បានផ្តើមកិច្ចសហប្រតិបត្តិការជាអចិន្ត្រៃយ៍ជាមួយភាគីពាក់ព័ន្ធ ដើម្បីកែលំអការងារធ្វើច្បាប់ ។

ប្រទេសហុងគ្រី បានបើកការិយាល័យប្រជាពលរដ្ឋមួយនៅក្នុងរដ្ឋសភានាឆ្នាំ ២០០២ ដែលមានបន្ទុករៀបចំកិច្ចសន្ទនារវាងប្រជាពលរដ្ឋ និងរដ្ឋសភា នៅក្នុងក្របខ័ណ្ឌនៃដំណើរការធ្វើច្បាប់ ។

សភាIslande បានជ្រើសរើសរណសិរ្សពីរដោយស្នើសុំយោបល់ពីក្រុមផលប្រយោជន៍ អង្គការNGO និងសមាគមផ្សេងៗ និងពីប្រជាពលរដ្ឋផ្ទាល់ផង ។

សភានៃសាធារណរដ្ឋ Moldova ចុះផ្សព្វផ្សាយសេចក្តីព្រាងច្បាប់សំខាន់ៗក្នុងគេហទំព័រ ដើម្បីអូសទាញសង្គមស៊ីវិល និងប្រជាពលរដ្ឋឱ្យចូលរួមផ្តល់យោបល់ ។

**បញ្ហាដទៃទៀតដែលគួរយកចិត្តទុកដាក់**

បញ្ហាដែលគួរយកចិត្តទុកដាក់ គឺពាក់ព័ន្ធនឹងការចូលរួមរបស់អង្គការរបស់ប្រជាពលរដ្ឋ និងអង្គការ NGO នៅក្នុងដំណើរការធ្វើច្បាប់ ។

បញ្ហាសំខាន់បំផុត គឺក្នុងកំរិតប៉ុណ្ណាដែលអង្គការទាំងនោះជាតំណាងពិតប្រាកដរបស់មណ្ឌលណាមួយ ឬផលប្រយោជន៍សង្គមរបស់ប្រជាជន ។ តើអង្គការទាំងនេះឯករាជ្យពិតប្រាកដ និងមានតម្លាភាព ស្វ័យចាត់ចែង ឬក៏អង្គការទាំងនេះគ្រាន់តែត្រូវបានដឹកនាំពីចំងាយ និងផ្តល់ហិរញ្ញប្បទានដោយរដ្ឋាភិបាល? សំណួរទីពតើអង្គការទាំងនោះមានឥទ្ធិពលត្រឹមកំរិតណា ដោយខ្លាចថា អង្គការខ្លះខ្លាំងក្លា និងទទួលហិរញ្ញប្បទានច្រើនអាចមានឥទ្ធិពលហួសហេតុទៅលើដំណើរការធ្វើច្បាប់ ។

កង្វល់ទាំងនេះបង្ហាញថា សភាត្រូវធ្វើច្បាប់ដើម្បីរៀបចំក្របខ័ណ្ឌតម្លាភាពសមស្របសម្រាប់ដំណើរការដោយល្អរបស់អង្គការនៃសង្គមស៊ីវិល ។ ជាឧទាហរណ៍ វិស័យស្ម័គ្រចិត្ត និងសកម្មភាពគ្មានកំរៃ មានការចុះបញ្ជីសាធារណៈនូវរាល់អង្គការដែលធ្វើការងារឡបប៊ីសភា (កត់ត្រាឈ្មោះសមាជិក និងប្រភពនៃចំណូល) ។

សភាអាចធានាថា ការប្រាស្រ័យឆ្លើយឆ្លងចេញមកពីសង្គមស៊ីវិលឆ្លងកាត់តាមផ្លូវផ្លូវការ ហើយខ្លឹមសាររបស់វាត្រូវបានផ្សព្វផ្សាយជាសាធារណៈ ។

ជាឧទាហរណ៍នៅសភា Bubdestag Allemand មានបទបញ្ជាដែលបញ្ជាក់ច្បាស់ថា ក្រុមទាំងឡាយដែលចង់ឱ្យតម្លៃ ឬការពារនូវផលប្រយោជន៍របស់ខ្លួនចំពោះមុខសភា ត្រូវចុះនូវសំណើរបស់ខ្លួននៅក្នុងបញ្ជីផ្លូវការរបស់សភា ។

សភាប៉ូឡូញកំពុងសិក្សាសេចក្តីព្រាងច្បាប់ស្តីពីការឡបប៊ី ដោយកំណត់ថាជាសកម្មភាពត្រូវធ្វើនៅក្នុងក្របខ័ណ្ឌច្បាប់ ដើម្បីឱ្យអំណាចសាធារណៈយកចិត្តទុកដាក់ពិចារណាលើទឡ្ហីករណ៍ និងផលប្រយោជន៍របស់ក្រុមសង្គម ឬក្រុមវិជ្ជាជីវៈដោយឡែក កំណត់អំពីមធ្យោបាយដែលអាចប្រើប្រាស់បាន ដើម្បីសាកល្បងជះឥទ្ធិពលទៅលើសេចក្តីសម្រេចរបស់អាជ្ញាធរ និងដាក់តាំងនូវយន្តការត្រួតពិនិត្យទៅលើការឡបប៊ី ។

## ជួយប្រជាពលរដ្ឋឱ្យគេទទួលស្តាប់

វាពុំគ្រប់គ្រាន់ឡើយត្រឹមតែរារាំងក្រុមផលប្រយោជន៍ដ៏ខ្លាំងក្លាកុំឱ្យមានតួនាទីគ្របដណ្តប់ វាចាំបាច់ត្រូវអនុញ្ញាតឱ្យប្រជាពលរដ្ឋធម្មតាត្រូវបានគេទទួលស្តាប់នូវសម្លេងរបស់ពួកគាត់ ។ សម្រាប់កិច្ចការនេះ ត្រូវផ្សព្វផ្សាយជាមុននូវកាលបរិច្ឆេទនៃសវនាការសាធារណៈ និងកិច្ចប្រជុំរបស់គណៈកម្មការនានា ។ ត្រូវណែនាំប្រជាពលរដ្ឋអំពីរបៀបទាក់ទងនឹងគណៈកម្មការ ដើម្បីឱ្យគេយកមកពិចារណា ។

សភានូវែលហ្សេឡង់ដ៏បានបោះពុម្ពផ្សាយនូវសេចក្តីណែនាំ ដើម្បីឱ្យអ្នកលើកសំណើចេះបង្ហាញសំណើដើម្បីងាយអាន និងងាយយល់ដោយសមាជិករបស់គណៈកម្មការ ។ ធ្វើរបៀបនេះប្រជាពលរដ្ឋមានសំណាងច្រើនអាចឱ្យគេទទួលស្តាប់ ហើយអនុសាសន៍ ឬយោបល់របស់ពួកគេមានឥទ្ធិពលទៅលើគណៈកម្មការ ។

កំណត់បង្ហាញនេះមានប្រយោជន៍ តែធ្វើបានលុះណាតែយល់អំពីរបៀបធ្វើការរបស់គណៈកម្មការ ។

សភា Afrique du Sud បានលើកឡើងថា អ្នកក្រ និងអ្នកអនាថាមានការលំបាកបំផុតដើម្បីឱ្យអ្នកធ្វើច្បាប់ទទួលស្តាប់បាន ។ ដូច្នេះសម្លេងរបស់អ្នកខ្លាំងត្រូវបានគេទទួលស្តាប់ ក្នុងពេលដែលប្រជាជនភាគច្រើននៅស្ងប់ស្ងៀម ដែលជាទណ្ឌកម្មដោយកាលៈទេសៈប្រវត្តិសាស្ត្រ ។

ចំពោះសំណូមពរចំពោះគណៈកម្មការនានា មានឧបសគ្គជាច្រើន

- ពេលវេលា កាតព្វកិច្ចរបស់អ្នកក្រីក្រមានច្រើន ពួកគេពុំអាចចូលរួមសកម្មភាពណាបានឡើយក្រៅពីសកម្មភាពចាំបាច់សម្រាប់ការរស់រានមានជីវិត និងការបំពេញកង្វះខាត ។
- ការទាក់ទងនឹងប្រព័ន្ធឃោសនា នេះជាល័ក្ខខ័ណ្ឌមួយចាំបាច់សម្រាប់ការចូលរួមក្នុងជីវភាពសាធារណៈ ។ ភាគនៃប្រជាជនដែលអនាថា គឺជាអ្នកក្រីក្រ អ្នកជនបទទទួលការអប់រំតិចតួច ។
- ការខ្វះមធ្យោបាយដឹកជញ្ជូន វាមិនងាយស្រួលជានិច្ចឡើយ ដើម្បីភាគនៃប្រជាជននេះបង់ប្រាក់សម្រាប់ការដឹកជញ្ជូនទៅកាន់សភា ។
- វិសមភាពខ្លាំងក្លាក្នុងវិស័យអប់រំ ល័ក្ខខ័ណ្ឌដទៃទៀតដើម្បីឱ្យប្រជាពលរដ្ឋទទួលបានព័ត៌មាន និងសកម្ម គឺប្រជាជននោះត្រូវតែចេះអក្សរ ។
- ភាពចម្រុះខាងភាសា ការជ្រើសរើសនូវភាសាផ្លូវការ និងសាមញ្ញមានសារសំខាន់បំផុត ។ ប្រការនេះនាំឱ្យប្រជាពលរដ្ឋទទួលបានព័ត៌មាន និងចូលរួមក្នុងជីវភាពសាធារណៈ មានមធ្យោបាយជាច្រើនដើម្បីបន្ថយការលំបាក ដូចជាការចែកចាយធនធានឱ្យក្រុមជនអនាថា ដើម្បីពួកគេអាចទទួលស្តាប់នូវយោបល់ និងចូលរួមក្នុងសវនាការ ។

ការរៀបចំការប្រជុំគណៈកម្មការនៅតាមខេត្ត និងការរៀបចំសភារបស់ប្រជាជន។ តែដំណោះស្រាយទាំងនេះត្រូវបង់ថ្លៃខ្ពស់ ហើយវិសមភាពខាងឥទ្ធិពលនៅតែច្រើនដដែល ។

ប្រទេសដទៃទៀត បានជ្រើសរើសរៀបចំសវនាការសាធារណៈលើសេចក្តីព្រាងច្បាប់នៅគ្រប់សង្កាត់ ដោយធានាថា ការពិភាក្សាមានលក្ខណៈមិនផ្លូវការ ហើយសក្ខីកម្មជាសាក្សីត្រូវបាននិយាយដោយផ្ទាល់មាត់ បន្ទាប់មកគេប្រមូលផ្តុំដើម្បីបញ្ជូនទៅឱ្យគណៈកម្មការសភាពាក់ព័ន្ធ ។

ដើម្បីជម្រុញការចូលរួមរបស់ប្រជាពលរដ្ឋ សភាតំណាងហ្វីលីពីនរៀបចំសវនាការសាធារណរដ្ឋនៅតាមខេត្ត រហូតដល់ឃុំនៅដាច់ស្រយាល ដើម្បីឱ្យគ្រប់មណ្ឌល គ្រប់មុខសញ្ញា និងក្រុមផលប្រយោជន៍មានលទ្ធភាពឱ្យគេបានទទួលស្តាប់ និងផ្តល់យោបល់របស់ខ្លួនទៅលើបញ្ហាធ្វើច្បាប់ ។

រដ្ឋសភា Saint-Kitts ដាក់សេចក្តីព្រាងច្បាប់ឱ្យសាធារណៈបានដឹង ដើម្បីឱ្យប្រជាពលរដ្ឋចូលរួមពិនិត្យ និងធ្វើអត្ថាធិប្បាយបន្ទាប់ពីការពិនិត្យជាលើកទី១(Première Lecture)ហើយមតិរបស់ប្រជាពល-រដ្ឋត្រូវយកមកពិចារណា នាការពិនិត្យលើកទី២ និងលើកទី៣ (Seconde et Troisième lectures) ។

**<u>វេទិកា ឬការប្រជុំសាធារណៈ</u>**

នៅប្រទេសខ្លះ ការចូលរួមរបស់សង្គមស៊ីវិលក្នុងការងារសភា មានរូបភាពជាវេទិកា ឬការប្រជុំសាធារណៈដូចជា ឧទាហរណ៍នៅប្រទេសលីបង់ និងប្រទេសរុស្ស៊ី ។

សភារបស់ប្រជាជនគឺជាស្ថាប័នមួយដែលមានគោលដៅដូចគ្នា ទោះបីជាទូទៅគេប្រជុំតែម្តងក្នុងមួយឆ្នាំក្តី ។ នៅប្រទេស Afrique de Sud ការប្រជុំសភារបស់ប្រជាជនជាលើកទី១ ប្រព្រឹត្តទៅនៅឆ្នាំ ២០០៤ ក្នុងឱកាសខួបលើកទី១០ នៃលទ្ធិប្រជាធិបតេយ្យ ។ អ្នកតំណាងដែលបានទទួលការអញ្ជើញមាន ៦០នាក់ មកពីមុខសញ្ញា ៥ គឺ : យុវជន ជនពិការ នារី អ្នកទទួលផលពីកំណែទម្រង់ខាងកសិកម្ម និងពលករ ។ ពួកគេពិចារណាទៅលើច្បាប់ស្តីពីសិទ្ធិមនុស្ស និងរដ្ឋធម្មនុញ្ញទៅលើជីវិតរបស់ពួកគេ និងការធ្វើកំណែទម្រង់ឱ្យបានលឿននៅក្នុងវិស័យរបស់ពួកគេ ។ ការប្រជុំត្រូវផ្សព្វផ្សាយជាសាធារណៈ និងទទួលបាននូវការគាំទ្រឱ្យរៀបចំប្រជុំជារៀងរាល់ឆ្នាំ ។

**<u>អង្គធាតុដែលអនុគ្រោះឱ្យពង្រីកការចូលរួមរបស់ប្រជាពលរដ្ឋ</u>**

ដើម្បីពង្រីងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការងារធ្វើច្បាប់ និងសកម្មភាពដទៃទៀតរបស់គណៈ-កម្មការនានា ត្រូវមានអង្គធាតុដូចតទៅ

- បញ្ជីសាធារណៈមួយអំពីអង្គការ NGO និងសមាគមផ្សេងទៀតតាមវិស័យជាផលប្រយោជន៍ តែក៏តាមលំដាប់អក្សរផងដែរ ។
- បញ្ជីដូចគ្នាអំពីអ្នកឯកទេស ។
- ការផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាពនៅក្នុងប្រព័ន្ធឃោសនាផ្សេងៗ កាលបរិច្ឆេទ និងពេលម៉ោងប្រជុំពិនិត្យសេចក្តីព្រាងច្បាប់ ការស៊ើបអង្កេត សវនាការសាធារណៈ.... ។ល ។
- អញ្ជើញអង្គការ និងអ្នកឯកទេសពាក់ព័ន្ធឱ្យលើកសំណើ ឬផ្តល់សាក្សី ។
- នីតិវិធីដើម្បីទាក់ទងទៅគណៈកម្មការដោយប្រជាពលរដ្ឋជាបុគ្គល ។
- មគ្គុទ្ទេសក៏ណែនាំ ឬកម្មវិធីបណ្តុះបណ្តាលដើម្បីឱ្យចេះលើកសំណើ ឬចេះផ្តល់សាក្សីនៅមុខគណៈកម្មការរបស់សភា ។
- បញ្ជីសាធារណៈតាមគេហទំព័រអំពីសំណូមពរ និងសំណើដែលបានបញ្ជូនមក ។
- សវនាការសាធារណៈនៅតាមមជ្ឈមណ្ឌលមូលដ្ឋាន ដោយមានរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីសក្តិកម្ម និងការដាក់បណ្តឹង ។

## នារី និងការងារធ្វើច្បាប់ ឧទាហរណ៍មួយនៃកិច្ចសហប្រតិបត្តិការរវាងអង្គការ NGO និងសភា

នារី និងសមាគមនារី គឺជាឧបករណ៍ដ៏ប្រសើរមួយអំពីកិច្ចសហប្រតិបត្តិការរវាងអង្គការ NGO និងសភា ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។ នារីដោយមានចំនួនកាន់តែច្រើននៅក្នុងសភា តែងប្រើប្រាស់ទំនាក់ទំនងរបស់ខ្លួនជាមួយអង្គការ NGO នារី ដើម្បីជម្រុញឱ្យមានច្បាប់ជឿនលឿន ។

នៅក្នុងក្របខ័ណ្ឌនៃកម្មវិធីបណ្តុះបណ្តាល និងព័តិមានរបស់ខ្លួន រដ្ឋសភា Afrique du Sud រៀបចំសិក្ខាសាលាសម្រាប់នារីមកពីតំបន់ជនបទ ដើម្បីពន្យល់ពួកគេ ព្រមទាំងប្រធានសហគមន៍មូលដ្ឋានអំពីដំណើរការរបស់សភា និងដំណើរការធ្វើច្បាប់ ។ ការប្រជុំការងារអនុញ្ញាតឱ្យទទួលបាននូវសំណើផ្សេងៗទៅលើសេចក្តីព្រាងច្បាប់ដែលបានដាក់មកសភា ព្រមទាំងការដាក់អនុវត្តន៍នូវច្បាប់ជាធរមាន ជាពិសេសច្បាប់ស្តីពីអំពើហឹង្សាក្នុងគ្រួសារ ឆ្នាំ ១៩៩៨ ព្រមទាំងលើវិសោធនកម្មទៅលើច្បាប់ស្តីពីការទទួលស្គាល់អាពាហ៍ពិពាហ៍តាមប្រពៃណី ។

សភាខ្លះបានបង្កើតនូវទម្រង់ជាស្ថាប័នអចិន្ត្រៃយ៍សម្រាប់ទំនាក់ទំនងរវាងអង្គការ NGO នារី និងគណៈកម្មការសភាពាក់ព័ន្ធដូចជា គណៈកម្មការសិទ្ធិមនុស្ស គណៈកម្មការសមភាព ឬគណៈកម្មការនារី ។

នៅប្រទេសម៉ិចស៊ិច សភានារីម៉ិចស៊ិកដែលរួមមានអ្នកធ្វើច្បាប់សហព័ន្ធ និងមូលដ្ឋាន និងនារីក្នុងសង្គមស៊ីវិលក្នុងប្រទេសទាំងមូល តែងកោះប្រជុំមួយឆ្នាំម្តងតាំងពីឆ្នាំ ១៩៩៨ ។ សភានេះមានគោលបំណងដឹកនាំការងារធ្វើច្បាប់អំពីសមភាពរវាងបុរស និងនារី នៅគ្រប់កំរិតនៃការគ្រប់គ្រង និងលើគ្រប់វិស័យនៃជីវភាពសង្គម និងសេដ្ឋកិច្ច ។

## ថវិកាសម្រាប់សមភាពរវាងបុរស និងនារី

កិច្ចសហប្រតិបត្តិការរវាងអង្គការ NGO នារី និងសមាជិកសភា អនុគ្រោះនៅក្នុងប្រទេសជាច្រើននាំឱ្យមានការគិតគូរដល់ថវិកាសម្រាប់សមភាពរវាងបុរស និងនារី ។ ដំណើរការថវិកានេះនាំឱ្យមានការវិភាគជាប្រព័ន្ធអំពីសំណើ និងលទ្ធផល ដើម្បីកំណត់បានអំពីផលប៉ះពាល់តាមភេទ ។ ការវិភាគទាំងនេះ ជាញឹកញាប់នាំឱ្យឃើញថានារីតែងបាត់ប្រយោជន៍ ដោយពុំត្រឹមតែបណ្តាលមកពីការផ្ទេរថវិកាតិចសម្រាប់នារីប៉ុណ្ណោះទេ តែដោយការកាត់បន្ថយច្បាស់ ជាឧទាហរណ៍សម្រាប់ការចំណាយខាងវិស័យកសិកម្មដែលធ្វើឱ្យកសិករក្រីក្ររងគ្រោះ និងកាត់បន្ថយចំណូលរបស់ពួកគេ ។

ប្រទេស Afrique du Sud បានបង្កើតនាឆ្នាំ១៩៩៥ នូវគំនិតផ្តួចផ្តើមខាងថវិកាសម្រាប់នារី ។ នេះជាលទ្ធផលនៃសម្ព័ន្ធភាពរវាងអង្គការ NGO ពីរ និងសមាជិកាសភាដែលមោះមុតចំពោះបុព្វហេតុនេះ ។ អង្គការ NGO ទទួលបន្ទុកធ្វើការងារស្រាវជ្រាវ និងវិភាគ ដែលសភាខ្លួនឯងពុំអាចធ្វើបានអាស្រ័យដោយខ្វះមធ្យោបាយ ។ សមាជិកាសភាប្រើឥទ្ធិពលទៅលើអ្នកទទួលខុសត្រូវរបស់រដ្ឋាភិបាល ដើម្បីឱ្យថវិកាក្រសួងនានាមានសមធម៌សម្រាប់នារី ។

សាធារណរដ្ឋ Tanzanie និងប្រទេស Ouganda ដែលបានអនុម័តយកប្រភេទថវិកាបែបនេះ ខិតខំធ្វើឱ្យសេវាដែលផ្តល់ហិរញ្ញប្បទានដោយមូលនិធិជាតិ ត្រូវធានាឱ្យបានសមធម៌នៅកំរិតមូលដ្ឋាន ។

ជាទូទៅ បទពិសោធន៍បង្ហាញថា ថវិកាសមធម៌សម្រាប់នារីក៏បំរើដល់បុរសផងដែរ ជាឧទាហរណ៍ដោយកាត់បន្ថយការខ្ជះខ្ជាយ និងការខ្វះខាតនៅក្នុងអំណាចសាធារណៈ និងនីតិវិធីសភានៅក្នុងការត្រួតពិនិត្យថវិកា ។

បច្ចុប្បន្ននេះមានប្រទេសកំពុងអភិវឌ្ឍន៍ជាង ២០ប្រទេស និងប្រទេសអភិវឌ្ឍន៍ជាច្រើនកំពុងអនុវត្តន៍កម្មវិធីកសាងថវិកាដោយគោរពតាមសមភាពរវាងបុរស និងនារី ។

## ការចូលរួមរបស់ប្រជាពលរដ្ឋតាមរយៈគណបក្សនយោបាយ

ការយកចិត្តទុកដាក់របស់ពិភពលោកបច្ចុប្បន្នទៅលើសង្គមស៊ីវិល និងអង្គការ NGO ពុំត្រូវធ្វើឱ្យយើងភ្លេចដល់របៀបជាប្រពៃណីរបស់ប្រជាពលរដ្ឋ ដែលរហូតមកដល់ពេលនេះបានចូលរួមដល់ជីវភាពនយោបាយ ការចូលជាសមាជិកនៃគណបក្សណាមួយនោះ ។ ជាសមាជិកនៃគណបក្សមួយ ឥទ្ធិពលរបស់ពួកគេប្រព្រឹត្តឡើងតាមរបៀបជាច្រើន តាមការជ្រើសរើសបេក្ខជន ឬក្នុងពេលបោះឆ្នោតជ្រើសតាំងមន្ត្រីដឹកនាំរបស់គណបក្ស ដោយភ្ជាប់ទំនាក់ទំនងជាមួយតំណាងមូលដ្ឋាន ឬស្រុក ឬក៏ចូលរួមក្នុងសន្និសីទ ឬការប្រជុំតំបន់ ឬជាតិរបស់គណបក្ស ។

នៅក្នុងប្រទេសប្រជាធិបតេយ្យខាងលិចភាគច្រើន ចំនួនអ្នកចូលជាសមាជិកគណបក្សកាន់តែថយចុះ។ គេតែងឃើញនូវផលវិបាកនៃការស្រកចុះនៃលទ្ធិប្រជាធិបតេយ្យនៅក្នុងគណបក្សផងដែរ ដែលបង្ហាញតាមរយៈការធ្វើបាបទៅលើអ្នកទាំងឡាយណា ដែលពុំឯកភាពជាផ្លូវការជាមួយខ្សែបន្ទាត់របស់ថ្នាក់ដឹកនាំ ។ គណបក្សនយោបាយត្រូវបង្ខំជានិច្ច ចាត់ចែងការបែកបាក់គ្នាខាងមនោគមវិជ្ជាជាដុំកំភួនរវាងសមាជិកសកម្ម និងអ្នកបោះឆ្នោត ដែលការគាំទ្រវាចាំបាច់បំផុតដើម្បីទទួលជោគជ័យនៅក្នុងការបោះឆ្នោត ជាពិសេសយុវវ័យជំនាន់ក្រោយ ។

នៅក្នុងក្របខ័ណ្ឌពិភពលោក ឧទាហរណ៍របស់គណបក្សនយោបាយដែលចេះកែប្រែខ្លួនឡើងវិញ មានតែមួយឬពីរប្រទេសប៉ុណ្ណោះក្នុងមួយតំបន់ ជាញឹកញាប់ក្នុងឱកាសនៃយុទ្ធនាការប្រាកដប្រជា ។ តែដោយសារសំខាន់របស់គណបក្សនៅក្នុងដំណើរការតំណាងនោះ ការធ្វើជាថ្មីឡើងវិញឱ្យបានជាទូទៅ និងល្អប្រសើរនូវមូលដ្ឋានប្រជាធិបតេយ្យរបស់គណបក្សនយោបាយ នៅត្រូវរង់ចាំតទៅទៀត ។

## គំនិតផ្តួចផ្តើមរបស់ពលរដ្ឋ និងប្រជាមតិ

ដើម្បីបង្កិតសភាឱ្យទៅជិតប្រជាពលរដ្ឋ ប្រទេសជាច្រើនបានផ្តល់ឱ្យប្រជាពលរដ្ឋនូវសិទ្ធិផ្តួចផ្តើមគំនិត ឬក៏ប៉ងប្រាថ្នាចង់ឱ្យប្រជាពលរដ្ឋមាននូវសិទ្ធិនោះ ។ ដូច្នេះប្រជាពលរដ្ឋអាច

- លើកសំណើដោយខ្លួនឯងដោយផ្ទាល់នូវសេចក្តីស្នើច្បាប់ ។
- កែប្រែ ឬផ្តល់យោបល់លើអត្ថបទច្បាប់ដែលដាក់មកសភា ។

ដូច្នេះអាចមាន ២ រូបភាព

- ការចូលរួមរបស់ប្រជាពលរដ្ឋក្រោមរូបភាព គំនិតផ្តួចផ្តើម ។
- ប្រតិកម្មទៅលើសេចក្តីព្រាងច្បាប់ ។

កាលណាប្រទេសណាមួយមានបទបញ្ញត្តិដើម្បីបង្ខិតសភាឱ្យទៅក្បែរសង្គមស៊ីវិល បទបញ្ញត្តិនោះតែងនាំដល់ការលើកសំណើឱ្យមានសេចក្តីព្រាងច្បាប់ថ្មី ឬក៏ការកែប្រែនូវច្បាប់ជាធរមាន ដែលអាចចាត់ទុកថាជាទម្រង់នៃការផ្តួចផ្តើមរបស់ប្រជាពលរដ្ឋ ។

ដូចគ្នានេះដែរ កាលណាសភារៀបចំនូវវេទិកាសាធារណៈទៅលើកម្មវត្ថុអ្វីមួយ ឬចាប់ផ្តើមស៊ើបអង្កេតទៅលើបញ្ហាពិសេសដើម្បីរៀបចំកសាងច្បាប់ នេះគឺជាការអនុវត្តជាធម្មតា ។

ប៉ុន្តែការផ្តួចផ្តើមគំនិតរបស់ប្រជាពលរដ្ឋ គឺជាសិទ្ធិពិសេស និងការដាក់ប្រតិបត្តិនូវសិទ្ធិនេះ ចាំបាច់ត្រូវមានចំនួនហត្ថលេខាជាអប្បបរិមាមួយនៃអ្នកបោះឆ្នោត ។

គំនិតផ្តួចផ្តើមរបស់ប្រជាពលរដ្ឋមានតម្លៃពិគ្រោះយោបល់ ឬចាប់បង្ខំសម្រាប់សភា ។ ម្យ៉ាងទៀតវាអាចនាំទៅដល់ការធ្វើប្រជាមតិ ។

ជាឧទាហរណ៍ ប្រទេសស្វីសជាប្រទេសដែលគេស្គាល់ថា គាំទ្រជានិច្ចដល់គំនិតផ្តួចផ្តើមរបស់ប្រជាពលរដ្ឋ ។ មុនឆ្នាំ ១៩៧០ សិទ្ធិនេះត្រូវបានអនុវត្តនម្តងម្កាល ។ តែចាប់ពីឆ្នាំ ១៩៧៤ ដល់ឆ្នាំ ១៩៩៣ មានការធ្វើប្រជាមតិចំនួន ១៦៧លើក ក្នុងនោះ ៦៣លើក ជាគំនិតផ្តួចផ្តើមវិជ្ជមានលើកស្នើឡើងដោយក្រុមប្រជាពលរដ្ឋ ។ គេហៅថា គំនិតផ្តួចផ្តើមអវិជ្ជមាន គឺគំនិតផ្តួចផ្តើមឱ្យមានប្រជាមតិអវិជ្ជមាន ឬវេតូចំពោះសេចក្តីព្រាងច្បាប់ដែលបានដាក់មកសភា ។ ប្រការដែលមានប្រជាមតិច្រើនលើក អាស្រ័យដោយការកកើតនូវក្រុមជំនាញ ដែលមានសមត្ថភាពប្រមូលហត្ថលេខាប្រជាពលរដ្ឋនៅក្នុងក្របខ័ណ្ឌប្រទេសទាំងមូល ។

ប្រទេសអឺរ៉ុបមួយទៀតដែលមានប្រពៃណីធ្វើប្រជាមតិលើច្បាប់ (Référendum legislative) គឺប្រទេសអ៊ីតាលី ។ មាត្រា ៧៥នៃរដ្ឋធម្មនុញ្ញអនុញ្ញាតឱ្យធ្វើប្រជាមតិដើម្បីវេតូ ឬកែច្បាប់ ក្រោមល័ក្ខខ័ណ្ឌយ៉ាងតិចមានហត្ថលេខា ៥០០,០០០នាក់ និងការយល់ព្រមពីតុលាការធម្មនុញ្ញ ។ ទោះបីមានក្របខ័ណ្ឌបែបនេះក្តី សិទ្ធិនេះក៏អាចចាត់ទុកថាជាគំនិតផ្តួចផ្តើមវិជ្ជមានបានដែរ ព្រោះវាអនុវត្តន៍ទៅលើច្បាប់ជាធរមាន ហើយកាលណាគេកែច្បាប់ចាស់ទាំងមូល ឬដោយផ្នែក គេសម្រេចនូវការកែប្រែដ៏សំខាន់ ។

## **<u>ហេតុការណ៍ថ្មីៗនេះ</u>**

សភា Slovènie មានយន្តការអនុញ្ញាតឱ្យរៀបចំធ្វើប្រជាមតិ តាមសំណើមួយភាគបីនៃសមាជិកក្រុមប្រឹក្សាជាតិ ឬក៏អ្នកបោះឆ្នោតចំនួន ៤០០,០០០នាក់ ។

នៅក្នុងប្រទេសផ្សេងទៀត សភាពុំមានសិទ្ធិអនុម័តច្បាប់ឡើយ ប្រសិនបើប្រជាមតិកំពុងធ្វើឡើង ។

សភាខ្លះទៀតចាត់ទុកប្រជាមតិជាការគ្រប់គ្រាន់ដើម្បីមោឃភាពសេចក្ដីព្រាងច្បាប់ដែលបានអនុម័ត (ដូចជាប្រទេសអ៊ីតាលី និង Suisse) ។

បទបញ្ញត្តិធម្មនុញ្ញត្រូវបែងចែកឱ្យបានច្បាស់លាស់ និងបទបញ្ញត្តិដែលអនុញ្ញាតឱ្យប្រជាពលរដ្ឋមានសិទ្ធិផ្ដួចផ្ដើមគំនិត ដើម្បីដាក់បញ្ចូលបញ្ហាទៅក្នុងរបៀបវារៈរបស់សភា ។ សភាមានសិទ្ធិពិភាក្សា ឬមិនពិភាក្សាលើបញ្ហាទាំងនោះ ។ នេះគឺជាករណីនៃប្រទេសជាច្រើន ដែលបានអនុម័តឱ្យមានសិទ្ធិផ្ដួចផ្ដើមគំនិតរបស់ប្រជាពលរដ្ឋ ។

ចំនួនចាប់ផ្ដើមអប្បបរិមាចាំបាច់សម្រាប់ការផ្ដួចផ្ដើមគំនិត ជាទូទៅច្រើនតិចជាងចំនួនចាប់ផ្ដើមចាំបាច់សម្រាប់ប្រជាមតិ ។

នៅប្រទេស Macédoine គេត្រូវការ ១៥០,០០០ ហត្ថលេខាសម្រាប់ករណីប្រជាមតិ តែត្រឹមតែ ១០,០០០ ហត្ថលេខាសម្រាប់សេចក្ដីព្រាងច្បាប់ សភាជាអ្នកសម្រេចលើសំណើទាំងនោះ ។

ប្រទេសកូស្តារីកា បានបង្កើតការិយាល័យផ្ដួចផ្ដើមគំនិតរបស់ប្រជាជន ដើម្បីទទួលយោបល់ គំនិតផ្ដួចផ្ដើម និងសេចក្ដីព្រាងច្បាប់របស់ប្រជាពលរដ្ឋ ។

នៅប្រទេស Equateur ប្រជាពលរដ្ឋ និងសមាគមមានអំណាចស្នើច្បាប់ និងចូលរួមក្នុងការពិភាក្សាសេចក្ដីព្រាងច្បាប់ ដែលសភាបានយល់ព្រមយកមកពិនិត្យ ។

ចាប់ពីឆ្នាំ ២០០៣ ប្រជាពលរដ្ឋព័រទុយហ្គាល់បានទទួលសិទ្ធិផ្ដួចផ្ដើមគំនិតធ្វើច្បាប់របស់ប្រជាពលរដ្ឋដែលបង្ខំឱ្យរដ្ឋសភាយកមកពិភាក្សា និងអនុម័តតាមសំណើដែលមានការគាំទ្រជាង ៣៥,០០០ ហត្ថលេខា ។

រដ្ឋសភាហុល្លង់មានបំណងផ្ដល់ឱ្យប្រជាពលរដ្ឋនូវសិទ្ធិផ្ដួចផ្ដើមគំនិតក្នុងកំរិតជាតិ តែរក្សាលទ្ធភាពចាត់ការ ឬមិនចាត់ការបន្ត ។ រដ្ឋសភានេះកត់សម្គាល់ថា គំនិតផ្ដួចផ្ដើមរបស់ប្រជាពលរដ្ឋបែបនេះអាចមានផលល្អប្រពៃ ជាអាទិ៍ ការបង្ខិតប្រជាពលរដ្ឋឱ្យជិតនឹងនយោបាយ ។

## លទ្ធិប្រជាធិបតេយ្យដោយផ្ទាល់ និងលទ្ធិប្រជាធិបតេយ្យតំណាង

ដើម្បីបំពេញរណ្ដៅចន្លោះរវាងប្រជាពលរដ្ឋ និងនយោបាយ សភាទាំងឡាយខិតខំធ្វើឱ្យប្រជាពលរដ្ឋចូលរួមដល់ដំណើរការធ្វើច្បាប់ ស្នើសុំការចូលរួមវិភាគទាននៅក្នុងការពិភាក្សាទៅលើសេចក្ដីព្រាងច្បាប់ អញ្ជើញប្រជាពលរដ្ឋឱ្យស្នើច្បាប់ ឬក៏កែប្រែអត្ថបទច្បាប់ជាធរមាន ។

វិធីសាស្ត្រសំខាន់ៗរួមមានដូចតទៅ

- សេចក្តីអញ្ជើញបើកចំហដល់ប្រជាពលរដ្ឋ និងក្នុងករណីខ្លះដល់ NGO និងសមាគមឯកទេស ឱ្យផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ ។
- យន្តការសហការអចិន្ត្រៃយ៍រវាងគណៈកម្មការសភា និងក្រុមប្រជាពលរដ្ឋ និងអ្នកឯកទេស ។
- វេទិកា ឬការប្រជុំពិសេសសម្រាប់សង្គមស៊ីវិល ដោយប្រជុំដាច់ដោយឡែក ឬដោយមានការចូលរួមពីសមាជិកសភា ។
- នីតិវិធីសម្រាប់គំនិតផ្តួចផ្តើមរបស់ប្រជាពលរដ្ឋ និងប្រជាមតិ ។
- ការបូកផ្សំវិធីសាស្ត្រខាងលើបញ្ចូលគ្នា ។

សំណួរសួរថា តើវិធីសាស្ត្រណាមួយល្អជាងគេ?

ប្រការនេះពឹងផ្អែកលើកាលៈទេសៈផ្ទាល់នៅនឹងកន្លែងរបស់ប្រទេសនីមួយៗ ។

ជាឧទាហរណ៍ ការខ្វះធនធាន ឬឧបសគ្គដទៃទៀត មិនអាចឱ្យរៀបចំធ្វើប្រជាមតិកើត ។ តែទោះជាមានសិទ្ធិផ្តួចផ្តើមរបស់ប្រជាពលរដ្ឋ សេចក្តីសម្រេចចុងក្រោយស្ថិតនៅលើសភា ។ ទោះដោយវិធីសាស្ត្រណាក៏ដោយបញ្ហានេះបង្ហាញថា សភាតែងមានកង្វល់ចង់ផ្សារភ្ជាប់ដោយជិតស្និទ្ធប្រជាពលរដ្ឋ និងដំណើរការធ្វើច្បាប់ ។

ព្រឹត្តិការណ៍ថ្មីៗនេះចោទអំពីសុចរិតភាពនៃប្រជាធិបតេយ្យតំណាង តើសមាជិកសភាអាចនិយាយក្នុងនាមអ្នកបោះឆ្នោតរបស់ខ្លួនបានដែរឬទេ? ព្រោះវាមានប្រជាធិបតេយ្យដោយផ្ទាល់ ដែលបង្កលក្ខណៈឱ្យប្រជាពលរដ្ឋចេះរៀបចំខ្លួន និងធ្វើឱ្យគេស្តាប់ខ្លួន ។

បញ្ហាមិនស្ថិតត្រង់ប្រជាធិបតេយ្យដោយផ្ទាល់ ឬប្រជាធិបតេយ្យតំណាងឡើយ ។ អ្នកតំណាងជាប់ឆ្នោតត្រូវមានការសន្ទនាជាអចិន្ត្រៃយ៍ជាមួយអ្នកបោះឆ្នោតរបស់ខ្លួន ។ ត្រូវមានឆន្ទៈធ្វើឱ្យមានដំណើរការជាប្រព័ន្ធកាន់តែមានតម្លាភាព និងកៀងគរផ្តុំ ដើម្បីកុំឱ្យក្រុមដែលមានផលប្រយោជន៍ជាបុព្វសិទ្ធិធ្វើអ្វីផ្តាច់មុខកំបាំងពីភ្នែកសាធារណជន ។

## V- <u>សភាដែលចេះរាយការណ៍</u>

កាតព្វកិច្ចដើម្បីរាយការណ៍របស់អ្នកកាន់តំណែងមុខងារសាធារណៈជាន់ខ្ពស់ ឬតំណែងសំខាន់ បច្ចុប្បន្ននេះត្រូវចាត់ទុកជាលក្ខខ័ណ្ឌជាគ្រឹះនៃជីវភាពសាធារណៈនៅក្នុងលទ្ធិប្រជាធិបតេយ្យ ។

កាលណាគេនិយាយអំពីកាតព្វកិច្ចនេះរបស់សភា គេត្រូវចែកជា ២ ទិដ្ឋភាពខុសគ្នា

- ទិដ្ឋភាពទី១ ផ្សារភ្ជាប់ទៅនឹងតួនាទីកណ្តាលរបស់សភា ដែលប្រគល់ដោយអង្គបោះឆ្នោត ដែលតម្រូវនៅក្នុងការប្រតិបត្តិនូវមុខងារត្រួតពិនិត្យ និងឱ្យរដ្ឋាភិបាលរាយការណ៍ ។ ទិដ្ឋភាពនេះសំខាន់ណាស់សម្រាប់ប្រសិទ្ធភាពប្រជាធិបតេយ្យរបស់សភា ។
- ទិដ្ឋភាពទី២ គឺកាតព្វកិច្ចរបស់សភា និងសមាជិកសភាត្រូវរាយការណ៍ឱ្យអ្នកបោះឆ្នោត ទស្សនៈអំពីបញ្ហានេះមានមុខជាច្រើន ។

គំនិតទី១ គឺថា អ្នកដែលមានមុខងារសាធារណៈ ត្រូវរាយការណ៍អំពីសកម្មភាពរបស់ខ្លួនចំពោះមុខអ្នកដែលទទួលខុសត្រូវរបស់ខ្លួន ។ នេះជាការទូទាត់នូវអំពើរបស់ខ្លួន ។ ការរាយការណ៍របស់អ្នកតំណាងចំពោះអង្គបោះឆ្នោតធ្វើឡើងតាមរយៈការសន្ទនាជាអចិន្ត្រៃយ៍ នេះជាអង្គធាតុសំខាន់ ។

គំនិតទី២ កាតព្វកិច្ចសម្រាប់អ្នកមានមុខងារសាធារណៈ ដែលត្រូវបំពេញលក្ខណៈវិនិច្ឆ័យការងារមួយចំនួន និងសុចរិតភាពនៅក្នុងការប្រតិបត្តិអាណត្តិ ។ ការវាយតម្លៃរឿងនេះធ្វើឡើងដោយស្ថាប័នទទួលខុសត្រូវ ដែលមានអំណាចផ្តល់ទណ្ឌកម្ម ប្រសិនបើគេពុំបានបំពេញតាមលក្ខណៈវិនិច្ឆ័យ ។ តាមន័យនេះសមាជិកសភាត្រូវទទួលខុសត្រូវចំពោះមុខអង្គបោះឆ្នោត ដែលអាចដាក់ទណ្ឌកម្មចុងក្រោយ ពុំបោះឆ្នោតឱ្យជាប់ឡើងវិញ ។ ប៉ុន្តែទណ្ឌកម្មតាមការបោះឆ្នោតនេះមានទស្សនៈវិស័យមិនច្បាស់លាស់ និងត្រូវប្រើពេលវេលា ដូច្នេះនាប៉ុន្មានឆ្នាំចុងក្រោយនេះ គេបានបង្កើតយន្តការ និងគណៈកម្មការដូចជា គណៈកម្មការសភាដែលសមាជិកសភាត្រូវរាយការណ៍អំពីមារយាទរបស់ខ្លួន (ក្នុងការគោរពវិន័យ) ។

## ការទទួលខុសត្រូវបណ្តោយ និងទទឹង

**(Responsabilité Horizontale et Verticale)**

កាតព្វកិច្ចរាយការណ៍នាំឱ្យមានការបែងចែកនូវការទទួលខុសត្រូវជាពីរ

១- ការទទួលខុសត្រូវបណ្តោយ ផ្តល់ការត្រួតពិនិត្យឱ្យយន្តការកំណត់បទបញ្ជា និងអង្គការត្រួតពិនិត្យ ដែលមានសមាសភាពជាអ្នកឯកទេសដែលធ្វើសកម្មភាពក្នុងនាមប្រជាពលរដ្ឋ ។

២- ការទទួលខុសត្រូវទទឹង សំដៅដល់ការត្រួតពិនិត្យពីមូលដ្ឋានដោយប្រជាពលរដ្ឋផ្ទាល់តែម្តង តាមរយៈយន្តការ ក្នុងនោះមានការបោះឆ្នោត នីតិវិធីប្តឹង និងសំណង សកម្មភាពរបស់អង្គការនៃសង្គមស៊ីវិល.... ។ល ។

នៅក្នុងវិស័យសាធារណៈ ការរួមបញ្ចូលគ្នានូវខ្សែរយៈទទឹង/បណ្តោយ ដែលធ្វើឱ្យការទូទាត់រាយការណ៍ (Reddition des comptes) មានប្រសិទ្ធភាព ។ ជាឧទាហរណ៍ ការកាត់បន្ថយអំពើពុករលួយនៅ

ក្នុងមុខងារសាធារណៈ តម្រូវជាចម្បងតាឱ្យមានការបូកផ្សំរួមគ្នានូវអង្គធាតុទាំងពីរ ការបង្កើតឱ្យមាននូវគណៈកម្មការប្រឆាំងអំពើពុករលួយឯករាជ្យ ដែលមានអំណាចគតិយុត្តិ និងស៊ើបអង្កេត ព្រមទាំងអន្តរាគមន៍របស់ក្រុមប្រជាពលរដ្ឋសកម្ម អង្គការតាមដាន និងអ្នកសារព័ត៌មានធ្វើការស៊ើបអង្កេត ។

ការរួមបញ្ចូលគ្នានូវអង្គធាតុនេះ អនុញ្ញាតឱ្យថែរក្សាបាននូវការគោរពបទដ្ឋានសីលធម៌របស់សមាជិកសភា ។

ប៉ុន្តែទិដ្ឋភាពនយោបាយនៃការទទួលខុសត្រូវសភា គឺរាយការណ៍ដល់អ្នកបោះឆ្នោតរបស់ខ្លួន ។

**<u>ការរាយការណ៍</u>**

មានទិដ្ឋភាព ២ សំខាន់នៃការទូទាត់រាយការណ៍របស់សមាជិកសភាទៅឱ្យអ្នកបោះឆ្នោតរបស់ខ្លួន

១- លទ្ធភាពទទួលបានព័ត៌មានអំពីសកម្មភាពរបស់សមាជិកសភា ។

២- សមត្ថភាពរបស់អ្នកបោះឆ្នោត ដើម្បីសាកសួរសំណួរដល់តំណាងរបស់ខ្លួន តាមរយៈព័ត៌មានក្នុងលទ្ធភាពទី១ ។

ដូច្នេះបានជាគេនិយាយដល់ក្នុងជំពូកមុនអំពីភាពចាំបាច់នៃតម្លាភាព និងការចូលមកជិតសមាជិកសភា ។ ប៉ុន្តែទស្សនៈអំពីការទទួលខុសត្រូវ តម្រូវឱ្យមានការទូទាត់រាយការណ៍ឱ្យចំចំណុច និងមានលក្ខណៈជាប្រព័ន្ធ បន្ទាប់ពីមានសកម្មភាព ឬអន្តរាគមន៍ដែលសាធារណជនអាចមានប្រតិកម្ម ។ ជាឧទាហរណ៍ អ្នកបោះឆ្នោតចង់ដឹងថា តើតំណាងរបស់ខ្លួនបានបោះឆ្នោតទៅបញ្ហាសំខាន់គន្លឹះ ដែលបានពិភាក្សាអនុម័តនៅក្នុងសភានោះយ៉ាងដូចម្តេច? ហើយតែងចង់សួរអំពីសកម្មភាពរបស់តំណាងរបស់ខ្លួន ។ ការទទួលខុសត្រូវខាងនយោបាយ តម្រូវឱ្យសមាជិកសភារាយការណ៍អំពីរបៀបដែលខ្លួនបានបោះឆ្នោតលើបញ្ហាណាមួយ ហើយសមាជិកសភានោះត្រូវត្រៀមការពារនូវជំហររបស់ខ្លួន ។ ការអភិវឌ្ឍ Internet នាពេលសព្វថ្ងៃ នាំឱ្យមានការសាកសួរបែបនេះកាន់តែច្រើនឡើង ។

ការអនុវត្តមួយទៀតដែលមិនសូវញឹកញាប់ គឺបោះពុម្ពមួយឆ្នាំម្តង ឬមួយសម័យប្រជុំម្តង នូវរបាយការណ៍ដែលសមាជិកសភារៀបចំអំពីសកម្មភាពការងារសភារបស់ខ្លួន ។ រូបមន្តក៏អាចមានរូបភាពជារបាយការណ៍ជាសមូហភាពទៅលើសកម្មភាពរួមរបស់សភាផងដែរ ។

ជាឧទាហរណ៍ សភារ៉ូម៉ានីតែងបោះពុម្ពផ្សាយនៅចប់សម័យប្រជុំម្តងៗ នូវរបាយការណ៍សកម្មភាពដែលត្រូវបោះផ្សាយនៅក្នុងសៀវភៅរាជកិច្ច ។

សភាហ្វាំងឡង់ ផ្សព្វផ្សាយតាម Internet នូវរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ។ ក្រៅពីសកម្មភាពនៅក្នុងវិស័យនីតិកម្ម និងអន្តរជាតិ របាយការណ៍នេះក៏លើកអំពីបញ្ហាចាត់តាំង ហិរញ្ញវត្ថុ និងគណនេយ្យរបស់សភាផងដែរ ។

សភាបារាំងបោះផ្សព្វផ្សាយជារៀងរាល់ឆ្នាំនូវរបាយការណ៍ស្តីពីថវិការបស់សភាទាំងពីរ ។

ប្រទេសលុចហ្សំបួរ របាយការណ៍របស់រដ្ឋសភាត្រូវបានចែកផ្សព្វផ្សាយដល់គ្រប់ផ្ទះ នៅក្នុងប្រទេសទាំងមូល ។

នៅប្រទេស Saint-Kitts-et-Nevis របាយការណ៍ត្រូវធ្វើដោយផ្ទាល់មាត់ ប្រជាពលរដ្ឋសាកសួរសមាជិកសភាអំពីសកម្មភាពក្នុងមួយឆ្នាំ ក្នុងឱកាសនៃការប្រជុំជាសាធារណៈ ។

ជាការពិត ឧទាហរណ៍របស់ប្រទេស Luxembourg និង Saint-Kitts-et-Nevis សមស្របសម្រាប់ប្រទេសដែលមានប្រជាជនតិច តែសមាជិកសភានៃប្រទេសដទៃអាចធ្វើតាមបាននៅក្នុងកំរិតមណ្ឌល ឬស្រុក ។

ការផ្ញើរបាយការណ៍ប្រចាំឆ្នាំ ឬមួយសម័យប្រជុំទៅឱ្យអ្នកបោះឆ្នោតរបស់ខ្លួន របស់សមាជិកសភាម្នាក់ រួមទាំងការបញ្ជាក់អំពីការបោះឆ្នោតរបស់ខ្លួនលើបញ្ហាផ្សេងៗ និងលទ្ធភាពដែលអ្នកបោះឆ្នោតអាចសាកសួរសមាជិកសភានោះតាមរយៈ E-mail ឬក្នុងកិច្ចប្រជុំសាធារណៈ មានភាពល្អប្រពៃ បញ្ជាក់នូវការទទួលខុសត្រូវចំពោះអ្នកបោះឆ្នោតរបស់ខ្លួន ពុំមែនត្រឹមតែក្នុងកម្លុងពេលបោះឆ្នោតប៉ុណ្ណោះទេ ។ នេះជាការយកការពិតទៅឆ្លុះបញ្ចាំងនឹងការសន្យាក្នុងពេលរកសន្លឹកឆ្នោត ។

## ការដកហូតអាណត្តិសភា

ដោយហេតុថា ការបោះឆ្នោតប្រព្រឹត្តទៅក្នុងចន្លោះជាច្រើនឆ្នាំនោះ ដូច្នេះមានបញ្ហាថា វាមិនគ្រប់គ្រាន់សម្រាប់សមាជិកសភាត្រូវដាក់ខ្លួនគោរពតាមកាតព្វកិច្ច ដើម្បីរាយការណ៍អំពីអំពើរបស់ខ្លួនជូនអង្គបោះឆ្នោត ។ ប្រការនេះនាំឱ្យមានការលើកសំណើឱ្យប្រគល់អំណាចឱ្យប្រជាពលរដ្ឋ ដើម្បីដកអ្នកបោះឆ្នោតរបស់ខ្លួនក្នុងពេលកំពុងបំពេញអណត្តិ ។ វិធានការបែបនេះត្រូវបានអនុវត្តន៍នៅប្រទេស និងដែនដីចំនួន ២ គឺ : Ouganda និងខេត្ត Colombie britannique នៃប្រទេសកាណាដា ។

នៅប្រទេស Ouganda តាមមាត្រា ៨៤ នៃរដ្ឋធម្មនុញ្ញ សមាជិកសភាត្រូវបានដកហូតដោយមានមូលហេតុមួយក្នុងចំណោមមូលហេតុដូចខាងក្រោម

- អសមត្ថភាពខាងរាងកាយ ឬស្មារតីដែលធ្វើឱ្យសមាជិកសភាមិនអាចបំពេញមុខងាររបស់ខ្លួនបាន ឬ
- កំហុសធ្ងន់ធ្ងរ ឬមារយាទអាក្រក់ដែលជម្រុញឱ្យមានគំនុំ គំនិតខុសឆ្គង ឬការមាក់ងាយ ឬក៏ការធ្វើឱ្យប៉ះពាល់ដល់មុខងារ ឬ
- ការបោះបង់ចោលអ្នកបោះឆ្នោត ( អវត្តមានរយៈពេលយូរ) ដោយគ្មានមូលហេតុយកជាការបាន

ការដកហូតបែបនេះតម្រូវឱ្យមានការបញ្ជូនញត្តិ ចុះហត្ថលេខាដោយអ្នកបោះឆ្នោតយ៉ាងតិចចំនួន ២ ភាគ ៣ ដែលបានចុះឈ្មោះក្នុងមណ្ឌល ឬក្រុមសង្គម ដែលបានលើកឈ្មោះបេក្ខជនរូបនេះកាលពីពេលបោះឆ្នោត ។ តាមរយៈការស៊ើបអង្កេតជាសាធារណៈដ៏ជ្រាលជ្រៅ ដែលគណៈកម្មការបោះឆ្នោតអារកាត់ទៅលើសុពលភាពរបស់ញត្តិ ហើយសម្រេច ឬមិនសម្រេចលើការដកហូតអណត្តិរបស់អ្នកជាប់ឆ្នោតដែលមានបញ្ហានោះ ។

នៅខេត្ត Colombie britannique មូលហេតុនៃការដកហូតអណត្តិពុំមានបញ្ជាក់ទេ ។ នីតិវិធីខុសពីការអនុវត្តនៅប្រទេស Ouganda ព្រោះតម្រូវឱ្យមានហត្ថលេខាត្រឹមតែ ៤០%នៃអ្នកបោះឆ្នោតដែលបានចុះឈ្មោះក្នុងមណ្ឌលប៉ុណ្ណោះ ។ បន្ទាប់ពីនោះការបោះឆ្នោតដោយផ្នែកត្រូវរៀបចំធ្វើឡើង ។ ក្នុងឆ្នាំ ២០០១ មានញត្តិចំនួន ៩ បានស្នើឡើង តែគ្មានញត្តិណាមួយបានសម្រេចឡើយ ។

ការព្រួយបារម្ភបានកើតឡើងពាក់ព័ន្ធនឹងការប្រើប្រាស់សិទ្ធិបែបនេះ ព្រោះវានាំឱ្យចំណាយពេលវេលា និងប្រាក់កាសច្រើន ។ ម៉្យាងទៀត នាគ្រប់ករណីត្រូវត្រួតពិនិត្យជាផ្លូវការលើគ្រប់ហត្ថលេខារបស់សាមីជន ។ អញ្ចឹងហើយបានជាសិទ្ធិដកហូតនេះ ពុំទាន់បានអនុវត្តន៍ឱ្យទូលំទូលាយនៅឡើយ ។

## គោលការណ៍ និងក្រមសីលធម៌សភា

ក្នុងពេលដែលយន្តការដកហូត គឺជាឧទាហរណ៍មួយនៃការទទួលខុសត្រូវតាមខ្សែទទឹង វិធីសាស្ត្រធម្មតាដើម្បីដាក់ទណ្ឌកម្មលើមារយាទអាក្រក់របស់សមាជិកសភា តម្រូវឱ្យអនុវត្តន៍តាមខ្សែបណ្តោយ នូវក្រមសីលធម៌ដោយគណៈកម្មការពិសេសដែលធ្វើការក្នុងនាមសាធារណៈជន ។

ទសវត្សចុងក្រោយនេះត្រូវកត់សម្គាល់ដោយការរៀបចំ និងការអនុម័តជាទូទៅនូវគោលការណ៍ និងក្រមសីលធម៌សម្រាប់សេវាសាធារណៈជាទូទៅ និងសម្រាប់សមាជិកសភាជាពិសេស ។ គួរឱ្យកត់សម្គាល់ថាសម្រាប់ប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យយូរយាជាពិសេស ចាំបាច់ត្រូវតែមានដើម្បីប្រតិកម្មទៅនឹងការបាត់ជំនឿពីសាធារណជនទៅលើសីលធម៌របស់សមាជិកសភា និងស្ថាប័នដែលទទួលភារៈតំណាងឱ្យប្រជាជន ។

ប្រការដែលសំខាន់ត្រូវដឹងថា តើប្រតិកម្មរបស់សាធារណជននេះបង្ហាញនូវការធ្លាក់ចុះពិតប្រាកដ នៃបទដ្ឋានសីលធម៌ ឬក៏ឆ្លុះបញ្ចាំងជាសាមញ្ញអំពីការខ្វះខាតផ្សេងៗ ដែលបច្ចុប្បន្ននេះកាន់តែងាយនឹងចោទប្រកាន់ និងពិភាក្សា តែពិបាកនឹងអត់ឱនឱ្យ ។ រឿងសំខាន់ គឺការយល់ឃើញរបស់អង្គបោះឆ្នោត ។

ជាឧទាហរណ៍ នៅប្រទេសអូស្ត្រាលីនាឆ្នាំ ២០០០ សាធារណជនអូស្ត្រាលីតាមការស្ទង់មតិ មានទំនុកចិត្តលើអ្នកបោះពុម្ពផ្សាយ អ្នកយកព័ត៌មាន និងអ្នកលក់រថយន្ត ។ សមាជិកសភាស្ថិតនៅលំដាប់ថ្នាក់លេខ៤។ តែមកដល់ឆ្នាំ ២០០៥ ក្នុងចំណោម ២៣ប្រភេទវិជ្ជាជីវៈ សមាជិកសភាស្ថិតនៅលេខក្រោយគេ ( ប្រជាជនទុកចិត្តតិចបំផុត) ។

ភាពវិបល្លាសក្នុងចិត្តរបស់សាធារណជន គឺលើបញ្ហាហិរញ្ញវត្ថុ ជាពិសេស ដោយហេតុថា សមាជិកសភាប្រើប្រាស់ឋានៈរបស់ខ្លួន ដើម្បីជម្រុញផលប្រយោជន៍សេដ្ឋកិច្ចរបស់ខ្លួនឯងផ្ទាល់ ឬផលប្រយោជន៍របស់បុគ្គល និងអង្គការពាក់ព័ន្ធដែលខ្លួនត្រូវដឹងគុណ ។ ក្នុងចំណោមបញ្ហាផ្សេងទៀត មានអវត្តមានញឹកញាប់ ការប្រើប្រាស់ព័ត៌មានសម្រាប់ភាពសម្ងាត់នៃវិជ្ជាជីវៈដោយរំលោភ និងការប្រើប្រាស់ពុំបានល្អនូវលាភសក្ការៈសភា ។

សូមបញ្ជាក់ថា បទបញ្ជាផ្ទៃក្នុងសម្រាប់ការប្រព្រឹត្តរបស់សមាជិកសភាតែងមានជានិច្ច តែបទបញ្ជានេះតែងតែនិយាយអំពីអាកប្បកិរិយា ដែលនាំឱ្យច្របូកច្របល់ដល់ដំណើរការដ៏ល្អនៃនីតិវិធីសភាប៉ុណ្ណោះ ។ អញ្ចឹងហើយបានជាសភាជាច្រើនតែងមានបទដ្ឋានជាស្តង់ដាហាមឃាត់ពាក្យសំដីខ្វះ ឬអាកប្បកិរិយាបង្កហេតុ ឬគំរាមកំហែងទៅលើសមាជិកដទៃទៀត ឬត្រូវចាត់ទុកដូចជាប៉ះពាល់ទៅលើសេរីភាពសម្តែងយោបល់ និងបោះឆ្នោត ឬមិនសម្តែងការគោរពចំពោះស្ថាប័ន ឬប្រធានស្ថាប័ន ។

ដាច់ពីបញ្ហាទាំងអស់នេះដែលពាក់ព័ន្ធដល់របៀបរបបផ្ទៃក្នុង និងសុជីវធម៌ត្រូវយល់ថា សមាជិកសភាត្រូវបានជាប់ឆ្នោតដើម្បីការពារផលប្រយោជន៍សាធារណៈ ពុំមែនជាផលប្រយោជន៍ផ្ទាល់ខ្លួន ឬឯកជនឡើយ ។ នេះជាអង្គធាតុថ្មី ដែលសភាជាច្រើនតែងបញ្ជាក់ច្បាស់អំពីគោលការណ៍នេះ ហើយបានបញ្ចូលទៅក្នុងបទដ្ឋានមួយចំនួន និងក្នុងក្រមសីលធម៌ ដើម្បីឱ្យមានជំនឿទុកចិត្តលើសុចរិតភាពរបស់សភា ។

ជាឧទាហរណ៍ បុព្វកថារបស់ក្រមសីលធម៌នៃសភាកាណាដា បានចែងដូចតទៅ

១- ត្រូវទទួលស្គាល់ថាមុខងារសភា គឺជាអណត្តិសាធារណៈ ។

២- ត្រូវថែរក្សា និងបង្កើនទំនុកចិត្តរបស់សាធារណជនទៅលើសុចរិតភាពរបស់សមាជិកសភាម្នាក់ៗ និងសុចរិតភាពរបស់សភាទាំងមូល ។

៣- ត្រូវបង្ហាញដល់សាធារណជនថា សមាជិកសភាត្រូវគោរពតាមបទដ្ឋានសីលធម៌ ដែលលើកកំពស់ផលប្រយោជន៍សាធារណៈមុនផលប្រយោជន៍បុគ្គលរបស់សមាជិកសភា និងត្រូវបង្កើតយន្តការមានតម្លាភាព ដើម្បីឱ្យសាធារណជនជឿជាក់ថា ធ្វើបានដូច្នេះមែន ។

៤- ត្រូវផ្តល់ការណែនាំច្បាស់លាស់ដល់សមាជិកសភា អំពីរបៀបសម្របសម្រួលផលប្រយោជន៍ផ្ទាល់ខ្លួនទៅនឹងមុខងារផ្លូវការរបស់សមាជិកសភា ។

៥- ត្រូវជម្រុញឱ្យបង្កើតបាននូវកុងសង់ស៊ុសក្នុងចំណោមសមាជិកសភា ដោយរៀបចំនូវបទបញ្ជារួម និងរៀបចំក្របខ័ណ្ឌមួយ ដែលមានទីប្រឹក្សាឯករាជ្យមួយរូប និងមិនប្រកាន់បក្សពួកអាចឆ្លើយតបទៅនឹងបញ្ហាសីលធម៌ ។

ចំណុចទី៤ និងចំណុចទី៥ ជាបញ្ហាពិបាកតែងកើតមាននៅគ្រប់ពេលដែលត្រូវរៀបចំក្រមសីលធម៌ ។ ចំណុចមួយពិបាកត្រង់ថា ប្រសិនបើសមាជិកសភាខ្លួនឯងពុំអាចរកកុងសង់ស៊ុសបានទេនោះ ច្បាប់ ឬក្រមអ្វីក៏ដោយនឹងពិបាកអនុវត្តន៍បានបំផុត ។ ជាញឹកញាប់ ការស្វែងរកកុងសង់ស៊ុសជារឿងពិបាកបំផុត ដោយបញ្ហាស្មុគស្មាញនឹងលើកយកមកជជែកគ្នា ហើយក៏មានចំណុចមិនច្បាស់លាស់ជាច្រើនកន្លែងដែលនាំឱ្យមានចម្រូងចម្រាស់ កាលណាគេត្រូវបកស្រាយក្រមសីលធម៌នោះឱ្យបានច្បាស់លាស់ ។ ការសិក្សាអំពីចំណុចមិនច្បាស់លាស់ខ្លះ ជាពិសេសពាក្យថា ទំនាស់ផលប្រយោជន៍នាំមើលឃើញអំពីទិដ្ឋភាពចម្បងនៃការទទួលខុសត្រូវរបស់សភា ។

## ផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ឯកជន

បេះដូងនៃគោលការណ៍ និងក្រមសីលធម៌របស់សភា គឺភាពចាំបាច់នៃការបែងចែកឱ្យច្បាស់លាស់អំពីផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍បុគ្គល ឬឯកជន ។ ការបែងចែកនេះ គឺជាគ្រឹះនៃកែវភ្នែកប្រជាធិបតេយ្យ ដែលចែងថា មូលហេតុនៃបន្ទុកជាប់ឆ្នោត គឺដើម្បីបំរើសាធារណជន ពុំមែនធ្វើឱ្យខ្លួនឯងក្លាយជាអ្នកមាន ឬបង្កើនទំនាក់ទំនងផ្ទាល់ខ្លួនឡើយ ។ ជាភាសាធម្មតា ការប្រើប្រាស់ដោយមិនបានត្រឹមត្រូវនូវមុខងារសាធារណៈដើម្បីធ្វើមានបានផ្ទាល់ខ្លួនហៅថា "ការពុករលួយ" ។ ក្នុងភាសាសភា គេនិយាយអំពី "ទំនាស់ផលប្រយោជន៍" ។

ក្នុងក្រមសីលធម៌របស់សភាតំណាង Irlande កំណត់ដូចតទៅ

វាមានទំនាស់ផលប្រយោជន៍ កាលណានៅក្នុងការប្រតិបត្តិអណត្តិរបស់ខ្លួន សមាជិកសភាចូលរួមក្នុងការធ្វើសេចក្តីសម្រេច ឬខ្លួនឯងធ្វើសេចក្តីសម្រេច ដោយដឹងថា ដោយផ្ទាល់ ឬដោយប្រយោល ប្រការនេះ

អនុគ្រោះដោយពុំត្រឹមត្រូវ និងដោយពុំស្មោះត្រង់នូវផលប្រយោជន៍ហិរញ្ញវត្ថុរបស់ខ្លួន ឬផលប្រយោជន៍របស់បុគ្គលឯកជនណាមួយ ។ វាមានទំនាស់ផលប្រយោជន៍ កាលណាសមាជិកសភាម្នាក់ ឬបុគ្គលណាម្នាក់ទៀតទទួលបានផលប្រយោជន៍ក្នុងនាមជាសមាជិកម្នាក់របស់សាធារណៈ ឬក៏ជាប្រភេទក្រុមមនុស្សដ៏សំខាន់ ។

ពាក្យថា "ឬប្រភេទក្រុមមនុស្សដ៏សំខាន់" ជូនកាលជាប្រភពនៃការពិបាក ។ ជាឧទាហរណ៍ សមាជិកសភាដែលមានវណ្ណៈជាម្ចាស់កម្មសិទ្ធិដីធ្លី ឬក៏ជាអ្នកមានភាគហ៊ុនក្នុងក្រុមហ៊ុនប្រេងកាត ឬឱសថ ឬប្រព័ន្ធឃោសនា តើពួកគេមិនសូវយកចិត្តទុកដាក់ឬយ៉ាងណា ពេលដែលពួកគេត្រូវធ្វើច្បាប់ដែលផ្តល់ផលប្រយោជន៍ឱ្យក្រុមទាំងនោះ ឬក៏គេយកចិត្តទុកដាក់ខិតខំពេលណាត្រូវលើកតម្កើងផលប្រយោជន៍របស់ពួកគេផ្ទាល់? ក្រោមភ្នែករបស់សាធារណជន ការបែងចែកគឺពុំច្បាស់លាស់ដដែល ។ អញ្ចឹងហើយបានសភាជាច្រើនតម្រូវឱ្យសមាជិករបស់ខ្លួនប្រកាសអំពីទ្រព្យសម្បត្តិរបស់ខ្លួន ហើយឱ្យសមាជិកសភាតែងតាំងមន្ត្រីមួយរូបមិនប្រកាន់បក្ខពួក ដែលមានសមត្ថភាពផ្តល់យោបល់ឱ្យពួកគេ និងអារកាត់លើបញ្ហាទំនាស់ផលប្រយោជន៍ទាំងអស់ ។ ជាធម្មតា ត្រូវចុះបញ្ជីនូវបរិមាណហិរញ្ញវត្ថុរបស់សមាជិក ភាគហ៊ុនដែលពួកគេមាននៅក្នុងក្រុមហ៊ុនសាធារណៈ ឬឯកជន ដីធ្លី និងទ្រព្យសម្បត្តិដែលពួកគេមាន មុខតំណែងដឹកនាំដែលមានប្រាក់បៀវត្សដែលកាន់កាប់ និងការចូលរួមជាដៃគូនានា ។

ប្រការខាងលើនេះ ពុំអាចបញ្ចប់នូវប្រភពនៃទំនាស់ផលប្រយោជន៍បានឡើយ ។ ចំណុចមិនច្បាស់លាស់មួយទៀតពាក់ព័ន្ធនឹងអង្គការខាងក្រៅដែលសមាជិកសភាជាប់ជំពាក់ ដោយហេតុថាបានទទួលប្រាក់បំណាច់សម្រាប់សេវាដែលបានផ្តល់ក្នុងអណត្តិជាកុងសង់តង់ ឬជាអ្នកនាំពាក្យមិនផ្លូវការ ។ សភាជាច្រើនហាមឃាត់សមាជិករបស់ខ្លួនមិនឱ្យចុះកុងត្រាជាមួយអង្គការខាងក្រៅ ដើម្បីធ្វើសកម្មភាពក្នុងនាមអង្គការទាំងនេះនៅក្នុងសភា ។

សភាអង់គ្លេសនាឆ្នាំ ១៩៤៧ បានចេញសេចក្តីសម្រេចពីបញ្ហាខាងលើនេះ ។

ប៉ុន្តែខ្សែបន្ទាត់ដែលបែងចែកកិច្ចព្រមព្រៀងក្រៅផ្លូវការមួយ និងកិច្ចព្រមព្រៀងផ្លូវការមួយជាមួយអង្គការខាងក្រៅ គឺស្តើងបំផុត ។ អញ្ចឹងហើយបានជានៅក្នុងបញ្ជីទ្រព្យសម្បត្តិ និងប្រាក់កាសដែលសមាជិកសភាម្នាក់ត្រូវប្រកាសនៅពេលចូលកាន់តំណែង រួមមានអណត្តិជាកុងសង់តង់ បទបញ្ញត្តិអំពីប្រាក់លាភការដែលបានទទួល វត្ថុអនុស្សាវរីយ៍បានទទួល ពិធីជប់លៀង ការហូបបាយទឹក និងសំបុត្រទស្សនាសិល្បៈបានទទួល ប្រាក់ទទួលសម្រាប់ការធ្វើដំណើរ និងផលប្រយោជន៍ផ្សេងៗទៀត ។

ចំណុចមិនច្បាស់លាស់មួយទៀត គឺថាសមាជិកអាចយល់ព្រមធ្វើការងារមួយទៀតមានបៀវត្ស ក្នុងពេលដែលខ្លួនមានប្រាក់បៀវត្ស ដើម្បីធ្វើការពេញម៉ោងក្នុងកាតព្វកិច្ចជាសមាជិកសភា ។ សភាខ្លះមានយោបល់ថា វាជាការល្អដែលសមាជិករបស់ខ្លួនមានសកម្មភាពទទួលប្រាក់កំរៃនៅខាងក្រៅពិភពនយោបាយ ហើយសាធារណជនពុំដែលរករឿងពីបញ្ហានេះឡើយ ។ ជាការពិត វាជាការពិបាកដើម្បីរារាំងសមាជិកសភាម្នាក់មិនឱ្យមានការងារឯករាជ្យ ជាឧទាហរណ៍ ជាអ្នកកាសែត ឬជាអ្នកធ្វើអត្ថាធិប្បាយខាងនយោបាយ ឬជាអ្នកនិពន្ធ សកម្មភាពដទៃទៀតដែលអាចចាត់ទុកថា ជាការបន្តដោយធម្មជាតិជាមួយសកម្មភាពសភារបស់ខ្លួន ។ ត្រង់កន្លែងនេះ កាតព្វកិច្ចប្រកាសអំពីប្រភពនៃចំណូលរបស់ខ្លួននៅក្នុងបញ្ជីទ្រព្យសម្បត្តិ និងប្រាក់កាសត្រូវប្រគល់ទៅឱ្យសាធារណជនជាអ្នកអារកាត់ ទំនាស់ផលប្រយោជន៍ ឬអត់ស្រេចនៅលើការវាយតម្លៃរបស់សមាជិកសភាដទៃទៀត និងអ្នកបោះឆ្នោត ។

## <u>បញ្ជីទ្រព្យសម្បត្តិ និងហិរញ្ញវត្ថុ</u>

សភា Afrique du Sud បានកំណត់អំពីផលប្រយោជន៍ខាងហិរញ្ញវត្ថុ ដែលត្រូវប្រកាសដូចតទៅ

១- ភាគហ៊ុន ឬផលប្រយោជន៍ដទៃទៀត ដែលមាននៅក្នុងក្រុមហ៊ុន ឬបុគ្គលតំណាង ។

២- ការងារមានបៀវត្សនៅខាងក្រៅសភា ។

៣- មុខតំណែងដឹកនាំ និងដៃគូ ។

៤- មុខតំណែងជាកុងសង់តង់ ។

៥- មុខងារជំនួស ។

៦- អំណោយ និងផលប្រយោជន៍ផ្សេងៗដែលចេញមកពីបុគ្គលដទៃក្រៅពីសមាជិកគ្រួសារ ឬភរិយា ឬស្វាមីរបស់សាមីជន ។

៧- ផលប្រយោជន៍ដទៃទៀត ។

៨- ដំណើរទៅក្រៅប្រទេស (ក្រៅពីដំណើរផ្ទាល់បង់ថ្លៃដោយសមាជិកសភាខ្លួនឯង ដំណើរពាណិជ្ជកម្មមិនពាក់ព័ន្ធនឹងមុខងារតំណាង និងដំណើរផ្លូវការបង់ថ្លៃដោយរដ្ឋ ឬដោយគណបក្សដែលខ្លួនជាសមាជិក) ។

៩- ដីធ្លី ទ្រព្យសម្បត្តិ និងអង្គធាតុដទៃទៀតនៃទ្រព្យសម្បត្តិ ។

១០- សោធននិវត្ត ។

សភាជាច្រើនពុំមានបញ្ជីរបៀបនេះឡើយ ។

ក្នុងចំណោមសភាដែលមានបញ្ជី គេកត់សម្គាល់ឃើញមានភាពខុសគ្នារវាងខ្លឹមសារ និងដំណើរការ ដូចជា

- ការចុះបញ្ជី គឺជាកាតព្វកិច្ច ឬគ្រាន់តែជាការស្ម័គ្រចិត្តដោយសេរី (នេះជាជម្រើសរបស់ប្រទេសនៅអឺរ៉ុបខាងជើង) ។
- សាមីជនគ្រាន់តែប្រកាសអំពីទ្រព្យសម្បត្តិ និងកម្មសិទ្ធិដូចនៅប្រទេសប្រើភាសាបារាំង ឬរួមបញ្ចូលផងដែរ នូវផលប្រយោជន៍ហិរញ្ញវត្ថុដទៃទៀត ។
- ការប្រកាសទ្រព្យសម្បត្តិភ្ជាប់ជាមួយ ឬមិនភ្ជាប់ជាមួយនូវទ្រព្យសម្បត្តិ និងកម្មសិទ្ធិរបស់ប្រពន្ធប្ដី និងកូន ។
- ខ្លឹមសារទាំងមូលនៃបញ្ជីត្រូវផ្សព្វផ្សាយជាសាធារណៈ ឬក៏ភាគខ្លះប៉ុណ្ណោះដែលត្រូវរាយការណ៍ឱ្យប្រធាន ឬក៏ឱ្យកម្មលេខាធិការ (Greffier) ដោយមូលហេតុគោរពដល់ជីវិតឯកជន ។
- សមាជិកសភាធ្វើសេចក្ដីប្រកាសទ្រព្យសម្បត្តិនៅពេលផ្ដើម និងនៅពេលបញ្ចប់អណត្តិរបស់ខ្លួន ឬក៏សមាជិកសភាត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ។
- សមាជិកសភាត្រូវបង្ហាញតាមដែលអាចធ្វើបាន អំពីលទ្ធភាពនៃទំនាស់ផលប្រយោជន៍ កាលណាសមាជិកសភាធ្វើសកម្មភាពណាមួយដែលអាចបង្កឱ្យមានហានិភ័យនោះ ឬក៏គ្រាន់តែគេណែនាំផ្ទាល់មាត់មិនឱ្យធ្វើ ។
- បញ្ជីនោះត្រូវដាក់ក្រោមការត្រួតពិនិត្យពីអង្គការមួយនៅខាងក្រៅ ដែលទទួលបន្ទុកណែនាំឱ្យគោរពតាមបទបញ្ជា ឬក៏ក្រោមគណៈកម្មការមួយរបស់សភា ឬក៏ក្រោមអង្គការមួយចម្រុះ ។

ដូច្នេះសភានានាមានរបៀបចាត់ការរៀងៗខ្លួន ដោយពឹងផ្អែកទៅលើកុងសង់ស៊ីសក្នុងពេលរៀបចំនូវក្រមសីលធម៌របស់សភា ។

មានអនុសាសន៍តែមួយ កាលណាមានជម្លោះផលប្រយោជន៍កាន់តែច្រើន ដែលសាធារណជននៃប្រទេសមួយកាន់តែយកចិត្តទុកដាក់ វាកាន់តែចាំបាច់រឹតបន្តឹង ឬរៀបចំឡើងវិញនូវទំនុកចិត្តរបស់ប្រជាពលរដ្ឋ ត្រូវបង្កើតបញ្ជីទ្រព្យសម្បត្តិអមដោយបទបញ្ជាអនុវត្តន៍ ហើយត្រូវប្រគល់ការគ្រប់គ្រងទៅឱ្យឥស្សរជនមិនប្រកាន់បក្សពួក ដែលមានសមត្ថភាពនឹងអារកាត់ ។

ចំពោះយន្តការដើម្បីអនុវត្តន៍នូវក្រមសីលធម៌ NDI បានរៀបចំនូវបទដ្ឋានអន្តរជាតិសម្រាប់សភាប្រជាធិបតេយ្យ ដូតទៅ

ប្រទេសជាច្រើនបានផ្ទុកផ្តាក់ស្ថាប័នឯករាជ្យមិនប្រកាន់បក្សពួកមួយ ឱ្យធានានូវការគោរពនូវក្រមសីលធម៌ ។ ជាឧទាហរណ៍ ប្រទេសអង់គ្លេសមានស្នងការខាងសីលធម៌ ។ ការដាក់ជាធរមាននូវក្រមសីលធម៌ត្រូវបានប្រគល់ឱ្យគណៈកម្មការអំពីការអនុវត្តបទដ្ឋាន និងអភ័យឯកសិទ្ធិ ។ ស្នងការផ្តល់យោបល់ដល់គណៈកម្មការនោះ កាន់កាប់បញ្ជីប្រចាំថ្ងៃនៃផលប្រយោជន៍ហិរញ្ញវត្ថុរបស់សមាជិក ផ្តល់យោបល់ជាសម្ងាត់ឱ្យសមាជិកពាក់ព័ន្ធនឹងការចុះបញ្ជី និងតាមដានការអនុវត្តក្រមសីលធម៌ ។ ក្រៅពីនោះ ស្នងការទទួលនូវពាក្យបណ្តឹងរបស់សមាជិកសភា និងប្រជាពលរដ្ឋ ចាត់ចែងការស៊ើបអង្កេត ។ ទោះបីស្នងការគ្មានសិទ្ធិនឹងដាក់ទណ្ឌកម្ម ព្រោះជាសមត្ថកិច្ចរបស់គណៈកម្មការ ស្នងការត្រូវបំពេញការងារដោយមិនប្រកាន់បក្សពួក ដើម្បីឱ្យគណៈកម្មការបំពេញនូវភារកិច្ចស្ម័យត្រួតពិនិត្យរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ។

## ភាពស្និតស្នាញក្នុងសម័យប្រជុំពេញអង្គរបស់សភា

ក្រមសីលធម៌ភាគច្រើនយកចិត្តទុកដាក់តែលើបញ្ហាហិរញ្ញវត្ថុ និងទំនាស់ផលប្រយោជន៍ដែលអាចកើតមានប៉ុណ្ណោះ ។ តែបញ្ហាអស់នោះមិនមែនជាបញ្ហាតែមួយគត់ធ្វើឱ្យអ្នកបោះឆ្នោតអស់ជំនឿទុកចិត្តលើសមាជិកសភាប៉ុណ្ណោះទេ ។ ជាឧទាហរណ៍ បញ្ហាស្និតស្នាញក្នុងសម័យប្រជុំពេញអង្គរបស់សភាក៏ត្រូវសាធារណជនយកចិត្តទុកដាក់ផងដែរ ។ មើលតាមទូរទស្សន៍ក្នុងសភាខ្លះ ពេលប្រជុំពេញអង្គ កៅអីជាង២ភាគ៣នៅទំនេរ ដែលធ្វើឱ្យមានអារម្មណ៍សាធារណៈមិនល្អ ។ តាមពិតអាចសមាជិកសភាអវត្តមាន ជាប់រវល់កិច្ចការផ្សេងទៀតរបស់សភា ឬរបស់មណ្ឌល ។ សភាជាច្រើនចែងក្នុងបទបញ្ជាអំពីបញ្ហាវត្តមានក្នុងសម័យប្រជុំពេញអង្គ ឬក្នុងគណៈកម្មការ ដោយគ្រោងជាទូទៅអំពីកាតព្វកិច្ចរាយការណ៍ឱ្យប្រធានសភាបានដឹងអំពីមូលហេតុនៃអវត្តមាន ។ ទណ្ឌកម្មគ្រោងសម្រាប់ករណីអវត្តមានគ្មានមូលហេតុ មានដូចតទៅ

- ការផ្សព្វផ្សាយនូវបញ្ជីវត្តមាន/អវត្តមាន
- ស្តីបន្ទោស ឬណែនាំឱ្យគោរព
- បាត់បង់ភាគខ្លះនៃបៀវត្សសភា
- ការព្យួរបណ្តោះអាសន្ន
- ការដកអណត្តិសភា

នៅសហរដ្ឋអាមេរិក និងហ្វីលីពីន មានបទបញ្ញត្តិពិសេសដែលអនុញ្ញាតឱ្យប្រធានសន្តិសុខរបស់សភា (Sergent d'armes de la chambre) ចាប់អ្នកប្រព្រឹត្តខុស និងនាំខ្លួនដោយបង្ខំមកកាន់សភា ។

## ហិរញ្ញប្បទានរបស់គណបក្ស និងយុទ្ធនាការបោះឆ្នោត

ក្រមសីលធម៌ ជាការបង្ហាញដល់ការយកចិត្តទុកដាក់របស់អ្នកបោះឆ្នោតទៅលើការទទួលខុសត្រូវរបស់សភា តែជាការអនុវត្តសម្រាប់សមាជិកសភាក្នុងនាមជាបុគ្គល ។

សាធារណជនក៏សម្តែងការព្រួយបារម្ភទៅលើគណបក្សនយោបាយ ដែលចូលរួមការងារសាធារណៈ អំពីរបៀបដែលគណបក្សទាំងនេះទទួលបានហិរញ្ញប្បទាន ។

ម្យ៉ាងចំណាយនៃយុទ្ធនាការបោះឆ្នោតកាន់តែកើនឡើង ដែលគេហៅថា ការរត់ប្រណាំងខាងសព្វាវុធក្នុងពេលបោះឆ្នោត ។ ម្យ៉ាងទៀត ការបង់វិភាគទានរបស់សមាជិកគណបក្សមិនគ្រប់គ្រាន់ ។ អញ្ចឹងហើយគណបក្សនយោបាយត្រូវចាប់បង្ខំ ស្វះស្វែងរកការគាំទ្រខាងហិរញ្ញវត្ថុពីបុគ្គលដែលមានទ្រព្យសម្បត្តិ និងស្ថាប័ន ឬសហគ្រាសដែលរកស៊ីបានធូរធា ។ ដូច្នេះហើយកើតមានការព្រួយបារម្ភថា អ្នកតំណាងជាប់ឆ្នោតមានអារម្មណ៍ជារួមថាខ្លួនត្រូវរាយការណ៍ឱ្យម្ចាស់អំណោយដែលមានឥទ្ធិពល ជាជាងរាយការណ៍ឱ្យអ្នកបោះឆ្នោតរបស់ខ្លួន ។

ជាទូទៅ គណបក្សនយោបាយត្រូវបានទទួលការវាយតម្លៃថាមានតួនាទីសំខាន់នៅក្នុងជីវភាពសភា និងនយោបាយនៅប្រទេសភាគច្រើន ។

ដើម្បីអាចមានឥទ្ធិពលទៅលើជម្រើសធំៗរបស់ជាតិ ប្រជាពលរដ្ឋ និងសមាជិកសភា ត្រូវរួបរួមចងសម្ព័ន្ធជាមួយបុគ្គលដែលមានអារម្មណ៍ដូចគ្នា ប្រសើរជាងការខិតខំដោយខ្លួនឯងទោល ។ គណបក្សនយោបាយផ្តល់នូវ "បាយអ" ចាំបាច់ដែលអនុគ្រោះឱ្យថែរក្សាឯកភាពនយោបាយរបស់ប្រទេស ។ មានតែគណបក្សនយោបាយដែលអាចស្នើដល់អ្នកបោះឆ្នោតនូវដំណោះស្រាយ និងកម្មវិធីធ្វើច្បាប់ឱ្យមានការផ្លាស់ប្តូរ ដែលមានសំណាងត្រូវបានអនុម័ត ឬក៏យ៉ាងហោចណាស់ត្រូវបានទិទាន និងត្រូវបានតស៊ូដោយប្រទាក់ក្រឡា ។ អ្នកបោះឆ្នោតដឹងច្បាស់ថាខ្លួនត្រូវបោះឆ្នោតឱ្យបេក្ខជនដែលស្នើឡើងដោយគណបក្សណាមួយនោះ ។ បេក្ខជននោះនឹងគាំទ្រ ប្រសិនបើគេបានជាប់ឆ្នោត ដល់ខ្លឹមសារនៃកម្មវិធីនយោបាយរបស់គណបក្សនោះ ព្រមទាំងថ្នាក់ដឹកនាំរបស់គណបក្ស ។ គឺអង្គធាតុគ្រោងទុកបែបនេះហើយ ដែលផ្តល់ដោយគណបក្សនយោបាយអនុញ្ញាតឱ្យអង្គបោះឆ្នោតប្រើឥទ្ធិពលជារួមទៅលើសមាសភាព និងកម្មវិធីរបស់សភា ។

ដោយមានតួនាទីជាសារវ័ន្តបែបនេះហើយ ដែលស្របទៅនឹងផលប្រយោជន៍សាធារណៈ គណបក្សនយោបាយត្រូវបានផ្តល់ហិរញ្ញប្បទានដោយសមស្រប និងមានតម្លាភាព ដើម្បីអាចបំពេញភារកិច្ចក្នុងយុទ្ធ-នាការឃោសនាបោះឆ្នោត ចាត់តាំង និងការអប់រំ ។ ប្រហែលជិតពីរទសវត្សមកហើយ គេពុំដែលដឹងអំពី

បញ្ហាហិរញ្ញប្បទានរបស់គណបក្សឡើយ ។ គេចាត់ទុកបញ្ហាហិរញ្ញប្បទាននោះដូចជាសមាគមឯកជនដូចគេដូចឯង ដែលត្រូវវាយការណ៍ឱ្យតែខ្លួនឯងប៉ុណ្ណោះ ។ ទើបតែថ្មីៗនេះ បញ្ហាហិរញ្ញប្បទានគណបក្សក្លាយជារឿងរ៉ាវនៅលើឆាក ហើយគេយល់ថាហិរញ្ញប្បទានមានឥទ្ធិពលខ្លាំងក្លានៅលើដំណើរការបោះឆ្នោត និងការទទួលខុសត្រូវរបស់សភា ។

គេបានធ្វើការសិក្សាទៅលើបញ្ហាហិរញ្ញប្បទានដល់គណបក្សនយោបាយ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ចំនួន ២២ ។ ការសិក្សានោះបង្ហាញថា មាគ៌ាដែលត្រូវដើរឆ្ពោះទៅរកការអនុវត្តឱ្យបានល្អ ភាគច្រើនពឹងផ្អែកទៅលើបរិបទជាតិផ្ទាល់ ។ ការសិក្សាបានលើកអំពីវិស័យ ៣ នៃការត្រូវយកចិត្តទុកដាក់ទៅលើបញ្ហាហិរញ្ញប្បទានដល់គណបក្សនយោបាយ :

### ១_ភាពពុំគ្រប់គ្រាន់នៃធនធាន

នេះជាបញ្ហារ៉ាំរ៉ៃនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដែលការបង់វិភាគទានមានស្ដួចស្ដើង ហើយដែលបេក្ខជន ជាញឹកញាប់ត្រូវចំណាយលើយុទ្ធនាការបោះឆ្នោតដោយប្រាក់ហោប៉ៅខ្លួនឯងផ្ទាល់ រហូតដល់ពេលខ្លះខ្លួនត្រូវដួលរលំខាងហិរញ្ញវត្ថុ ។ ដោយហេតុនេះ បេក្ខជនជាច្រើនត្រូវរក្សាទំនាក់ទំនងជាមួយម្ចាស់អំណោយឯកជនដែលរង់ចាំទទួលមកវិញនូវការជំពាក់គុណស្រ័យ ពេលដែលបេក្ខជននោះបានជាប់ឆ្នោត ។ រឿងដែលអាក្រក់ជាងនេះ អ្នកកែទម្រង់ខ្លះប្រកែកមិនឈរឈ្មោះ សុខចិត្តទុកកន្លែងឱ្យទំនេរឱ្យបេក្ខជនដែលមានទ្រព្យសម្បត្តិឈរវិញ ។

### ២_វិសមភាពខាងធនធាន

ល្បែងបោះឆ្នោតអាចមានកំហុស អាស្រ័យដោយវិសមភាពនៃមធ្យោបាយរបស់អ្នកប្រកួតប្រជែង ។ វាក៏អាចមានភាពភ្លាត់ផងដែរ កាលណាគណបក្សកាន់អំណាចប្រើដោយរំលោភនូវធនធាន ទីកន្លែង និងភាពគ្របដណ្ដប់របស់រដ្ឋាភិបាល ដើម្បីទាញយកផលប្រយោជន៍ជាប្រៀបទៅលើគណបក្សប្រឆាំង ។ មានតែគណបក្សកាន់អំណាចប៉ុណ្ណោះដែលអាចផ្ដល់កុងត្រា និងភាពអនុគ្រោះផ្សេងៗ ឬប្រើប្រាស់ដោយមិនស្របច្បាប់នូវថវិការដ្ឋ ។

### ៣_ធនធានដែលអាចអនុគ្រោះ

ទឹកប្រាក់ដែលផ្ដល់ដោយផលប្រយោជន៍របស់អ្នកខ្លាំង ដើម្បីធ្វើហិរញ្ញប្បទានលើយុទ្ធនាការបោះឆ្នោតណាមួយនោះ តែងតែរង់ចាំទទួលត្រឡប់មកវិញនូវផលប្រយោជន៍ខាងច្បាប់ ឬផលប្រយោជន៍ដទៃទៀត ដែលអាចធ្វើឱ្យអន្តរាយដល់ដំណើរការប្រជាធិបតេយ្យ ឬក៏ឱ្យវិនាសដល់ជំនឿទុកចិត្តរបស់សាធារ-

ណាជនទៅលើសុចរិតភាពរបស់រដ្ឋាភិបាល ។ នេះជាការអនុគ្រោះឱ្យ "ប្រាក់ដែលអមដោយផលប្រយោជន៍" មានឥទ្ធិពលទៅលើសមភាពនៃសិទ្ធិរបស់អ្នកបោះឆ្នោត ។

អ្វីដែលគេចង់បាន គឺសីលធម៌នៃដំណើរការបោះឆ្នោត និងសមត្ថភាពបង្កើតសភាមួយ ដែលតាមលក្ខណៈនយោបាយ ជាតំណាងឱ្យអង្គបោះឆ្នោត ។ ភាពជាតំណាងខាងសង្គមរបស់សភាត្រូវរំខានដោយថាខ្លះត្រូវប្រើទ្រព្យសម្បត្តផ្ទាល់ខ្លួនដើម្បីក្លាយខ្លួនជាបេក្ខជន ។ បញ្ហាមួយទៀត គឺសភាត្រូវរាយការណ៍ឱ្យអ្នកបោះឆ្នោត ។

## ឆ្លើយតបចំពោះការយកចិត្តទុកដាក់របស់អ្នកបោះឆ្នោត

តើត្រូវឆ្លើយតបចំពោះការយកចិត្តទុកដាក់ទាំងនោះយ៉ាងដូចម្តេច? ការសិក្សាបង្ហាញថា យុទ្ធសាស្ត្រទាំងឡាយដែលបានយកមកប្រើប្រាស់ តែងតែប្រែប្រួលយ៉ាងខ្លាំងទៅតាមបរិបទជាតិ ហើយគ្មានគំរូនៃការអនុវត្តល្អលើពិភពលោកណាមួយយកមកប្រើប្រាស់បានឡើយ ។

ប៉ុន្តែទោះបីយ៉ាងណាក៏អាចមានបន្ទាត់ដឹកនាំជាគោលខ្លះ ដែលពាក់ព័ន្ធទៅនឹងបញ្ហាហិរញ្ញប្បទានរបស់គណបក្សដែរ ។ តាមបទពិសោធន៍ គឺមិនអាចប្រើយុទ្ធសាស្ត្រតែមួយគត់បានឡើយ ចាំបាច់ត្រូវប្រើយុទ្ធសាស្ត្រចម្រុះ : យុទ្ធសាស្ត្រខាងច្បាប់ (កំណត់បទបញ្ជា) យុទ្ធសាស្ត្រឧបត្ថម្ភធន និងយុទ្ធសាស្ត្រតម្លាភាព ។

ពហុភាពនៃប្រភពធនធានត្រូវជម្រុញលើកទឹកចិត្តឱ្យមាន។ ច្បាប់ត្រូវបានអនុវត្តន៍ដោយមានប្រសិទ្ធភាព ក្រោមការត្រួតពិនិត្យរបស់ស្ថាប័នតែមួយគត់ ។ គ្មានប្រព័ន្ធណាមួយដែលអាចជិតឈឹងនោះទេ ព្រោះដំណើររបស់ប្រាក់ប្រៀបដូចជាដំណើររបស់ទឹក ហើយមនុស្សតែងចេះដើរវាងច្បាប់ ។

## យុទ្ធសាស្ត្រខាងច្បាប់ (កំណត់បទបញ្ជា)

កម្មវត្ថុនៃការកំណត់បទបញ្ជា គឺរឹតត្បិតព្រមគ្នាអំពីការស្នើសុំធនធានដោយគណបក្សនយោបាយ និងបែបបទនៃការផ្តល់ (របៀបដែលប្រាក់ត្រូវបានផ្តល់) ។

ពីខាងការស្នើសុំ មានវិធានការពីរធម្មតា ដែលអនុញ្ញាតឱ្យមានការរឹតដល់ការរត់ប្រណាំងខាងហិរញ្ញប្បទានបោះឆ្នោត ការកំណត់អំពីទឹកប្រាក់ដែលត្រូវចំណាយក្នុងយុទ្ធនាការបោះឆ្នោត និងការរឹតអំពីការផ្សព្វផ្សាយដោយបង់ប្រាក់តាមប្រព័ន្ធឃោសនា ក្នុងឱកាសបោះឆ្នោតក៏ដូចជាក្នុងចន្លោះពេលនៃការបោះឆ្នោតមួយទៅដល់ការបោះឆ្នោតមួយទៀត ។

ពីខាងការផ្តល់មូលនិធិ គេអាចហាមឃាត់ដល់ការបង់វិភាគទានលើសពីការកំណត់មួយចំនួន ឬបានមកពីប្រភពបរទេស ឬក៏បានមកពីអង្គការផ្សេងៗដែលពុំមែនជាបុគ្គល ។

ការហាមឃាត់ទាំងនេះ ត្រូវតែជាកម្មវត្ថុនៃការស្រុះស្រួលគ្នាខាងនយោបាយដោយទូលំទូលាយ ។ ប្រសិនបើគេពុំចង់ឱ្យ គេដើរវាងច្បាប់តាមរយៈមធ្យោបាយក្រឡៃបញ្ឆិតដោយប៉ិនប្រសប់នោះ ការហាមឃាត់ទាំងនោះត្រូវតែអនុវត្តន៍ឱ្យមានប្រសិទ្ធភាព ។

## យុទ្ធសាស្ត្រឧបត្ថម្ភធន

ហិរញ្ញប្បទានសាធារណៈដល់គណបក្សនយោបាយ ជារឿងអប្រជាប្រិយភាពបំផុត ។ វាអាចក្លាយជារឿងមិនល្អ ប្រសិនបើវាបំផ្លាញនូវស្មារតីផ្តួចផ្តើមគំនិតរបស់គណបក្សនយោបាយ រហូតដល់ពួកគេឈប់ស្វះស្វែងរកនូវការគាំទ្រដោយស្ម័គ្រចិត្តពីសមាជិកគាំទ្ររបស់ខ្លួន ។ តែហិរញ្ញប្បទានសាធារណៈនេះ អាចជួយឱ្យមានតួនាទីសាធារណៈកាន់តែសំខាន់ ។ ការឧបត្ថម្ភធនជាប្រភេទ (Les subventions en nature) ត្រូវបានគេវាយតម្លៃថាល្អជាងការឧបត្ថម្ភធនជាប្រាក់កាស (Les subventions en espèces) ។

ការឧបត្ថម្ភធនជាប្រភេទអាចមានច្រើនរូបភាព : ពេលវេលាឃោសនាដោយអត់បង់ថ្លៃនៅក្នុងប្រព័ន្ធឃោសនាសាធារណៈ ការចែកផ្សព្វផ្សាយដោយអត់បង់ថ្លៃនូវប័ណ្ណឃោសនា ការប្រើប្រាស់ដោយសេរីនូវអគារសាធារណៈដើម្បីរៀបចំការប្រជុំ.... ។ល ។

ការឧបត្ថម្ភធនជាប្រាក់កាស ជួនកាលដោយប្រយោល ជួនកាលមានរូបរាងជាការលើកលែងពន្ធសម្រាប់គណបក្ស ឬការបន្ថយពន្ធដល់បុគ្គល ឬក្រុមហ៊ុនដែលធ្វើអំណោយដល់គណបក្ស ។ ចំពោះការឧបត្ថម្ភធនដោយផ្ទាល់ ហួសពីកំរិតអប្បបរិមាត្រូវដាក់សន្ទស្សន៍យោងទៅលើចំនួនសមាជិកនៃគណបក្សណាមួយ ឬទៅលើការបង់វិភាគទានដែលគណបក្សនោះបានទទួល ហើយធ្វើបែបនេះដើម្បីលើកទឹកចិត្តគណបក្សឱ្យស្វះស្វែងរកនូវការគាំទ្រដោយស្ម័គ្រចិត្តពីអ្នកគាំទ្ររបស់ខ្លួន ។

ការឧបត្ថម្ភធនបំរើផងដែរ ដើម្បីលើកទឹកចិត្តឱ្យមានការអនុវត្តល្អនៅក្នុងវិស័យផ្សេងទៀត នៃសកម្មភាពរបស់គណបក្ស ដូចជាការជ្រើសរើសបេក្ខជនជាដើម ។

## យុទ្ធសាស្ត្រតម្លាភាព

នៅក្នុងប្រទេសជាច្រើន គេមាននិន្នការបិទបាំងភាពលំអិតពាក់ព័ន្ធនឹងហិរញ្ញប្បទានដល់គណបក្ស ។ ភាពលំអិតនេះត្រូវបានមនុស្សតិចបំផុតបានដឹង ។ ក្នុងវិស័យនេះក៏ដូចជាវិស័យផ្សេងទៀតដែរ មានតែតម្លាភាពប៉ុណ្ណោះដែលអនុគ្រោះឱ្យមានទំនុកចិត្តពីមហាជន ។ ប្រការនេះពឹងផ្អែកលើការអនុវត្តដោយប្រសិទ្ធភាព ហើយគ្មានហិរញ្ញប្បទានសាធារណៈណាទទួលយកបានឡើយ បើគ្មានតម្លាភាពនោះ ។ ការកាន់កាប់គណនីបើកចំហ តម្រូវឱ្យសមាជិកគណបក្ស និងសមាជិកនៃគណបក្សប្រកួតប្រជែង អាចរួមវិភាគទានដល់ការ

អនុវត្តប្រកបដោយប្រសិទ្ធភាពនូវបទបញ្ជា ។ ប្រការនេះបង្ហាញឱ្យឃើញថា ដើម្បីទទួលខុសត្រូវបានល្អ គណបក្សមួយត្រូវផ្សារភ្ជាប់ការទូទាត់របាយការណ៍តាមខ្សែបណ្តោយទៅឱ្យអង្គការជំនាញមួយ ដែលទទួលបន្ទុកធានានូវការអនុវត្តច្បាប់ និងការទូទាត់របាយការណ៍តាមខ្សែទទឹងទៅឱ្យសាធារណជន ។

ជាឧទាហរណ៍ ក្នុងការកែប្រែរដ្ឋធម្មនុញ្ញឆ្នាំ ១៩៦១ ប្រទេសក្រិកបានបញ្ចូលបទបញ្ញត្តិអំពីហិរញ្ញប្បទានគណបក្ស និងការបោះឆ្នោតដូចតទៅ :

គណៈបក្សនយោបាយមានសិទ្ធិទទួលនូវជំនួយហិរញ្ញវត្ថុពីរដ្ឋ ក្នុងនាមជាការចំណាយសម្រាប់ការបោះឆ្នោត និងដំណើរការទៅតាមល័ក្ខខ័ណ្ឌកំណត់ដោយច្បាប់ ។ បទបញ្ជាមួយនឹងបញ្ជាក់អំពីការធានាដល់តម្លាភាពចាំបាច់ក្នុងការចំណាយសម្រាប់ការបោះឆ្នោត និងជាទូទៅសម្រាប់ការចាត់ចែងគណនីរបស់គណបក្សនយោបាយ សមាជិកសភា បេក្ខជនឈរឈ្មោះបោះឆ្នោត និងបេក្ខជនឈរឈ្មោះសម្រាប់មុខងារនៅរដ្ឋបាលមូលដ្ឋាន ។ ក្រឹត្យមួយនឹងបញ្ជាក់អំពីទឹកប្រាក់អតិបរិមានៃការចំណាយបោះឆ្នោត ហាមឃាត់រូបភាពខ្លះនៃការឃោសនាមុនការបោះឆ្នោត និងបញ្ជាក់អំពីកាលៈទេសៈ ដែលការបំពានទៅលើបទដ្ឋានផ្សេងៗរបស់ច្បាប់អាចនាំឱ្យមានការបាត់បង់មុខងារសភា ។ សវនកម្មលើការចំណាយបោះឆ្នោតរបស់គណបក្សនយោបាយ និងរបស់បេក្ខជនសម្រាប់ការបោះឆ្នោតសភា ត្រូវបានប្រគល់ទៅឱ្យស្ថាប័នពិសេស ដែលមានសមាជិកជាមន្ត្រីជាន់ខ្ពស់របស់រដ្ឋបាលតុលាការ ដែលបានគ្រោងទុកដោយច្បាប់ ។

ប្រទេសកាណាដាមានច្បាប់ឆ្នាំ ២០០៤ ដែលបញ្ជាក់ដូចតទៅ

រហូតដល់ឆ្នាំ ២០០៤ មានតែបេក្ខជន និងគណបក្សនយោបាយប៉ុណ្ណោះ ដែលត្រូវប្រកាសដល់អគ្គនាយកទទួលបន្ទុកការបោះឆ្នោត អំពីប្រភព និងទឹកប្រាក់នៃការរួមវិភាគទានដែលបានទទួល ។ កាតព្វកិច្ចជូនព័ត៌មាននេះ ត្រូវបានពន្លាតចាប់ពីនេះតទៅ ដល់គ្រប់តួអង្គនៃជីវភាពនយោបាយ ដែលមានបេក្ខជន គណបក្សនយោបាយ សមាគមបោះឆ្នោតថ្នាក់ស្រុក បេក្ខជនសម្រាប់មុខតំណែងដឹកនាំ និងបេក្ខជនចូលកាន់តំណែង ។ រាល់តួអង្គទាំងអស់នៃជីវភាពនយោបាយត្រូវប្រកាសអំពីវិភាគទានដែលលើសពី ២០០$ ។ រហូតដល់ឆ្នាំ២០០៤ វិភាគទាននេះអាចចេញមកពីបុគ្គល ក្រុមហ៊ុន សហជីព ឬអង្គការផ្សេងទៀត ហើយទឹកប្រាក់ពុំមានកំណត់ចំនួនឡើយ ។ ចាប់ពីពេលនេះតទៅ មានតែបុគ្គល គឺប្រជាពលរដ្ឋ និងអ្នកមានទីលំនៅអចិន្ត្រៃយ៍ប៉ុណ្ណោះ ដែលអនុញ្ញាតឱ្យធ្វើវិភាគទានហិរញ្ញវត្ថុដល់គណបក្សដែលបានចុះឈ្មោះដោយត្រឹមត្រូវ និងដល់បេក្ខជនសម្រាប់មុខតំណែងដឹកនាំ និងចូលកាន់តំណែង ។ ការរួមវិភាគទាននេះត្រូវបានកំណត់ត្រឹម ៥០០០$ ក្នុងមួយឆ្នាំ ។

ដើម្បីទូទាត់ដល់គណបក្សពីការបាត់បង់ចំណូលបណ្ដាលមកពីការកែប្រែនេះ ទៅលើបទបញ្ជានៃអំណោយ គេបានគ្រោងផ្ទេរជារៀងរាល់ឆ្នាំដល់គណបក្ស ដែលបានចុះឈ្មោះដោយត្រឹមត្រូវនូវទឹកប្រាក់ ១.៧៥$ សម្រាប់មួយសម្លេងដែលគណបក្សនេះបានទទួលកាលពីការបោះឆ្នោតទូទៅ (ទឹកប្រាក់នេះអាចកែតម្រូវដោយគិតដល់អតិផរណា) ហើយលុះណាតែគណបក្សនោះបានទទួលសម្លេងគាំទ្រ ២% ដែលមានសុពលភាពក្នុងកំរិតជាតិ គឺ៥% នៃសម្លេងនៅក្នុងមណ្ឌលដែលខ្លួនបានដាក់បេក្ខជន ។ បទបញ្ជានេះត្រូវបានរៀបចំ ដើម្បីកុំឱ្យមានផលវិបាកទៅលើចំណូលជាតិ ពីព្រោះគេគិតថា គណបក្សនយោបាយដែលមានហិរញ្ញប្បទានល្អ រួមវិភាគទានដល់ភាពជាប់លាប់នៃដំណើរការបោះឆ្នោត ។ ការកែប្រែនេះ គឺជាការជម្រុញអ្នករួមវិភាគទានផងដែរ ព្រោះផ្នែកនៃអំណោយត្រូវបានរួចពន្ធ ៧៥% អាចឡើងពី ២០០$ ទៅ ៤០០$ ។

## ស្ថាបជីពចររបស់សាធារណជន

របៀបមួយដើម្បីដឹងអំពីការទទួលខុសត្រូវរបស់សភា តម្រូវឱ្យស្ទាបជីពចររបស់សាធារណជនឱ្យបានជាប្រក្រតី តាមរយៈការស្ទង់មតិ ។ ក្នុងឋានៈជាស្ថាប័ន សភាតែងទទួលនូវការវាយតម្លៃនៅក្នុងស្មារតីរបស់សាធារណជន ។ ជាឧទាហរណ៍ ប្រទេសនៅក្នុងសហគមន៍អឺរ៉ុបតែងមានស្ថិតិជានិច្ច ហើយបានបង្ហាញអំពីការធ្លាក់ចុះនៃជំនឿទុកចិត្តរបស់សាធារណជនចំពោះសភា នៅពាក់កណ្ដាលទសវត្សរ៍៨០ និងចុងទសវត្សរ៍៩០ ។

ការរកឃើញបានបង្ហាញថា ប្រជាពលរដ្ឋចូលចិត្តអ្នកតំណាងមូលដ្ឋានរបស់ខ្លួនច្រើនជាងស្ថាប័នសភា ព្រោះនេះជាបរិបទមូលដ្ឋាន ហើយទំនាក់ទំនងរវាងបុគ្គល គឺរឿងសំខាន់នៅក្នុងប្រព័ន្ធតំណាង ។

ការពុំទុកចិត្តសភាក៏ស្ថិតនៅក្នុងបរិបទទូទៅ ដែលប្រជាពលរដ្ឋពុំកក់ក្ដៅចំពោះស្ថាប័នសាធារណៈទាំងមូល ។

បញ្ហាមួយទៀតក៏មានចំណងទាក់ទងនឹងការធ្លាក់ចុះកិត្តិស័ព្ទរបស់សភា ដោយអំពើប្រព្រឹត្តរបស់សមាជិកសភាខ្លួនឯង និងការបាត់បង់សមាជិករបស់គណបក្សនយោបាយដែលមានអសនៈក្នុងសភា ដោយបែកបាក់គ្នា ។

ក្នុងដំណាក់កាលនៃសាកលភាវូបនីយកម្ម បញ្ហាខ្លះដែលប៉ះពាល់ដល់សុខុមាលភាពរបស់ប្រជាពលរដ្ឋពុំស្ថិតនៅក្នុងដៃនៃសមត្ថកិច្ចស្ថាប័ននយោបាយជាតិឡើយ ។

## សភាអាចបង្កឥទ្ធិពលទៅលើសាធារណៈមតិ

កំរិតនៃការធ្លាក់ចុះជំនឿទុកចិត្តរបស់សាធារណជនទៅលើសភា អាចបណ្ដាលមកពីដំណើរការសង្គមកាន់តែទូលាយ ដែលសភាពុំបានចាប់អារម្មណ៍អើពើ ។

ដើម្បីកែប្រែមុខមាត់ មានការខិតខំជាច្រើនដូចជា ធ្វើឱ្យសភាកាន់តែមានលក្ខណៈតំណាង កាន់តែតម្លាភាព កាន់តែខិតចូលជិតបាន ។ នេះក៏ដើម្បីទប់ទល់ទៅនឹងការទិទានផ្សេងៗក្នុងឱកាសនៃការស្ទង់មតិ ។

ការកែទម្រង់ដែលសភាជាច្រើនប្រកាន់យក គឺសំដៅកែប្រែមុខមាត់សាធារណៈ និងការចាប់អារម្មណ៍ដែលគេបានទទួល ។

ជាឧទាហរណ៍ សភាស៊ុយអែតបានកត់សម្គាល់ថា ហាក់ដូចជាមានការគាំទ្រពីសាធារណជនច្រើនជាងមុនដល់សភា បន្ទាប់ពីរយៈពេល១០ឆ្នាំ នៃការខិតខំបើកចំហ និងធ្វើឱ្យតម្លាភាព ។ ប្រជាពលរដ្ឋមានអារម្មណ៍ថា សព្វថ្ងៃនេះងាយស្រួលនឹងទាក់ទងជាមួយសភា ហើយចង់ដឹងច្រើនអំពីសភា ។

សភាទួរគីបានបញ្ជាក់ថា បន្ទាប់ពីខិតខំឱ្យកាន់តែបើកចំហ និងចូលជិតបាន លេខរៀងនៃជំនឿទុកចិត្តក្នុងចំណោមស្ថាប័នជាតិ បានឡើងពីលេខ១០ មកលេខ៤ វិញ ។

ឧទាហរណ៍ទាំងនេះបញ្ជាក់ថា គេអាចកែសម្រួលទំនុកចិត្តរបស់សាធារណជនមកលើសភាបាន ក្នុងឋានៈជាស្ថាប័ន ។ វាចាំបាច់ សភានីមួយៗត្រូវធ្វើការស្ទាបស្ទង់មតិជាប្រព័ន្ធដើម្បីដឹងថា អ្នកបោះឆ្នោតគិតពីសភាយ៉ាងណា ។ វាជាការមានផលប្រយោជន៍ ដើម្បីវាយតម្លៃអំពីផលប៉ះពាល់ទៅលើសាធារណជន បណ្តាលមកអំពីវិធានការប្រជាធិបតេយ្យដែលសភា ឬរដ្ឋាភិបាលប្រកាន់យក ។

## VI-សភាប្រកបដោយប្រសិទ្ធភាព

### (១)_គោលជាតិ

តើសភាត្រូវរៀបចំខ្លួនយ៉ាងម៉េច ដើម្បីបំពេញភារកិច្ចសំខាន់ៗរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព?

ពាក្យថា "ប្រសិទ្ធភាព" វាមានតម្លៃប្រជាធិបតេយ្យ តែមានសារសំខាន់បំផុតកាលណានិយាយដល់មុខងារចាំបាច់នៃដំណើរការប្រជាធិបតេយ្យ ការងារធ្វើច្បាប់ ត្រួតពិនិត្យសកម្មភាពរបស់អង្គនីតិប្រតិបត្តិ ត្រួតពិនិត្យហិរញ្ញវត្ថុ... ។ល ។

ផលប្រយោជន៍របស់អ្នកបោះឆ្នោតនឹងពុំអាចបំរើបានល្អឡើយ កាលណាសភាគ្មានធនធានគ្រប់គ្រាន់ដើម្បីអនុវត្តន៍នូវតួនាទីរបស់ខ្លួន កាលណាសភាខ្វះខ្វាយថវិកាសាធារណៈ ឬគ្មានប្រសិទ្ធភាពនៅក្នុងការប្រើប្រាស់ធនធានរបស់ខ្លួន ។

បញ្ហានេះមានទាំងទិដ្ឋភាព "បច្ចេកទេស" ឬ "នីតិវិធី" តែមានផលប៉ះពាល់ទៅលើលទ្ធផល មិនថាលើច្បាប់ដែលបានអនុម័ត ឬការចំណាយដែលបានធ្វើសម្រាប់ការរីកចំរើនរបស់សមូហភាព ។

ទិដ្ឋភាពមួយទៀតនៃប្រសិទ្ធភាពរបស់សភា គឺសមត្ថភាពរបស់សភាដើម្បីលើកតម្កើង និងថែរក្សាឯកភាពជាតិ ជាពិសេស ក្នុងករណីដែលឯកភាពជាតិនេះត្រូវបានគម្រាមកំហែង ។

ប្រសិទ្ធភាពរបស់សភាផ្សារភ្ជាប់ទៅនឹងពាក្យថា "អំណាច" ដែលមានន័យច្រើន តែមានន័យពីរសំខាន់

១- អំណាចក្នុងនាមជាសមត្ថភាព មានសិទ្ធិធ្វើច្បាប់ និងធនធាន (ហិរញ្ញវត្ថុ មនុស្ស និងការចាត់តាំង) ដើម្បីសម្រេចភារកិច្ចចាំបាច់ ។

២- អំណាចក្នុងន័យជាទំនាក់ទំនង មានអំណាចគ្រប់គ្រាន់ និងឯករាជ្យភាព ដើម្បីត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពលើសកម្មភាពរបស់អង្គនីតិប្រតិបត្តិ ។ សភាត្រូវរកឱ្យឃើញនូវតុល្យ-ភាពរវាងសហប្រតិបត្តិការជាមួយអង្គនីតិប្រតិបត្តិ និងការត្រួតពិនិត្យទៅលើអង្គនីតិប្រតិបត្តិ ។ ការរារាំងទាំងស្រុង ឬដោយសាមញ្ញតែងប្រឆាំងនឹងផលប្រយោជន៍សាធារណៈ ។

ប៉ុន្តែគ្រោះថ្នាក់សំខាន់នៅក្នុងពិភពលោកបច្ចុប្បន្ន គឺគ្រោះថ្នាក់នៃការគ្របដណ្តប់របស់អង្គនីតិប្រតិ-បត្តិ ដោយមកពីសភាគ្មាននូវសមត្ថភាពចាំបាច់ ឬដោយសភាពុំចង់ប្រតិបត្តិនូវអំណាចដែលខ្លួនមាន ។

មានភាពខុសគ្នារវាងប្រព័ន្ធប្រធានាធិបតី និងប្រព័ន្ធសភា ។ នៅក្នុងករណីប្រព័ន្ធប្រធានាធិបតី ខ្សែបន្ទាត់បែងចែករវាងអង្គនីតិប្រតិបត្តិ និងអង្គនីតិបញ្ញត្តិមានកំណត់ច្បាស់ជាង ។ លក្ខណៈមួយនៃប្រព័ន្ធប្រធានាធិបតីខ្លះដូចជានៅទ្វីបអាមេរិកឡាទីនជាដើម គឺអសមត្ថភាពរបស់ប្រធានាធិបតី ដើម្បីមាននៅក្នុងសភានូវសម្លេងភាគច្រើនក្រៅពីសម្លេងភាគច្រើនបណ្តោះអាសន្ន ។ តែក្នុងករណីបែបនេះក៏ដោយ ភាពទន់ខ្សោយ ឬអប្រសិទ្ធភាពរបស់សភា ពុំបានបំរើនូវផលប្រយោជន៍នៃលទ្ធិប្រជាធិបតេយ្យឡើយ ។

ការសិក្សាអំពីវឌ្ឍនភាពនៃប្រជាធិបតេយ្យូបនីយកម្មនៅអតីតរដ្ឋដែលធ្លាប់ប្រកាន់របបកុម្មុយនីស្តបានបង្ហាញឱ្យឃើញថា ពុំមែនប្រព័ន្ធធម្មនុញ្ញ (ប្រធានាធិបតី ពាក់កណ្តាលប្រធានាធិបតី ឬសភា) ឡើយដែលកំណត់នូវកំរិត និងគុណភាពនៃដំណើរការប្រជាធិបតេយ្យូបនីយកម្ម ។ តាមពិតទៅគ្មានអ្វីក្រៅអំពីអំណាច និងប្រសិទ្ធភាពនៃអង្គនីតិបញ្ញត្តិរបស់ខ្លួនឯងប៉ុណ្ណោះដែលជាកត្តាកំណត់ ។

អាស្រ័យហេតុនេះ គឺអំណាចនីតិបញ្ញត្តិខ្លាំង ដែលត្រួតពិនិត្យបានល្អប្រសើរនូវអង្គនីតិប្រតិបត្តិ ហើយជម្រុញថែមទៀតនូវការបង្កើតគណបក្សនយោបាយ ។ កម្លាំងរបស់អំណាចនីតិបញ្ញត្តិជាតិ គឺជាកូនសោរមួយ (កូនសោរធម្មនុញ្ញ) នៃប្រជាធិបតេយ្យូបនីយកម្មសង្គម ។

នៅក្នុងរបបដែលមានអង្គនីតិបញ្ញត្តិខ្សោយ អ្នកប្រជាធិបតេយ្យត្រូវចាត់ទុកអាទិភាពទី១របស់ខ្លួនថា ត្រូវតែខិតខំពង្រឹងអង្គនីតិបញ្ញត្តិ ។

សភាមួយដែលសន្មត់ថាខ្លាំង ឬមានប្រសិទ្ធភាព ត្រូវគិតដល់ :

- បរិក្ខា និងការចាត់តាំងរបស់សភា
- មធ្យោបាយដើម្បីកែលំអនីតិវិធីធ្វើច្បាប់
- ការត្រួតពិនិត្យសកម្មភាពរបស់អង្គនីតិប្រតិបត្តិ
- នីតិវិធីត្រួតពិនិត្យថវិកា និងហិរញ្ញវត្ថុ
- តួនាទីក្នុងការលើកតម្កើងឯកភាពជាតិតាមមធ្យោបាយប្រជាធិបតេយ្យ

**<u>បរិក្ខា និងការចាត់តាំងរបស់សភា</u>**

មានភាពខុសគ្នាដ៏សម្បើមរវាងធនធាន និងបរិក្ខារបស់សភានៅក្នុងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ ។

ប្រទេសកំពុងអភិវឌ្ឍន៍មានការកៀបសង្កត់ដ៏ធំទៅលើថវិកា អាស្រ័យដោយសេចក្តីត្រូវការជាអាទិ-ភាពនៃការអភិវឌ្ឍជាតិ ។

កាលណាសភាមួយមានធនធានគ្រប់គ្រាន់ (ដូចជាប្រទេសអភិវឌ្ឍន៍) សភាត្រូវមានដូចតទៅ

- បុគ្គលិកគ្រប់គ្រាន់ដែលមានឯកទេស ដើម្បីផ្តល់សេវាមិនប្រកាន់បក្ខពួកដល់សមាជិកសភានៅគ្រប់ប្រភេទនៃវិស័យសកម្មភាពរបស់សភា ។
- បណ្ណាល័យមួយ និងមានសេវាឯកសារប្រកបដោយប្រសិទ្ធភាព ។
- ការិយាល័យសម្រាប់សមាជិកសភាប្រើប្រាស់ ដោយមានលេខាធិការដ្ឋានផ្ទាល់ និងមធ្យោបាយរៀបចំឯកសារ និងវិភាគផ្ទាល់ ។
- បរិក្ខាសម្រាប់គណបក្សប្រឆាំងសំខាន់ៗ ។

នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ បរិក្ខាទាំងនេះពុំគ្រប់គ្រាន់ឡើយ (ជួនកាលគ្មានតែម្តង) ដោយខ្វះធនធាន និងបុគ្គលិកដែលមានឯកទេស ។

គួយ៉ាងដូចជានៅប្រទេស Afrique du Sud ទោះបីក្របខ័ណ្ឌរដ្ឋបាលរបស់គណៈកម្មការឡើងពី ១០នាក់ ទៅ ១៦៤នាក់ក្តី ក៏សមាជិកសភានៅតែត្អូញត្អែរថា ចំនួនបុគ្គលិករដ្ឋបាលនៅពុំទាន់គ្រប់គ្រាន់ ហើយចំពោះការងារធ្វើពុំទាន់មានប្រសិទ្ធភាពនៅឡើយ ។

កាលណាសភាមានធនធានតិច ដូច្នេះសមត្ថភាពពុំគ្រប់គ្រាន់ទេនោះ ប្រការនេះនាំឱ្យមានផលវិបាកអវិជ្ជមានជៀសពុំផុត ទៅលើលំនឹងនៃអំណាចជាមួយអង្គនីតិប្រតិបត្តិ ។ ការងារត្រួតពិនិត្យរបស់សភាមិនសូវហ្មត់ចត់ ។ សមាជិកសភាត្រូវពឹងផ្អែកទៅលើអ្នកឯកទេសខាងរដ្ឋាភិបាល ដែលឈរនៅជាមួយខាងអង្គនីតិប្រតិបត្តិ ។ រដ្ឋាភិបាលតែងចង់ដើរវាងសភាទាំងស្រុង នៅពេលរដ្ឋាភិបាលត្រូវកំណត់អំពីគោលនយោបាយរបស់ខ្លួន ឬក៏សរសេរច្បាប់ ។ ជាផលវិបាក សភាត្រូវអស់តម្លៃចំពោះមុខភ្នែករបស់ប្រជាពលរដ្ឋ តួនាទីរបស់សភាពុំត្រូវបានគេស្គាល់ និងយល់ដឹង ហើយសភាលែងមានអំណាចដើម្បីទាមទារនូវធនធានបន្ថែម ទៅលើថវិកាជាតិដែលមានកំរិត ។

សភាជាច្រើនបានដាក់ចេញនូវយុទ្ធសាស្ត្រសំដៅកែប្រែបញ្ហាធនធាននេះ ដូចតទៅ :

- ការបណ្តុះបណ្តាលកាន់តែមានប្រសិទ្ធភាពចំពោះសមាជិកសភាខ្លួនឯង ដែលត្រូវបានលើកទឹកចិត្តឱ្យមានឯកទេស ។
- ការស្វះស្វែងរកជាប្រព័ន្ធនៅក្នុងវិស័យផ្សេងៗ នូវអ្នកឯកទេសដែលចេញមកពីសង្គមស៊ីវិល និងមជ្ឈដ្ឋានសាកលវិទ្យាល័យ ដើម្បីគាំទ្រការងាររបស់គណៈកម្មការ និងក្រុមសមាជិកសភា ។
- កម្មវិធីកម្មសិក្សាសំដៅលុបបំបាត់ការខ្វះខាតធនធានរបស់សភា ។
- មធ្យោបាយតាម Internet ដើម្បីបង្កើនសមត្ថភាពវិភាគ និងឯកសាររបស់សភា ជាពិសេសនៅក្នុងបណ្ណាល័យ ។

កម្មវិធីពង្រឹងសមត្ថភាពសមាជិកសភា និងបុគ្គលិករដ្ឋបាល គឺជាវិស័យមួយដែលការឧបត្ថម្ភពីខាងក្រៅអាចនាំឱ្យមានការប្រែប្រួលនៅក្នុងប្រទេសប្រជាធិបតេយ្យក្មេងខ្ចី ។ គឺក្នុងមូលហេតុនេះហើយ ដែលកម្មវិធីទាំងនេះត្រូវបានគាំទ្រដោយអង្គការផ្សេងៗដូចជា សហភាពអន្តរសភា និងអង្គការអន្តរជាតិខាងអភិវឌ្ឍន៍ជាច្រើន ។

ប៉ុន្តែគេពុំត្រូវគិតថា ប្រភេទនៃការជួយឧបត្ថម្ភពីខាងក្រៅអាចជំនួសបរិញ្ញប្បទានសមស្របពីថវិកាជាតិបានឡើយ ។

តាមការសិក្សារបស់សហភាពអន្តរសភាពីការចំណាយរបស់សភានានាចំនួន៥២ប្រទេស នាឆ្នាំ១៩៩៩ បង្ហាញថា ភាគនៃថវិកាជាតិដែលបានបែងចែកឱ្យសភា ស្ថិតនៅចន្លោះ 0.0១% (Danemark) និង ១.៦% (Grèce) ។ តាមតួលេខនេះសភាពុំត្រូវបានចាត់ទុកថា ជាអ្នកចាយលុយច្រើនឡើយ ។

## ស្វយ័តភាពរបស់សភា

ក្រៅពីកិរិតនៃធនធាន និងចំនួនបុគ្គលិក នៅមានទស្សនៈជាគោលដែលថា សភាត្រូវតែឯករាជ្យពីអង្គនីតិប្រតិបត្តិនៅក្នុងរបៀបចាត់តាំង ត្រូវធ្វើជាម្ចាស់នៃប្រក្រតីទិនការងារផ្ទាល់ ហើយអាចកោះប្រជុំក្រៅពីសម័យប្រជុំសាមញ្ញកាលណាកាលៈទេសៈតម្រូវ ។ នេះជាចំណុចជាក់ស្តែង ដែលខុសគ្នាខាងធម្មនុញ្ញរវាងប្រព័ន្ធប្រធានាធិបតី និងប្រព័ន្ធសភា ។ ក្នុងប្រព័ន្ធប្រធានាធិបតី ការពិបាកត្រង់បង្កើតឱ្យមានកិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពរវាងអង្គនីតិបញ្ញត្តិ និងអង្គនីតិប្រតិបត្តិ ។ ក្នុងប្រព័ន្ធសភា ការពិបាកត្រង់រៀបចំឱ្យមានឯករាជ្យភាពពិតប្រាកដ ឬស្វ័យតភាពនៅក្នុងការចាត់តាំង ។

តើអ្វីទៅជាស្វ័យតភាពរបស់សភា?

សមាគមអគ្គលេខាធិការសភាពិភពលោក (ASGP) បានកំណត់នាឆ្នាំ១៩៩៨ អំពីបរិបទនេះ ដូចតទៅ :

ស្វ័យភាព គឺមួយផ្នែក ការមិនរណប និងការមិនចំណុះរបស់សភាទៅនឹងអង្គនីតិប្រតិបត្តិ ។ មួយផ្នែកទៀត សភាមានលទ្ធភាព និងមានសេរីភាព យ៉ាងហោចខ្លះៗ ដកខ្លួនចេញពីច្បាប់ធម្មតា ដើម្បីដើរតាមបទបញ្ជារបស់ខ្លួនឯងផ្ទាល់ ។

នៅក្នុងរដ្ឋជាច្រើន គោលការណ៍នៃស្វ័យភាពរបស់សភាមានចែងជាផ្លូវការនៅក្នុងអត្ថបទរដ្ឋធម្មនុញ្ញដែលនិយាយអំពីការចែកអំណាចដាច់ពីគ្នា ។ លើការជាក់ស្តែង និន្នាការទូទៅ គឺសំដៅការពង្រឹងនូវគោលការណ៍នេះ ។

សភា Slovénie បានលើកករណីដូចតទៅ

- ទទួលបន្ទុកជ្រើសរើសបុគ្គលិកផ្ទាល់
- ត្រួតពិនិត្យលើថវិកាផ្ទាល់របស់ខ្លួន
- រៀបចំការងាររបស់សភាតាមបំណងរបស់សភា

សភាឥណ្ឌា និងកាណាដា ជ្រើសរើសបុគ្គលិកសភាឯករាជ្យពីរដ្ឋ និងពីមុខងារសាធារណៈ ព្រមទាំងពីគណបក្សនយោបាយ ។

ស្វ័យតភាពរបស់សភានាំឱ្យមានការបង្កើតនូវសេវាច្បាប់ឯករាជ្យ ទទួលបន្ទុកផ្តល់យោបល់ដល់សភាអំពីវិសាលភាពខាងច្បាប់ នៃសកម្មភាពរបស់រដ្ឋាភិបាល ព្រមទាំងការតាក់តែងសេចក្តីស្នើច្បាប់ ។

ជាឧទាហរណ៍ សភាអ៊ីស្រាអែលបានប្រមូលផ្តុំសេវាច្បាប់របស់ខ្លួនបង្កើតជានាយកដ្ឋានមួយ ដែលបំរើគ្រប់សកម្មភាពសភាទាំងអស់ ។

## **ការត្រួតពិនិត្យថវិកា**

នៅក្នុងសភាមួយ ឯករាជ្យភាពគឺជាការត្រួតពិនិត្យទៅលើថវិការបស់សភាដោយខ្លួនឯងផ្ទាល់ ។

សហភាពអន្តរសភាបានកំណត់អំពីសភា និងថវិកាដូចតទៅ

ស្របតាមគោលការណ៍ជាគ្រឹះអំពីការបែងចែកអំណាចដាច់ពីគ្នា ថវិកាផ្ទៃក្នុងរបស់សភាត្រូវបានរៀបចំនៅក្រោមការទទួលខុសត្រូវរបស់សភា ហើយត្រូវបញ្ជូនឱ្យរដ្ឋាភិបាលដើម្បីបញ្ចូលទៅក្នុងថវិការដ្ឋ ។ អង្គនីតិប្រតិបត្តិពុំត្រូវតាំងខ្លួន នាឱកាសនោះ ជាចៅក្រមអារកាត់អំពីមធ្យោបាយដែលសភាត្រូវការ ដើម្បីប្រតិបត្តិបេសកកម្មរបស់ខ្លួនឡើយ ។

នៅប្រទេសបារាំង ស្វ័យតភាពខាងហិរញ្ញវត្ថុគឺដាច់ខាត ទាំងលើការរៀបចំថវិកា ការបោះឆ្នោតលើថវិកា ទាំងការអនុវត្តថវិកា ។

សភាថ្មីៗនៅអាហ្វ្រិកតែងមានបំណងប្រាថ្នាស្របច្បាប់ ដើម្បីរំដោះខ្លួនពីភាពជាអាណាព្យាបាលរបស់រដ្ឋាភិបាល ជាពិសេស របស់ក្រសួងហិរញ្ញវត្ថុ ។

## **ភាពធ្វើជាម្ចាស់នៃប្រក្រតីទិនការងាររបស់សភា**

សភាមួយដែលស្វយ័តត្រូវតែធ្វើខ្លួនឯងជាម្ចាស់នៃរបៀបវារៈប្រចាំថ្ងៃរបស់ខ្លួន អំពីពេលវេលាបែងចែកសម្រាប់ចំណុចនីមួយៗដែលត្រូវពិនិត្យ និងបែងចែកសម្រាប់ក្រុមសភានានា ។

ក្នុងប្រព័ន្ធសភាតាមប្រពៃណី Westminster ពីមុនរបៀបវារៈ ជាទូទៅត្រូវកំណត់ដោយការព្រមព្រៀងគ្នារវាងអ្នកដឹកនាំប្រចាំនៅសភា (ប្រធាននៃក្រុមភាគច្រើនរបស់សភា-រដ្ឋមន្ត្រី១រូប) ប្រធានគណបក្សប្រឆាំង និងប្រធានក្រុមសភា ។ បច្ចុប្បន្ននេះកិច្ចព្រមព្រៀងទាំងនេះ ត្រូវផ្ទុកផ្តាក់ទៅឱ្យគណៈកម្មការមួយរបស់សភា ដែលទទួលបន្ទុករៀបចំរបៀបវារៈប្រចាំថ្ងៃ ដែលក្នុងនោះមានតំណាងរបស់ក្រុមនយោបាយទាំងអស់ ក្រោមការដឹកនាំរបស់ប្រធានសភា ។

## **កែលំអដំណើរការធ្វើច្បាប់**

សភាជាច្រើនបានខិតខំរកដំណោះស្រាយ ដើម្បីរៀបចំដំណើរការធ្វើច្បាប់ឱ្យបានកាន់តែល្អប្រសើរជៀសវាងយ៉ាងណាកុំឱ្យការកៀបសង្កត់នៃពេលវេលា រារាំងដល់ការពិនិត្យសេចក្តីព្រាងច្បាប់ឱ្យបានគ្រប់ជ្រុង

ជ្រោយ ហើយអាទិភាពត្រូវប្រមូលផ្តុំទៅលើអង្គធាតុទាំងឡាយ (ដែលមាននៅក្នុងសេចក្តីព្រាងច្បាប់) ដែលចាត់ទុកសំខាន់បំផុត ឬរសើបបំផុត ។

ជាឧទាហរណ៍ រដ្ឋសភាអ៊ីតាលីបានរៀបចំនូវកម្មវិធីហ្មត់ចត់ជាងមុនសម្រាប់ការងារធ្វើច្បាប់របស់ខ្លួន ព្រោះដំណើរការត្រូវរាំងស្ទះដោយវិសោធនកម្មច្រើនពេក ហើយសម័យប្រជុំការងារត្រូវធ្វើច្រើនលើក ហើយនៅតែមិនចប់ទៀត ។ ដើម្បីដោះស្រាយបញ្ហានេះ សភាអ៊ីតាលីបានបង្កើតប្រក្រតីទិន-កម្មវិធីសម្រាប់សេចក្តីព្រាងច្បាប់ ដោយស្នើសុំឱ្យក្រុមសភាសម្រាំងយកតែវិសោធនកម្មមួយចំនួនមកសុំការអនុម័ត ទៅតាមតម្រូវការរបស់ខ្លួន ។

ដូចគ្នានេះដែរ រដ្ឋសភាអង់គ្លេសយោងទៅតាមសំណើរបស់គណៈកម្មការទំនើបកម្មរបស់ខ្លួន បានរៀបចំកម្មវិធីជាប្រព័ន្ធទៅលើការងារធ្វើច្បាប់ ដោយបែងចែកប្រក្រតីទិនសម្រាប់ការដាក់យកមកពិនិត្យលើសេចក្តីព្រាងច្បាប់នីមួយៗ ដែលធ្វើឱ្យអាចគ្រោងផែនការ និងជៀសវាងការកាត់បន្ថយពេលវេលាភ្លាមៗនៃការពិភាក្សាដោយសារអស់ពេលវេលា ។

**<u>គុណភាពរបស់ច្បាប់</u>**

លក្ខណៈវិនិច្ឆ័យមួយទៀត ចោទអំពីបញ្ហាគុណភាពរបស់សេចក្តីព្រាងច្បាប់ដែលជាការយកចិត្តទុកដាក់របស់សភាជាច្រើន ដែលប្រឈមមុខនឹងអត្ថបទច្បាប់ជាច្រើន ជាពិសេសនៅក្នុងប្រទេសទាំងឡាយដែលច្បាប់ត្រូវសមស្របទៅនឹងការតម្រូវរបស់សហគមន៍អឺរ៉ុប ។

ដើម្បីដោះស្រាយបញ្ហាមិនគ្រប់គ្រាន់នៅក្នុងការតាក់តែងច្បាប់ សភាដាណឺម៉ាក ជាឧទាហរណ៍បានបង្កើតនូវគណៈកម្មការការងារចម្រុះមួយជាមួយរដ្ឋាភិបាលស្តីពីគុណភាពរបស់ច្បាប់ ។ អាស្រ័យហេតុនេះ ខាងរដ្ឋាភិបាលបានកំណត់នូវសេចក្តីណែនាំលំអិតដល់មន្ត្រីនៃក្រសួង ដែលទទួលបន្ទុករៀបចំអត្ថបទច្បាប់ ដោយគូសបញ្ជាក់អំពីល័ក្ខខ័ណ្ឌដែលការងារត្រូវឆ្លើយតប ។ ម្យ៉ាងទៀត រាល់សេចក្តីព្រាងច្បាប់ត្រូវបង្ហាញអំពីផលវិបាកខាងហិរញ្ញវត្ថុ និងរដ្ឋបាល ដែលអាចចេញមកពីអត្ថបទច្បាប់នេះ ទៅលើវិស័យសាធារណៈ និងវិស័យឯកជន ផលវិបាកទៅលើបរិស្ថាន និងដល់បទបញ្ញត្តិរបស់សហគមន៍ ។

ធម្មនុញ្ញភាពរបស់សេចក្តីព្រាងច្បាប់ គឺជាទិដ្ឋភាពមួយទៀតនៃគុណភាពដែលត្រូវគិតគូរដល់ ។

នៅសភាហ្វាំងឡង់ ការទទួលខុសត្រូវនេះធ្លាក់ទៅលើប្រធានសភា ដោយការជួយឧបត្ថម្ភពីគណៈ-កម្មការនីតិកម្មធម្មនុញ្ញ ។ គណៈកម្មការនេះត្រួតពិនិត្យមើលទៅលើធម្មនុញ្ញភាព ដោយសហការជាមួយសាស្ត្រាចារ្យនៃសាកលវិទ្យាល័យជាអ្នកឯកទេសខាងធម្មនុញ្ញ ដែលត្រូវអញ្ជើញឱ្យមកជួយផ្តល់យោបល់ដល់

គណៈកម្មការ ។ បើកត់សម្គាល់ឃើញមានចន្លោះ គណៈកម្មការត្រូវបង្ហាញពីរបៀបដែលធ្វើឱ្យអត្ថបទច្បាប់សមស្របទៅនឹងធម្មនុញ្ញ ។

សភាក្រិកមានសេវាវិទ្យាសាស្ត្រដែលមានសមាសភាពជាអ្នកច្បាប់មកពីសាកលវិទ្យាល័យ ដើម្បីបង្ហាញតាមរយៈរបាយការណ៍អំពីភាពទំនាស់ជាយថាហេតុរវាងសេចក្តីព្រាងច្បាប់ និងរដ្ឋធម្មនុញ្ញ ច្បាប់ជាតិ អន្តរជាតិ ឬអឺរ៉ុប ព្រមទាំងចន្លោះដែលអាចកើតមាន ។

ទិដ្ឋភាពមួយទៀតនៃគុណភាពរបស់ច្បាប់ ភាពច្បាស់លាស់នៃអត្ថបទ ។ សភាអ៊ីតាលីបានបង្កើតគណៈកម្មការនីតិកម្មពិសេសមួយ ដែលមានសមាជិកស្មើគ្នាមកពីគណបក្សសម្លេងភាគច្រើន និងគណបក្សប្រឆាំងដែលវាយតម្លៃទៅលើគុណភាពនៃអត្ថបទច្បាប់ អំពីសភាគភាព (Homogéneité) ភាពសាមញ្ញ (Simplicité) ភាពច្បាស់លាស់ (Clarté) និងភាពត្រឹមត្រូវនៃអង្គសេចក្តី (La justesse de leur énoncé) ព្រមទាំងប្រសិទ្ធភាពរបស់អត្ថបទទាំងនេះសម្រាប់ការធ្វើឱ្យសាមញ្ញ (Simplification) និងការរៀបចំឡើងវិញ (La Réorganisation) នៃច្បាប់ជាធរមាន ហើយលើមូលដ្ឋាននៃការកំណត់នេះ ជូនយោបល់ដល់គណៈកម្មការ ។

**មធ្យោបាយអេឡិចត្រូនិច**

គឺនៅក្នុងវិស័យនៃការងារធ្វើច្បាប់ ដែលការដាក់ប្រើប្រាស់នូវមធ្យោបាយបច្ចេកវិទ្យាព័ត៌មានសំរាប់សមាជិកសភាមានសារសំខាន់បំផុត ។

សភាជាច្រើនពុំទាន់បានចូលក្នុងដំណាក់កាលដំបូងនៃដំណើរការនេះនៅឡើយទេ ។ ប៉ុន្តែមានសភាមួយចំនួនកំពុងឆ្លងកាត់ទាំងស្រុងពីការប្រើប្រាស់ក្រដាសនៅក្នុងការរៀបចំ និងការវិភាគអត្ថបទច្បាប់ ទៅកាន់ការបង្ហាញឯកភាពតាមអេឡិចត្រូនិច ។

ឧទាហរណ៍ សភាអូទ្រីសបានអនុវត្តន៍នូវគម្រោង E-RECH (Droit Electronique) ដែលអត្ថបទច្បាប់លើក្រដាស ត្រូវជំនួសដោយអត្ថបទច្បាប់អេឡិចត្រូនិច តាំងពីដំណាក់កាលដំបូង (ពីរដ្ឋាភិបាលមកដល់កិរិតគណៈកម្មការ សម័យប្រជុំពេញអង្គ និងការប្រកាសជាធរមាន) ប្រជាពលរដ្ឋអាចចូលរួមពិគ្រោះយោបល់ និងមានតម្លាភាពបំផុតក្នុងដំណើរការកសាងច្បាប់ ។

ក្រៅពីបំពេញពេលវេលា ប្រព័ន្ធនេះនាំឱ្យចំណេញក្រដាស ៦០តោន ក្នុងមួយឆ្នាំ (ជាង១លានអឺរ៉ូ) ។

នៅសាធារណរដ្ឋកូរ៉េកំពុងធ្វើបដិវត្តអេឡិចត្រូនិច ។

សភាហុងគ្រីកំពុងដើរតាមផ្លូវនេះ ដោយដាក់អត្ថបទនៃសេចក្តីព្រាងច្បាប់ដែលបានបញ្ជូនមករដ្ឋសភា (រួមទាំងវិសោធនកម្ម សេចក្តីសម្រេច សេចក្តីថ្លែងហេតុ របាយការណ៍ ការកោះហៅ សំណួរ..។ល។) នៅក្នុងប្រព័ន្ធ Internet ។

បដិវត្តនេះសំដៅជាសារវ័ន្ត សម្រួល និងកែលំអដល់ការងាររបស់សមាជិកសភា តែក៏អនុញ្ញាតឱ្យប្រជាពលរដ្ឋពិគ្រោះយោបល់លើអត្ថបទច្បាប់ ។

## តួនាទីរបស់សភាជាន់ខ្ពស់

វិធានការខាងលើនេះមានបំណងដើម្បីកែលំអ ពុំត្រឹមតែដំណើរការធ្វើច្បាប់ប៉ុណ្ណោះទេ តែផងដែរនូវការសហការរវាងសភាទាំងពីរថ្នាក់ កាលណាមានរបបទ្វិសភា ។ គោលបំណងរបស់សភាជាន់ខ្ពស់ គឺដើម្បីធានាការពិនិត្យឱ្យបានសព្វគ្រប់លើអត្ថបទច្បាប់ ហើយដាក់អត្ថបទច្បាប់នោះឱ្យទទួលបានយោបល់ទូលំទូលាយ ទាំងកំរិតជាតិ និងភូមិភាគ ដូចជាក្នុងករណីប្រព័ន្ធសហព័ន្ធ ទៅតាមចំណេះដឹង និងបទពិសោធន៍ប្លែកៗគ្នា ឬដល់គណបក្សផ្សេងៗ ។ ដំណើរការនេះសម្រួលឱ្យមានការស្រុះស្រួលគ្នាទៅលើសេចក្តីព្រាងច្បាប់ ហើយគេអាចសង្ឃឹមថា ទទួលយល់ព្រមដោយប្រជាពលរដ្ឋ ។ ត្រូវចងចាំថា លទ្ធិប្រជាធិបតេយ្យនាំឱ្យមានការស្រុះស្រួលគ្នា ការទទួលយល់ព្រមយកអត្ថបទច្បាប់ដោយប្រជាពលរដ្ឋ គឺការធានាសម្រាប់ប្រសិទ្ធភាព ។

## តាមដានស្ថានភាពដើរទៅមុខរបស់ច្បាប់

មានបញ្ហាពីរដែលត្រូវពិចារណា :

ទី១ ការសម្រេចរបស់រដ្ឋាភិបាល ក្រោមផ្លាកប្រតិភូកម្មធ្វើច្បាប់ (Délégation legislative) ជាសេចក្តីសម្រេចដែលផុតពីការត្រួតពិនិត្យរបស់សភា ដែលក្នុងករណីខ្លះ អាចដើរហួសពីអ្វីបានកំណត់ទុកនៅក្នុងច្បាប់នោះថែមទៀត ។

ជាឧទាហរណ៍ សភាក្រិកចាត់ទុកបញ្ហានេះជាបញ្ហាចម្បង ព្រោះអត្ថបទជាបទដ្ឋានដែលរៀបចំដោយរដ្ឋាភិបាល ជាញឹកញាប់ដើរហួសព្រំដែននៃប្រតិភូកម្មដែលកំណត់ដោយច្បាប់ ហើយចាំបាច់ត្រូវតែកែតម្រូវ ។

ដើម្បីដោះស្រាយបញ្ហានេះ សភាជាច្រើនតម្រូវថា ការធ្វើប្រតិភូកម្មខាងច្បាប់ ឬសកម្មភាពកំណត់បទដ្ឋានរបស់អង្គប្រតិបត្តិត្រូវកំណត់ដោយកាលបរិច្ឆេទកំណត់ច្បាស់លាស់ (មាត្រារំលត់ ឬចប់ដោយស្វ័យប្រវត្តិ) ដើម្បីគេអាចពិនិត្យឡើងវិញទៅលើបទបញ្ជា ហើយអនុក្រឹត្យដែលបានអនុម័តក្នុងក្របខ័ណ្ឌនេះត្រូវផ្តល់យោបល់ព្រមដោយសភានៅក្នុងរយៈពេលខ្លីបំផុត ។

បញ្ហាទី២ គឺការត្រួតពិនិត្យលើការអនុវត្តច្បាប់នានា ។ វាចាំបាច់ត្រូវសភាដឹងថា តើច្បាប់ត្រូវបានអនុវត្តន៍ដោយត្រឹមត្រូវដែរឬទេ ហើយក្នុងករណីផ្ទុយនោះតើមានផលវិបាកអ្វីខ្លះនៅក្នុងការជាក់ស្តែង ។

សភា Afrique du Sud បញ្ជាក់ថា ការងារធ្វើច្បាប់មិនចប់ត្រឹមការអនុម័តសេចក្តីព្រាងច្បាប់ឡើយ ។ គឺតាមការត្រួតពិនិត្យលើការអនុវត្តអត្ថបទច្បាប់ប៉ុណ្ណោះ ដែលសមាជិកសភារកឃើញនូវចំណុចមិនល្អ ហើយពួកគេចាត់ការកែប្រែការបកស្រាយច្បាប់ពុំបានល្អ ឬការអនុវត្តមិនបានល្អរបស់រដ្ឋការ ។

មូលហេតុជាធម្មតាដែលធ្វើឱ្យច្បាប់ពុំត្រូវបានអនុវត្តន៍ដោយល្អនោះ ព្រោះពុំមានបទបញ្ញត្តិខាងហិរញ្ញវត្ថុសម្រាប់ការអនុវត្ត អញ្ចឹងហើយបានជាចាំបាច់ត្រូវចែងឱ្យបានច្បាស់អំពីផលប៉ះពាល់ខាងហិរញ្ញវត្ថុរបស់ច្បាប់ដែលបានស្នើឡើង ហើយត្រូវធានាថា បានគិតដល់ការផ្ទេរនូវឥណទានជាថវិកា ។

បញ្ហាទាំងពីរនេះផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងមុខងារត្រួតពិនិត្យរបស់សភា ។

## <u>ការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពទៅលើសកម្មភាពរបស់អង្គប្រតិបត្តិ</u>

ក្រៅពីការងារធ្វើច្បាប់ដែលជាបន្ទុក សភាត្រូវត្រួតពិនិត្យទៅលើរដ្ឋាភិបាលក្នុងនាមប្រជាពលរដ្ឋ ។ ការពិនិត្យទៅលើថវិកា និងការត្រួតពិនិត្យខាងហិរញ្ញវត្ថុ ជាវិស័យពីរពិសេស ។

ភារកិច្ចទូទៅបំផុតនៃការត្រួតពិនិត្យទៅលើសកម្មភាពរបស់រដ្ឋាភិបាល និងរដ្ឋការ គឺជាវិសាលភាពនៃកាតព្វកិច្ចរបស់រដ្ឋាភិបាលត្រូវរាយការណ៍ចំពោះមុខសភា និងតាមរយៈសភាចំពោះមុខអ្នកបោះឆ្នោត ។

វិស័យនៃការងាររបស់សភានេះជាងការងារផ្សេងៗទៀត ត្រូវគិតដល់អំណាច និងទំនាក់ទំនង ។ វាពុំមែនតែគិតដល់ការកំណត់នូវអំណាចពាក់ព័ន្ធរបស់សភា និងរដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែត្រូវគិតដល់តុល្យភាពនៃកម្លាំងរវាងគណបក្ស និងក្នុងគណបក្សនានា ។ ម្យ៉ាងទៀត ជាញឹកញាប់គឺការសំដែងចេញនៃអំណាចរបស់គណបក្ស ដែលកំណត់នូវទំនាក់ទំនងរវាងសភា និងអង្គនីតិប្រតិបត្តិ ។

នៅក្នុងប្រព័ន្ធប្រធានាធិបតី ប្រសិនបើសភាត្រូវគ្រប់ដណ្តប់ដោយគណបក្សមួយទៀតក្រៅពីគណបក្សរបស់ប្រធានាធិបតី ពុំត្រឹមតែការត្រួតពិនិត្យក្លាយជាស្រួចស្រាល់ប៉ុណ្ណោះទេ តែការប្រកួតប្រជែងរវាងគណ-បក្សអាចនឹងបណ្តាលឱ្យមានការរំខាន និងការជាប់គាំង ។

នៅក្នុងប្រព័ន្ធសភា ព្រមទាំងក្នុងប្រព័ន្ធប្រធានាធិបតី ប្រសិនបើគណបក្សតែមួយត្រួតត្រាបានទៅលើសាខាទាំងពីរនៃការគ្រប់គ្រង (សភា/រដ្ឋាភិបាល) គេសង្កេតឃើញនូវនិន្នាការបញ្ច្រាសវិញ ការត្រួតពិនិត្យត្រូវចុះខ្សោយដោយមូលហេតុនៃល្បែងរបស់កម្លាំងរបស់សម្ព័ន្ធភាព ឬគណបក្សដែលគ្រប់ដណ្តប់ រហូតដល់កាប្រកួតប្រណាំងរវាងគណបក្សជម្រុញឱ្យស្ងប់ស្ងាត់នូវការបែកបាក់ផ្ទៃក្នុង និងពុំឱ្យបញ្ចេញនូវការបែកបាក់

ទាំងនោះទៅខាងក្រៅជាសាធារណៈ ។ ដូច្នេះផលប្រយោជន៍របស់គណបក្សប្រឆាំងតម្រូវឱ្យត្រួតពិនិត្យដោយហ្មត់ចត់ទៅលើសកម្មភាពរបស់អង្គប្រតិបត្តិ តែសមាជិករបស់គណបក្សកាន់អំណាច ដោយពឹងផ្អែកលើសម្លេងភាគច្រើនរបស់ខ្លួន អាចមើលថែទាំដើម្បីកុំឱ្យរដ្ឋមន្ត្រីរបស់ខ្លួនត្រូវបានទើសទាល់ដោយរឿងអាស្រូវណាមួយ ឬមានរបាយការណ៍ទិទាន ។

គណបក្សនយោបាយមានមធ្យោបាយមិនផ្លូវការជាច្រើន ដើម្បីថែរក្សាសមាជិកសភារបស់ខ្លួនឱ្យដើរត្រង់បន្ទាត់ តាមរយៈប្រធានក្រុម ដោយចាត់សមាជិកសភាឱ្យជួយនៅក្នុងគណៈកម្មការសំខាន់ៗ ទស្សនៈវិស័យនៃការតម្លើងឋានៈ/តួនាទី ការចាត់តាំងចូលក្នុងគណៈប្រតិភូទៅក្រៅប្រទេស.. ។ល ។ ឬដោយគម្រាមកំហែងដកលេខរៀងល្អនៅក្នុងបញ្ជីបោះឆ្នោត គម្រាមដកចេញពីយន្តការសភា ។ វិធានការក្បៀបសង្កត់ និងវិន័យទាំងនេះ ជូនកាលអាចរំខានដល់ការត្រួតពិនិត្យរបស់សភា ។

នេះជាឧទាហរណ៍របស់សភា Afrique du Sud : ជាការពិត គណបក្សទាំងអស់នៅក្នុងសភាសុទ្ធតែមានតំណាងនៅក្នុងគណៈកម្មការនានា ។ ប៉ុន្តែល្បែងនៃអំណាចនៅក្នុងគណបក្សអាចធ្វើឱ្យគណៈកម្មការអសមត្ថភាព ដើម្បីត្រួតពិនិត្យជាសមូហភាពទៅលើរដ្ឋការ ។ ម្យ៉ាងទៀត ភាពគន្លែកគ្នាខាងផលប្រយោជន៍ក្នុងគណបក្សមួយ តែងតែពុំចាំបាច់ផ្សព្វផ្សាយជាសាធារណៈឡើយ ។ ឋានានុក្រម និងវិន័យរបស់គណបក្សអាចរារាំងដល់អ្នកនយោបាយមិនឱ្យចោទសួរនូវសំណួរផ្សេងៗ ដែលធ្វើឱ្យរដ្ឋាភិបាលទើសទាល់ ឬប៉ះពាល់ដល់ឯកភាពរបស់គណបក្ស ។ ថ្នាក់ដឹកនាំគណបក្សអាចទទួលបានដោយពុំពិបាក នូវភាពស្មោះត្រង់របស់សមាជិកខ្លួន ហើយតែងចាប់បង្ខំនូវវិន័យជាដែកថែប ព្រោះសមាជិកសភាត្រូវការនូវគណបក្សរបស់ខ្លួនដើម្បីបានទទួលកន្លែងនៅក្នុងបញ្ជីបោះឆ្នោត និងបានចូលមកកាន់សភា ។ នេះជាសភាពការណ៍មួយដែលអាចរារាំងគណៈកម្មការពុំឱ្យប្រតិបត្តិប្រកបដោយប្រសិទ្ធភាពនូវការងារត្រួតពិនិត្យរបស់ខ្លួន ។

នេះគឺជាល្បែងនៃអំណាចរវាងគណបក្សនយោបាយ នៅក្នុងគណបក្សនីមួយៗដែលត្រូវគិតគូរនៅក្នុងការវិភាគអំពីវិធីសាស្ត្រនៃការត្រួតពិនិត្យរបស់សភា ។ វានឹងពុំមានការត្រួតពិនិត្យរបស់សភាទៅលើអង្គនីតិប្រតិបត្តិឡើយ ប្រសិនបើសភាគ្រាន់តែជាអង្គការឯកភាព និងរួមសំបាច់ស្អិតជាប់គ្នា ។ មុខងារទាំងអស់នៃការត្រួតពិនិត្យត្រូវកើតឡើងដោយការប្រកួតប្រជែងរវាងគណបក្សនានា និងតាមប្រតិកម្មដែលអាចកើតមានរបស់សាធារណៈមតិ ។ ជាពិសេស គឺគណបក្សភាគតិច ឬគណបក្សប្រឆាំង ដែលនៅក្នុងនីតិកាលដែលត្រូវទទួលបន្ទុកលើការត្រួតពិនិត្យតាមវិធីសាស្ត្រផ្សេងៗ "ត្រូវចឹក" ។

នៅក្នុងប្រព័ន្ធសភា ការត្រួតពិនិត្យទាំងនេះត្រូវបានសម្របសម្រួលជាទូទៅដោយ "រដ្ឋាភិបាលស្រមោលមួយ Cabinet fantôme" ជាផ្លូវការ ឬមិនផ្លូវការនៅក្នុងប្រពៃណីអង់គ្លេស ។

## **ការត្រួតពិនិត្យដោយប្រព័ន្ធគណៈកម្មការ**

វិធីសាស្ត្រជាប្រព័ន្ធបំផុតនៃការត្រួតពិនិត្យទៅលើសកម្មភាពរបស់អង្គនីតិប្រតិបត្តិ គឺជាការត្រួតពិនិត្យរបស់គណៈកម្មការសភានានា ដែលផ្ទៀងផ្ទាត់ការងាររបស់រដ្ឋការនីមួយៗ ក្រសួងនីមួយៗ និងស៊ើបអង្កេតទៅលើទិដ្ឋភាពរសើបបំផុតនៃនយោបាយ និងការចាត់ចែងរបស់រដ្ឋការ និងក្រសួង ។

សភាជាច្រើនបានធ្វើការកែទម្រង់ប្រព័ន្ធគណៈកម្មការរបស់ខ្លួន ដើម្បីឱ្យគណៈកម្មការនានាមានរចនាសម្ព័ន្ធប្រហាក់ប្រហែលទៅនឹងរដ្ឋការដែលខ្លួនទទួលបន្ទុក និងទទួលបាននូវបទពិសោធនីចាំបាច់ ។

នៅក្នុងប្រទេសជាច្រើន គណៈកម្មការទាំងនេះស្ថិតនៅក្រោមសភាទាំងពីរ ។ ជាការពិត ទោះបីជាគណៈកម្មការជំនាញពុំអាចមើលអស់ទៅលើការចាត់ចែងរបស់រដ្ឋការក្តីប៉ុន្តែវាគ្រប់គ្រាន់តាមន័យនៃតម្លាភាពដោយគ្រាន់តែរដ្ឋការសាមីដឹងខ្លួនថា ការស៊ើបអង្កេតដ៏ម៉ឺងម៉ាត់មួយទៅលើទិដ្ឋភាពមួយនៃសកម្មភាពរបស់រដ្ឋការអាចធ្វើបានជានិច្ច ។ នៅក្នុងការជាក់ស្តែង គណៈកម្មការទាំងនេះត្រូវជាអ្នកជ្រើសសម្រាំងលើការត្រួតពិនិត្យ (កំណត់បញ្ហា) ។

សភា Afrique du Sud បានកែទម្រង់ប្រព័ន្ធគណៈកម្មការដូចតទៅ :

ភារកិច្ចខ្លះ ជាអាទិ៍ភារកិច្ចដែលតម្រូវឱ្យមានការពិនិត្យដោយលំអិត ត្រូវបានប្រគល់ឱ្យក្រុមដែលមានគ្នាតិច ជាជាងឱ្យសម័យប្រជុំពេញអង្គ ។ ដូច្នេះគណៈកម្មការមានតួនាទីសំខាន់បំផុតសម្រាប់ការត្រួតពិនិត្យរបស់គណៈកម្មការ ។ ប្រព័ន្ធចាស់ដែលមាន ១៣ គណៈកម្មការ ដែលតែងប្រជុំជាសម្ងាត់ ហើយតែងយល់ព្រមលើសកម្មភាពរបស់គណបក្សជាតិកាន់អំណាច (ANC) ត្រូវបានជំនួសដោយគណៈកម្មការដែលសកម្ម និងឯករាជ្យពីរដ្ឋាភិបាល ។ នៅរដ្ឋសភា គណៈកម្មការមួយត្រូវបានបង្កើតសម្រាប់រដ្ឋការមួយ ក្នុងពេលដែលគណៈកម្មការនីមួយៗរបស់ក្រុមប្រឹក្សាជាតិរបស់ខេត្ត ទទួលមើលសំណុំរដ្ឋការមួយសំណុំ ។ គណៈកម្មការទាំងនេះមានអំណាចទូលំទូលាយ រួមទាំងអំណាចធ្វើសវនាការជាមួយជនដែលអាចផ្តល់សាក្សី ឬឯកសារចាំបាច់ផ្សេងៗ ។

សភាស៊ុយអែតចាត់ទុកមុខងារត្រួតពិនិត្យរបស់សភាស្ថិតនៅជួរទី១ ដោយហេតុថា សកម្មភាពរបស់រដ្ឋាភិបាលកណ្តាលពុំត្រូវបានគ្រប់គ្រងដោយច្បាប់ និងបទដ្ឋានថវិកាលំអិតឡើយ ប៉ុន្តែដោយទិសដៅទូទៅ

និងការតម្រូវនៃលទ្ធផល ។ ដូច្នេះភារកិច្ចរបស់សភាតម្រូវឱ្យផ្ទៀងផ្ទាត់ជាខាងក្រោយថា ទិសដៅ និងការតម្រូវជាលទ្ធផលត្រូវបានគោរព ។ ត្រង់នេះ ការងារ និងអាទិភាពរបស់គណៈកម្មការសភាដើរតួនាទីសំខាន់ ។

តាមនិយមន័យ ការត្រួតពិនិត្យអាចនឹងធ្វើទៅបានលុះណាតែគណៈកម្មការអាចសម្រេចបានទៅលើទិដ្ឋភាពនៃសកម្មភាពរបស់រដ្ឋាភិបាល ដែលអាចជាកម្មវត្ថុនៃការស៊ើបអង្កេត ។ ចំពោះបញ្ហានេះ នៅរដ្ឋសភាហ្វីលីពីន ការសម្រេចត្រូវអនុម័តដោយសម្លេងភាគច្រើននៃសមាជិករបស់គណៈកម្មការ ។

សភាន័រវេសបានសម្រេចថា ភាគតិចនៃសមាជិករបស់គណៈកម្មការទទួលបន្ទុកត្រួតពិនិត្យ និងធម្មនុញ្ញ (ត្រឹមតែមួយភាគបីគ្រប់គ្រាន់) ដើម្បីផ្ដើមការស៊ើបអង្កេត ។ បទដ្ឋាននេះសំខាន់សម្រាប់កិច្ចការពារសម្លេងភាគតិចនៅក្នុងសភា ។

ដើម្បីឱ្យការស៊ើបអង្កេតរបស់គណៈកម្មការមានប្រសិទ្ធភាព គណៈកម្មការត្រូវមានសិទ្ធិធ្វើសវនាការជាមួយរដ្ឋមន្ត្រី និងមន្ត្រី ព្រមទាំងអាចទទួលនូវឯកសារចាំបាច់ផ្សេងៗ រួមទាំងព័ត៌មានដែលចាត់ទុកថាសម្ងាត់ ។ បើពុំដូច្នោះទេ វានឹងពុំមានតម្លាភាពពិតប្រាកដឡើយ ។ ច្បាប់ស្ដីពីសេរីភាពខាងព័ត៌មានដែលមានចែងអំពីការលើកលែង ឬអនុញ្ញាតឱ្យរដ្ឋមន្ត្រីឱ្យភៀសខ្លួនជ្រកនៅខាងក្រោយកិច្ចការសម្ងាត់របស់រដ្ឋ ដើម្បីជាញឹកញាប់រារាំងសភាពុំឱ្យទទួលបាននូវព័ត៌មានខ្លះ អនុញ្ញាតឱ្យសភាជាច្រើនកែសម្រួលសភាពការណ៍បាន ។

ក្នុងពេលដែលគណៈកម្មការធ្វើការស៊ើបអង្កេតស៊ីជម្រៅ នោះទើបគណៈកម្មការដឹងច្បាស់អំពីសារៈ-សំខាន់នៃធនធានហិរញ្ញវត្ថុរបស់ខ្លួន ។ ទោះបីនៅក្នុងសភាដែលមានលទ្ធភាពច្រើនក្ដី បុគ្គលិករបស់គណៈ-កម្មការតែងតែពុំគ្រប់គ្រាន់ឡើយ កាលណាគេប្រៀបធៀបដល់មូលដ្ឋាននៃចំណេះធ្វើ ដែលខាងរដ្ឋការតែងប្រើប្រាស់ ។ មានដំណោះស្រាយជាច្រើនដែលអាចឱ្យគណៈកម្មការជំនះបាននូវឧបសគ្គនេះ ជាពិសេសតាមការប្រើប្រាស់អ្នកឯកទេសមកពីខាងក្រៅ ជាសមាជិកសង្គមស៊ីវិល ឬក៏មជ្ឈដ្ឋានសាកលវិទ្យាល័យជាលក្ខណៈទៀងទាត់ ឬក៏ជាទីប្រឹក្សា ។ សភាអង់គ្លេសទើបតែបង្កើតអង្គភាពត្រួតពិនិត្យមួយ ដើម្បីជួយជាទៀងទាត់ដល់គណៈកម្មការនានាដែលស្នើសុំ ។

ជាទូទៅ គណៈកម្មការធ្វើឱ្យចេញលទ្ធផលនៃការស៊ើបអង្កេតរបស់ខ្លួន ដោយបោះពុម្ពផ្សាយនូវរបាយការណ៍មួយ និងមានអនុសាសន៍ផ្ញើទៅខាងរដ្ឋាភិបាល ។ របាយការណ៍នោះត្រូវដាក់ជូនអង្គសភាទាំងមូល ។ ក្រោយនោះ គឺខាងរដ្ឋាភិបាលដែលត្រូវសម្រេចអំពីអាទិភាពនៃរបាយការណ៍នោះ និងត្រៀមចម្លើយពីខាងរដ្ឋាភិបាល ។

សភាឥណ្ឌាបានពង្រីងនីតិវិធីអំពីការតាមដានអនុសាសន៍ ដែលផ្តល់ដោយគណៈកម្មការទទួលបន្ទុកខាងរដ្ឋបាល ព្រោះពេលខ្លះឃើញថា ខាងរដ្ឋាភិបាលពុំបានប្រញាប់ប្រញាល់អនុវត្តន៍នូវអនុសាសន៍ដែលខ្លួនយល់ព្រមទទួលឡើយ ។ តាមនីតិវិធីថ្មី ជារៀងរាល់៦ខែម្តង ក្រសួងនីមួយៗដែលពាក់ព័ន្ធត្រូវបង្ហាញសេចក្តីថ្លែងការណ៍ជូនអង្គសភា អំពីការអនុវត្តអនុសាសន៍ដែលបានលើកឡើងដោយគណៈកម្មការ ។ តាមវិធានការនេះ ការយកចិត្តទុកដាក់អនុវត្តន៍នូវអនុសាសន៍មានល្បឿនលឿនជាងមុន ។

## ការត្រួតពិនិត្យដោយ និងលើអង្គការសាធារណៈឯករាជ្យ

ក្នុងវិស័យត្រួតពិនិត្យរបស់សភាត្រូវកត់សម្គាល់ថាមានអង្គការឯករាជ្យ ២ ប្រភេទ

១- អង្គការដែលទទួលបន្ទុកជួយរួមវិភាគទានដល់ការត្រួតពិនិត្យទៅលើសកម្មភាពរបស់រដ្ឋាភិបាល ដូចជា អ្នកសម្រុះសម្រួល (Médiateur) គណៈកម្មការសិទ្ធិមនុស្ស គណៈកម្មការប្រឆាំងអំពើពុករលួយ តុលាការគណនី (La cour des comptes) ។ ការត្រួតពិនិត្យនេះនឹងមានប្រសិទ្ធភាព ប្រសិនបើសមាជិកនៃស្ថាប័នទាំងនេះត្រូវបានយល់ព្រមដោយសភា ហើយត្រូវទទួលខុសត្រូវចំពោះមុខសភា ពុំមែនចំពោះមុខរដ្ឋាភិបាលឡើយ ។ ដោយចំណេះធ្វើប្រកបដោយឯកទេស និងការប្រាស្រ័យទាក់ទងជាមួយនឹងអង្គការនានានៃសង្គមស៊ីវិល អង្គការទាំងនេះដើរតួនាទីដ៏មានតម្លៃ ដើម្បីបំពេញបន្ថែមទៅលើការងារត្រួតពិនិត្យរបស់គណៈកម្មការសភា ។

សភាន័រវេសបានបង្ហាញអំពីស្ថាប័នឯករាជ្យ ៤ ដែលចាត់ទុកថាសំខាន់សម្រាប់មុខងារត្រួតពិនិត្យរបស់សភា អគ្គសវនាករ អ្នកសម្រុះសម្រួលសភាសម្រាប់មុខងារសាធារណៈ គណៈកម្មការត្រួតពិនិត្យសេវាស៊ើបការ ឃ្លាំមើល និងសន្តិសុខ និងអ្នកសម្រុះសម្រួលខាងកងកម្លាំងប្រដាប់អាវុធ ។ ដោយលើកលែងតែស្ថាប័នចុងក្រោយដែលត្រូវរាយការណ៍ឱ្យគណៈកម្មការការពារជាតិ ស្ថាប័នផ្សេងទៀតរាយការណ៍ឱ្យគណៈកម្មការត្រួតពិនិត្យរបស់សភា ។

នៅក្នុងប្រទេសជាច្រើន មជ្ឈមណ្ឌលជាតិខាងស្ថិតិរួមវិភាគទានផងដែរដល់ការត្រួតពិនិត្យរបស់សភា ។ និន្នាការដែលចង់សម្របសម្រួលស្ថិតិ ដើម្បីបង្ហាញថានយោបាយរបស់រដ្ឋាភិបាលមានលក្ខណៈអនុគ្រោះល្អ គឺជាមូលហេតុដែលត្រូវធ្វើឱ្យមជ្ឈមណ្ឌលស្ថិតិឱ្យឯករាជ្យ និងទទួលខុសត្រូវចំពោះមុខសភា ពុំមែនចំពោះមុខរដ្ឋាភិបាលឡើយ ។ ប្រទេសអង់គ្លេសកំពុងធ្វើការអំពីបញ្ហានេះ ។

២- ស្ថាប័នឯករាជ្យដែលអនុវត្តភាគខ្លះនូវមុខងារប្រតិបត្តិ និងរៀបចំបទដ្ឋានរបស់រដ្ឋាភិបាលខ្លួនឯង ។ នេះពុំមែនជាអង្គការរួមវិភាគទានដល់ប្រព័ន្ធត្រួតពិនិត្យរបស់សភាឡើយ (ពុំមែនដូចប្រភេទទី១ ខាងលើទេ) ។ បញ្ហាត្រង់ថា តើត្រូវត្រួតពិនិត្យអង្គការទាំងនេះដោយខ្លួនឯងរបៀបណា ពីព្រោះអង្គការទាំងនេះមិនស្ថិតនៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលឡើយ ។

រដ្ឋាភិបាលនៅក្នុងប្រទេសជាច្រើនតែងធ្វើប្រតិភូកម្មមុខងារសាធារណៈ ដូចជាសកម្មភាពរៀបចំលិខិតបទដ្ឋាន ឬលាភសក្ការៈរបស់សេវាសាធារណៈដូចជា ធនាគារកណ្តាល ឬសេវាសាធារណៈខាងការផ្សព្វផ្សាយ អាជ្ញាធរខាងបទដ្ឋានសុខភាព និងសន្តិសុខសាធារណៈ សេវាដឹកជញ្ជូន ផ្ទះសម្បែង អប់រំ នីតិសម្បទាសង្កាត់ ប្រព័ន្ធពន្ធធនាគារ.. ។ល។ ជួនកាលនៅក្នុងក្របខ័ណ្ឌដៃគូសាធារណៈ-ឯកជន ដែលជំនួសទាំងការត្រួតពិនិត្យ ទាំងការទទួលខុសត្រូវរបស់អង្គការសាធារណៈមូលដ្ឋាន ។

អង្គការសាធារណៈឯករាជ្យបែបនេះ ពុំមែនគ្មានបញ្ហាចោទឡើងនោះទេ ។

សភាក្រិកបានសម្តែងការព្រួយបារម្ភ អំពីការផ្ទេរនៃអំណាចសម្រេចខាងបទដ្ឋានរបស់សភាទៅឱ្យអាជ្ញាធរឯករាជ្យ ។ បញ្ហាផ្សេងទៀត ការចុះខ្សោយនៃខ្សែសង្វាក់ទទួលខុសត្រូវ និងតម្លាភាព ។ ជាទ្រឹស្តី ពុំមានអ្វីហាមឃាត់ថា មិនឱ្យអង្គការឯករាជ្យមួយមិនស្ថិតនៅក្រោមអាណាព្យាបាលរបស់រដ្ឋការឡើយ ។ តែដំណើរការនេះវាធ្វើឱ្យស្មុគ្រស្មាញដល់ការត្រួតពិនិត្យរបស់សភា ជួនកាលគេផ្តល់មូលនិធិសាធារណៈឱ្យច្រើន ដោយពុំដឹងអំពីការបែងចែកយ៉ាងដូចម្តេច ។

## ការត្រួតពិនិត្យដោយសំណួរ និងការកោះហៅទៅកាន់សភា

នៅក្នុងប្រព័ន្ធសភា និងប្រព័ន្ធដទៃទៀតដែលរដ្ឋមន្ត្រីក៏ជាសមាជិកសភាផងដែរនោះ សំណួរតាមចន្លោះពេលវេលាប្រក្រតី ទាំងផ្ទាល់មាត់ និងដោយលាយលក្ខណ៍អក្សរ គឺជាយន្តការមួយដ៏សំខាន់នៃការត្រួតពិនិត្យ ។ សំណួរដោយផ្ទាល់មាត់នៅក្នុងសម័យប្រជុំពេញអង្គ ជាញឹកញាប់អាចក្លាយជាការពិភាក្សាអឺងកងដែលពុំបាននាំមកនូវចម្លើយច្រើនឡើយ ។ សមាជិកសភានៃគណបក្សកាន់អំណាច ដែលលើកឡើងពីសំណួរសើរៗក្នុងន័យបញ្ចោរ ឯរដ្ឋមន្ត្រីស្វះស្វែងរកចំណុចដើម្បីចុចយកឈ្នះលើគណបក្សប្រឆាំងជាជាងការពិភាក្សា ។ ម្យ៉ាងទៀត ចម្លើយដោយលាយលក្ខណ៍អក្សរ ត្រូវបានរៀបចំដោយមន្ត្រីដ៏ប៉ិនប្រសប់ តែងចៀសវាងមិននិយាយដល់ចំណុចណាមួយដែលអាចទាល់ច្រកឡើយ ។ សំណួរសភាដែលបានសាកសួរប្រកបដោយប្រសិទ្ធ-

ភាព គឺជាមធ្យោបាយមួយនៃការស៊ើបអង្កេត និងការត្រួតពិនិត្យ ។ វាជារឿងដ៏ល្អដែលតម្រូវឱ្យរដ្ឋមន្ត្រីពន្យល់ និងបំភ្លឺអំពីសកម្មភាពរបស់ខ្លួនចំពោះមុខសភា ក្នុងចន្លោះពេលវេលាជាប្រក្រតី និងឱ្យឆ្លើយជាសាធារណៈអំពីការខ្វះខាតទាំងអស់ ។

សភា Zambie បានឃើញពីបញ្ហានេះដូចតទៅ

សំណួរនៅក្នុងសភា ជាដំបូងមានកម្មវត្ថុអនុញ្ញាតឱ្យសមាជិកសភាសាកសួរព័ត៌មានទៅលើកិច្ចការសាធារណៈ ។ ជាបន្ទាប់ សំណួរនេះតម្រូវឱ្យរដ្ឋាភិបាលត្រូវធ្វើសកម្មភាព ។ សម័យប្រជុំលើកសំណួរ នាំឱ្យសមាជិកសភាមានលទ្ធភាព ម្យ៉ាងទៀតបានធ្វើឱ្យរដ្ឋាភិបាលបានដឹងនូវទស្សនៈរបស់ប្រជាពលរដ្ឋទៅលើបញ្ហាជាបច្ចុប្បន្នភាព ហើយនឹងវាយតម្លៃទៅលើរដ្ឋមន្ត្រី និងអ្នកទទួលខុសត្រូវទៅតាមចំណាត់ការបន្ត ដែលពួកគេធ្វើចំពោះបញ្ហាដែលបានសាកសួរ ។ ដូច្នេះរដ្ឋមន្ត្រីត្រូវរក្សាការប្រុងប្រយ័ត្នក្រែងគេចាប់ថ្នាក់បាន ។ សំណួរជាទូទៅរួមវិភាគទានឱ្យរដ្ឋាភិបាលដំណើរការបានល្អ ។

ប្រសិនបើដំណើរការសំណួរកាន់តែញឹកញាប់ សំណាងក៏មានកាន់តែធំ ដើម្បីឈានទៅដល់ទិសដៅខាងលើនេះ ។

នេះជាឧទាហរណ៍នៃនីតិវិធីដែលប្រើប្រាស់ដោយសភា Irlande :

នាយករដ្ឋមន្ត្រីឆ្លើយនឹងសំណួរដែលបានផ្តល់ជាមុន ព្រមទាំងសំណួរបន្ថែម ដោយពុំបានដឹងជាមុនក្នុងរយៈពេល ៩០នាទី ជារៀងរាល់អាទិត្យ ។ នាយករដ្ឋមន្ត្រីក៏ឆ្លើយផងដែរទៅនឹងសំណួររបស់ប្រធានគណបក្សប្រឆាំង (ដោយពុំដឹងសំណួរជាមុន) ក្នុងរយៈពេល ៤០នាទី ជារៀងរាល់អាទិត្យ ។ រដ្ឋមន្ត្រីដទៃទៀតតាមវេនត្រូវឆ្លើយនឹងសំណួរ ២១០នាទី ជារៀងរាល់អាទិត្យ ។ ពួកគេបានឆ្លើយប្រមាណ ១៩០០សំណួរ ដោយបានដឹងជាមុនក្នុងឆ្នាំ២០០៤ ។ ក្រៅពីនោះពួកគេត្រូវផ្តល់ចម្លើយជាលាយលក្ខណ៍អក្សរចំនួន ២៦.០០០ សំណួរផ្សេងទៀត ។

នៅសភាសេណេហ្គាល់ សំណួរដល់រដ្ឋមន្ត្រីមានទម្ងន់ជាការពិភាក្សាដោយមានកម្មវិធីលំអិត និងក្រមដំណើរការដូចតទៅ

| | |
|---|---|
| ១- ការអានសំណួរដោយម្ចាស់សំណួរ | ៣ នាទី |
| ២- ចម្លើយរបស់រដ្ឋមន្ត្រី | ១៥ នាទី |
| ៣- អន្តរាគមន៍របស់ម្ចាស់សំណួរ | ១០ នាទី |
| ៤- អន្តរាគមន៍របស់ក្រុមសម្លេងភាគច្រើន | ១០ នាទី |

៥- អន្តរាគមន៍របស់ក្រុមសម្លេងភាគតិច ១០ នាទី

៦- ចម្លើយជាថ្មីរបស់រដ្ឋមន្ត្រី ១៥ នាទី

៧- ការសម្តែងយោបល់ជាថ្មីរបស់ម្ចាស់សំណួរ ៣ នាទី

៨- ចម្លើយចុងក្រោយរបស់រដ្ឋមន្ត្រី ៥ នាទី

នេះគឺជាទម្ងន់នៃការត្រួតពិនិត្យរហ័សទៅលើបញ្ហាណាមួយដែលច្បាស់លាស់ទៅលើរដ្ឋាភិបាលដោយរដ្ឋសភា ។

សភាដទៃទៀតបានអនុម័តយកទម្រង់ប្លែកៗនៃអន្តរាគមន៍ ដើម្បីត្រួតពិនិត្យទៅលើរដ្ឋមន្ត្រី ដើម្បីបំពេញបន្ថែមទៅលើនីតិវិធីនៃការប្រជុំសួរសំណួរជាផ្លូវការ ។

ជាឧទាហរណ៍ សភាឥណ្ឌាបានដាក់អនុវត្តន៍នីតិវិធី "កោះហៅ" ដូចខាងក្រោម

សមាជិកសភាទាំងអស់ ដោយមានសេចក្តីអនុញ្ញាតជាមុនពីប្រធានសភា ឬប្រធានអង្គប្រជុំ អាចកោះហៅរដ្ឋមន្ត្រីមួយរូបមកសាកសួរទៅលើបញ្ហាជាសាធារណៈណាមួយដែលបន្ទាន់ ។ រដ្ឋមន្ត្រីសាមីអាចធ្វើសេចក្តីរាយការណ៍ដោយខ្លី ឬក៏អាចស្នើសុំពន្យាការថ្លែងការណ៍ទៅពេលក្រោយវិញ ។ នីតិវិធីនេះអាចនាំឱ្យសមាជិកសភាលើកមកបង្ហាញពីការខ្វះចន្លោះ នៃសកម្មភាពរបស់រដ្ឋាភិបាលនៅក្នុងវិស័យណាមួយ ។

ប្រព័ន្ធប្រធានាធិបតី ពុំបានគ្រោងអំពីនីតិវិធីជាប្រព័ន្ធសំណួរដល់រដ្ឋមន្ត្រីដូចជាប្រព័ន្ធសភាឡើយ ។ ប៉ុន្តែមានដំណោះស្រាយ ដើម្បីអាចបានទទួលចម្លើយពីទេសរដ្ឋមន្ត្រីក្រៅអំពីនីតិវិធីធម្មតារបស់គណៈកម្មការ ។

ដូចជាករណីសភាឈីលី អាចកោះទេសរដ្ឋមន្ត្រីមកចូលសម័យប្រជុំវិសាមញ្ញរបស់សភាណាមួយដើម្បីទេសរដ្ឋមន្ត្រីនោះជំរាបដល់សមាជិកសភា ទៅលើបញ្ហាដែលពាក់ព័ន្ធដល់សមត្ថកិច្ចរបស់ខ្លួន ។

## ការយល់ព្រមរបស់សភាទៅលើការតែងតាំងសម្រាប់មុខតំណែងទទួលខុសត្រូវរបស់អន្តប្រតិបត្តិ

នៅក្នុងប្រព័ន្ធប្រធានាធិបតី ដែលរដ្ឋមន្ត្រីពុំមែនជាសមាជិកសភា មធ្យោបាយមួយសម្រាប់ការត្រួតពិនិត្យដ៏សំខាន់បំផុត គឺលទ្ធភាពយល់ព្រមទៅលើការតែងតាំងសម្រាប់មុខតំណែងជារដ្ឋមន្ត្រី ឬការទទួលខុសត្រូវខ្ពស់នៅក្នុងអង្គនីតិប្រតិបត្តិ ជាអាទិ៍ ដោយមានការអង្កេតជ្រាលជ្រៅសំដៅវាយតម្លៃអំពីសមត្ថភាពរបស់បុគ្គលសាមី ។ ការស៊ើបអង្កេតទាំងនេះ អាចធ្វើទៅបានសម្រាប់ការតែងតាំងសម្រាប់ការទទួលខុសត្រូវនៅក្នុងក្បាលម៉ាស៊ីនតុលាការ ឬមុខតំណែងជាអគ្គរដ្ឋទូត ។

ប្រព័ន្ធសភាខ្លះ ក៏បានបំពាក់នូវនីតិវិធីត្រួតពិនិត្យសម្រាប់ការតែងតាំងក្នុងមុខតំណែងជាន់ខ្ពស់នៅក្នុងមុខងារសាធារណៈ ទោះបីការអនុវត្តនេះពុំសូវទូទៅក្តី ។

ផ្ទៃកបញ្ហាសមកវិញ គឺការដកហូតមកមុខតំណែង ។ សិទ្ធិរបស់សភាដើម្បីដកហូតប្រធានាធិបតីដោយនីតិវិធីពិសេសនៅក្នុងប្រព័ន្ធប្រធានាធិបតី គឺជាមធ្យោបាយចុងក្រោយ ដោយមានមូលហេតុជាធម្មតាពាក់ព័ន្ធដល់ការរំលោភបំពានធ្ងន់ធ្ងរដល់ច្បាប់ ឬរដ្ឋធម្មនុញ្ញ ។

ផ្ទុយទៅវិញនៅក្នុងប្រព័ន្ធសភា ជាទូទៅ ការបង្ហាញអំពីការបាត់បង់នូវការគាំទ្រខាងនយោបាយ តែដែលពុំនាំឱ្យមានផលវិបាក ដូចជាការប្រឈមមុខរវាងអង្គនីតិប្រតិបត្តិ និងនីតិបញ្ញត្តិ ពីព្រោះរដ្ឋាភិបាលកើតចេញពីសភា ។ សភាខ្លះបានគ្រោងផងដែរអំពីការបោះឆ្នោតសម្តែងការមិនទុកចិត្តទៅលើរដ្ឋមន្ត្រី តែពុំបណ្តាលឱ្យប៉ះពាល់ដល់រដ្ឋាភិបាលទាំងមូលឡើយ ។

## <u>គណៈកម្មការត្រួតពិនិត្យពិសេស</u>

គណៈកម្មការស៊ើបអង្កេតពិសេស គឺជាឧបករណ៍មួយផ្សេងទៀតនៃការត្រួតពិនិត្យ ដែលអនុញ្ញាតឱ្យសភារកឃើញបញ្ហាសំខាន់ៗនៃផលប្រយោជន៍សាធារណៈ ហើយជាទូទៅពាក់ព័ន្ធនឹងវិស័យសកម្មភាពរបស់រដ្ឋបាលជាច្រើន ហើយជាសមត្ថកិច្ចរបស់គណៈកម្មការជាច្រើន ។ ស្ថាប័នទាំងនេះត្រូវចែកឱ្យដាច់ពីគណៈកម្មការស៊ើបអង្កេត ដែលបង្កើតដោយរដ្ឋាភិបាលខ្លួនឯង ហើយដែលបេសកកម្ម និងបុគ្គលិកត្រូវបានជ្រើសរើសដោយអង្គនីតិប្រតិបត្តិផងដែរ ។ ជាការពិត អង្គការបែបនេះជូនកាលសម្របសម្រួលគ្នាដើម្បីខ្ទប់រឿងអាស្រូវណាមួយ ឬធ្វើឱ្យសម្លេងទិទានរដ្ឋាភិបាលស្ងប់ស្ងាត់ ។ នៅក្នុងករណីបែបនេះ មិនអាចនិយាយអំពីឧបករណ៍នៃការត្រួតពិនិត្យបានទេ ។

កិច្ចការពារផ្តល់ដល់ជនជាសាក្សីតាមច្បាប់ស្តីពីការចោទប្រកាន់ គឺជាអង្គធាតុដ៏ចម្បងមួយ ហើយកិច្ចការពារនេះមិនកើតឡើងតែក្នុងបរិបទណាមួយឡើយ ។

នៅក្នុងបទដ្ឋានអន្តរជាតិសម្រាប់សភាប្រជាធិបតេយ្យ NDI បានលើកឡើងថា : គឺជាបុព្វសិទ្ធិរបស់អំណាចនីតិបញ្ញត្តិ ដើម្បីអាចបង្កើតនូវគណៈកម្មការស៊ើបអង្កេតទៅលើគ្រប់បញ្ហាជាផលប្រយោជន៍រួម ។ សិទ្ធិនេះនាំឱ្យមានលទ្ធភាពដើម្បីទទួលបានព័ត៌មាន និងសាក្សី (ជនទាំងអស់ដែលបើកកកាយអំពីការរំលោភបំពាន) ដើម្បីផ្តល់ព័ត៌មានជាក់លាក់ ដោយមានការធានាថា អត្តសញ្ញាណរបស់ខ្លួនពុំត្រូវបានបែកខ្ញែរខ្ចាយ ហើយសក្ខីកម្មរបស់ខ្លួនមិននាំឱ្យមានការប្រទូស្តរាយជាលក្ខណៈបុគ្គល ឬវិជ្ជាជីវៈឡើយ ។

ប្រទេសជាច្រើនមានច្បាប់ប្រភេទនេះ តែកិរិតនៃកិច្ចការពារដែលមានផ្តល់ឱ្យខុសប្លែកគ្នាជាច្រើន ។ កាលណាកិច្ចការពារគ្របដណ្តប់តែលើការបែកធ្លាយដោយផ្លូវស្របច្បាប់នោះ នីតិវិធីនេះអាចនាំឱ្យមានបញ្ហា ឬជូនកាលរហូតដល់ "កប់បាត់" ដោយសម្ងាត់ទៀតផង ។

នៅសហរដ្ឋអាមេរិក ផ្ទុយទៅវិញ ជនដែលធ្វើការឱ្យរដ្ឋាភិបាលសហព័ន្ធ ដែលបើកកកាយការរំលោភបំពាន ពុំត្រូវនាំមកបង្ហាញសក្តីកម្មតាមផ្លូវផ្លូវការផ្សេងៗឡើយ ។ ម្យ៉ាងទៀត ជននោះត្រូវបានការពារ ទោះបីព័ត៌មានដែលជននោះបានឆ្លើយប្រាប់ ត្រូវបានទំលាយតាមសារព័ត៌មានក្តី ។

## <u>ការសិក្សាអំពីករណីត្រួតពិនិត្យលើនយោបាយសន្តិសុខ</u>

វិស័យដែលបញ្ហាត្រួតពិនិត្យរបស់សភានៅចម្រូងចម្រាស់ គឺការត្រួតពិនិត្យទៅលើនយោបាយសន្តិសុខ ។

មានបញ្ហា ៣ ពាក់ព័ន្ធនឹងការត្រួតពិនិត្យរបស់សភានៅក្នុងវិស័យនេះ

- ច្បាប់ស្តីពីការសម្ងាត់ អាចរារាំងដល់តម្លាភាពនៅក្នុងវិស័យសន្តិសុខ ។
- វិស័យសន្តិសុខ គឺជាទីលានស្មុគស្មាញ ដែលសភាត្រូវត្រួតពិនិត្យទៅលើបញ្ហាដូចជា ទីផ្សារអាវុធ ការត្រួតពិនិត្យសព្វាវុធ និងការរៀបចំអង្គភាពយោធា ។ តែសមាជិកសភាពុំមែនសុទ្ធតែយល់ដឹង និងមានបទពិសោធន៍ ដើម្បីចាត់ចែងបញ្ហានេះដោយត្រឹមត្រូវឡើយ ។
- សារសំខាន់ផ្តល់ចំពោះសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យសន្តិសុខ អាចមានផលវិបាកដល់តម្លាភាព និងភាពស្របច្បាប់តាមលទ្ធិប្រជាធិបតេយ្យ នៃនយោបាយសន្តិសុខរបស់ប្រទេសមួយ ។ មានទិដ្ឋភាព២ នៃការយកចិត្តទុកដាក់ដល់ការត្រួតពិនិត្យនៅក្នុងវិស័យនេះ

  ទិដ្ឋភាពទី១ ពាក់ព័ន្ធនឹងការយល់ព្រមឱ្យវាយកងទ័ពជាតិនៅខាងក្រៅប្រទេស ។ ដើម្បីមានអភិបាលកិច្ចល្អ និងក្នុងទស្សនៈវិស័យប្រជាធិបតេយ្យ វាជាការប្រសើរដែលសភាអាចចូលរួមក្នុងការសម្រេចបញ្ជូនកងទ័ពទៅខាងក្រៅប្រទេស ។ នៅប្រទេសជាច្រើន ការអនុវត្តមានការខុសៗគ្នា ក្នុងប្រទេសខ្លះ ការវាយកងទ័ពនៅខាងក្រៅប្រទេសតម្រូវឱ្យមានការយល់ព្រមជាមុនពីសភា ឬក្នុងករណីបន្ទាន់ ការយល់ព្រមបន្ទាប់ពីហេតុការណ៍ ។ នៅប្រទេសខ្លះទៀត ការវាយកងទ័ពនេះគឺជាសិទ្ធិផ្តាច់មុខរបស់អង្គនីតិប្រតិបត្តិ ។ សភាអាចជជែកពិភាក្សាអំពីបញ្ហានេះ តែមិនអាចត្រួតពិនិត្យទៅលើការប្រតិបត្តិអំណាចជាឆន្ទានុសិទ្ធិរបស់អង្គនីតិប្រតិបត្តិបានឡើយ ។

ជាឧទាហរណ៍ ប្រទេសពីរគឺ ស៊ុយអែត និងអាល្លឺម៉ង់ អនុវត្តន៏នូវប្រភេទទី១ គឺការយល់ព្រមជាមុនពីសភា ដោយលើកលែងតែករណីបន្ទាន់។ សភា Bundestag អាចដកការយល់ព្រមរួចហើយអំពីការវាយទ័ពបានគ្រប់ពេលវេលា ។

**<u>ច្បាប់ប្រឆាំងភេរវកម្ម</u>**

ទិដ្ឋភាពចម្រូងចម្រាស់មួយទៀត គឺច្បាប់ប្រឆាំងភេរវកម្ម ដែលចោទដល់សង្គមប្រជាធិបតេយ្យនូវបញ្ហាមួយដ៏ធ្ងន់ធ្ងរ : តើត្រូវរកលំនឹងរវាងសន្តិសុខ និងកិច្ចការពារសេរីភាពស៊ីវិល និងនយោបាយយ៉ាងដូចម្តេច ពីព្រោះការតម្រូវទាំងពីរនេះពុំអាចសម្របសម្រួលគ្នាបានឡើយ ។

ជាការពិត វាជាការចាំបាច់បំផុតត្រូវមានតុល្យភាពរវាងសេរីភាព និងសន្តិសុខ ហើយបញ្ហាតុល្យភាពពុំមែនជាបន្ទុកផ្តាច់មុខរបស់អង្គនីតិប្រតិបត្តិឡើយ ។ ក្នុងឋានៈជាតំណាង និងជាអ្នកធានានូវសិទ្ធិរបស់ប្រជាពលរដ្ឋ សភាត្រូវត្រួតពិនិត្យដោយយកចិត្តទុកដាក់នៅក្នុងវិស័យនេះ តាមជំហានផ្សេងៗដូចជា

- អនុម័តយកទស្សនៈទូលាយនៃការតស៊ូប្រឆាំងអំពើភេរវកម្ម ជាទស្សនៈដែលមិនគិតត្រឹមតែកិច្ចការពារ និងសន្តិសុខប៉ុណ្ណោះទេ តែប្រមូលផ្តុំផងដែរនូវការសិក្សាអំពីមូលហេតុដំបូង ។
- ធានាថារដ្ឋបានចូលនៅក្នុងអនុសញ្ញាអន្តរជាតិ និងក្នុងពិធីសារពាក់ព័ន្ធនឹងការប្រឆាំងអំពើភេរវកម្ម ។
- អនុម័តវិធានការតាមផ្លូវច្បាប់សំដៅទូទាត់សំណងដល់អ្នករងគ្រោះដោយអំពើភេរវកម្ម នៅក្នុងក្របខ័ណ្ឌសាមគ្គីជាតិ ។
- ធានាឱ្យច្បាប់ប្រឆាំងភេរវកម្មថែរក្សាបាននូវតុល្យភាពដ៏ល្អ រវាងតម្រូវការសន្តិសុខ និងការប្រតិបត្តិនូវសិទ្ធិស៊ីវិល និងនយោបាយ ។

បទដ្ឋាននានានៃអនុសញ្ញាតំបន់ និងអន្តរជាតិ ត្រូវខិតខំរក្សាលំនឹងបែបនេះ ពុំអាចបន្ធូរបន្ថយបានឡើយ ហាមឃាត់ដាច់ខាតការប្រើប្រាស់ការធ្វើទារុណកម្ម រួមទាំងការចាប់នាំខ្លួននូវជនភៀសខ្លួន ឬអាណិក-ជនបរទេសទៅកាន់ប្រទេសដែលមានការអនុវត្តនូវការធ្វើទារុណកម្ម ការហោះហើរឆ្លងកាត់ដែនអាកាសប្រទេសមួយសម្រាប់គោលដៅនេះ ។

សភាមានការទទួលខុសត្រូវពិសេស គឺការស៊ើបអង្កេតទៅលើការអនុវត្តទាំងនេះ និងធ្វើការប្រឆាំងកាលណាមានករណីបែបនេះកើតឡើង ។

## ការត្រួតពិនិត្យថវិកា និងហិរញ្ញវត្ថុ

ជាប្រពៃណី សភាត្រូវទទួលបន្ទុកត្រួតពិនិត្យចំណូល និងចំណាយសាធារណៈ ។ ពាក្យស្លោកដ៏ល្បីល្បាញ "គ្មានពន្ធ គ្មានភាពតំណាង" បញ្ជាក់ថា មានតែការយល់ព្រមដោយអ្នកតំណាងជាប់ឆ្នោតប៉ុណ្ណោះ ដែលធ្វើឱ្យការយកពន្ធត្រូវទទួលយកបានដោយប្រជាពលរដ្ឋ ។ ការត្រួតពិនិត្យរបស់សភាទៅលើហិរញ្ញវត្ថុសាធារណៈ មានចែកជាពីរដំណាក់កាល : ការពិនិត្យ និងយល់ព្រមទៅលើផែនការរបស់រដ្ឋាភិបាលសម្រាប់ចំណូល និងចំណាយ ដើម្បីធានាថាចំណូល និងចំណាយនេះសមស្របទៅនឹងល័ក្ខខ័ណ្ឌដែលយល់ព្រមដោយសភា ។ ជាការពិត ដំណាក់កាលទី១តែងមានផលវិបាកទៅលើដំណាក់កាលទី២ ព្រមទាំងលើការវិលមួយជុំប្រចាំឆ្នាំ ដែលជាដំណើរការបន្តបន្ទាប់ ។

## ការត្រួតពិនិត្យថវិកា

គឺអង្គនីតិប្រតិបត្តិត្រូវកំណត់គម្រោងថវិកាប្រចាំឆ្នាំ ដោយលំអិតដែលលើកឡើងអំពីចំណូល និងចំណាយសាធារណៈ ។

នៅប្រព័ន្ធសភា Westminster ប្រពៃណីគឺបង្ហាញថវិកាដល់សភា នៅមួយថ្ងៃជាក់លាក់ និងតែម្តងគត់ ដែលធ្វើឱ្យមានលក្ខណៈចង្អៀតក្នុងការកែប្រែនៅក្នុងសភា ។ រដ្ឋមន្ត្រីទទួលបន្ទុកខាងការរៀបចំថវិកាតែងទទួលសំណើពីវិស័យសេដ្ឋកិច្ច-សង្គមផ្សេងៗនៅក្នុងដំណើរការរៀបចំថវិកា តែសភាខ្លួនឯងត្រូវបានពិគ្រោះ ឬជំរាបជូនតែនៅពេលនៃការបង្ហាញថវិកាតាមថ្ងៃដែលបានគ្រោងទុកប៉ុណ្ណោះ ។ ចាប់ពីពេលនោះតួនាទីរបស់សភាតម្រូវឱ្យពិភាក្សាទៅលើបន្ទាត់ជាគោលការណ៍ធំៗនៃគម្រោងថវិកាក្នុងសម័យប្រជុំពេញអង្គ ហើយរកឱ្យឃើញនូវភាពមិនស៊ីសង្វាក់ ឬការសន្សំសំចៃដែលអាចធ្វើបានយោងទៅតាមការវិភាគលំអិតរបស់គណៈកម្មការហិរញ្ញវត្ថុ ។

នៅសភាតណ្ណាមានគណៈកម្មការវាយតម្លៃរបស់សភា ដែលមានភារកិច្ចពិនិត្យគម្រោងចំណាយរបស់រដ្ឋាភិបាល ដូចដែលចែងនៅក្នុងសេចក្តីថ្លែងការណ៍នយោបាយខាងហិរញ្ញវត្ថុប្រចាំឆ្នាំ និងបង្ហាញអំពីកំហុសដែលអាចកើតឡើងពីការមិនស៊ីសង្វាក់ ព្រមទាំងការសន្សំសំចៃ ការកែលំអការចាត់តាំង កំណើនប្រសិទ្ធភាព ឬការកែលំអខាងរដ្ឋបាល ដែលអាចសម្រេចបានស្របទៅតាមនយោបាយ ដែលការវាយតម្លៃធ្វើជាមូលដ្ឋាន ។

ជាទូទៅនៅក្នុងប្រទេសជាច្រើន សភាទទួលគម្រោងថវិកាក្នុងរយៈពេលពី២ ទៅ ៤ខែ មុនពេលផ្តើមមាតិកាហិរញ្ញវត្ថុថ្មី ។ រយៈពេលនេះអនុញ្ញាតឱ្យសភាដើរតួនាទីកាន់តែកំណត់សម្រាប់ការកំណត់ទិសដៅនៃថវិកាចុងក្រោយ ទោះតាមរយៈការពិភាក្សា និងការចរចាមុនពេលរៀបចំថវិកា ឬក្នុងដំណាក់កាលត្រួត

ពិនិត្យទៅលើសំណើរបស់រដ្ឋាភិបាលក្តី ។ វិភាគទានរបស់សភាលើចំណុចនេះ ចាត់ទុកថាសំខាន់បំផុតនៅប្រទេសន័រវេស ព្រោះការកំណត់អំពីការចំណាយសរុប និងការបែងចែកថវិកាតាមមាតិកាផ្សេងៗប្រព្រឹត្តទៅនៅក្នុងសភា ។ នីតិវិធីនេះមាននិន្នាការបង្កើនចំណាយ ដើម្បីសម្របសម្រួលដល់អាទិភាពរបស់គណបក្សផ្សេងៗ តែចុងក្រោយនេះសភាន័រវេសបានកែប្រែនីតិវិធី ដោយគណបក្សទាំងអស់ឯកភាពគ្នាមុន អំពីកញ្ចប់ចំណាយសរុប និងកញ្ចប់ចំណាយតាមវិស័យជាមុន មុននឹងចូលដល់ចំណុចលំអិតនៅក្នុងវិស័យ ។

សភាស៊ុយអែតបានធ្វើកំណែទម្រង់ដូចគ្នា ដើម្បីរារាំងមិនឱ្យបង្កើនកញ្ចប់ថវិកាដោយគ្មានប្រាក់ចាំបាច់សម្រាប់ធ្វើហិរញ្ញប្បទាន ។

នៅប្រទេសសេណេហ្កាល់ ឥទ្ធិពលរបស់សភាទៅលើថវិការបស់រដ្ឋាភិបាលបានកើនឡើង បន្ទាប់ពីការអនុម័តយកការពិភាក្សាស្តីពីការកំណត់ទិសដៅថវិកា ដែលសមាជិកសភាអាចពិនិត្យទៅលើលក្ខណៈវិនិច្ឆ័យសំខាន់ៗនៃច្បាប់ហិរញ្ញវត្ថុ មុនចូលដល់ការបង្ហាញច្បាប់ ។

នៅប្រទេសហ្ស៊ីមបាវេ ដំណើរការត្រួតពិនិត្យរបស់សភា មានដំណាក់កាលមួយមុនការពិនិត្យថវិកាដោយគណៈកម្មការនានាទៅលើសំណើចំណាយរបស់ក្រសួងផ្សេងៗ ព្រមទាំងដំណាក់កាលមួយទៀតបន្ទាប់ពីការបង្ហាញជាផ្លូវការនូវថវិកា ។ បន្ទាប់ពីនោះ គណៈកម្មការតាមវិស័យពិនិត្យជាថ្មីម្តងទៀត ។ គណៈកម្មការថវិកាតាក់តែងរបាយការណ៍សរុបមួយ ស្តីពីគោលដៅម៉ាក្រូសេដ្ឋកិច្ច និងអាទិភាពទូទៅ។ គណៈកម្មការសភាអាចប្រឹក្សាជាមួយប្រជាពលរដ្ឋ ក្រសួង និងអង្គការស៊ីវិល ទៅលើតួលេខ និងកម្មវិធីនៃគម្រោងថវិកា ។

នៅពេលដែលសភាមានតួនាទីកាន់តែសំខាន់នៅក្នុងការពិភាក្សាមុនការពិនិត្យថវិកា សភាមានលទ្ធភាពពិនិត្យទៅផលប៉ះពាល់នៃការបែងចែកថវិកាទៅលើក្រុមសង្គមផ្សេងៗ និងមានឥទ្ធិពលទៅលើទម្រង់នៃគម្រោងថវិកា ដែលនឹងដាក់ចុងក្រោយមកសភា។ អញ្ចឹងបានឃើញជាឧទាហរណ៍ នូវគំនិតផ្តួចផ្តើមហិរញ្ញវត្ថុសម្រាប់សមភាពរវាងបុរស និងនារី (ជំពូកទី៤) ។

ទិដ្ឋភាពមួយទៀតនៃថវិកាជាតិ ដែលសភានៃប្រទេសកំពុងអភិវឌ្ឍន៍ពិបាកនឹងបង្កឥទ្ធិពល គឺទិដ្ឋភាពនៃបរិមាណទឹកប្រាក់ និងល័ក្ខខ័ណ្ឌនៃការសងបំណុលដែលផ្តល់ដោយអង្គការអន្តរជាតិ ដូចជាមូលនិធិហិរញ្ញវត្ថុអន្តរជាតិ IMF ដោយដឹងច្បាស់ថា ល័ក្ខខ័ណ្ឌទាំងនោះអាចកំណត់នូវថវិកាជាតិសម្រាប់មួយជំនាន់ ។

## ការត្រួតពិនិត្យចំណាយសាធារណៈ

ការត្រួតពិនិត្យជាខាងក្រោយ (A posteriori) លើការចំណាយរបស់រដ្ឋាភិបាល ត្រូវបានសភានៃប្រទេសជាច្រើនប្រគល់ទៅឱ្យគណៈកម្មការគណនីសាធារណៈ ឬទៅឱ្យស្ថាប័នថ្នាក់ស្មើ ជាទូទៅ ស្ថិតនៅ

ក្រោមសមាជិកសភាមួយរូប ដែលស្ថិតនៅគណបក្សផ្សេងពីគណបក្សរបស់រដ្ឋាភិបាល ដើម្បីធានានូវឯករាជ្យភាពរបស់ខ្លួន ។ ដើម្បីត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព ត្រូវឆ្លើយនឹងសំណួរដូចតទៅ

- តើថវិកាសាធារណៈត្រូវបានចំណាយតាមគោលដៅដែលបានចែងដែរឬទេ?
- តើថវិកាសាធារណៈត្រូវបានចំណាយប្រកបដោយប្រសិទ្ធភាព និងគ្មានការខ្ជះខ្ជាយដែរឬទេ?
- តើមានភស្តុតាងនៃកំហុស ការបង្វែ ឬភាពមិនប្រក្រតីដទៃទៀតដែរឬទេ?

សភាខ្លះបានបោះបង់ការត្រួតពិនិត្យដោយលំអិត ដោយមានការតាមដានលើដំណើរនៃការចំណាយជំនួសវិញដោយការវិភាគទៅលើលទ្ធផលដោយធៀបទៅនឹងគោលដៅនៃការងារ នៅក្នុងក្របខ័ណ្ឌនៃប្រភេទថវិកាធំទូលាយ ។ កំណែទម្រង់ថវិកាបារាំងឆ្នាំ ២០០១ បានអនុវត្តន៍តាមរបៀបនេះ ដើម្បីទុកឱ្យអ្នកអនុវត្តន៍នូវលទ្ធភាពបត់បែនក្នុងការប្រើប្រាស់ឥណទានក្នុងកម្មវិធី និងអនុញ្ញាតឱ្យមានការត្រួតពិនិត្យទៅលើសកម្មភាពរបស់រដ្ឋាភិបាល ទៅតាមគោលដៅ និងលទ្ធផលនៃនយោបាយដែលបានផ្តល់ហិរញ្ញប្បទានដោយថវិការដ្ឋ ។ ជាការពិត ការផ្សារភ្ជាប់កម្មវិធីនៃគោលដៅទៅនឹងលទ្ធផលរំពឹងទុក អនុគ្រោះឱ្យប្រែប្រួលពីវប្បធម៌មធ្យោបាយទៅកាន់វប្បធម៌វាយតម្លៃលើការងារ ។

ក្នុងភារកិច្ចត្រួតពិនិត្យហិរញ្ញវត្ថុ សភាជាច្រើនតែងពឹងផ្អែកទៅលើការជួយឧបត្ថម្ភរបស់អគ្គសវនករដែលទទួលបន្ទុកផ្ទៀងផ្ទាត់គណនីទាំងអស់របស់រដ្ឋាភិបាល រួមទាំងគណនីរបស់សហគ្រាសសាធារណៈ និងអង្គភាពស្វយ័តដែលចំណាយថវិកាសាធារណៈ (ក្នុងករណីប្រទេសជាច្រើន) ។

នៅសាធារណរដ្ឋកូរ៉េ រដ្ឋសភាពុំមានស្ថាប័នឯករាជ្យទទួលបន្ទុកជួយដល់ការត្រួតពិនិត្យគណនីសាធារណៈឡើយ ។ នាឆ្នាំ២០០៣ គេបានបង្កើតអង្គភាពសេវាថវិការបស់រដ្ឋសភា ក្រោមបន្ទុកផ្ទាល់របស់ប្រធានរដ្ឋសភា ។ អង្គភាពសេវាថវិការបស់សភាប្រមូលផ្តុំអ្នកឯកទេស៨០រូប ដែលឯករាជ្យពីគណបក្សនានា ទទួលបន្ទុកពុំត្រឹមតែវិភាគទៅលើថវិកា និងគណនីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ាន់ប្រមាណការចំណាយដែលចេញមកពីការរៀបចំ ឬការកែប្រែសេចក្តីព្រាងច្បាប់ រួមទាំងបទដ្ឋានផ្សេងៗរបស់សភាផង ។ រដ្ឋសភាថែរក្សាសកម្មភាពធ្វើច្បាប់នៅក្នុងក៏រិតនៃការចំណាយសមហេតុផល ដោយរារាំងការប្រកាសឱ្យប្រើនូវច្បាប់ ឬការកែប្រែសេចក្តីព្រាងច្បាប់ ដែលអាចជះឥទ្ធិពលធ្ងន់ធ្ងរទៅលើថវិកាជាតិ ។

ប្រព័ន្ធតស៊ូប្រឆាំងអំពើពុករលួយ គឺជាធាតុសំខាន់មួយនៃការត្រួតពិនិត្យទៅលើការចំណាយសាធារណៈនៅក្នុងប្រទេសជាច្រើន ។

ច្បាប់របស់ប្រទេស Afrique du Sud ពាក់ព័ន្ធនឹងការចាត់ចែងថវិកាសាធារណៈឆ្នាំ ១៩៩៩ បានដាក់អ្នកទទួលខុសត្រូវជាន់ខ្ពស់នៃរដ្ឋបាល ជាអ្នកទទួលខុសត្រូវចំពោះការប្រើប្រាស់ជាយថាហេតុពុំបានត្រឹមត្រូវនូវមូលនិធិសាធារណៈ តម្រូវឱ្យអ្នកទទួលខុសត្រូវជាន់ខ្ពស់បង្កើតនៅក្នុងរដ្ឋបាលរបស់ខ្លួន នូវប្រព័ន្ធត្រួតពិនិត្យដែលរារាំងការរំលោភបំពានផ្សេងៗ ។ ច្បាប់នេះតម្រូវផងដែរឱ្យគ្រប់រដ្ឋបាលឱ្យរៀបចំយុទ្ធសាស្ត្រតស៊ូប្រឆាំងអំពើពុករលួយ និងអំពើកិបកេង និងដាក់ជូនអគ្គរតនាគារនៅក្នុងពេលវេលាកំណត់ ។

ប្រទេសជាច្រើនបានបង្កើតគណៈកម្មការប្រឆាំងអំពើពុករលួយឯករាជ្យ ដែលមានសិទ្ធិស៊ើបអង្កេត និងបង្ខំឱ្យគោរពតាមច្បាប់ ហើយតាមរយៈរបាយការណ៍ផ្ញើជូនសភា តែងជួយដល់ការងាររបស់អគ្គសវនករ និងគណៈកម្មការគណនីសាធារណៈ ។

## ការលើកតម្កើងឯកភាពជាតិតាមមធ្យោបាយប្រជាធិបតេយ្យ

ក្នុងចំណោមភារកិច្ចសំខាន់ផ្សេងៗទៀតដែលពុំសូវជាមើលឃើញ ដែលសភាត្រូវខិតខំនោះ គឺមានការលើកតម្កើងនូវសមាហរណកម្មជាតិ តាមរយៈការពឹងផ្អែកទៅលើដំណើរការស្ថាប័នប្រជាធិបតេយ្យទៅលើដែនដីជាតិទាំងមូល ។

នៅប្រទេសជាច្រើន ជាពិសេសនៅប្រព័ន្ធនយោបាយសហព័ន្ធ មុខងារនេះត្រូវបានផ្ទេរទៅឱ្យសភាទីពីរ ។

ជាឧទាហរណ៍ នៅប្រទេស Afrique de Sud សភាទីពីរគឺក្រុមប្រឹក្សាជាតិរបស់ខេត្ត (NCOP) គឺជាតំណាងឱ្យផលប្រយោជន៍របស់ខេត្តនានា និងផលប្រយោជន៍មូលដ្ឋាននៅក្នុងក្របខ័ណ្ឌជាតិ ។ តួនាទីនេះត្រូវបានរៀបចំឡើងនៅក្នុងបរិបទដែលមានមុខព្រួញឆ្ពោះទៅកាន់សហប្រតិបត្តិការ បានន័យថា នយោបាយជាតិត្រូវតែចាប់អារម្មណ៍ដល់ការយកចិត្តទុកដាក់ និងដល់សេចក្តីត្រូវការរបស់មូលដ្ឋាន និងភូមិភាគ។ ប្រការនេះបានន័យផងដែរថា ក្រុង ជាពិសេសខេត្តនានា ពុំត្រូវធ្វើសកម្មភាពទោលដោយឯកោឡើយ ប៉ុន្តែជាផ្នែករួមនៃដំណើរការនយោបាយរបស់ជាតិ ។

នៅប្រទេសឥណ្ឌា សភាជាន់ខ្ពស់ (ក្រុមប្រឹក្សានៃបណ្តារដ្ឋ) មានសមាសភាពជាតំណាងជាប់ឆ្នោតដោយសមាជិក (ខ្លួនឯងក៏បានជាប់ឆ្នោតរួចហើយ) នៃសភារបស់រដ្ឋនីមួយៗ ឬដែនដីរបស់សហភាព ។ ក្រុមប្រឹក្សានៃបណ្តារដ្ឋ មានបន្ទុកជាពិសេសសម្របសម្រួលនយោបាយ និងច្បាប់ជាតិនៅក្នុងដែនដីរបស់សហភាពទាំងមូល ។ សន្និសីទមួយនៃប្រធានស្ថាប័ននីតិបញ្ញត្តិ ក្នុងកំរិតកណ្តាល និងតំបន់ បានប្រព្រឹត្តទៅជារៀងរាល់ឆ្នាំ ដើម្បីផ្លាស់ប្តូរគំនិត និងបទពិសោធន៍នៃការអនុវត្ត ដើម្បីធានាថាប្រព័ន្ធគ្រប់គ្រងតាមរយៈសភាអភិវឌ្ឍន៍

ទៅតាមផ្លូវត្រូវ អនុសញ្ញា និងបទដ្ឋានផ្សេងទៀតត្រូវអនុម័តទៅតាមទិសដៅនេះ និងតាមអាចធ្វើទៅបាន មានភាពឯកភាពគ្នានៅក្នុងការអនុវត្ត និងនីតិវិធីរបស់សភាជាតិ និងសភាតាមបណ្ដារដ្ឋ ។

នេះគឺជាមុខងារសម្របសម្រួលដែលមាននៅក្នុងប្រទេសបារាំងផងដែរ ដែលមានតួនាទីប្រហាក់ប្រហែលគ្នាចំពោះស្ថាប័នជាប់ឆ្នោតដទៃទៀតនៅក្នុងប្រទេស

ក្នុងឋានៈជាតំណាងឱ្យសមូហភាពមូលដ្ឋាន បានន័យថាប្រជាពលរដ្ឋនៅក្នុងឃុំ ស្រុក ភូមិភាគរបស់ខ្លួននោះ ព្រឹទ្ធសភារៀបចំសន្និសីទស្ដីពី "ស្ថានភាពទូទៅរបស់អ្នកជាប់ឆ្នោតមូលដ្ឋាន" ដែលប្រមូលផ្ដុំជុំវិញប្រធានព្រឹទ្ធសភានូវអ្នកជាប់ឆ្នោតមូលដ្ឋានទាំងអស់ ដើម្បីដោះស្រាយបញ្ហាចំពោះសមូហភាពដែនដី ដែលបានធ្វើវិមជ្ឈការ ហើយព្រឹទ្ធសភាគឺជាអ្នកនាំពាក្យ ។ សន្និសីទចុងក្រោយមានប្រធានបទអំពីភាពទាក់ទងគ្នាអន្តរឃុំ ។

ដូចគ្នានេះដែរ សភាអ៊ុយក្រែនបានបង្កើតគណៈកម្មការពិគ្រោះយោបល់មួយ ស្ដីពីការគ្រប់គ្រងស្វយ័តក្រោមអំណាចរបស់ប្រធានសភា ទទួលបន្ទុកដើម្បីពង្រឹងភាពស្វយ័តរបស់មូលដ្ឋាន ជម្រុញការបង្កើតសមាគមនៃសហគមន៍ស្វយ័ត និងធ្វើសកម្មភាពក្នុងនាមជាអ្នកសម្រុះសម្រួលរវាងគណៈកម្មការសភា និងស្ថាប័នតំណាងមូលដ្ឋានសម្រាប់បញ្ហាពាក់ព័ន្ធនឹងបទបញ្ញត្តិផ្សេងៗ ។

## ការដោះស្រាយវិវាទ និងជម្លោះ

លក្ខណៈពិសេសមួយនៃតួនាទី ដែលសភាត្រូវសម្ដែងនៅក្នុងការលើកតម្កើងនូវឯកភាពជាតិ នោះគឺការរួមវិភាគទានរបស់សភានៅក្នុងការដោះស្រាយវិវាទ ។

សភាត្រៀមខ្លួនយ៉ាងល្អ ដើម្បីដោះស្រាយវិវាទនយោបាយតាមរយៈមធ្យោបាយប្រជាធិបតេយ្យនៃការសន្ទនា និងការសម្របសម្រួលគ្នា ។ សម្រាប់កិច្ចការនេះ សភាមានតួនាទីដ៏មានតម្លៃសម្រាប់សម្ដែងជួយឱ្យជំនះលើការបែកបាក់គ្នាដ៏ធ្ងន់ធ្ងរខាងទស្សនៈ និងជម្លោះដែលហែកហួរសង្គមទាំងមូល ។ ជាការពិតជម្លោះទាំងនេះអាចមើលឃើញថែមទាំងកើនឡើងថែមទៀត ដោយសារការប្រកួតប្រជែងដែលគណបក្សនានាខិតខំនៅក្នុងសភា ជាពិសេស កាលណាភាពបដិបក្ខមានដំណើរការដាច់ខាតតាមតែគណបក្សរៀងៗខ្លួន ហើយអនុម័តយកនូវគោលការណ៍ "អ្នកឈ្នះយកទាំងអស់" ។ នៅក្នុងករណីបែបនេះ សភាត្រូវមានការទទួលខុសត្រូវពិសេស ចង្អុលផ្លូវដោយបង្ហាញថា វាមានប្រយោជន៍សំខាន់នឹងរាប់រកជាមួយអ្នកដែលមានទស្សនៈខុសគ្នា ដោយក្ដីគោរព និងចាប់ផ្ដើមជាមួយពួកគេតាមការសន្ទនាដោយមានការយកចិត្តទុកដាក់ ។

នៅក្នុងសេចក្តីណែនាំអន្តរជាតិ ស្តីពីការពង្រឹងសមត្ថភាពរបស់សភា ក្នុងការបង្ការវិបត្តិ និងការចាត់ចែងស្ថានការណ៍ក្រោយជម្លោះ (២០០៦) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ UNDP ទទួលស្គាល់អំពីការរួមវិភាគទានដ៏សំខាន់របស់សភានៅក្នុងវិស័យនេះ ។ UNDP បានកត់សម្គាល់ថា ការរៀបចំបោះឆ្នោតនៅក្នុងស្ថានការណ៍មួយក្រោយជម្លោះ ត្រូវបានគេគិតថា ជាល័ក្ខខ័ណ្ឌចាំបាច់ និងគ្រប់គ្រាន់សម្រាប់ការពង្រឹងសន្តិភាព តែគេច្រើសប្រហែសជាញឹកញាប់អំពីតួនាទីដ៏ខ្លាំងក្លាក្នុងរយៈពេលវែងរបស់សភានៅក្នុងវិស័យនេះ ។

អភិបាលកិច្ចស្របច្បាប់ និងមានលក្ខណៈតំណាងប្រកបដោយប្រសិទ្ធភាព ឈរលើការលើកតម្កើងសិទ្ធិ និងការគោរពសេរីភាព និងសិទ្ធិជាមូលដ្ឋានរបស់មនុស្ស នោះគឺជាមធ្យោបាយដែលមានប្រសិទ្ធភាពបំផុត ដែលសង្គមទាំងឡាយរកឃើញដើម្បីបង្ការជម្លោះ ចាត់ចែងជម្លោះ និងងើបឡើងផុតពីជម្លោះ ។ គឺនៅក្នុងដែននយោបាយ ដែលសភាទាំងឡាយចាត់ចែងជាញឹកញាប់នូវវិវាទ ដោយជៀសវាងកុំឱ្យវិវាទទាំងនោះប្រែក្លាយទៅជាជម្លោះប្រកបដោយហឹង្សា ។ ប៉ុន្តែនៅក្នុងសង្គមប្រជាធិបតេយ្យខ្លះ គេបានចាប់អារម្មណ៍អំពីវិភាគទានរបស់សភាតែនៅពេលសភាបរាជ័យប៉ុណ្ណោះ ។ ការពិភាក្សារបស់សភា ការព្រមព្រៀងរវាងគណបក្សនយោបាយ អន្តរកម្មរវាងសភា អ្នកត្រូវគេគ្រប់គ្រង និងសង្គមស៊ីវិល ការផ្លាស់ប្តូរយោបល់មិនផ្លូវការរវាងសមាជិកសភា តែងនាំដល់ការថែរក្សាសន្តិភាព ។ បទពិសោធន៍ចេញមកពីស្ថានការណ៍ថ្មីៗនៅក្រោយជម្លោះបង្ហាញថា ការជួយឧបត្ថម្ភពីតួអង្គខាងក្រៅ តែងជាញឹកញាប់វាយតម្លៃពុំត្រឹមត្រូវអំពីតួនាទីដ៏ខ្លាំងក្លារបស់ស្ថាប័នសភា និងរបស់តំណាងជាប់ឆ្នោតឡើយ ។

បទពិសោធន៍នៅហ្វីមបាវេ, ម៉ាលី បានបង្ហាញអំពីផ្លែផ្កានៃការងាររបស់សភា ដើម្បីរួមចំណែកដោះស្រាយជម្លោះ និងពង្រឹងសន្តិភាព-ស្ថេរភាព ។

ជួនកាលមានពេលខ្លះ សភាអាចបើកផ្លូវដល់ការដោះស្រាយជម្លោះណាមួយដែលមានឫសគល់ជ្រាលជ្រៅ ដែលផ្ទុះឡើងនៅក៏រិតចម្មនុញ្ញ ដូចជាករណីនៅប្រទេសអ៊ុយក្រែន ដែលផ្សារភ្ជាប់នឹងបដិវត្តពណ៌ទឹកក្រូចនាឆ្នាំ ២០០៤។

## VII-<u>សភាប្រកបដោយប្រសិទ្ធភាព</u>

### (២)_<u>ការចូលរួមរបស់សភាក្នុងកិច្ចការអន្តរជាតិ</u>

តាមប្រពៃណី សភារហូតមកដល់ពេលនេះចូលឡូកឡំដោយតិចបំផុតនៅក្នុងកិច្ចការអន្តរជាតិ។ គ្មានអ្វីដែលភ្ញាក់ផ្អើលនោះទេ ពីព្រោះកិច្ចការអន្តរជាតិសំដៅទំនាក់ទំនាក់រវាងប្រទេសមួយ និងប្រទេសផ្សេង

ទៀត ។ ទំនាក់ទំនងអន្តរជាតិនេះ ត្រូវដឹកនាំដោយអង្គនីតិប្រតិបត្តិ និងតាមផ្លូវការទូត ដែលជាញឹកញាប់ដោយសម្ងាត់ ។

ជាការពិត សភាជាច្រើនបានដើរតួនាទីសំខាន់ដោយផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀង ដែលជាលទ្ធផលនៃការទាក់ទងគ្នាតាមផ្លូវការទូត តែជាភាគច្រើន ការចូលរួមរបស់សភាពុំដែលបានដើរទៅឆ្ងាយឡើយ លើកលែងតែករណីប្រទេសខ្លះដូចជា សហរដ្ឋអាមេរិក និងប្រទេសម៉ិចស៊ិក ដែលសភាដើរតួនាទីចម្បងនៅក្នុងកិច្ចការបរទេស ។

សតវត្សទី២០ បាននាំមកនូវការផ្លាស់ប្តូរ២ដ៏សំខាន់ និងខុសគ្នា ។

❶ នៅក្នុងសតវត្សមានការករកើតនូវសហប្រតិបត្តិការអន្តរជាតិ ឬពហុភាគី ដោយមានការបង្កើតនូវអង្គការអន្តរជាតិជាច្រើន ខ្លះដោយសម្បញ្ញជញ្ញៈអំពីការពឹងពាក់គ្នារវាងប្រជាជាតិនានា ដែលបានពង្រឹងនូវបាតុភូតនេះ ។ វិស័យនៃសមត្ថកិច្ចរបស់អង្គការទាំងនេះប៉ះពាល់ទៅស្ទើរតែគ្រប់សកម្មភាពរបស់មនុស្ស : សិទ្ធិមនុស្ស និងសិទ្ធិសង្គម នយោបាយ ការងារ និងផ្សេងៗទៀត ។ ស្ថាប័នទាំងនោះ គឺជាអាទិភាពនៃការចរចាជាអន្តរជាតិ ដែលតំណាងរបស់រដ្ឋាភិបាលធ្វើការសម្រេចចិត្ត និងព្រមព្រៀងគ្នាលើសន្និសញ្ញា ។ តែនៅក្នុងករណីជាច្រើននៃកិច្ចព្រមព្រៀងទាំងនេះ សភាជាភាគច្រើនពុំដែលបានពិគ្រោះយោបល់ឡើយ នៅពេលចាប់ផ្តើមនៃការចរចា ។

សភាបានត្រឹមតែអញ្ជើញឱ្យផ្តល់សច្ចាប័នដល់កិច្ចព្រមព្រៀង ដែលបានបញ្ចប់រួចហើយ និងអនុម័ត (ឬធ្វើវិសោធនកម្ម) នូវច្បាប់ចាំបាច់នានា ដើម្បីដាក់អនុវត្តនូវការព្រមព្រៀងទាំងនោះ ។

❷ នៅពាក់កណ្តាលសតវត្សទី២០ មានកកើតនូវដំណើរការសមាហរណកម្មតំបន់ ដែលឆ្លើយតបទៅនឹងមូលហេតុជាច្រើនពីសំណាក់ប្រទេសពាក់ព័ន្ធ ដែលមានបំណងប្រាថ្នាឆ្ពោះទៅកាន់ឯកភាព ដើម្បីជំនះលើការបែកបាក់គ្នាក្នុងប្រវត្តិសាស្ត្រ និងធានាស្ថេរភាព និងសន្តិភាពតំបន់ ជំនឿថា "ការចូលរួមគ្នាគឺជាកម្លាំង" ការភ្ញាក់រលឹកអំពីសហគមន៍នៃជោគវាសនា ព្រមទាំងបំណងរួមគ្នាធ្វើសេចក្តីសម្រេចសំខាន់ៗ ដើម្បីភាពកាន់តែល្អប្រសើរ និងកសាងក្របខ័ណ្ឌជីវភាពល្អប្រសើរសម្រាប់សង្គមរៀងៗខ្លួន ។ ប្រទេសនានាបានសម្រេចធ្វើសមាហរណកម្មជាលំដាប់នូវទីផ្សារសេដ្ឋកិច្ច និងអង្គធាតុផ្សេងទៀតរបស់រដ្ឋរៀងៗខ្លួន ដោយគិតគូរអំពីគោលការណ៍បំពេញបន្ថែម (Principe de subsidiarité) ដែលចង់ថា គេពុំចាំបាច់គិតនៅក្នុងកំរិតសហគមន៍នូវបញ្ហាទាំងឡាយណា ដែលអាចជាកម្មវត្ថុនៃសេចក្តីសម្រេចដ៏ល្អប្រសើរនៅក្នុងកំរិតជាតិឡើយ ។ ដំណើរការនេះឆ្លុះបញ្ចាំងដោយឥតប្រែប្រួលនូវការផ្ទេរអំណាច ចាប់ពីនេះតទៅ សេចក្តីសម្រេចដែលប៉ះពាល់

ដល់ជីវភាពរបស់ប្រជាពលរដ្ឋ ត្រូវបានសម្រេចនៅឆ្ងាយពីរដ្ឋធានី ហើយរបូតពីការត្រួតពិនិត្យដែលធ្លាប់មានរបស់សភាជាតិ ។ ប្រការបាននាំឱ្យមានបញ្ហាជាច្រើន ដែលខុសពីភាពចាំបាច់នៃកិច្ចសហប្រតិបត្តិការអន្តរ-ជាតិ ។

ភារកិច្ចកាន់តែពិបាក ព្រោះយើងកំពុងរស់នៅក្នុងពិភពលោកមួយដែលកាន់តែពឹងពាក់គ្នាទៅវិញទៅមក ។ នៅគ្រប់ប្រទេសទាំងអស់ សកម្មភាពរបស់ភ្នាក់ងារខាងក្រៅដ៏ច្រើនពាក់ព័ន្ធនឹងរដ្ឋាភិបាល ព្រមទាំងប្រជាពលរដ្ឋ ហើយមានផលប៉ះពាល់ទៅលើសុខុមាលភាពរបស់ប្រជាជន ព្រោះវាពាក់ព័ន្ធនឹងបរិស្ថាន សន្តិសុខរាងកាយរបស់មនុស្ស និងសន្តិសុខខាងការផ្លាស់ប្តូរព័ត៌មាន សុខភាពសាធារណៈ ដំណើរអន្តោប្រវេសន៍ ឧក្រិដ្ឋកម្ម ការរួចពន្ធ... នេះជាបាតុភូតដែលបង្កើនល្បឿននៅ២០ឆ្នាំចុងក្រោយនេះ ដែលធ្វើឱ្យមានការពឹងពាក់គ្នារវាងប្រទេសនានាកាន់តែខ្លាំងក្លាឡើង ។

ដល់ថ្ងៃនេះទើបយើងហ៊ានប្រកាសថា បណ្តាលមកពីដំណើរការសាកលភាវូបនីយកម្ម រដ្ឋនៅក្នុងទម្រង់របស់ខ្លួនបានបាត់បង់នូវអំណាច ចំពោះមុខកម្លាំង និងស្ថាប័នពិភពលោក ដែលរឹតត្បិតនូវស្វ័យភាពរបស់រដ្ឋាភិបាលនានា ។ សម្រាប់ប្រទេសខ្លះដែលខិតខំទាក់ទាញនូវការវិនិយោគអន្តរជាតិ និងថែរក្សា (កែលំអ) នូវសមត្ថភាពបញ្ចូលប្រជាពលរដ្ឋឱ្យចូលធ្វើការនោះ កម្លាំងសេដ្ឋកិច្ចពិភពលោក និងទីផ្សារអន្តរជាតិ គឺជាឧបសគ្គក្នុងការចាត់ចែងសេដ្ឋកិច្ចក្នុងក៏រិតជាតិ ។

ផលប៉ះពាល់នៃស្ថានភាពបែបនេះទៅលើលទ្ធិប្រជាធិបតេយ្យ គឺជាក់ស្តែង ។ តើចាំបាច់មានស្ថាប័នប្រជាធិបតេយ្យក្នុងក៏រិតជាតិធ្វើអ្វី ប្រសិនបើសេចក្តីសម្រេចជាច្រើនដែលពាក់ព័ន្ធដល់ជីវភាពរបស់ប្រជាពលរដ្ឋ រួមទាំងបញ្ហាសន្តិសុខ ត្រូវបានសម្រេចនៅខាងក្រៅព្រំដែនជាតិ ឬដោយស្ថាប័នដែលពុំស្ថិតក្រោមការត្រួតពិនិត្យប្រជាធិបតេយ្យ ឬដែលត្រូវមានកាតព្វកិច្ចរាយការណ៍? ប្រការនេះហើយដែលគេនិយាយអំពី "ឱនភាពនៃលទ្ធិប្រជាធិបតេយ្យអន្តរជាតិ" ។

## ការចូលរួមរបស់សមាជិកសភាក្នុងកិច្ចការពហុភាគី

ឧបសគ្គសំខាន់នៃការចូលរួមរបស់សភានៅក្នុងកិច្ចការអន្តរជាតិ ឬពហុភាគី ជាភាគច្រើននៅស្ទើរគ្រប់ប្រទេស គឺថានយោបាយការបរទេស និងអន្តរជាតិ ស្ថិតនៅក្នុងដៃដាច់មុខរបស់អង្គនីតិប្រតិបត្តិ ។

នាពេលបច្ចុប្បន្ននេះ ខ្សែបន្ទាត់ដែលបែងចែករវាងនយោបាយក្នុងប្រទេសជាមួយនយោបាយបរទេស ឬអន្តរជាតិកាន់តែលែងច្បាស់លាស់ ។ ហេតុនេះសភាត្រូវរកមធ្យោបាយដើម្បីដើរហួស ឬជំនះឆ្លងកាត់ ផ្លាស់

នូវទម្លាប់ជាប្រពៃណី ដែលអង្គនីតិប្រតិបត្តិទទួលកាន់កាប់តែឯងនូវនយោបាយអន្តរជាតិ ហើយធ្វើឱ្យរដ្ឋាភិបាលដាក់នយោបាយអន្តរជាតិមកឱ្យសភាត្រួតពិនិត្យ ដូចនយោបាយខាងក្នុងប្រទេសដែរ ។

វិសាលភាពរបស់សភានៅក្នុងសហប្រតិបត្តិការអន្តរជាតិ ត្រូវធ្វើឱ្យបានជាក់ស្តែងដោយសភាខ្លួនឯង តាមរបៀប ៤ យ៉ាងដែលផ្សារភ្ជាប់គ្នាដូចតទៅ

- បង្កើនឥទ្ធិពលទៅលើនយោបាយរបស់ប្រទេសរៀងៗខ្លួន ស្តីអំពីបញ្ហាត្រូវដោះស្រាយនៅអង្គការសហប្រជាជាតិ និងវេទិកាចរចាអន្តរជាតិផ្សេងទៀត ។
- ដោយទទួលបានព័ត៌មានអំពីកិច្ចដំណើរការប្រជុំ និងលទ្ធផលនៃការចរចាទាំងនេះ ។
- ផ្តល់សច្ចាប័នកាលណារដ្ឋធម្មនុញ្ញ អនុញ្ញាតទៅលើអត្ថបទសន្ធិសញ្ញាដែលចុះហត្ថលេខាដោយរដ្ឋាភិបាល ។
- ដោយរួមវិភាគទានយ៉ាងសកម្មដល់ការដាក់អនុវត្តនីនូវលទ្ធផលនៃការចរចា ។

ដើម្បីសភាមួយអាចដើរតួនាទីមានប្រសិទ្ធភាពនូវកិច្ចការអន្តរជាតិ សភានោះត្រូវ

- មានបទដ្ឋានគតិយុត្តិច្បាស់លាស់ ដែលជាគ្រឹះសម្រាប់ការចូលរួមរបស់សភា ។
- ទទួលបានព័ត៌មានអំពីគោលនយោបាយប្រកាន់យកដោយរដ្ឋាភិបាល និងជំហរជុំវិញការចរចាជាមុន ហើយត្រូវបានពិគ្រោះយោបល់អំពីព័ត៌មានច្បាស់លាស់ស្តីពីខ្លឹមសារ និងបរិបទនៃគោលនយោបាយដែលគ្រោងប្រកាន់យក ។
- មានការចាត់តាំង និងធនធានគ្រប់គ្រាន់សម្រាប់សិក្សាបញ្ហានេះ ជាពិសេស មាននៅក្នុងជួរសមាជិកសភាដែលត្រូវមានឯកទេសចាំបាច់ នៅក្នុងឱកាសនៃការប្រជុំការងាររបស់គណៈកម្មការឯកទេស ។
- មានលទ្ធភាពចោទសួរសំណួរដល់មន្ត្រី និងអ្នកចរចាពាក់ព័ន្ធ ហើយអាចសម្តែងយោបល់នយោបាយជូនរដ្ឋាភិបាល ទោះបីយោបល់នោះតាមផ្លូវច្បាប់ ពុំមែនជាការចាប់បង្ខំក្តី ។
- ត្រូវរួមបញ្ចូលដោយពេញសិទ្ធិក្នុងគណៈប្រតិភូរដ្ឋាភិបាលទៅប្រជុំនៅវេទិកាអន្តរជាតិ ។

ជាឧទាហរណ៍មានវិស័យ ៤ ជាអាទិ៍ សិទ្ធិមនុស្ស សមភាពរវាងភេទ ការអភិវឌ្ឍ និងការផ្លាស់ប្តូរពាណិជ្ជកម្ម ដែលជាគំរូសម្រាប់ការអភិវឌ្ឍដល់វិស័យផ្សេងទៀត ។

## សិទ្ធិមនុស្ស

សភា និងសមាជិកសភាមានតួនាទីគន្លឹះនៅក្នុងការលើកតម្កើង និងកិច្ចការពារសិទ្ធិមនុស្ស ។ សកម្មភាពរបស់សភាទាំងមូល ជាអាទិ៍ ធ្វើច្បាប់ អនុម័តថវិកា និងត្រួតពិនិត្យទៅលើរដ្ឋាភិបាល គ្របដណ្ដប់ទាំងស្រុងទៅលើសិទ្ធិនយោបាយ ស៊ីវិល សេដ្ឋកិច្ច សង្គម និងវប្បធម៌ ។ បានន័យថា មានផលភ្លាមៗទៅលើការប្រតិបត្តិសិទ្ធិមនុស្ស ។ សភាគឺជាឆ្នាំការពារសិទ្ធិមនុស្ស ។

តែជាទូទៅ សភាមិនបានចូលរួមដោយផ្ទាល់នៅក្នុងដំណើរការរៀបតាក់តែង និងការសម្រេច ដែលពាក់ព័ន្ធដល់ការចុះហត្ថលេខាលើសន្ធិសញ្ញាអន្តរជាតិ ឬតំបន់ឡើយ ។ តែវាសំខាន់ដែលសភាត្រូវឆ្លៀតឱកាសបានដឹងអំពីដំណើរទៅមុខនៃការចរចា អាចសាកសួរដល់មន្ត្រី (លាយល័ក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់) អំពីវឌ្ឍនភាពសម្រេចបាន ពិភាក្សាពីរឿងនេះនៅក្នុងសម័យប្រជុំពេញអង្គ និងក្នុងគណៈកម្មការជំនាញ ឬគណៈកម្មការចង្អៀត ថែមទាំងអាចរួមដំណើរជាមួយរដ្ឋមន្ត្រីទៅចូលរួមអង្គប្រជុំនៃការចរចា ដើម្បីមានគំនិតច្បាស់លាស់អំពីវឌ្ឍនភាពដែលសម្រេចបាន ។

ដើម្បីកែប្រែស្ថានការណ៍នេះ សភាមួយចំនួនបានបង្កើតគណៈកម្មការសិទ្ធិមនុស្ស ឬក៏ប្រគល់ឱ្យគណៈកម្មការសភាដែលមានបច្ចុប្បន្ននូវអណត្តិពាក់ព័ន្ធនឹងវិស័យសិទ្ធិមនុស្ស ។

នៅពេលបច្ចុប្បន្នមានអង្គការរបស់សភា១៦៤ ដែលមានអណត្តិពាក់ព័ន្ធនឹងវិស័យសិទ្ធិមនុស្ស ។ សភាកាន់តែច្រើនឡើងបានបង្កើតនូវអ្នកសម្រុះសម្រួល ដែលជាញឹកញាប់សហការជាមួយអង្គការរបស់សភាដែលបន្ទុកអំពីកិច្ចការសិទ្ធិមនុស្ស ។

អង្គការរបស់សភាទាំងនេះច្រើនធ្វើកិច្ចសហប្រតិបត្តិការជាប្រក្រតី ដោយជិតស្និទ្ធជាមួយអង្គការក្រៅរដ្ឋាភិបាល ។ តែកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នអន្តរជាតិ និងតំបន់ ទទួលបន្ទុកខាងសិទ្ធិមនុស្ស និងយន្តការរបស់អង្គការសហប្រជាជាតិសម្រាប់សិទ្ធិមនុស្សនៅមានកំរិត ហើយពុំទាន់ជារបត់នៅឡើយ ។

សហភាពអន្តរសភាបានប្រជុំសមាជិកនៃស្ថាប័នទាំងនេះក្នុងកិច្ចប្រជុំប្រចាំឆ្នាំ ដែលអាចជម្រុញឱ្យមានកិច្ចសហប្រតិបត្តិការជាមួយយន្តការរបស់អង្គការសហប្រជាជាតិ ដែលទទួលបន្ទុកខាងសិទ្ធិមនុស្ស ។

ដើម្បីចូលជាធរមាននូវសន្ធិសញ្ញាអន្តរជាតិ រួមទាំងសន្ធិសញ្ញាដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ចាំបាច់មិនអាចខ្វះបាននូវការយល់ព្រមផ្ដល់សច្ចាប័នពីសភា ។

សេចក្ដីណែនាំរួមរបស់សហភាពអន្តរសភា និងស្នងការសហប្រជាជាតិខាងសិទ្ធិមនុស្ស បានរៀបរាប់អំពីវិធានការដែលសមាជិកសភាអាចប្រកាន់យកក្នុងឱកាសនៃដំណើរការផ្ដល់សច្ចាប័ន

- ផ្ទៀងផ្ទាត់តើរដ្ឋាភិបាលបានផ្តល់សច្ចាប័ន (យ៉ាងហោច) ដល់ឧបករណ៍ទាំង៧ ដែលពាក់ព័ន្ធដល់សិទ្ធិមនុស្សហើយឬនៅ?
- ប្រសិនបើពុំទាន់បានធ្វើទេ បញ្ជាក់សួរ តើរដ្ឋាភិបាលមានឆន្ទៈនឹងចុះហត្ថលេខាដែរឬទេ? នៅក្នុងករណីអវិជ្ជមាន ប្រើប្រាស់នីតិវិធីសភា ដើម្បីស្វែងយល់អំពីមូលហេតុនៃការគ្មានសកម្មភាពបែបនេះ និងលើកទឹកចិត្តរដ្ឋាភិបាលឱ្យចាប់ផ្តើមភ្លាមៗនូវនីតិវិធីចុះហត្ថលេខា និងផ្តល់សច្ចាប័ន ។
- ប្រសិនបើនីតិវិធីចុះហត្ថលេខាកំពុងប្រព្រឹត្តទៅ ផ្ទៀងផ្ទាត់ថាតើរដ្ឋាភិបាលមានបំណងស្នើឡើងនូវភាពបម្រុងខ្លះចំពោះឧបករណ៍នោះដែរឬទេ ហើយក្នុងករណីមានបំណងនោះ ផ្ទៀងផ្ទាត់ថាតើភាពបម្រុងទាំងនោះវាចាំបាច់ និងសមស្របចំពោះកម្មវត្ថុ និងគោលបំណងរបស់ឧបករណ៍ដែរឬទេ ។ ប្រសិនបើមានការសន្និដ្ឋានថា ភាពបម្រុងនោះគ្មានមូលដ្ឋាន សូមធ្វើសកម្មភាពដើម្បីធានាថា រដ្ឋាភិបាលវិលមកចុះហត្ថលេខាវិញ ដោយគ្មានភាពបម្រុង ។
- ផ្ទៀងផ្ទាត់ថា តើការត្រៀមបម្រុងដោយប្រទេសរបស់ខ្លួនចំពោះឧបករណ៍ដែលបានចូលជាធរមានវានៅមានភាពចាំបាច់ដែរឬទេ? ប្រសិនបើយល់ថា គ្មានភាពចាំបាច់ទេនោះ ធ្វើសកម្មភាពដើម្បីដកចេញនូវការត្រៀមបម្រុងទាំងនោះ ។

ក្រៅពីសភាត្រូវចូលរួមការចរចា តាមដានការចរចា និងជម្រុញឱ្យមានការផ្តល់សច្ចាប័នលើសន្ធិសញ្ញា ការទទួលយកនូវសន្ធិសញ្ញាតម្រូវឱ្យអនុវត្តន៍នូវសន្ធិសញ្ញាទាំងនេះនៅក្នុងកិច្ចជាតិ ពុំខុសគ្នាអ្វីទៅនឹងការពិបាក ដែលសមាជិកសភាត្រូវជួបប្រទះនៅក្នុងសកម្មភាពការងារប្រចាំថ្ងៃរបស់ខ្លួនឡើយ ។ ក្នុងការងារប្រចាំថ្ងៃ សភាត្រូវអារកាត់លើការបែងចែកថវិកា វិសោធនកម្មច្បាប់ និងបង្កើតច្បាប់ថ្មី ព្រមទាំងត្រួតពិនិត្យទៅសកម្មភាពរបស់រដ្ឋាភិបាល ។

ប៉ុន្តែសមាជិកសភាត្រូវយកចិត្តទុកដាក់ថែមទៀតដល់ភារកិច្ចអន្តរជាតិ ដែលមានច្រើនវិស័យ ។

**សមភាពរវាងភេទ**

សន្ធិសញ្ញាជាច្រើនតម្រូវឱ្យរដ្ឋឱ្យដាក់ជូននូវរបាយការណ៍តាមពេលកំណត់ទៀងទាត់ ស្តីអំពីស្ថានភាពនៃដំណើរទៅមុខក្នុងការអនុវត្តនូវសិទ្ធិសញ្ញាទាំងនេះនៅក្នុងកិច្ចជាតិ ។ ជាឧទាហរណ៍ ករណីអនុសញ្ញាស្តីពីការលុបបំបាត់នូវគ្រប់រូបភាពនៃការរើសអើងចំពោះនារី និងពិធីសារ (តាមការស្ម័គ្រចិត្ត) ។

គណៈកម្មការសហប្រជាជាតិសម្រាប់ការលុបបំបាត់ការរើសអើងប្រឆាំងនារី គឺជាអង្គការ (បង្កើតឡើងតាមឧបករណ៍នេះ) ទទួលបន្ទុកតាមដានមើលលើការអនុវត្តឧបករណ៍ និងផ្តល់យោបល់ និងអនុសាសន៍

ដែលត្រូវបញ្ជូនដល់រដ្ឋសាមី ដើម្បីជួយសម្រួលដល់ការអនុវត្ត ។ រហូតមកដល់ពេលថ្មីៗ សភាជាច្រើនពុំបានដឹងអំពីនីតិវិធីនេះឡើយ ។

ជាឧទាហរណ៍នៅប្រទេស Afrique du Sud រាល់របាយការណ៍ជាតិដែលបញ្ជូនឱ្យគណៈកម្មការ (និងទៅគ្រប់ស្ថាប័នអន្តរជាតិខាងត្រួតពិនិត្យ) ត្រូវតែបានរក្សាទុកនៅក្នុងសភា ។ សភាត្រូវធានាថារបាយការណ៍នោះឆ្លុះបញ្ចាំងបានល្អនូវពហុភាពនៃមតិយោបល់ដែលបានសម្តែង ជាអាទិ៍យោបល់របស់សង្គមស៊ីវិល ។ ដើម្បីកិច្ចការនេះ សភារៀបចំនូវការពិភាក្សា និងសវនាការសាធារណៈ កោះហៅរដ្ឋមន្ត្រី និងស្នើសុំសេចក្តីចម្លងនៃរបាយការណ៍ ព្រមទាំងឯកសារដែលចេញមកពីអង្គភាពផ្តល់សេវាជាច្រើន និងក្រុមរបស់ប្រជាជន ។ នៅប្រទេស Afrique du Sud សមាជិកសភាចូលរួមក្នុងគណៈប្រតិភូជាតិនានា ដែលចូលរួមការពិភាក្សារបស់គណៈកម្មការ ដែលអនុញ្ញាតឱ្យសមាជិកសភាយល់បានច្បាស់លាស់អំពីអនុសាសន៍របស់គណៈកម្មការ ហើយបន្ទាប់នោះ សភាអាចខិតខំដោយសកម្មជម្រុញឱ្យអនុវត្តន៍នូវអនុសាសន៍ទាំងនោះនៅក្នុងកិរិតជាតិ ។

នៅក្នុងឱកាសនៃការអនុម័តច្បាប់ជាតិពាក់ព័ន្ធនឹងសន្និសញ្ញា ស្តីពីការរើសអើងគ្រប់ប្រភេទប្រឆាំងនារី សភាហុល្លង់បានបន្ថែមនូវមាត្រាមួយ តម្រូវឱ្យរដ្ឋាភិបាលត្រូវធ្វើរបាយការណ៍ ៤ឆ្នាំម្តង ស្តីពីការអនុវត្តនូវសន្និសញ្ញាមុនពេលដែលរដ្ឋាភិបាលត្រូវរាយការណ៍ឱ្យគណៈកម្មការ ដែលត្រូវបញ្ជូនក្នុងនាមជារដ្ឋសាមី ។ មតិកត់សម្គាល់ចុងក្រោយរបស់គណៈកម្មការ ក៏ត្រូវបញ្ជូនដែរមកកាន់សភា ។

សភាខ្លះទៀត ដូចជាសភា Uraguay រៀបចំនូវសម័យប្រជុំមួយ ស្តីពីការអនុវត្តតាមអនុសាសន៍របស់គណៈកម្មការ និងអញ្ជើញសមាជិករដ្ឋាភិបាលឱ្យមកចូលរួមពិភាក្សាគ្នា ។

នៅប្រទេស Trinité-et-Tobago ដែលគ្មានគណៈកម្មការសភាទទួលបន្ទុកបញ្ហាពាក់ព័ន្ធនឹងសមភាពរវាងភេទ របាយការណ៍បញ្ជូនទៅគណៈកម្មការរបស់សហប្រជាជាតិ ត្រូវបានសរសេរដោយអង្គភាពសិទ្ធិមនុស្សនៃក្រសួងយុត្តិធម៌ ក៏ដូចជារបាយការណ៍ផ្សេងទៀត ដែលតម្រូវឱ្យធ្វើពាក់ព័ន្ធនឹងសន្និសញ្ញាអន្តរ-ជាតិ ។ អង្គភាពនេះត្រូវបានគាំទ្រដោយគណៈកម្មការខាងសិទ្ធិមនុស្សមួយ ដែលមានសមាសភាពតំណាងក្រសួងចំនួន ១៣ ដែលរដ្ឋាភិបាលមាន និងតំណាងមួយរូបរបស់សភា ។ កាលណារបាយការណ៍នោះបានចប់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវយកមកបង្ហាញជូនសភា ។

សភាស៊ុយអែតបានរៀបចំការប្រជុំពិសេស នាខែ មេសា ឆ្នាំ ២០០២ ដើម្បីបានដឹងអំពីការកំណត់សម្គាល់ចុងក្រោយរបស់គណៈកម្មការសហប្រជាជាតិ ។ ការប្រជុំនោះអាចនាំឱ្យជួបជុំនូវសមាជិកសភា NGo និងប្រធានសភា ។

តាមគំរូដែលបានធ្វើចំពោះសិទ្ធិមនុស្ស សភាកាន់តែច្រើនបានបង្កើតគណៈកម្មការពិសេស ឬស្ថាប័នដទៃទៀតដែលទទួលបន្ទុកអំពីបញ្ហាសមភាពរវាងភេទ និង/ឬប្រគល់ឱ្យគណៈកម្មការសភាដែលមានស្រាប់នូវអាណត្តិអំពីបញ្ហានេះ ។ ជាឧទាហរណ៍ សភាបារាំងបានបង្កើតនូវគណៈប្រតិភូសិទ្ធិមនុស្ស និងសមភាពនៃសំណាងរវាងបុរស និងនារី ។

បញ្ហាអំពីសមភាពរវាងភេទ គឺជាឧទាហរណ៍មួយទៀតនៃការយកចិត្តទុកដាក់ចូលរួមរបស់សភា ដែលមានផលទៅលើវិស័យផ្សេងទៀត ។ ជារៀងរាល់ឆ្នាំ សហភាពអន្តរសភារៀបចំនូវការប្រជុំរបស់សភានៅទីស្នាក់ការអង្គការសហប្រជាជាតិ នៅទីក្រុង New York ក្នុងឱកាសនៃការប្រជុំរបស់គណៈកម្មការអំពីស្ថានភាពរបស់នារី ។ ការប្រជុំនេះអនុញ្ញាតឱ្យសមាជិកសភា(បុរស/នារី) ដែលទទួលបន្ទុកលើបញ្ហាពាក់ព័ន្ធនឹងសមភាពរវាងភេទ បានផ្លាស់ប្តូរគំនិត និងបទពិសោធន៍ទៅវិញទៅមក ពិភាក្សាអំពីបញ្ហាដែលចុះក្នុងរបៀបវារៈរបស់អង្គការសហប្រជាជាតិ និងរៀបចំយុទ្ធសាស្ត្រជាតិដើម្បីអនុវត្តន៍ ។

**ការអភិវឌ្ឍ**

បញ្ហានៃការចូលរួមរបស់សភាកាន់តែមានសារសំខាន់ នៅក្នុងការអនុវត្តនូវគោលដៅសហស្សវត្សសម្រាប់ការអភិវឌ្ឍ ។ នេះជាវិធីសាស្ត្រប្រកបដោយមហិច្ឆតា ដែលសហគមន៍អន្តរជាតិត្រូវខិតខំ ហើយបានស្នើឡើងពីនេះរហូតដល់ឆ្នាំ២០១៥ ឱ្យសម្រេចបាននូវចង្កោមគោលដៅដូចតទៅ លុបបំបាត់ចោលការអត់ឃ្លាន និងភាពក្រីក្របំផុត បង្កើតនូវការសិក្សាកំរិតបឋមជាសាកល ជម្រុញសមភាពរវាងភេទ និងប្រគល់ស្វ័យភាពកាន់តែធំឱ្យនារី បញ្ចុះអត្រាមរណភាពរបស់កុមារ ការពារសុខភាពមាតា ប្រយុទ្ធប្រឆាំងជម្ងឺ HIV/SIDA គ្រុនចាញ់ និងជម្ងឺដទៃទៀត ការពារបរិស្ថាន និងរៀបចំភាពជាដៃគូរបស់ពិភពលោក ដើម្បីការអភិវឌ្ឍដែលមានទិសដៅច្បាស់លាស់ពាក់ព័ន្ធនឹងជំនួយ ការផ្លាស់ប្តូរពាណិជ្ជកម្ម និងការបន្ធូរបន្ថយបំណុល ។

ដើម្បីអាចពិភាក្សានៅក្នុងសភា អំពីបញ្ហាពាក់ព័ន្ធដល់ការអភិវឌ្ឍ សមាជិកសភាត្រូវតែយល់ដឹងអំពីបញ្ហាសិទ្ធិមនុស្ស ។ នាឆ្នាំ២០០១ ស្នងការសហប្រជាជាតិខាងសិទ្ធិមនុស្សបានផ្តល់យោបល់ថា ប្រទេសទាំងឡាយត្រូវបង្កើតនូវការអភិវឌ្ឍឈរលើមូលដ្ឋាននៃការគោរពនូវសិទ្ធិទាំងឡាយ ។ គោលការណ៍ទាំងឡាយត្រូវតម្រង់ទៅតាមទិសដៅនេះ ។ គឺសភាដែលត្រូវជួយរៀបចំនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងប្រយុទ្ធប្រឆាំង

ភាពក្រីក្រ ។ ទស្សនៈនេះមានគុណសម្បត្តិ ២ យ៉ាង : **ទី១** កំចាត់ចោលនូវទស្សនៈអន់ថយអំពីជំនួយដល់ការអភិវឌ្ឍដែលចាត់ទុកថា អំពើសប្បុរសធម៌ ។ **ទី២** វាកំណត់នូវគោលដៅដោយផ្សារភ្ជាប់ទៅនឹងសិទ្ធិតាមគតិយុត្តិជាកាតព្វកិច្ច ។

កម្មវិធីជាតិនៃការកាត់បន្ថយភាពក្រីក្រដែលគេស្គាល់ក្រោមនាមថា ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃការប្រយុទ្ធប្រឆាំងភាពក្រីក្រ (CSLP) គឺជាយន្តការដែលអនុញ្ញាតឱ្យសម្រេចគោលដៅសហស្សវត្សសម្រាប់ការអភិវឌ្ឍនៅប្រទេសចំនួន៧០ ដែលក្រីក្របំផុតនៅលើផែនដី ។ ក្របខ័ណ្ឌយុទ្ធសាស្ត្រ CSLP គឺជាតំណាងនៃផែនការអនុវត្តន៍ដែលបានចរចារវាងរដ្ឋាភិបាលនានា ធនាគារពិភពលោក និងមូលនិធិអន្តរជាតិ ដែលផ្តល់មូលដ្ឋានឱ្យកាត់បន្ថយបំណុល និងផ្តល់ធនធានហិរញ្ញវត្ថុដោយមានល័ក្ខខ័ណ្ឌអនុគ្រោះ ។

ទោះបីដំណើរការនេះមានផលគួរឱ្យកត់សម្គាល់ ទៅលើវិធានការដែលបានសម្រេចក្នុងក្របខ័ណ្ឌអន្តរជាតិទៅលើនយោបាយក្នុងប្រទេសយ៉ាងនេះក្តី សភាក៏បន្តស្ថិតនៅក្រៅសង្វៀនដដែល ។ ទោះបីធនាគារពិភពលោកបានបញ្ជាក់ដោយពេញទំហឹងថា ប្រទេសនានាត្រូវទទួលបន្ទុកលើយុទ្ធសាស្ត្រនៃការកាត់បន្ថយភាពក្រីក្ររៀងៗខ្លួនក្តី ក៏ការពិគ្រោះយោបល់ផ្ទៃក្នុងដូចជា ការចរចាជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ជាទូទៅបានដើរវៀងសភា ។ ធនាគារពិភពលោកខ្លួនឯងបានទទួលស្គាល់អំពីបញ្ហានេះ ។

ការពាក់ព័ន្ធរបស់សភា ជាទូទៅ មានកំរិតត្រឹមតែការផ្តល់សច្ចាប័នជាផ្លូវការទៅលើក្របខ័ណ្ឌ CSLP និងការត្រួតពិនិត្យទៅលើទិដ្ឋភាពហិរញ្ញវត្ថុ នៃការដាក់អនុវត្តន៍នៅក្នុងក្របខ័ណ្ឌវដ្តនៃការកសាងថវិកាប៉ុណ្ណោះ ។ ត្រង់ចំណុចនេះទៀត ការត្រួតពិនិត្យថវិកាដែលបានផ្តល់ដោយម្ចាស់កំចីមូលនិធិ ជាញឹកញាប់ត្រូវត្រួតពិនិត្យដោយម្ចាស់ជំនួយខ្លួនឯង ។

ក្នុងការឆ្លើយទៅនឹងកង្វល់ពាក់ព័ន្ធនឹងតួនាទីមានកំរិតប្រគល់ឱ្យសភា នៅក្នុងដំណាក់កាលទី១ នៃក្របខ័ណ្ឌយុទ្ធសាស្ត្រ CSLP ធនាគារពិភពលោកបានបោះផ្សាយនូវមគ្គុទ្ទេសក៍របស់ធនាគារពិភពលោកសម្រាប់សមាជិកសភា ។ ជាឧទាហរណ៍ :

- នៅប្រទេស Mauritanie សមាជិកសភាជាផ្នែកនៃក្រុមការងារ CSLP និងគណៈកម្មការទទួលបន្ទុកតាមដានដំណើរការទាំងមូល ។ មុននឹងអនុម័តក្របខ័ណ្ឌ CSLP សមាជិកសភាបានរៀបចំការពិភាក្សាជាមួយ NGO សមាជិកសង្គមស៊ីវិល និងដៃគូសកម្មភាពអភិវឌ្ឍន៍ ។
- នៅប្រទេស Honduras និង Nicaragua សមាជិកសភាជាច្រើនបានដើរតួនាទីយ៉ាងសកម្ម និងសំខាន់ក្នុងពេលពិគ្រោះយោបល់ពាក់ព័ន្ធនឹងក្របខ័ណ្ឌ CSLP ។

- នៅប្រទេស Niger រដ្ឋសភាបានចូលរួមតាំងពីដំបូងនៅក្នុងដំណើរការ CSLP ។ សមាជិកសភាជាចំណែកនៃក្រុមតាមប្រធានបទ ដែលជាវិស័យគន្លឹះនៃការអភិវឌ្ឍ ។ ឯកសារយុទ្ធសាស្ត្រចុងក្រោយត្រូវបានអនុម័តដោយក្រុមប្រឹក្សារដ្ឋមន្ត្រី បន្ទាប់មកដាក់ជូនសភាដើម្បីពិភាក្សា ។

តាមឧទាហរណ៍ខាងលើនេះ មានវិធីសាស្ត្រ ២របៀប នៃការចូលរួមរបស់សភានៅក្នុងដំណើរការ CSLP ដែលមានប្រយោជន៍សម្រាប់ការអនុវត្ត

- ការចូលរួមរបស់សមាជិកសភាក្នុងការរៀបចំគោលនយោបាយជាតិ តាមរយៈកិច្ចការដែលបានសម្រេចនៅក្នុងគណៈកម្មការពិសេសរបស់សភា និងសកម្មភាពដែលបានធ្វើក្នុងក្រុមការងារតាមវិស័យ ។
- ការត្រួតពិនិត្យផ្ទាល់លើទីកន្លែង អំពីការអនុវត្តគោលនយោបាយដែលចាប់អារម្មណ៍ ពុំត្រឹមតែដើម្បីផ្ទៀងផ្ទាត់ទិដ្ឋភាពគណនេយ្យប៉ុណ្ណោះទេ តែថែមទាំងដើម្បីកំណត់ថា តើគោលនយោបាយនេះអាចកាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធភាពដែរឬទេ?

**<u>ពាណិជ្ជកម្ម</u>**

អង្គការពាណិជ្ជកម្មពិភពលោក (WTO ឬ OMC) ពុំមែនគ្រាន់តែជាអង្គការសាមញ្ញខាងពាណិជ្ជកម្មប៉ុណ្ណោះទេ ។ ការសម្រេចរបស់ WTO មានចម្ងាយហួសពីវិស័យជាប្រពៃណីនៃពាណិជ្ជកម្មទំនិញ និងអត្រាពន្ធគយ ។ ការសម្រេចរបស់ WTO ត្រូវបានអនុវត្តនីពីពេលនេះតទៅ នៅក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋនានា ហើយប៉ះពាល់ដល់វិស័យប្លែកៗគ្នាដូចជា កម្មសិទ្ធិបញ្ញា សេវា ធនាគារ ទូរគមនាគមន៍ និងការចាត់ចែងទីផ្សាររបស់រដ្ឋ ។ WTO មានឥទ្ធិពលកើនឡើងនៅក្នុងប្រព័ន្ធជាតិខាងការធានារ៉ាប់រង សុខភាព អប់រំ ការងារ សន្តិសុខស្បៀង បរិស្ថាន ព្រមទាំងការចាត់ចែងធនធានធម្មជាតិ (ព្រៃឈើ នេសាទ និងប្រព័ន្ធទឹក) ។

ផ្ទុយពីសន្ធិសញ្ញាអន្តរជាតិផ្សេងទៀត ពុំត្រឹមតែកិច្ចព្រមព្រៀងទាំងឡាយរបស់ WTO មានលក្ខណៈបង្ខំចំពោះការកំណត់នូវគោលដៅរួមប៉ុណ្ណោះទេ តែការអនុវត្តនូវកិច្ចព្រមព្រៀងទាំងនេះ ត្រូវបានគ្រប់គ្រងដោយរបបដោះស្រាយជម្លោះប្រកបដោយប្រសិទ្ធភាព ។ ប្រការនេះតែងបណ្តាលឱ្យមានផលប៉ះពាល់ខាងសេដ្ឋកិច្ចដោយផ្ទាល់ ទាំងលើប្រជាជាតិនានា ទាំងលើវិស័យឯកជន ។

ការរីកធំធាត់បន្តរបស់ WTO នៅក្នុងវិស័យថ្មីៗ មានផលប៉ះពាល់ដ៏ជ្រាលជ្រៅសម្រាប់សមាជិកសភា ដែលមើលឃើញការលូកដៃនៅក្នុងកិច្ចការពួកគេ និងមានប្រតិកម្មដោយការពាររបៀបនៃការដោះស្រាយទៅតាមលំនឹងនៃអំណាច ដែលកំណត់ទុកដោយរដ្ឋធម្មនុញ្ញនៃប្រទេសនីមួយៗ ។ ដំណើរការបែបនេះ

ប្រែប្រួលពីប្រព័ន្ធជាតិមួយទៅប្រព័ន្ធជាតិមួយទៀត តែជាសំខាន់មាន ២ប្រភេទធំៗគឺ : ផលប៉ះពាល់ខាងច្បាប់ទម្លាប់ (Effets régulateurs) កាលណាសមត្ថភាពធ្វើច្បាប់របស់សមាជិកសភាត្រូវប៉ះទង្គិចដោយការដាក់ចេញនូវបទដ្ឋានថ្មីៗ ក្នុងកំរិតអន្តរជាតិ និងផលប៉ះពាល់ខាងធម្មនុញ្ញ(Effets constitutionnels) ការផ្ទេរអំណាចពីអ្នកធ្វើច្បាប់ទៅឱ្យអង្គនីតិប្រតិបត្តិ ។

នៅក្នុងករណីជាច្រើន សេចក្តីសម្រេចនានារបស់ WTO សំដៅដើម្បីលើកតម្កើងពាណិជ្ជកម្មអន្តរ-ជាតិ ដោយបញ្ជាក់អំពីច្បាប់នានា ដែលអ្នកធ្វើច្បាប់អាចអនុម័ត ឬពុំអាចអនុម័ត ព្រមទាំងកំណត់នូវបទដ្ឋានដែលអ្នកធ្វើច្បាប់ត្រូវតែគោរពតាម ។ តាមរបៀបនេះ សភានានាពុំមានជម្រើសណាក្រៅពីទទួលយកនូវច្បាប់នីតិសម្បទារកម្មដែលខាងរដ្ឋាភិបាលបានបញ្ជូនមក ដោយពុំអាចធានាបានថា ច្បាប់ទាំងនោះសមស្របទៅនឹងគោលដៅជាតិ និងបំណងប្រាថ្នារបស់ប្រជាជនឡើយ ។ ការប្រឆាំងគ្នារវាងសេចក្តីសម្រេចរបស់ WTO និងច្បាប់ជាតិកាន់តែធ្ងន់ធ្ងរ កាលណារដ្ឋាភិបាលស្វះស្វែងប្រើប្រាស់ប្រព័ន្ធដោះស្រាយជម្លោះ ដើម្បីប្រឆាំងទៅនឹងច្បាប់ជាតិរបស់ប្រទេសដទៃ ។

នេះគឺជាវិស័យមួយ ដែលការត្រួតពិនិត្យរបស់សភាទៅលើដំណើរការចរចាមានសារសំខាន់ ។ សភាជាច្រើនបានប្រកាន់យកវិធានការ ដើម្បីទទួលបានព័ត៌មានអំពីការរីកចំរើននៃការចរចា និងខិតខំណែនាំរដ្ឋា-ភិបាលឱ្យប្រកាន់យកនូវគោលនយោបាយសមស្រប ។ ដើម្បីបំពេញដល់ការខិតខំនេះ សភាទាំងនេះចូលរួមជាមួយសហភាពអន្តរសភា និងសភាអឺរ៉ុប ក្នុងសន្និសីទសភាប្រចាំឆ្នាំស្តីពី WTO ដែលអនុញ្ញាតឱ្យសភាអាចតាមដានសកម្មភាពរបស់ WTO បន្តការសន្ទនាដែលបានចាប់ផ្តើមជាមួយអ្នកចរចារបស់រដ្ឋាភិបាល និងជួយសម្រួលឱ្យមានការផ្លាស់ប្តូរព័ត៌មាន និងការពង្រឹងសមត្ថភាពរបស់សភាជាតិ នៅក្នុងវិស័យពាណិជ្ជកម្មអន្តរជាតិ ។

## ការចូលរួមរបស់សភានៅក្នុងដំណើរការសមាហរណកម្មតំបន់

តំបន់ជាច្រើននៅលើពិភពលោកកំពុងធ្វើដំណើរទៅតាមទិសសមាហរណកម្ម ។ បាតុភូតនេះមានប្រភពដើមនៅអឺរ៉ុប ពង្រីកទៅទ្វីបអាហ្វ្រិក អាមេរិកឡាទីន នៅអាស៊ី និងនៅក្នុងពិភពអារ៉ាប់ ។ ទោះបីប្រទេសទាំងនេះស្ថិតនៅក្នុងដំណាក់កាលខុសគ្នាក្តី តែពួកគេមានចំណុចរួមជាច្រើន ។

ដោយមានមូលហេតុប្លែកគ្នាទៅតាមតំបន់ រដ្ឋនានាបានសម្រេចធ្វើសមាហរណកម្មជាលំដាប់នូវទីផ្សារសេដ្ឋកិច្ច និងអង្គធាតុដទៃទៀតរបស់រដ្ឋ ។ ប្រការនេះមានន័យតាមជាក់ស្តែងថា ជាការបោះបង់ចោលនូវអធិបតេយ្យភាព ទោះដោយតិចតួចក្តី ជាគុណប្រយោជន៍ដល់រចនាសម្ព័ន្ធតំបន់រួម ។ នេះខុសគ្នាទាំងស្រុង

ទៅនឹងសហប្រតិបត្តិការដែលមានរវាងរដ្ឋក្នុងក្របខ័ណ្ឌពិភពលោក ។ រដ្ឋទាំងនេះ ពុំទាន់ចោលនូវអំណាចដ៏តិចតួចណាឡើយ ហើយសហប្រតិបត្តិការគ្នាដោយឈរលើគោលការណ៍ស្មើភាព ។

អង្គធាតុរួមនៃដំណើរការសមាហរណកម្មតំបន់ទាំងអស់ គឺការរៀបចំនូវរចនាសម្ព័ន្ធគ្រប់គ្រងមួយដែលចេញពីគោលការណ៍រដ្ឋ-ប្រជាជាតិ ។ ប្រការនេះនាំឱ្យបង្កើតឡើងនូវអង្គនីតិប្រតិបត្តិតំបន់មួយ និងសភាតំបន់មួយ ។ សភាតំបន់រួមរស់ទន្ទឹមគ្នាជាមួយនឹងសភាជាតិនានា និងបំពេញឱ្យគ្នាទៅវិញទៅមក ប្រហាក់ប្រហែលនឹងសភាពីរថ្នាក់នៅក្នុងទ្វិសភា នៅរដ្ឋសហព័ន្ធមួយ ។ សភាតំបន់ជាតំណាងឱ្យទស្សនៈ និងផលប្រយោជន៍របស់សហគមន៍ សភាជាតិតំណាងឱ្យទស្សនៈ និងផលប្រយោជន៍របស់ប្រជាជាតិ ។

សហភាពអឺរ៉ុបត្រូវបានគេចាត់ទុកជាដំណើរការសមាហរណកម្មតំបន់ ប្រកបដោយជោគជ័យជាងគេនៅលើពិភពលោកនេះ ។

តែសមាហរណកម្មតំបន់នេះ ក៏តែងនាំមកនូវការប្រឈមជាច្រើនដល់សភាជាតិនានា ។

ជាឧទាហរណ៍នៅក្នុងសហគមន៍អឺរ៉ុប ដើម្បីដោះស្រាយបញ្ហាតំបន់ និងពិភពលោកខ្លះ រដ្ឋាភិបាលនានាបានបោះបង់ចោលនូវសមត្ថកិច្ចនីតិកម្មរបស់ខ្លួន ជាគុណប្រយោជន៍ដល់ស្ថាប័នអធិជាតិ (Institutions supranationales) ។ បញ្ហាដែលចោទដល់សភាជាតិនានា គឺចង់ដឹងថា តើគេអាចតាមដានមើល និងប្រើឥទ្ធិពលទៅលើជំហរ ដែលប្រកាន់យកដោយរដ្ឋមន្ត្រីផ្ទាល់របស់ពួកនៅក្នុងស្ថាប័នទាំងនេះបានយ៉ាងដូចម្តេច ។

បែបបទនៃកិច្ចសហប្រតិបត្តិការនេះ ខុសគ្នាជាច្រើនទៅតាមរដ្ឋនានាជាសមាជិករបស់សហគមន៍អឺរ៉ុប ដែលមានសមត្ថកិច្ចទទួលបាននូវឯកសារសំខាន់ៗរបស់សហគមន៍អឺរ៉ុប តាំងពីមុនពេលមានការកំណត់នូវជំហរចរចា ដែលនឹងត្រូវសម្រេចដោយរដ្ឋមន្ត្រីដែលនឹងចូលរួមនៅក្នុងក្រុមប្រឹក្សា ។

សភាប៉័រទុយហ្គាល់. សភា Bundestag, សភាដាណឺម៉ាក, សភាហ្វាំងឡង់ មានឱកាសនឹងបង្ហាញនូវជំហររបស់ខ្លួនដល់រដ្ឋមន្ត្រី ដែលជាមូលដ្ឋានមួយសម្រាប់ការចរចានៅក្នុងក្រុមប្រឹក្សា ។ សភាជាតិនានាមានជំនឿថា គេមានឥទ្ធិពលពិតប្រាកដតែនៅពេលដែលគេបានចូលរួមតាំងពីដំបូងនៅការរៀបចំនយោបាយ ។

សភាខ្លះទៀតបានជ្រើសរើសវិធីបើកការិយាល័យនៅទីក្រុង Bruxelles ដែលជាទីស្នាក់ការរបស់សហគមន៍អឺរ៉ុប ។ ជាឧទាហរណ៍ សភាបារាំង ។ ការិយាល័យទាំងនេះប្រើប្រាស់សម្រាប់ជូនព័ត៌មានប្រញាប់ៗដល់សភា អំពីអ្វីដែលបានសម្រេចនៅទីក្រុង Bruxelles និងជាមូលដ្ឋានមួយផ្ទាល់ ដើម្បីជំរាបជូនស្ថាប័នអឺរ៉ុបនានាអំពីទស្សនៈរបស់សភាជាតិ ។

សភាជាតិជាច្រើន តែងជម្រុញឱ្យមាននីតិវិធីដើម្បីឱ្យមានការពិភាក្សាកំណត់ជំហរជាតិក្នុងសភាជាតិជាមុន ទើបខាងរដ្ឋាភិបាលបន្តនីតិវិធីចរចានៅក្នុងក៏រិតសហគមន៍ ។ ខាងរដ្ឋាភិបាលត្រូវផ្តល់ដល់សភាជាតិនូវការសិក្សាអំពីផលប៉ះពាល់នៃសេចក្តីព្រាងច្បាប់ ដោយមានសេចក្តីថ្លែងហេតុលំអិត អំពីផលប៉ះពាល់ទៅលើថវិកា សេដ្ឋកិច្ច បរិស្ថាន... ។ល ។

## <u>**សហប្រតិបត្តិការសភា**</u>

សហភាពអន្តរសភាគឺស្ថាប័ននាំមុខ នៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ឬពហុភាគី ។ អង្គការនេះត្រូវបានបង្កើតឡើងនាឆ្នាំ១៨៨៩ ក្នុងពេលគ្មានវេទិកានយោបាយណាមួយ ដែលអ្នកតំណាងរដ្ឋអាចជួបជុំគ្នាដើម្បីដោះស្រាយបញ្ហារួមឡើយ ។ គំនិតដើម គឺថាបង្កើតនូវចំណុចជួបគ្នាជាអចិន្ត្រៃយ៍មួយ ដែលអ្នកនយោបាយដែលមានឥទ្ធិពលអាចតាមរយៈការសន្ទនាគ្នា ជម្រុញសន្តិភាព និងសន្តិសុខ ។

ក្រោយពីនោះ មានយន្តការសហប្រតិបត្តិការអន្តរសភាជាច្រើនទៀតត្រូវបានបង្កើតឡើងយ៉ាងលឿនជាដំបូងនៅទ្វីបអឺរ៉ុប បន្ទាប់មកនៅតំបន់ផ្សេងទៀតនៃពិភពលោក ។ របៀបនៃកិច្ចសហប្រតិបត្តិការសភាទាំងក៏រិតពិភពលោក និងក៏រិតតំបន់ មានរូបភាពជាច្រើន : ការទូតសភា(Diplomatie Parlementaire) សហប្រតិបត្តិការអន្តរសភា (Coopération Interparlementaire) និងសហប្រតិបត្តិការបច្ចេកទេស (Coopération Technique) ។

## <u>**ការទូតសភា**</u>

ការទូត គឺជាបេសកជនរបស់អង្គនីតិប្រតិបត្តិ ដែលតំណាងនៅឯបរទេសនូវទស្សនៈរបស់រដ្ឋ ។ ផ្ទុយទៅវិញ សមាជិកសភា គឺជាបុរស ឬនារីនយោបាយដែលមានទស្សនៈផ្ទាល់ខ្លួន ដែលពុំចាំបាច់បង្ខំឱ្យដូចទៅនឹងជំហរផ្លូវការរបស់ប្រទេសខ្លួនឡើយ ។ ប្រការនេះបាននាំឱ្យពួកគេមានក្របខ័ណ្ឌយុទ្ធវិធីងាយស្រួលបត់បែនដែលអ្នកការទូតគ្មាន ។ សមាជិកសភាមានបំណងបញ្ចូលទៅក្នុងនយោបាយអន្តរជាតិ នូវវិសាលភាពខាងសីលធម៌ ដែលដើរហួសនូវនិយមន័យចង្អៀតអំពីផលប្រយោជន៍ជាតិដូចជា ការគាំទ្ររបស់ខ្លួនទៅលើគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ។ ភាពទន់ភ្លន់នេះបានអនុញ្ញាតឱ្យសមាជិកសភាពិភាក្សាដោយសេរីជាមួយសហសេវិកនៃប្រទេសផ្សេងទៀត និងលើកឡើងនូវសំណើថ្មីៗ ចំពោះបញ្ហាដែលហាក់ដូចជាពុំអាចដោះស្រាយបានរហូតមកដល់ពេលនោះ ។

អញ្ចឹងហើយបានជាកើតចេញនូវរូបមន្ត "ការទូតសភា" ។ នេះគឺជាសហប្រតិបត្តិការគ្រប់ប្រភេទរវាងសមាជិកសភា ។ ការទូតសភាបានបង្ហាញពីប្រសិទ្ធភាពនៅកម្លុងពេលសង្គ្រាមត្រជាក់ ពិសេសនៅក្នុងទ្វីបអឺរ៉ុប ។ ក្រោយមកបទពិសោធន៍ត្រូវបានពង្រីកទៅតំបន់មេឌីទែរ៉ាណេ ទ្វីបអាហ្វ្រិក និងទ្វីបដទៃទៀត ។

ការទូតសភាពុំត្រឹមតែជាទំនាក់ទំនងរវាងសមាជិកសភាប៉ុណ្ណោះទេ ។ សមាជិកនៃសភាមួយ អាចធ្វើដំណើរទៅកាន់ប្រទេសមួយទៀត ដើម្បីជួបសន្ទនាជាមួយអ្នកដឹកនាំនៃស្ថាប័នផ្សេងៗដើម្បីដោះស្រាយបញ្ហា ឬដើម្បីបញ្ចប់ជម្លោះ ។

## <u>សហប្រតិបត្តិការសភា</u>

ក្នុងទសវត្សចុងក្រោយ មានការបង្កើនការផ្លាស់ប្តូររវាងសភាជាច្រើនរូបភាព ។

សភាទាំងអស់បានចាប់ផ្តើមជារូបភាពសហប្រតិបត្តិការទ្វេភាគី ដូចជាបង្កើតក្រុមមិត្តភាពទ្វេភាគីដើម្បីជម្រុញសហប្រតិបត្តិការរវាងសភា និងប្រទេសសាមី ។

ក្រៅពីនោះ មានបណ្តាញមិនផ្លូវការរបស់សមាជិកសភា ដែលជួបជុំគ្នាដើម្បីពិចារណាដោះស្រាយអំពីបញ្ហាជាក់ស្តែងផ្សេងៗ ដូចជាបញ្ហាពាក់ព័ន្ធដល់ការអភិវឌ្ឍ ឬដល់ប្រជាសាស្ត្រ ការបន្ថយសព្វាវុធ ឬអាវុធធុនខ្លី... ។ល។

បណ្តាញរបស់សមាជិកសភាដើម្បីសកម្មភាពទាំងស្រុង (PGA: Parliamentarians for Global Action) មានកម្មវត្ថុជាច្រើន ជាពិសេស ទទួលបានជោគជ័យដើម្បីប្រមូលផ្តុំសាធារណជនឱ្យគាំទ្រដល់ការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ។

ក្រៅពីនោះ មានរចនាសម្ព័ន្ធសភាដែលមានលក្ខណៈផ្លូវការជាងដូចជា សមាគមសភា Commonwealth និងសមាគមសភានៃប្រទេសប្រើភាសាបារាំង (APF)... ។ល។

គេឃើញមានផងដែរនូវអង្គការសភាតំបន់ និងអនុតំបន់ (Assemblées Parlementaires Régionales et sous-Régionales) ។ ជានិន្នាការបច្ចុប្បន្ន សភានានាបានឧទ្ទិសកាន់តែច្រើននូវពេលវេលា និងធនធានសម្រាប់សហប្រតិបត្តិការសភានៅក្នុងតំបន់ ។

អង្គការសភាតំបន់មានការខិតខំជារួម ដើម្បីជម្រុញសមាហរណកម្មតំបន់ឱ្យកាន់តែប្រសើរឡើង និងការសហការគ្នាកាន់តែល្អប្រសើរឡើងរវាងប្រទេសជាសមាជិក ។

បញ្ហាប្រឈម គឺការជាន់គ្នាលើការងាររបស់អង្គការសភាតំបន់ និងអនុតំបន់ផ្សេងៗ ដែលជាការស្រូបពេលវេលា និងធនធានសម្រាប់ការប្រជុំច្រើនលើកក្នុងមួយឆ្នាំ ។

## ការជួយខាងបច្ចេកទេស

ពាក្យថា "ការជួយខាងបច្ចេកទេស Assistance Technique" និយាយដល់វិធានការប្រកាន់យក ដោយស្ថាប័ន ឬដោយបុគ្គលនានា ដើម្បីជួយពង្រឹងដល់សមត្ថភាពរបស់សភាណាមួយ ជាពិសេស នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសប្រជាធិបតេយ្យថ្មី ដើម្បីឱ្យសភាទាំងនោះបំពេញបាននូវមុខងាររបស់ខ្លួន ។ ការជួយខាងបច្ចេកទេសកើតចេញពីទស្សនៈថា សភាមួយដែលនៅក្មេងខ្ចីនៅឡើយ តែងខ្វះខាតនូវធនធានមនុស្ស និងសម្ភារៈដែលខ្លួនត្រូវការ ដើម្បីបំពេញដោយមានប្រសិទ្ធភាពនូវអណត្តិដែលប្រគល់ដោយរដ្ឋធម្មនុញ្ញ ។ គេអាចកំណត់អំពីជំនួយខាងបច្ចេកទេស ថាជាសំណុំនៃមធ្យោបាយហិរញ្ញវត្ថុ សម្ភារៈ និងឯកទេស (Expertise) ដែលប្រទេសប្រជាធិបតេយ្យដ៏រឹងមាំ និងប្រទេសអភិវឌ្ឍន៍នៅខាងជើងដាក់ឱ្យសភានៃប្រទេសប្រជាធិបតេយ្យទើបកកើត និងប្រទេសកំពុងអភិវឌ្ឍន៍នៅខាងត្បូងប្រើប្រាស់ ។

ការជួយខាងបច្ចេកទេស អាចមានរូបភាពផ្សេងៗដូចតទៅ ការអភិវឌ្ឍរចនាសម្ព័ន្ធ ការអភិវឌ្ឍស្ថាប័នតាមរយៈការបញ្ចូលនីតិវិធីថ្មីដែលបានកែលំអ ឬការធ្វើទំនើបកម្មនូវដំណើរការសភា ការណែនាំតាមរយៈការផ្លាស់ប្តូរបទពិសោធន៍ និងព័ត៌មានរវាងសមាជិកសភានៃប្រទេសផ្សេងៗ ការពង្រឹងសមត្ថភាព និងវិសិដ្ឋកម្មវិជ្ជាជីវៈ (ការបណ្តុះបណ្តាលមន្ត្រី និងសមាជិកសភា) និងការអភិវឌ្ឍនូវសមត្ថកិច្ចខាងច្បាប់ (នៅក្នុងក្របខ័ណ្ឌដែលសភាបានទទួលនូវការជួយឧបត្ថម្ភ ក្នុងពេលរៀបចំតាក់តែងច្បាប់ថ្មី ឬវិសោធនកម្មអត្ថបទច្បាប់ចាស់ពីមុន) ។

ជាធម្មតា ការជួយខាងបច្ចេកទេសគ្របដណ្តប់ទៅលើវិស័យផ្សេងៗដូចជា : បទបញ្ជាផ្ទៃក្នុងរបស់សភា និងបទដ្ឋាននៃនីតិវិធីផ្សេងៗទៀត ប្រព័ន្ធគណៈកម្មការ នីតិកម្ម មុខងារតំណាងរបស់សភា មុខងារត្រួតពិនិត្យ រដ្ឋបាល បណ្ណាល័យ សេវាឯកសារ និងស្រាវជ្រាវ និងកាលប្បវត្តិ ។ បញ្ហាពាក់ព័ន្ធនឹងសិទ្ធិមនុស្ស និងសមភាពរវាងភេទ បានប្រមូលផ្តុំវិស័យជាច្រើនដែលត្រូវអន្តរាគមន៍ ជាអាទិភាពមួយនៅក្នុងកម្មវិធីបណ្តុះបណ្តាល ព្រមទាំងសេវាពិគ្រោះយោបល់ ។ ការគាំទ្រដល់ការអភិវឌ្ឍរចនាសម្ព័ន្ធ គ្របដណ្តប់ជាអាទិ៍ទៅលើប្រព័ន្ធសូរស័ព្ទ ការថតសម្លេងទុក Audiovisuels និងការផ្សព្វផ្សាយតាមវិទ្យុអំពីសម័យប្រជុំពេញអង្គរបស់សភា សេវាបោះពុម្ព ការដឹកជញ្ជូន និងការជួសជុលកន្លែងធ្វើការ ។

ការជួយខាងបច្ចេកទេសមានទម្រង់ផ្សេងៗ ដូចតទៅ ការផ្តល់សេវាពិគ្រោះយោបល់ ការរៀបចំសិក្ខាសាលា ទស្សនកិច្ចសិក្សា ការទទួលបណ្តោះអាសន្ននូវបុគ្គលិក សេវាបណ្តុះបណ្តាលនៅនឹងកន្លែងធ្វើការ ការប្រជុំ និងសន្និសីទ ។

សូមកត់សម្គាល់ថា បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ គឺជាផ្នែកកាន់តែសំខាន់ឡើងនៅក្នុងកម្មវិធីជំនួយបច្ចេកទេស ។

ក្នុងកំរិតពហុភាគី សហភាពអន្តរសភាជាអ្នកនាំមុខគេ ដោយផ្តើមកម្មវិធីសហប្រតិបត្តិការបច្ចេក-ទេសក្នុងទសវត្ស ៧០ ។ នាពេលនោះ អង្គការអន្តរជាតិ និងម្ចាស់ជំនួយនានាចាត់ទុកថា ការជួយដល់សភាដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួន គឺជាការជ្រាតជ្រែកចូលទៅក្នុងជីវភាពនយោបាយផ្ទៃក្នុងប្រទេសមួយ ។

នៅទសវត្ស៩០ ស្ថាប័នកាន់តែច្រើនបានសម្រេចចិត្តចូលរួមក្នុងកិច្ចការនេះ ដូចជា Commonwealth Parliamentary Association (CPA) សមាគមសភានៃប្រទេសប្រើភាសាបារាំង (APF) និងបណ្តាញសភាដូចជា Association des Parlementaires européens pour l'Afrique (AWEPA) ។

អង្គការមិនមែនសភាដូចជា UNDP, USAID គណៈកម្មការអឺរ៉ុប ធនាគារអន្តរអាមេរិកខាងអភិវឌ្ឍន៍ វិទ្យាស្ថានធនាគារពិភពលោក ព្រមទាំង NDI និង IRI ជាអង្គការ NGO នៅសហរដ្ឋអាមេរិកបានផ្តើមកម្មវិធីដ៏សំខាន់នៃជំនួយបច្ចេកទេសផងដែរ ។

**<u>សេចក្តីសន្និដ្ឋាន</u>**

ទំនាក់ទំនងអន្តរជាតិកំពុងរងគ្រោះដោយឱនភាពប្រជាធិបតេយ្យ ដែលត្រូវតែខិតខំបំពេញដោយការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់សភា នៅក្នុងកិច្ចការពិភពលោក និងតំបន់ ។

នៅក្នុងកំរិតពិភពលោក សភាត្រូវខិតខំជាមួយវេទិកា ឬអង្គការអន្តររដ្ឋាភិបាល ដែលរដ្ឋត្រូវឈរលើសមភាព បង្កើតឡើងនូវកិច្ចព្រមព្រៀងទាំងឡាយដែលត្រូវយកមកអនុវត្តនីនៅរដ្ឋនីមួយៗ ។

នៅក្នុងកំរិតតំបន់ សភាត្រូវសម្របខ្លួនទៅនឹងស្ថានភាពថ្មី ដែលជាលទ្ធផលនៃការផ្ទេរអធិបតេយ្យភាពខ្លះ (គ្មានករណីបែបនេះទេនៅក្នុងកំរិតអន្តរជាតិ) ជាគុណប្រយោជន៍ដល់ស្ថាប័នថ្មីរបស់តំបន់ ។

ទោះបីខុសប្លែកគ្នាក្តី វិធានការដែលសមាជិកសភាត្រូវធ្វើ ដើម្បីបំពេញនូវឱនភាពប្រជាធិបតេយ្យមានភាពដូចគ្នានៅក្នុងករណីទាំងពីរ ។ វិធានការនោះត្រូវតែចាក់ឫសយ៉ាងជ្រាលជ្រៅនៅក្នុងសភាផ្ទាល់ និងត្រូវសម្រេចនៅក្នុងកំរិតជាតិ ។ ក្នុងករណីទាំងពីរនេះ ប្រការនេះនាំឱ្យត្រូវធ្វើការត្រួតពិនិត្យហ្មត់ចត់ទៅលើសកម្មភាពរបស់រដ្ឋាភិបាលរបស់ខ្លួន ។ ការចូលរួមរបស់សភាត្រូវឈរលើមូលដ្ឋានច្បាប់ច្បាស់លាស់ ។ សភាត្រូវបានជូនព័ត៌មានជាមុនដោយគ្រប់គ្រាន់ អំពីនយោបាយដែលប្រកាន់យកដោយរដ្ឋាភិបាល និងជំហររបស់ខ្លួនអំពីការចរចា ទទួលបាននូវព័ត៌មានលំអិតទៅលើនយោបាយដែលលើកឡើង និងបរិបទរបស់វា ហើយមានធនធាន និងរចនាសម្ព័ន្ធចាត់តាំងដើម្បីប្រឈមនឹងបញ្ហាទាំងអស់នេះ ។ បានន័យថា សមាជិកសភាសាមី

មានឯកទេសគ្រប់គ្រាន់ ដើម្បីធ្វើការនៅក្នុងគណៈកម្មការពិសេស ។ សមាជិកសភាត្រូវសាកសួរសំណួរដល់រដ្ឋមន្ត្រី និងអ្នកចរចា និងតាមពន្លឺនៃចម្លើយដែលបានទទួល ផ្តល់យោបល់ផ្ទាល់ខ្លួនដល់រដ្ឋាភិបាល (ទោះបីពុំមែនជាការចាប់បង្ខំក្តី) ។ ជាចុងក្រោយ សមាជិកសភាត្រូវចូលរួមដោយពេញសិទ្ធិក្នុងគណៈប្រតិភូរដ្ឋាភិបាលទៅកាន់អង្គការអន្តរជាតិ ។

ជាមួយនឹងការខិតខំក្នុងកិរិតជាតិ ត្រូវបន្ថែមនូវការចូលរួមអន្តរជាតិ តាមរយៈសហប្រតិបត្តិការអន្តរសភាអន្តរជាតិ និងតំបន់ ។

## VIII-ប្រឈមមុខនឹងអនាគតកាល

នាដើមសតវត្សទី២១នេះ សង្គម និងរដ្ឋាភិបាលនានាត្រូវពើបប្រទះនឹងការប្រឈមដ៏ធំធេង ។

ប្រសិនបើកិរិត និងទំហំ នៃការប្រឈមនេះខុសប្លែកគ្នាទៅតាមប្រទេសក្តី រដ្ឋាភិបាលនានាត្រូវចាប់បង្ខំឱ្យប្រឈមទៅនឹងសម្ពាធរបស់ពិភពលោក ដែលមានឥទ្ធិពលទៅលើសេដ្ឋកិច្ច បរិស្ថាន សុខភាព និងសន្តិសុខរបស់ប្រជាជន ។ រដ្ឋាភិបាលធ្វើការប្រឈមទាំងនេះដោយអនុម័តនូវនយោបាយ និងកម្មវិធី ដើម្បីកែលំអសុខុមាលភាពរបស់ប្រជាជនខ្លួន (ពុំមែនកាត់បន្ថយ ឬក៏ធ្វើឱ្យមានគ្រោះថ្នាក់ឡើយ) ។

ប្រការនេះ គឺជាការទទួលខុសត្រូវមួយដ៏ពិតប្រាកដ ដែលទាមទារនូវភាពច្នៃប្រឌិតរបស់មនុស្ស ព្រមទាំងសមត្ថភាពរបស់សង្គម ដើម្បីសហការ និងរួបរួមគ្នាក្នុងការសម្រេចបុព្វហេតុរួម ។

ដោយដាច់អំពីមុខងារធ្វើច្បាប់ និងត្រួតពិនិត្យ សភាមានគុណសម្បត្តិពិសេសដែលអាចដើរតួនាទីគន្លឹះប្រឈមមុខនឹងការប្រឈមទាំងនេះ

- សភាតំណាងឱ្យប្រជាជននៅក្នុងពហុភាពរបស់ខ្លួន និងអាចសម្តែងយោបល់ និងការគិតគូរបានក្នុងនាមប្រជាជន ។
- សភាអាចផ្សព្វផ្សាយជាសាធារណៈនូវជម្រើស និងបញ្ហាចម្រូងចម្រាស់ខាងនយោបាយដែលកំពុងជួបប្រទះ និងអប់រំសាធារណជនអំពីបញ្ហានេះ ។
- សភាផ្តល់នូវវេទិកាជាតិដែលអាចពិភាក្សាអំពីជម្រើស និងសំណើអំពីសកម្មភាពនយោបាយជាជំនួសវិញ ។
- ជម្រើសរបស់សភាអំពីការសន្ទនាដើម្បីដោះស្រាយមតិខុសគ្នា ផ្តល់ឱ្យសភានូវតួនាទីពិសេសនៅក្នុងដំណោះស្រាយជម្លោះសង្គម និងនយោបាយ ។

- សភាផ្តល់ការយកចិត្តទុកដាក់ជាពិសេសក្នុងការជម្រុញ និងកិច្ចការពារសិទ្ធិមនុស្ស ទាំងក្នុងវិស័យសេដ្ឋកិច្ច និងសង្គម ព្រមទាំងលើវិស័យស៊ីវិល និងនយោបាយ ។

គុណសម្បត្តិផ្ទាល់របស់សភា ជាតំណាងឱ្យសារវ័ន្តនៃលទ្ធិប្រជាធិបតេយ្យ ការគោរពនៃពហុភាពដែលឈរលើមូលដ្ឋាននៃជំនឿថា គ្មានមនុស្សណាម្នាក់មានតម្លៃខ្ពស់ជាងមនុស្សម្នាក់ទៀតឡើយ ការដោះស្រាយមតិខុសគ្នា និងជម្លោះតាមការសន្ទនា និងការពិភាក្សា ដើម្បីឱ្យសកម្មភាពរួមចាំបាច់ត្រូវបានប្រកាន់យក ដោយមានការព្រមព្រៀងពីទាំងអស់គ្នា ។

នៅក្នុងពិភពលោកដែលវិវត្តឆាប់រហ័ស ស្មារតីអំពីការសន្ទនាគ្នា ដែលបានជ្រួតជ្រាប និងអនុវត្តន៏ដោយអង្គនីតិបញ្ញត្តិ និងមជ្ឈដ្ឋាននយោបាយ គឺជាកត្តាសំខាន់ចម្បង នេះគឺដើម្បីប្រឈមទៅនឹងអតីតកាល និងអនាគតកាលរបស់សង្គមមួយ ដើម្បីស្វែងរកមធ្យោបាយរៀបចំអនាគតកាល ដោយពុំបំផ្លាញចោលនូវប្រពៃណីទាំងអស់ ដែលបានធ្វើឱ្យប្រទេសមាននូវភាពសាមញ្ញ ដើម្បីរំលឹកអំពីអតីតកាលដូចជា ប្រភពនៃការផ្លាស់ប្តូរប្រកបដោយលទ្ធផល ហើយពុំមែនជាឧបសគ្គដល់វឌ្ឍនភាពឡើយ ។

ក្នុងន័យប្រជាធិបតេយ្យ វាគ្មានគំរូតែមួយគត់ឡើយ ប៉ុន្តែមានការប្រែប្រួលបន្តបន្ទាប់ជុំវិញបទដ្ឋាន និងការអនុវត្តជាគន្លឹះ ទៅតាមប្រពៃណីនយោបាយជាពិសេសរបស់ប្រទេសនីមួយៗ ។

សភាទាំងឡាយកំពុងយកចិត្តទុកដាក់ដើម្បីដំណើរការកែទម្រង់ជាអចិន្ត្រៃយ៍ ធ្វើឱ្យការអនុវត្តកាន់តែល្អប្រសើរ និងច្បាស់លាស់ ធ្វើឱ្យសភាកាន់តែទទួលខុសត្រូវ និងសម្របខ្លួនបានល្អប្រសើរ ។ ប្រជាធិបតេយ្យភាវូបនីយកម្មពុំមែនជាដំណើរភប់ប្រទះដែលទៀងពេលវេលាឡើយ តែជាដំណើរការបន្តទាំងក្នុងប្រទេសប្រជាធិបតេយ្យក្មេងខ្ចី ទាំងក្នុងប្រទេសប្រជាធិបតេយ្យចាស់ជាយូរលង់ ។

## ដំណើរការកែទម្រង់ ប្រភពនៃការកែទម្រង់

ការកែទម្រង់ចាប់កំណើតមកពីប្រភពជាច្រើន ដែលខុសប្លែកគ្នាពីសភាមួយទៅកាន់សភាមួយទៀត ។ ប្រភពទាំងនេះតែងបំពេញឱ្យគ្នាទៅវិញទៅមក និងឆ្លើយឆ្លងគ្នា ពុំមែនជាកត្តាដាច់ៗពីគ្នាឡើយ ។

ជាទូទៅមានប្រភពពីរគឺ ប្រភពខាងក្រៅសភា និងប្រភពខាងក្នុងសភា ។

ប្រភពខាងក្រៅសភាមានដូចតទៅ

- **សេចក្តីត្រូវការនៃការប្រែប្រួលរបស់សង្គម** យោងទៅតាមប្រភេទរបស់សង្គម សេចក្តីត្រូវការតែងរេទៅតាមនោះ ហើយជាទូទៅ នោះហើយជាប្រភពនៃច្បាប់ ឬក៏ការកែប្រែនូវច្បាប់ចាស់ៗ ។ ប៉ុន្តែជួនកាលប្រភពទាំងនេះ ក៏អាចនាំផងដែរដល់ការផ្លាស់ប្តូររបៀបធ្វើការរបស់សភា ។ ដូច្នេះ

ហើយបានជាការវិវត្តនៃតួនាទីប្រគល់ទៅឱ្យនារីនៅក្នុងសង្គម បានក្លាយជាការផ្លាស់ប្តូរនៅក្នុងភាពតំណាងខាងនយោបាយក្នុងកំរិតជាតិ និងក្នុងវិធីសាស្ត្រដំណើរការរបស់សភា ។

- **ការកៀបសង្កត់ចេញមកពីសាធារណជន** ការកៀបសង្កត់នេះមានការប្រែប្រួល និងរីកធំឡើង ។ ប៉ុន្តែសភាជាច្រើនមានទស្សនៈរួមដូចគ្នា អំពីរណ្តៅដែលមានចន្លោះកាន់តែទូលាយរវាងសភា និងអ្នកបោះឆ្នោត ជាពិសេសជំនាន់យុវវ័យ ដែលនាំឱ្យសភាដកពិសោធន៍បែបបទថ្មី អំពីការចូលមកទាក់ទងរបស់សាធារណជនជាមួយសភា ។
- **វឌ្ឍនភាពបច្ចេកទេស** ឧទាហរណ៍ជាក់ស្តែងបំផុត គឺការវិវត្តដ៏លឿនរបស់បច្ចេកវិទ្យាព័ត៌មាន និងផលប៉ះពាល់របស់វា ទៅលើរបៀបដែលសភាត្រូវប្រាស្រ័យឆ្លើយឆ្លងផ្ទៃក្នុង និងជាមួយសាធារណជន ។ ការវិវត្តនៃបច្ចេកទេសទូរទស្សន៍ក៏នាំមកការផ្សព្វផ្សាយអំពីសម័យប្រជុំពេញអង្គផងដែរ ។
- **ឥទ្ធិពលអន្តរជាតិ** ជាអង្គធាតុរួម គឺរបៀបដែលសាកលភាវូបនីយកម្មខាងសេដ្ឋកិច្ច បានឆ្លុះបញ្ចាំងឱ្យឃើញនូវភាពកំរិតនៃការត្រួតពិនិត្យរបស់សភាទៅលើអង្គនីតិប្រតិបត្តិ ។ នៅក្នុងប្រទេសជាបេក្ខជនចូលរួមក្នុងសហគមន៍អឺរ៉ុប ភាពចាំបាច់នៃការធ្វើឱ្យច្បាប់ជាតិខ្លួនរលូន មុននឹងអាចក្លាយខ្លួនជាសមាជិកសហគមន៍អឺរ៉ុប បានកៀបសង្កត់យ៉ាងខ្លាំងក្លាទៅលើដំណើរការធ្វើច្បាប់ ហើយជម្រុញឱ្យសភាឱ្យធ្វើសទានកម្មនូវនីតិវិធីរបស់ខ្លួន ។ គ្រប់ប្រទេសតែងទទួលនូវឥទ្ធិពលនៃវប្បធម៌ពិភពលោក ។
- **គំរូពីសភាដទៃ** នេះចង់និយាយដល់ឥទ្ធិពលនៃការអនុវត្តរបស់សភាដទៃទៀត តាមរយៈក្របខ័ណ្ឌនៃទំនាក់ទំនងទ្វេភាគី និងដំណើរទស្សនកិច្ចក្នុងរង្វង់នៃបណ្តាញតំបន់ ឬតាមការចូលជាសមាជិកអង្គការនានាដូចជា សហភាពអន្តរសភា សមាគមអគ្គលេខាធិការសភាពិភពលោក CPA (សមាគមសភា Commonwealth)... ។

ល័ក្ខខ័ណ្ឌផ្ទៃក្នុងសភាដែលជម្រុញឱ្យមានការកែទម្រង់ រួមមាន

- ការចាប់អារម្មណ៍ភ្ញាក់រលឹកចំពោះភាពកំរិតនៃនីតិវិធីនានា ដែលរារាំងដល់ប្រសិទ្ធភាពផ្ទៃក្នុងរបស់សភា ដោយគិតគូរដល់ការវិវត្តខាងបរិស្ថាននៅខាងក្រៅសភា ។
- អ្នកជម្រុញឱ្យមានការកែទម្រង់ : អាចជាឥស្សរជនដ៏មានឥទ្ធិពលដូចជា ប្រធានសភាដែលសកម្មជាពិសេស ក្រុមសមាជិកសភា គណៈកម្មការបទបញ្ជា និងការអនុវត្ត ឬដោយអគ្គលេខាធិការ-

ដ្ឋានដែលមានកង្វល់ឱ្យមានការកែទម្រង់។ តាមសភាភាគច្រើន ស្ថាប័ន្យបនីយកម្មនៃដំណើរការកែទម្រង់តាមរយៈគណៈកម្មការ គឺជាអង្គធាតុមួយជានិច្ចកាលនៃការអនុវត្តរបស់សភា ។

- កត្តាផ្ទាល់ដើម្បីប្រមូលការគាំទ្រចាំបាច់ និងដាក់អនុវត្តន៍នូវការកែទម្រង់ដែលជាតម្រូវការភាពចាំបាច់នូវការប្រមូលឱ្យបានធំទូលាយនូវសមាជិកសភា ដើម្បីគាំទ្រដល់កំណែទម្រង់ដែលចង់បាន អាចមានឥទ្ធិពលទៅលើចំងាយ និងខ្លឹមសារនៃកំណែទម្រង់ទាំងនេះ ក៏ដូចគ្នាផងដែរចំពោះនីតិវិធី ដែលអនុញ្ញាតឱ្យដាក់កំណែទម្រង់ទៅក្នុងការចាប់ផ្តើមអនុវត្តន៍ ។

របៀបដែលឥទ្ធិពលខុសៗគ្នាទាំងនេះ ធ្វើសកម្មភាពទៅលើគ្នាទៅវិញទៅមកនៅក្នុងរង្វង់សភាមួយ និងនៅក្នុងពេលវេលាពិសេសមួយ តែងប្រែប្រួលយ៉ាងខ្លាំង តែគេតែងឃើញឥទ្ធិពលខ្លះក្នុងចំណោមឥទ្ធិពលទាំងនេះ នៅក្នុងកម្មវិធីកំណែទម្រង់ទាំងអស់ដែលទទួលបានជោគជ័យ ។

## **ថាមភាពនៃប្រជាធិបតេយ្យភាវូបនីយកម្ម**

សភាទាំងអស់លើពិភពលោកនេះ តែងត្រូវទទួលរងនូវឥទ្ធិពលនៃចរន្តដ៏ខ្លាំងក្លារបស់ប្រជាធិបតេយ្យភាវូបនីយកម្ម ដែលចេញមក

- ចួន ដោយភាពសមហេតុផលផ្ទៃក្នុង ដែលផ្សារភ្ជាប់នឹងការវិវត្តផ្ទាល់របស់ខ្លួនទៅកាន់លទ្ធិប្រជា-ធិបតេយ្យកាន់តែទូលំទូលាយ ។
- ចួន ដោយបរិស្ថានពិភពលោក ។
- ចួន ដោយភាពគួបផ្សំនៃកត្តាទាំងពីរ ។

ប៉ុន្តែចរិត និងទំហំនៃការកែទម្រង់ ពឹងផ្អែកទៅលើដំណាក់កាលច្បាស់លាស់ នៃដំណើរការប្រជាធិប-តេយ្យភាវូបនីយកម្ម និងផ្លូវដើររបស់ខ្លួនផ្ទាល់ ។ ប្រទេសខ្លះ ស្ថិតនៅក្នុងដំណាក់កាលដំបូងនៃការឆ្លងកាត់ទៅកាន់លទ្ធិប្រជាធិបតេយ្យ ។ ប្រទេសខ្លះទៀត ខិតខំពង្រឹងសមិទ្ធផលនៃអន្តរកាលទៅកាន់លទ្ធិប្រជាធិប-តេយ្យ ជារបៀបដែលតាមផ្នែកខ្លះ នៅជិតដាមដោយទស្សនៈនៃរបបចាស់ ។ ប្រទេសមួយចំនួនទៀត ដែលលទ្ធិប្រជាធិបតេយ្យបានចាក់ឫសជាយូរយាមកហើយនោះ ត្រូវបានធ្វើឱ្យរស់រវើកនូវឆន្ទៈដើម្បីមានដំណើរថ្មីថែមទៀត ឬឆន្ទៈដើម្បីទប់ទល់ទៅនឹងជម្ងឺស៊ីរូងផ្ទៃក្នុង ។

ប្រសិនបើប្រទេសទាំងអស់ត្រូវប្រឈមមុខនឹងភារកិច្ច និងការតម្រូវខុសៗគ្នានោះ អង្គធាតុរួមមួយធ្វើឱ្យពួកគេដូចគ្នា តួនាទីកំណត់របស់សភានៅក្នុងដំណើរការកែទម្រង់ប្រជាធិបតេយ្យ ។

## លទ្ធិប្រជាធិបតេយ្យដែលបានចាក់ឫស

ចំពោះប្រទេសប្រជាធិបតេយ្យ ដែលបានដាក់តាំងរឹងមាំតាំងពីយូរយានោះ ប្រទេសខ្លះយល់ថា ការប្រឈមដ៏ចម្បងបំផុតនោះ គឺការប្រឈមដែលជម្រុញទៅកាន់ការកែទម្រង់សភា ធ្វើឱ្យស្ថាប័ននេះនៅតែទទួលបាននូវការជឿជាក់ មានសមត្ថភាពឆ្លើយតបទៅនឹងកង្វល់ចំពោះមុខ នៅក្នុងបរិបទមួយដែលការវិវត្តខាងសង្គមមានដំណើរលឿន និងប្រឈមទៅនឹងភាពសោះអង្គើយកាន់តែធំរបស់សាធារណជន ។

**សភាតំណាងអូស្ត្រាលី** កិច្ចការសំខាន់មួយ គឺរៀបចំក្របខ័ណ្ឌស្ថាប័នឱ្យបានសមស្របទៅនឹងសេចក្តីត្រូវការ និងទស្សនៈរបស់សាធារណជនដែលខ្លួនជាតំណាង ។

**សភាកាណាដា** ធ្វើឱ្យសាធារណជនជឿទុកចិត្តឡើងវិញ គឺជាទិសដៅមួយនៃការកែទម្រង់ដែលកំពុងធ្វើ ។

**សភាហុល្លង់** គឺឆន្ទៈធ្វើការខ្លាំងក្លា ដើម្បីឱ្យប្រជាពលរដ្ឋជឿទុកចិត្តឡើងវិញ ។

សម្រាប់ប្រទេសទាំងអស់ដែលលទ្ធិប្រជាធិបតេយ្យឈររឹងមាំ ការកែទម្រង់គឺជាដំណើរការមួយដែលប៉ងប្រាថ្នាចង់បាន ហើយជាទូទៅមានរចនាសម្ព័ន្ធដោយគណៈកម្មការមួយបង្កើតឡើងសម្រាប់កិច្ចការនេះ ។ តួយ៉ាងដូចជា ការកែទម្រង់ជាបន្តបន្ទាប់របស់សភាឥណ្ឌា អ៊ីស្រាអែល អ៊ីតាលី ព័រទុយហ្កាល់ និងអង់គ្លេស ។

## កត្តាជំរុញការកែទម្រង់ និងឧបសគ្គដែលរារាំងដល់ការកែទម្រង់

ទោះបីបានទទួលឥទ្ធិពលយ៉ាងណាក្តី កម្មវិធីនៃកំណែទម្រង់សភា គឺជាដំណើរការស្វ័យចាត់ចែង មិនថាជាកម្មវិធីធំទូលាយ ឬការប្រមូលផ្តុំនូវការកែទម្រង់តូចៗ ។ តែកំណែទម្រង់នេះអាចត្រូវបានសម្រួលធំទូលាយពីការជួយពីខាងក្រៅ ជាពិសេសសម្រាប់ករណីសភាដែលខ្វះធនធាន និងឯកទេស។ ក្នុងនោះមានការជួយពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ សហភាពអន្តរសភា និងអង្គការអន្តរជាតិផ្សេងទៀត។ ការផ្តល់ជំនួយនេះ នាំជាទូទៅឱ្យមានការរៀបចំនូវកម្មវិធីមួយអំពីកំណែទម្រង់សភា បែងចែកជាអាទិភាព ដែលមានកំណត់ច្បាប់ និងការរៀបរាប់លំអិតអំពីមធ្យោបាយចាំបាច់ដើម្បីដាក់អនុវត្តន៍ ។

ការជួយទាំងនេះមានជាឧទាហរណ៍ ករណីនៅប្រទេស Burkina Faso, Côte d'Ivoire, Fidji, Liban, Saint-kitts, Zambie ។

របៀបមួយក្នុងចំណោមរបៀបជាច្រើន ដើម្បីជម្រុញការកែទម្រង់ តម្រូវឱ្យមានការចូលរួមពីសាធារណជន ដើម្បីឱ្យពួកគេមានអារម្មណ៍ពាក់ព័ន្ធនឹងដំណើរការ និងមានមនោសញ្ចេតនាយល់ថា ខ្លួនជាអ្នកឈ្នះនៅក្នុងកិច្ចការទាំងនេះ ។

ការចាប់អារម្មណ៍ទាំងនេះ មានឥទ្ធិពលទៅលើជម្រើសដែលបានចាប់យកក្នុងការកែទម្រង់ ។ ប្រសិនបើមានវិបត្តិដែលប្រទេសកំពុងឆ្លងកាត់បច្ចុប្បន្នធ្វើឱ្យកំណែទម្រង់ដែលបានចាប់ផ្តើមត្រូវស្រកស្រុតចុះ ហើយធ្វើឱ្យការកែទម្រង់បាត់បង់ឥទ្ធិពលនោះ តែការចាប់អារម្មណ៍ទាំងនេះនៅតែមានសារសំខាន់សម្រាប់អនាគតរបស់សភា កាលណាសភាពការណ៍បានក្លាយជាប្រក្រតីឡើងវិញ ។

តើអ្វីខ្លះអាចជាឧបសគ្គញ៉ីកញ៉ាប់ដែលរារាំងដល់ដំណើរការកំណែទម្រង់ ?

- បរិបទនយោបាយ និងសង្គមមិនអនុគ្រោះ ដែលធ្វើឱ្យប៉ះពាល់ដល់កំណែទម្រង់ ។
- ការខ្វះខាតមិនគ្រប់គ្រាន់នូវធនធាន និងការខ្វះឯកទេស ទោះបីប្រទេសអាចពឹងផ្អែកលើជំនួយពីខាងក្រៅយ៉ាងណាក្តី ។
- វប្បធម៌ប្រឆាំងទៅនឹងកំណែទម្រង់ ជាពិសេស នៅក្នុងសភាចាស់យូរឆ្នាំ និងសង្គមប្រពៃណីនិយម ។
- ទំនាស់ផលប្រយោជន៍ដែលសម្តែងឡើងនៅក្នុងរង្វង់សភា ជាពិសេស ឥទ្ធិពលនៃផលប្រយោជន៍តាមផ្នែក ឬផ្ទាល់ខ្លួន ដែលប្រឆាំងចំពោះកំណែទម្រង់ ។
- សំណើលើកឡើងពុំមានមូលដ្ឋាន ឬរៀបចំពុំបានល្អ ឬសំណើដែលមានផលវិបាកពុំបានគ្រោងទុកដែលមានផលប៉ះពាល់ធ្វើឱ្យបាត់បង់នូវជំនឿទៅលើកំណែទម្រង់ ។

ចំពោះលទ្ធផលនៃការអនុវត្តកំណែទម្រង់ ត្រូវចាប់អារម្មណ៍ដល់បញ្ហាដូចតទៅ

- ត្រូវស្វែងរកការស្រុះស្រួលគ្នារវាងភាគីបដិបក្ខ ។
- ត្រូវយល់ថា គម្រោងកំណែទម្រង់តែងមាននូវផលវិបាកដែលត្រូវគ្រោងទុកជាមុន ។
- យុទ្ធសាស្ត្រនៃកំណែទម្រង់ដែលសភាជាច្រើនបានអនុវត្តន៍ គឺដាក់សាកល្បងអនុវត្តន៍នូវការប្រែប្រួលដែលបានស្នើឡើងមួយរយៈ ដើម្បីវិនិច្ឆ័យពីផលប៉ះពាល់របស់វា មុននឹងដាក់ឱ្យប្រើប្រាស់ជាអចិន្ត្រៃយ៍ ។
- សំណើដែលពីដំបូងត្រូវប៉ះទង្គិចដោយការទប់ទល់ដ៏ខ្លាំងក្លា នៅក្នុងការអនុវត្តជាក់ស្តែងតែងមានលទ្ធផលជាវិជ្ជមានបំផុត ។

**គិតគូរពីអនាគត**

សម្រាប់សភា " ប្រឈមមុខនឹងអនាគត" មានន័យជាច្រើន

- ឆ្លើយតបចំពោះក្ដីសង្ឃឹមរង់ចាំរបស់សង្គម និងប្រព័ន្ធពិភពលោកដែលកំពុងប្រែប្រួលយ៉ាងឆាប់រហ័ស តាមរបៀបដែលថែរក្សាបាននូវភាពដើមនៃប្រពៃណីជាតិ ។
- បើកចំហចំពោះកំណែទម្រង់លើរបៀបធ្វើការងាររបស់ខ្លួន ដើម្បីរបៀបធ្វើការងារនេះ អនុគ្រោះឱ្យជំនះបានទៅលើការប្រឈមរបស់យុគសម័យ និងការប្រតិបត្តិដោយសភានូវតួនាទីជាឆ្នាំរបស់លទ្ធិប្រជាធិបតេយ្យ ។
- ការគិតគូរតាមឆន្ទៈនិយមសម្រាប់រយៈពេលវែងទៅលើអនាគតរបស់ប្រទេស ដោយពុំត្រឹមតែធ្វើប្រតិកម្មទៅនឹងគំនិតផ្ដួចផ្ដើមដែលរដ្ឋាភិបាលបានដាក់មកប៉ុណ្ណោះទេ ។

សមាជិកសភាពិតជាមានលទ្ធភាពគិតគូរអំពីអនាគតរបស់ប្រទេស និងចូលរួមរចនាអនាគតនេះ ព្រោះពួកគេទទួលបាននូវអណត្តិ និងជំនឿទុកចិត្តពីប្រជាពលរដ្ឋ ដើម្បីប្រតិបត្តិអំណាចដែលបានប្រគល់ឱ្យ ។